**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# យុវជន និងការងារនៅកម្ពុជាបច្ចុប្បន្ន

ស្រាវជ្រាវ ចាប់ពីថ្ងៃទី០៣ ខែ មេសា ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១៧

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ៖ **កញ្ញា ខុន វិសាល**
**កញ្ញា ម៉ៅ ម៉េងគីម**

សាស្ត្រាចារ្យណែនាំ
**ហៀង សាង**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១០

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេររបាយការណ៍ ២០១៧

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំកញ្ញា **ខុន វិសាល** និង កញ្ញា **មៅ ម៉េងគីម** សូមលំអោនកាយគោរពប្រណិបតន៍ ស្តែងនូវ កតញ្ញូតាធម៌ និងការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

លោកឪពុក **ខុន សុភាព** អ្នកម្តាយ **គុណ ពិសី** និង លោកឪពុក **រុន សុខមៅ** និង អ្នកម្តាយ **ហេង លីណា** ដ៏មានគុណទាំងពីរ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាយើងខ្ញុំតាំងពីតូចរហូតមកដល់ពេលនេះ។ លោកទាំងពីរតែងតែអប់រំ ទូន្មាន ប្រៀនប្រដៅ ព្រមទាំងផ្តល់ទាំងសម្ភារសិក្សា ថវិកា កម្លាំងកាយ កម្លាំងចិត្ត កម្លាំងស្មារតី និង ពលីកម្មគ្រប់បែបយ៉ាងដើម្បីផ្គត់ផ្គង់ឲ្យយើងខ្ញុំបានសិក្សាតាំងពីថ្នាក់បឋមសិក្សា រហូតមកដល់ការបញ្ចប់បរិញ្ញាបត្រជាស្ថាពរនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានដឹកនាំប្រទេសប្រកបដោយសុខសន្តិភាព និងអភិវឌ្ឍជាលំដាប់ដែលជាសូចនាករមួយជំរុញឲ្យការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំបានបញ្ចប់ដោយរលូន។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យ និងមន្ត្រីរាជការទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងទាំងកម្លាំងកាយចិត្ត និង ស្មារតីក្នុងការជ្រោមជ្រែងដល់យើងខ្ញុំឲ្យមានចំណេះដឹងរហូតដល់ថ្ងៃសរសេរសារណានេះ។

លោកសាស្ត្រាចារ្យ **ហៀង សាង** ដែលបានលះបង់អស់ពីកម្លាំងកាយចិត្ត និង បញ្ញាក្នុងការណែនាំ ពន្យល់ព្រមទាំងកែសម្រួលរាល់កំហុសឆ្គងទាំងឡាយដែលកើតឡើងដោយអចេតនារបស់យើងខ្ញុំទាំងពីរនាក់។ លោក **ចឹក លីម** អគ្គនាយករងនៃអគ្គនាយកដ្ឋានយុវជន របស់ក្រសួងអប់រំយុវជន និងកីឡា លោក **ស៊ីវ យ៉ាង** អនុប្រធានផ្នែកផែនការ និង សហប្រតិបត្តិការនៃទីភ្នាក់ងារជាតិមុខរបរ និងការងារនៃក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង លោក **លី ពិជ័យ** ជាមន្ត្រីអង្គការតម្លាភាពកម្ពុជា ដែលបានចំណាយពេលវេលាមានតម្លៃក្នុងការផ្តល់បទសម្ភាសយ៉ាងក្បោះក្បាយ និង មានអត្ថន័យជ្រាលជ្រៅដល់យើងខ្ញុំទាំងពីរនាក់ នេះជាបច្ច័យដ៏សំខាន់មិនអាចខ្វះបានក្នុងការជំរុញឲ្យសមិទ្ធិផលមួយនេះលេចចេញជារូបរាងឡើង។

ជាទីបញ្ចប់យើងខ្ញុំសូមបួងសួងដល់ទេវតា និង វត្ថុស័ក្តិសិទ្ធិ ក្នុងលោកឲ្យជួយថែរក្សាអ្នកមានគុណទាំងពីរ និងអ្នកដែលបានខិតខំជួយជ្រោមជ្រែងទាំងអស់ឲ្យជួបតែសេចក្តីសុខ សុភមង្គល សុខភាពល្អ និង សំណាងល្អគ្រប់ពេលវេលា។

# អារម្ភកថា

ការកើតឡើងនូវសេដ្ឋកិច្ចទីផ្សារ និងការធ្វើសមាហារណកម្មទៅក្នុងទីផ្សារក្នុងតំបន់ និងទីផ្សារពិភពលោក បានធ្វើឲ្យប្រទេសកម្ពុជាមានការរីកចម្រើនលើវិស័យទីផ្សារការងារ ដោយមានការវិនិយោគពីបរទេស ជាហេតុធ្វើឲ្យមាននូវរោងចក្រ សហគ្រាស និងកម្មករនិយោជិតបម្រើការងារមានការកើនឡើង ដែលកម្មករនិយោជិតទាំងអស់នោះភាគច្រើនគឺជាយុជន។ ប្រាកដណាស់យុវជនជាជនដែលរាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ព្រោះថាយុវជនជាសសរទ្រូងនៃប្រទេសជាតិ មិនត្រឹមតែប៉ុណ្ណោះយុវជនមានរហូតចំនួន៣៣% បើគិតទៅប្រមាណជាជាងបួនលាននាក់ បើធៀបជាមួយចំនួនប្រជាជនសរុបនៅក្នុងប្រទេស ប៉ុន្តែអ្វីដែលសំខាន់នោះយុវជនមានបញ្ហាប្រឈមច្រើនចំពោះការស្វែងរកការងារធ្វើ ដែលត្រូវជំនាញ ការងារដែលពួកគេពេញចិត្តស្រឡាញ់ និង ទទួលបានប្រាក់បៀវត្សសមរម្យ។ ហេតុនេះហើយបានជាយើងខ្ញុំទាំងពីរនាក់សម្រេចចិត្តជ្រើសយកប្រធានបទ **"យុវជន និង ការងារនៅកម្ពុជាបច្ចុប្បន្ន"** មកធ្វើការសិក្សាស្រាវជ្រាវ និង រៀបចំជាសារណាសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញរដ្ឋបាលសាធារណៈនេះ។

យើងខ្ញុំទាំងពីរនាក់សង្ឃឹមថា អំណោះតទៅអត្ថបទដែលបានមកពីការស្រាវជ្រាវនាពេលនេះនឹងបានជាប្រយោជន៍ អាចចូលរួមចំណែកចែករំលែកនូវចំណេះដឹងបន្ថែមទៀតដល់ប្អូនៗនិស្សិតជំនាន់ក្រោយ និង ដល់អ្នកដែលមានបំណងចង់ស្វែងយល់ពីយុវជន និង ការងារនៅកម្ពុជានាពេលបច្ចុប្បន្នបន្ថែមមួយកម្រិតទៀត។ យើងខ្ញុំសូមអភ័យទោសទុកជាមុន នូវរាល់កំហុសឆ្គងនៃការរៀបរៀងកិច្ចការស្រាវជ្រាវសារណានេះឡើងដោយអចេតនា។ យើងខ្ញុំទាំងពីរនាក់រង់ចាំទទួលរាល់ការរិះគន់ និងការទិទានក្នុងន័យស្ថាបនាកែលម្អអំពីសាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានជានិច្ចដោយក្តីសោមនស្សរីករាយ។ សូមអរគុណចំពោះប្រិយមិត្តដែលបានចំណាយពេលដ៏មានតម្លៃក្នុងការអាន និង គាំទ្រដល់ស្នាដៃមួយនេះ។

# មាតិកា

**សេចក្តីផ្តើម...... ១**

**ជំពូកទី១ លក្ខណៈទូទៅរបស់យុវជននៅកម្ពុជា**

ស្ថានភាពទូទៅរបស់យុវជនកម្ពុជា......៤

១.១យុវជននិងការរៀន......៥

១.២.យុវជននិងការងារ......៥

១.២.១.យុវជននិងការងារស្ម័គ្រចិត្ត......៦

១.២.២.យុវជននិងការងារក្នុងវិស័យរដ្ឋ......៨

១.២.៣.យុវជននិងការងារក្នុងវិស័យឯកជន......៨

១.២.៤.យុវជននិងការងារក្នុងវិស័យសង្គមស៊ីវិល......៨

១.៣.យុវជននិងនយោបាយ......៩

**ជំពូកទី២ ក្របខណ្ឌគតិយុត្តពាក់ព័ន្ធយុវជន**

២.១.រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣......១១

២.២.គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា......១១

២.៣. ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧......១២

២.៤. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨......១២

២.៥. គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥......១៣

២.៦. ច្បាប់ស្តីពីមុខរបរ និងការងារកម្ពុជា......១៤

២.៧. ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងដំណើរការដោះស្រាយវិវាទការងារនៅកម្ពុជា......១៤

**ជំពូកទី៣ បញ្ហាប្រឈម និងដំណោះស្រាយបញ្ហាយុវជននៅកម្ពុជា**

**៣.១.បញ្ហាប្រឈម......១៥**

**៣.១.១. បញ្ហាប្រឈមក្នុងការអភិវឌ្ឍលក្ខណ្ឌការងារ......១៥**

ក. បញ្ហាប្រឈមការលើកកម្ពស់លក្ខខណ្ឌការងារឲ្យកាន់តែប្រសើរឡើង......១៥

ខ. បញ្ហាប្រឈមលើការពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ......១៥

គ. រោងចក្រសហគ្រាសដែលត្រូវចុះធ្វើអង្កេតមិនសូវសហការជាមួយនឹងក្រុមការងារ១៦

ឃ. បញ្ហាប្រឈមលើការពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារ......១៧

ង. បញ្ហាប្រឈមការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ......១៧

ច. បញ្ហាប្រឈមក្នុងការអភិវឌ្ឍមុខរបរ និងការងារ......១៨

**៣.១.២. កត្តាប្រវត្តិសាស្ត្រ ........................................................................ ១៨**
**៣.១៣. កត្តាអំពើពុករលួយ ........................................................................ ១៨**
ក. អំពើពុករលួយជាអ្វី? ........................................................................ ១៩
ខ. ប្រភេទនៃអំពើពុករលួយ ........................................................................ ១៩
គ. មូលហេតុកើតមានអំពើពុករលួយ ........................................................................ ១៩
ឃ.ផលប៉ះពាល់នៃអំពើពុករលួយ ........................................................................ ២០
**៣.១.៤. កត្តាអប់រំ ........................................................................ ២១**
ក. ការបាត់បង់ព្រលឹងក្នុងការសិក្សារបស់សិស្សានុសិស្សខ្មែរ ........................................ ២២
ខ. ឥរិយាបថអវិជ្ជមានរបស់គ្រូបង្រៀន ........................................................................ ២៣
គ. ឥរិយាបថអវិជ្ជមានរបស់ឪពុកម្តាយ និងអាណាព្យាបាល ........................................ ២៥
ឃ. ឥទ្ធិពលវប្បធម៌ពាលាអាវាសែបរទេស និងកង្វះការយកចិត្តទុកដាក់របស់សង្គម២៦
**៣.២. ដំណោះស្រាយ ........................................................................ ២៦**
**៣.២.១ដំណោះស្រាយរបស់រាជរដ្ឋាភិបាល ........................................................................ ២៦**
ក. ក្រសួងការងារ ........................................................................ ៣៣
ខ. ក្រសួងអប់រំ ........................................................................ ៣៤
ខ.១ សកម្មភាពនិងកម្មវិធីចម្បងៗ ........................................................................ ៣៤
ខ.២ ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី ........................................................................ ៣៥
**៣.២.២. អ្នកពាក់ព័ន្ធ ........................................................................ ៣៥**
ក. អង្គការសង្គមស៊ីវិល ........................................................................ ៣៥
ក.១ បង្កើតកម្មវិធីអប់រំ និងបណ្តុះបណ្តាល ........................................................................ ៣៥
ខ. វិស័យឯកជន ........................................................................ ៣៥
**សេចក្តីសន្និដ្ឋាន**
**អនុសាសន៍**
**ឯកសារយោង**
**ឧបសម្ពន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជាចាត់ទុកយុវជនជាធនធានគន្លឹះ និងមានតម្លៃបំផុតសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច វប្បធម៌ បរិស្ថាន និងការរក្សាសន្តិភាព ទាំងបច្ចុប្បន្ន និងទាំងអនាគត។ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើយុវជន ដែលជាសរសរទ្រូងនៃប្រទេសជាតិដោយ ផ្តល់ការសិក្សា ប្រកបដោយគុណភាពនិងប្រសិទ្ធភាព បន្ទាប់ពីកំណែទម្រង់ការប្រឡងថ្នាក់ជាតិមធ្យមសិក្សាទុតិយភូមិកាលពីឆ្នាំ២០១៤មក គឺដើម្បីឲ្យយុវជនទាំងអស់មានសមត្ថភាពអាចឈានចូលទៅក្នុងទីផ្សារការងារដោយងាយស្រួល។ ក្នុងនោះផងដែរ ក៏នៅមានយុវជនមួយចំនួនពុំទាន់មានឱកាសការងារសមស្របនៅឡើយ។ រីឯយុវជនដែលមានចំណេះដឹងតិចតួច បានទទួលកម្រៃទាបក្នុងនោះស្ត្រីមិនសូវទទួលបានការងារធ្វើដែលមានកម្រៃខ្ពស់នៅមានកម្រិត។ ចំណែកឯយុវជនមួយចំនួនទៀតបានធ្វើចំណាក់ស្រុកទៅកាន់ទីក្រុង ទីប្រជុំជននានា និងក្រៅប្រទេសដើម្បីស្វែងរកឱកាសការងារក្នុងការស្វែងរកប្រាក់ចំនូលដើម្បីចិញ្ចឹមជីវិត។ លើសពីនេះទៅទៀត ពួកគាត់ខ្លះប្រឈមមុខ នឹងការធ្លាក់ចូលក្នុងស្ថានភាពងាយរងគ្រោះ ដែលរួមមានការបោះបង់ការសិក្សា ការបាត់បង់ជម្រើសរបស់ខ្លួនការសេពគ្រឿងញៀនគ្រឿងស្រវឹង និងគ្រោះថ្នាក់នៅតាមកន្លែងធ្វើការ។

ដើម្បីលើកកម្ពស់សិទ្ធិ និងការទទួលខុសត្រូវរបស់យុវជនដែលជាកម្លាំងយ៉ាងសកម្មរបស់ប្រទេសជាតិនោះ នាងខ្ញុំទាំងពីរនាក់ក៏សម្រេចចិត្តលើកយកបញ្ហា "យុវជន និងការងារនៅកម្ពុជានាពេលបច្ចុប្បន្ន "មកសិក្សាស្រាវជ្រាវ ដើម្បីជាជំនួយដល់យុវជនជំនាន់ក្រោយស្តីពីមូលហេតុនៃភាពគ្មានការងារធ្វើ និងដំណោះស្រាយ ដោយរៀបចំឡើងស្របតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការងារ យុត្តសាស្ត្រចតុកោណ ផែនការយុត្តសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤ ២០១៨ និងឯកសារពាក់ព័ន្ធមួយចំនួនទៀត។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តាមរយៈការសិក្សាស្រាវជ្រាវទៅលើប្រធានបទៈ យុវជន និងការងារនៅកម្ពុជាបច្ចុប្បន្ន ចំណោទបញ្ហាចម្បងដែលគ្របដណ្តប់ប្រធានបទនេះទាំងមូលគឺ តើភាពអត់ការងារធ្វើរបស់យុវជននៅកម្ពុជាបច្ចុប្បន្នកម្រិតណា ហើយបញ្ហាអ្វីខ្លះដែលបង្កឲ្យយុវជនអត់ការងារធ្វើការបន្ទាប់ពីបញ្ចប់ការសិក្សាថ្នាក់មហាវិទ្យាល័យនាពេលបច្ចុប្បន្ន ដែលពាក់ព័ន្ធ និងដំណោះស្រាយ?

## ២.១. ចំណោទបញ្ហាបន្ទាប់បន្សំ

ក្នុងការសិក្សាទៅលើប្រធានបទនេះ ចំណោទបញ្ហាបន្ទាប់បន្សំមានដូចតទៅ៖

- យុវជនជាអ្នកណា? តើយុវជន និងការងារជាអ្វី?
- តើបញ្ហាប្រឈមរបស់យុវជនក្នុងការ រកការងារមានអ្វីខ្លះ?
- ដំណោះស្រាយរបស់រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ?
- គោលនយោបាយរាជរដ្ឋាភិបាល?

## ៣. គោលបំណងនៃការស្រាវជ្រាវ

មូលហេតុដែលធ្វើឲ្យយើងខ្ញុំយកបញ្ហានេះមកសិក្សាស្រាវជ្រាវ គឺដោយសារភាពអត់ការងារធ្វើរបស់យុវជននៅតែមានច្រើន បន្ទាប់ពីពួកគាត់បញ្ចប់ការសិក្សា ថ្នាក់មហាវិទ្យាល័យ ព្រមទាំងបង្ហាញពីទិដ្ឋភាពជាក់ស្តែងរបស់សង្គម តម្រូវការរបស់យុវជនទៅលើទីផ្សារការងារ ហើយដើម្បីសិក្សាពីគុណវុឌ្ឍិ និងកម្រិតសមត្ថភាពរបស់យុវជនបន្ទាប់ពី បញ្ចប់ថ្នាក់មហាវិទ្យាល័យដើម្បីប្រគួតប្រជែងជាមួយយុវជនដទៃទៀតទាំងក្នុង និងក្រៅស្រុក។ បន្ថែមលើសនេះទៅទៀត គឺដើម្បីធ្វើការសិក្សាទៅលើកត្តាប្រឈមអ្វីខ្លះដែលជះឥទ្ធិពលដល់យុវជនកម្ពុជារួមទាំងវិធានការដោះស្រាយ។ ជាចុងក្រោយ គឺដើម្បីក្រើនរំលឹកដល់ស្មារតីយុវជន ក៏ដូចជាជំនួយស្មារតីដល់យុវជនជំនាន់ក្នុងការស្រាវជ្រាវទៅលើបញ្ហានេះ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

អត្ថបទនេះ នឹងធ្វើការសិក្សាទៅលើមូលហេតុដែលបណ្តាលឲ្យយុវជនគ្មានការងារធ្វើ នឹងដំណោះស្រាយរបស់រាជរដ្ឋភិបាលនៅកម្ពុជានាពេលបច្ចុប្បន្ន។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវនេះយើងខ្ញុំបានប្រើវិធីសាស្រ្តចំនួនពីរយ៉ាងធំៗគឺ៖ ទិន្នន័យចម្បង៖ តាមរយៈទិន្ន័យចម្បងនេះ យើងខ្ញុំធ្វើឡើងក្នុងរូបភាព ការរៀបចំជាកម្រងសំណួរទៅសាកសួរព័ត៌មានផ្ទាល់តាមរយៈ ការណាត់ជួបសូមសម្ភាសន៍ ពីអគ្គនាយករងនៃអគ្គនាយកដ្ឋានយុវជន របស់ក្រសួងអប់រំ យុវជននិងកីឡា ប្រធានអង្គការសង្គមស៊ីវិលមួយចំនួន និងពីសំណាក់យុវជនមកពីកន្លែងផ្សេងៗផងដែរ។

ទិន្នន័យបន្ទាប់បន្សំ៖ ចំណែកឯទិន្នន័យបន្ទាប់បន្សំវិញ គឺត្រូវបានបង្ហាញឡើងតាមរយៈ ការប្រមូលឯកសារ សៀវភៅ និងទិន្នន័យ ដែលមានជាលាយលក្ខណ៍អក្សរ ព្រមទាំងឯកសារដកស្រង់ចេញពីអ៊ីនធឺណិតដូចជាគេហទំពររបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ

យុវជន និងកីឡា ព្រមទាំងទទួលការពន្យល់ណែនាំពីសាស្ត្រាចារ្យណែនាំសារណាបញ្ចប់ឆ្នាំសិក្សា។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាលើប្រធានបទនេះ បានផ្តល់សារៈសំខាន់ជាច្រើន ពីការស្រាវជ្រាវនេះដូចជា៖

- ធ្វើឲ្យយើងខ្ញុំកាន់តែយល់ច្បាស់ពីយុវជន ដែលជាសរសរទ្រូងនៃប្រទេសជាតិ
- ធ្វើឲ្យយើងខ្ញុំដឹងច្បាស់ ពីបញ្ហាប្រឈមយ៉ាងធំធេងរបស់យុវជន
- ធ្វើឲ្យយើងខ្ញុំដឹងច្បាស់ ពីកត្តាដែលបណ្តាលឲ្យយុវជនអត់ការងារធ្វើ
- ធ្វើឲ្យយើងខ្ញុំអាចសិក្សាពីការជះឥទ្ធិពលនៃភាពអត់ការងារធ្វើរបស់យុវជន ធ្វើឲ្យប៉ះពាល់ដល់សង្គម ក៏ដូចជាសេដ្ឋកិច្ចជាតិជាខ្លាំង
- ធ្វើឲ្យយើងខ្ញុំអាចស្វាបស្ទង់ពីកម្រិតនៃការប្រគួតប្រជែងសម្ថភាពរបស់យុវជនក្នុងការប្រគួតប្រជែងទីផ្សារការងារនាពេលបច្ចុប្បន្ន ក៏ដូចជានាពេលអនាគត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឲ្យការស្រាវជ្រាវនេះ ទទួលបាននូវគុណភាពល្អ ប្រសិទ្ធភាពខ្ពស់ឈានទៅរកភាពជោគជ័យនោះគឺ ទាមទារឲ្យមានការកំណត់រចនាសម្ព័ន្ធច្បាស់លាស់ ដើម្បីបង្ករភាពងាយស្រួលក្នុងការស្រាវជាវ។ សារណារនេះបែងចែកជា ៤ ជំពូក ដោយជំពូកទី១៖ លក្ខណៈទូទៅរបស់យុវជននៅកម្ពុជា ដែលបង្ហាញពីស្ថានភាពទូទៅរបស់យុវជនកម្ពុជាក្នុងការសិក្សា និងធ្វើការ។ ជំពូកទី២៖ ក្របខណ្ឌគតិយុត្តពាក់ព័ន្ធយុវជន ដែលបកស្រាយទៅលើ បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងយុវជនលើកមកបកស្រាយ។ ជំពូកទី៣៖ បញ្ហាប្រឈមរបស់យុវជន លើកយកកត្តាដែលនាំឲ្យអត់ការងារធ្វើរបស់យុវជន និងឪកាសការងាររបស់គាត់។ ជំពូកទី៣៖ ដំណោះស្រាយ ដែលបកស្រាយពីដំណោះស្រាយរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ ដែលរួមមានអង្គការសង្គមស៊ីវិល និងវិស័យឯកជន។

# ជំពូកទី១. លក្ខណៈទូទៅរបស់យុវជននៅកម្ពុជា

## ស្ថានភាពទូទៅរបស់យុវជនកម្ពុជា

ប្រទេសកម្ពុជាក្នុងបរិបទសង្គម វប្បធម៌ និងនយោបាយពាក្យថា យុវជន គឺជាបុរស ស្ត្រីដែលមានសញ្ជាតិខ្មែរពីអាយុ ១៥ ដល់៣០ឆ្នាំ នៅលីវ ឬរៀបការរួច នេះបើតាមជំរឿនទូទៅនូវប្រជាសាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ យុវជនមាន៣៣ភាគរយ នៃចំនួនប្រជាជនសរុប[1]។

យុវជនជាធនធានគ្រឹះដ៏សំខាន់ និងមានតម្លៃក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងការរក្សាសន្តិភាពទាំងក្នុងបច្ចុប្បន្ន និងអនាគត ហើយក៏ជាទំពាំងស្នងឫស្សីដែលសង្គមជាតិចង់បានឫស្សីល្អ និងមានគុណភាព។ ការអប់រំពិតជាមានសារៈសំខាន់ណាស់ចំពោះអ្នកសិក្សាគ្រប់រូប ហើយប្រទេសជាតិមានការអភិវឌ្ឍន៍រុងរឿងទៅបាន ក៏អាស្រ័យយុវជន ដែលជាធនធានមនុស្ស មិនអាចខ្វះបាន។ ប៉ុន្មានឆ្នាំចុងក្រោយនេះប្រព័ន្ធអប់រំនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ហើយយុវជនមានបំណងចង់ទទួលយកការសិក្សា រៀនសូត្រនូវអ្វីដែលថ្មី ឬជំនាញថ្មីៗបន្ថែមទៀត។ ប៉ុន្តែនិស្សិតមួយចំនួនធំជ្រើសរើសបន្តជំនាញគណនេយ្យ ទីផ្សារ ហិរញ្ញវត្ថុ និងធនាគារ តែជំនាញដែលត្រូវការអនុវត្តន៍ជាក់ស្តែងផ្សេងៗទៀតនោះ គឺនៅមានការខ្វះខាតនៅឡើយ។

អ្នកវិភាគមួយចំនួនបាននិយាយថា កម្ពុជាប្រហែលជាដើរក្រោយគេ ប្រសិនបើកម្លាំងពលកម្មដែលមានស្រាប់នេះមិនមានជំនាញដែលទីផ្សារកំពុងត្រូវការ ហើយអត្ថប្រយោជន៍ផ្សេងៗដែលត្រូវបានពីការធ្វើសមាហរណកម្មនឹងធ្លាក់ចុះ ឬបាត់បងឱកាសដោយសារតែសមត្ថភាពរបស់កម្លាំងពលកម្ម និងការអប់រំដល់ពួកគេគ្មានប្រសិទ្ធភាព។ ជារៀងរាល់ឆ្នាំ មានយុវជនរាប់ពាន់នាក់បានបោះជំហានចូលទីផ្សារពលកម្ម ប៉ុន្តែអ្វីដែលយុជនទាំងនោះមាននៅក្នុងខ្លួនដូចជា ចំណេះដឹង សមត្ថភាព ជំនាញគឺវាមិនទាន់សមស្របនឹងតម្រូវការបច្ចុប្បន្ន។

ដូចនេះកម្ពុជាចាំបាច់ត្រូវតែធ្វើ កំណែទម្រង់ប្រព័ន្ធអប់រំស៊ីជម្រៅដើម្បីឱ្យគុណភាព និងប្រសិទ្ធភាពឆ្លើយតបនិងតម្រូវការ បើមិនដូច្នេះទេ កម្ពុជា ជាពិសេសយុវជននិងជួបប្រទះ ឬប្រឈមនិងបញ្ហាជាច្រើនក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ ក៏ដោយសារតែការហូរចូលនូវពលករបរទេសដែលមានជំនាញមកប្រកួតប្រជែងជាមួយកម្ពុជា។

[1] កម្រងទស្សនសង្គម និងនយោបាយ បណ្ឌិត **កែម ឡី** ឆ្នាំ២០១៦ ស្ថានភាពយុវជន និងការងារ២០១៦ យុវជនត្រូវស្ថិតក្នុងរបៀបវារៈនៃការអភិវឌ្ឍន៍ ទំព័រទី២៨

## ១.១. យុវជននិងការរៀន

ការអប់រំត្រូវបានចាត់ទុកជាកត្តាសំខាន់សម្រាប់អភិវឌ្ឍន៍ប្រទេស។ ការសិក្សានៅកម្ពុជាត្រូវបានផ្លាស់ប្តូរពីមួយសម័យកាលទៅមួយសម័យកាល កាលពីមុនសតវត្សទី២០ ការអប់រំនៅកម្ពុជាត្រូវគ្រប់គ្រងដោយប្រពៃណី និងសាសនា គឺសាលារៀននៅក្នុងវត្ត ហើយព្រះសង្ឃជាគ្រូបង្រៀន សិស្សដែលអាចរៀនបានភាគច្រើនជាសិស្សប្រុស ហើយសិស្សស្រីស្ទើរតែគ្មាន។ រហូតមកដល់បច្ចុប្បន្ននេះ កម្ពុជា មានសាលារៀនជាច្រើន ស្ត្រី និងបុរសមានសិទ្ធិស្មើគ្នា ក្នុងការទទួល បានការអប់រំ។ យុវជនបច្ចុប្បន្ន ទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពីសាលាភាគច្រើន គឺទទួលបានត្រឹមតែទ្រឹស្តីតែប៉ុណ្ណោះ ឯការអនុវត្តវិញនោះគឺស្ទើរតែស្មើសូន្យ រួមទាំងកត្តាខ្លួនឯងផ្ទាល់ កត្តាគ្រួសារ កត្តាសង្គម។ ដែលមូលហេតុនេះ ធ្វើឲ្យយុវជន ងាយទទួលរងនូវភាពបរាជ័យនៅក្នុងការសិក្សា[2] ។ ព្រោះដោយសារតែបញ្ហាដូចជា៖

- សាលារៀននៅឆ្ងាយពីផ្ទះពេក
- គ្រូបង្រៀនគ្មានសមត្ថភាព ក្នុងការបណ្តុះបណ្តាល និងអប់រំ ខ្វះសមត្ថភាពក្នុងការគ្រប់គ្រង
- ការរៀបចំថ្នាក់រៀនមិនគោរពតាមគរុកោសល្យ (ថ្នាក់រៀនមានសិស្សច្រើនពេក)
- ខ្វះខាតសម្ភារបង្រៀន
- អំពើពុករលួយក្នុងសង្គម និងភាពអត់ការងារធ្វើ ជាមូលហេតុមួយធ្វើឲ្យសិស្សបាក់ទឹកចិត្តក្នុងការសិក្សា
- យុវជនខ្លួនឯងមិនខិតខំរៀនសូត្រមិនយកចិត្តទុកដាក់ក្នុងការសិក្សា ខ្ជិលច្រអូសក្នុងការសិក្សា មិនស្តាប់គ្រូពន្យល់ មានបញ្ញាមិនសូវល្អ
- ការរីកលូតលាស់បុគ្គលិកលក្ខណៈមិនល្អ មានជំងឺប្រចាំកាយ។
- ការសេពគប់មិត្តភក្តិមិនល្អ ភ្លើតភ្លើននឹងវប្បធម៌បរទេស
- ខ្វះខាតជីវភាពក្នុងគ្រួសារ គ្រួសារខ្វះការអប់រំ ឪពុកម្តាយគ្មានចំណេះដឹង គ្មានសមត្ថភាពអប់រំកូន ជាដើម។

## ១.២. យុវជននិងការងារ

តាមជំរឿនពលរដ្ឋនាឆ្នាំ២០០៨ និងពាក់កណ្តាលជំរឿនឆ្នាំ២០១៣ យុវជនមានប្រមាណ៣២ភាគរយ ឬជាង៤លាន៣សែននាក់ នៃប្រជាពលរដ្ឋកម្ពុជាសរុប។ យុវជនដែលមានអាយុចាប់ពី

[2] អត្ថបទចុះផ្សាយថ្ងៃទី២ខែមិថុនាឆ្នាំ២០១៥ ដោយវេបសាយព័ត៌មានថ្មីថ្មី តើសិស្សបរាជ័យក្នុងការសិក្សាបណ្តាលមកពីកត្តាអ្វីខ្លះ?

១៥ឆ្នាំ ដល់២៩ឆ្នាំ មានការងារធ្វើ បើធៀបទៅនឹងយុវជនសរុបមានចំនួន ៨៣.១ភាគរយ និងកម្លាំងយុវជនមានរហូតដល់ ៨៥.១ភាគរយ (Global Employment Trends Survey2015, ILO) [3]។

### ១.២.១. យុវជននិងការងារសង្គម (ការងារស្ម័គ្រចិត្ត)

បច្ចុប្បន្ន មានយុវវ័យមួយចំនួន មិនសូវជាចាប់អារម្មណ៍ ទៅលើការងារស្ម័គ្រចិត្តប៉ុន្មានឡើយ ម្ល៉ោះហើយពួកគេយល់ឃើញថា ការងារស្ម័គ្រចិត្ត គ្មានប្រាក់បៀវត្ស ឬប្រាក់កម្រៃតិច ថែមទាំងមានការលំបាកទៀតផង។ ការងារស្ម័គ្រចិត្ត គឺជាការងារណាដែលផ្តើមចេញពីឆន្ទៈផ្ទាល់របស់មនុស្សម្នាក់ៗ ដោយមិនផ្តោតខ្លាំងពេកទៅលើតែ កម្រៃ ឬប្រាក់បៀវត្ស ហើយធ្វើដើម្បីផលប្រយោជន៍ខ្លួនឯង សហគមន៍ ក្រុមគ្រួសារ និងសង្គមជាតិ ទាំងមូល។ ប្រសិនបើសម្លឹងមើលក្នុងសង្គមខ្មែរយើង ប្រពៃណីនៃការងារស្ម័គ្រចិត្ត គឺមានតាំងពីយូរលង់ណាស់មកហើយ ដូចជា ការចូលរួមកសាងទីអារាម សាលាឆទាន លើកផ្លូវ ជាដើម នេះបើយោងតាមឯកសារមួយចំនួន។ ប៉ុន្តែសម្រាប់ការងារស្ម័គ្រចិត្តនាសម័យបច្ចុប្បន្ននេះ អាចនិយាយបានថា ជាស្ពានចម្លង ឱ្យយុវវ័យទទួលបាននូវបទពិសោធន៍ ក្នុងការឆ្ពោះទៅរកភាពជោគជ័យ ហើយក៏ជាទុនមួយដែលអាចបំពេញនូវក្តីបំណងប្រាថ្នា ដោយចាប់ផ្តើមពីការងារក្នុងក្តីស្រមៃ ដើម្បីបំពេញមហិច្ឆតា ទៅថ្ងៃអនាគតខាងមុខ។ ជាក់ស្តែង ការងារស្ម័គ្រចិត្ត ផ្តល់នូវអត្ថប្រយោជន៍ធំៗ២ គឺ ដល់អ្នកធ្វើ និងអ្នកទទួល។ អ្នកធ្វើនឹងទទួលបាននូវ បទពិសោធន៍ ចំណេះដឹងថ្មី និងសម្របខ្លួនឱ្យចុះទៅតាមស្ថានភាពសង្គម ដែលប្រែប្រួលជារៀងរាល់ថ្ងៃ និងមិនធ្លាប់ជួបប្រទះពីមុនមក ទន្ទឹមនឹងពេលជាមួយគ្នានេះ ប្រសិនបើនិយាយដល់អ្នកទទួល ពោលគឺប្រជាពលរដ្ឋក្នុងសហគមន៍ ខ្លួនឯងផ្ទាល់ សង្គមគ្រួសារ និងសង្គមជាតិ ទាំងមូល។ ជាការពិតណាស់ ការងារស្ម័គ្រចិត្ត គឺទាមទារនូវឆន្ទៈខ្ពស់ បំពេញការងារឥតរុញរា និងមិនទាន់គិតពីប្រាក់កម្រៃហើយសិស្សនិស្សិតអាចស្វែងរកការងារស្ម័គ្រចិត្តតាមរយៈបណ្តាញសង្គម ឬបណ្តាអង្គការ ស្ថាប័ន ក្រុមហ៊ុន និងគ្រឹះស្ថានសាធារណៈ ផ្សេងៗ។ យោងតាមការសិក្សារបស់អង្គការក្រៅរដ្ឋាភិបាល មួយចំនួន បានបង្ហាញពីចំណុចខ្វះខាតមួយចំនួន ដែលបណ្តាលឱ្យនិស្សិតមួយចំនួន ដែលបានបញ្ចប់ការងារសិក្សា រកការងារមិនបានធ្វើ គឺបណ្តាលមកពីខ្វះនូវបទពិសោធន៍ ខ្វះជំនាញបន្ថែម ខ្វះការពង្រឹងសមត្ថភាព។ ដូច្នោះហើយ យុវវ័យ គួរតែងាកមកសម្លឹងរកឱកាសការងារស្ម័គ្រចិត្ត ដើម្បីបង្កើននូវជំនាញបន្ថែម និងពង្រឹងសមត្ថភាព ព្រមទាំងបទពិសោធន៍ពិសេស កាងារដែលទាក់ទងទៅ នឹងមុខវិជ្ជា ដែលខ្លួនកំពុងសិក្សា។ ការងារស្ម័គ្រចិត្ត បានចូលរួម

[3] កម្រងទស្សនសង្គម និងនយោបាយ បណ្ឌិត **កែម ឡី** ឆ្នាំ២០១៦ ស្ថានភាពយុវជន និងការងារ២០១៦ យុវជនត្រូវស្ថិតក្នុងរបៀបវារៈនៃការអភិវឌ្ឍន៍

ចំណែក ជួយសង្គម បានមួយចំណែកតូចដែរ ដូចជាយុវវ័យកាកបាទក្រហមកម្ពុជា ចូលរួមធ្វើយុទ្ធនា ការអប់រំច្បាប់ចរាចរដល់អ្នកបើកបរ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរនៅតាមចំណុចភ្លើងស្តុបនានា នៅតាមបណ្តាដងផ្លូវសំខាន់ៗក្នុងរាជធានី និងតាមបណ្តាខេត្ត ផ្សេងៗ ទៅទាំងប្រទេស នៅរៀងរាល់ចុងសប្តាហ៍ ជាដើម។ ទស្សនៈអសកម្ម យុវវ័យ ខ្លះយល់ឃើញថា ការងារស្ម័គ្រចិត្ត គឺជាការងារមួយ ដែលចាំតែធ្វើតាមបញ្ជារគេ ប៉ុន្តែ ការយល់ឃើញដូច្នេះ វាហាក់ដូចគ្រាន់តែជាលេសមួយ សម្រាប់គេចវេសពីការពិតតែប៉ុណ្ណោះ។ ព្រោះគ្មាននរណាម្នាក់ អាចឈានបោះជើងមួយជំហាន បានសម្រេចគោលដៅនោះឡើយ គឺត្រូវចេះរៀបចំគម្រោង និងចាប់ផ្តើមអនុវត្តន៍ ចេញអំពីចំណុចក្រោមដូចគ្នា ដូច្នេះចៀសមិនផុតអំពីការនៅក្រោមបញ្ជាររបស់អ្នកដឹកនាំ នោះឡើយ។ ចំពោះទស្សនៈដែលគិតថា ការងារស្ម័គ្រចិត្ត មិនមានសារៈសំខាន់នោះ គឺមិនត្រឹមត្រូវនោះឡើយ ព្រោះការងារស្ម័គ្រចិត្តមិនត្រឹមតែជួយឱ្យអ្នកដែលធ្វើទទួលបាននូវប្រយោជន៍នោះទេថែមទាំងផ្តល់នូវប្រយោជន៍ជាសាធារណៈ ដល់សង្គមទៀតផង។ អាចមានយុវវ័យ យុវជន យុវតី មួយចំនួន រុញរានឹងការងារស្ម័គ្រចិត្ត ខ្លាចរអាការបញ្ជូនទៅតាមកន្លែងឆ្ងាយៗ ព្រួយបារម្ភអំពីសុវត្ថិភាព ការស្នាក់នៅ ហូបចុក។ ប៉ុន្តែ គំនិតនេះវាសម័យទៅហើយ ព្រោះសម័យទំនើបភាវូបនីយកម្មនេះ មនុស្សទាំងអស់ ក៏ដូចជាយុវវ័យទាំងប្រុស ស្រី គឺមានសិទ្ធិស្មើគ្នា សមភាព សមធម៌ យេនឌ័រ ដែលគាំទ្រដោយរាជរដ្ឋាភិបាល។ ចូរចងចាំថា " អ្វីដែលបុរសអាចធ្វើបាន នោះស្ត្រីក៏អាចធ្វើបានដូចគ្នាដែរ។ ហើយការងារខ្លះ ដែលស្ត្រីអាចធ្វើបាន ប៉ុន្តែបុរសបែរជាពុំអាចធ្វើបាន ក៏មានដែរ "។ សម្រេចជ្រើសរើសធ្វើការងារស្ម័គ្រចិត្ត មានន័យថា យើងបានជួយសង្គមជាតិ ហើយក៏ដូចជា ជួយខ្លួនឯងផងដែរ ក្នុងការសន្សំបទពិសោធន៍ បង្កើននូវទំនាក់ទំនងល្អ ជាមួយមជ្ឈដ្ឋានខាងក្រៅ ដើម្បីឈានឆ្ពោះទៅរកការងារល្អ និងជោគជ័យ នាពេលអនាគត។ ប្រាកដណាស់ ការងារស្ម័គ្រចិត្ត អាស្រ័យទៅលើលក្ខណៈការងារដែរ ការងារខ្លះត្រូវការរយៈពេលយូរ ប៉ុន្តែប្រសិនបើការងារនោះ ទាក់ទងទៅនឹងមុខវិជ្ជា ដែលយើងកំពុងសិក្សា គួរតែស្វែងរកការងារណា ដែលមានរយៈពេលយូរ ដើម្បីឈានទៅរកឱកាសការងារល្អមួយ នាពេលខាងមុខ។ យុវវ័យទាំងឡាយ គួរតាំងជំហរថា ការងារស្ម័គ្រចិត្ត គឺជាទុនដ៏សំខាន់បំផុត មួយ ដែលអាចបំពេញក្តីបំណងនៃការងារក្នុងក្តីស្រមៃរបស់យើង បានដោយប្រត្យក្ស។ យុវវ័យរាល់រូប សុទ្ធតែអាចធ្វើវិភាគទានដល់សង្គមបាន ដោយបែបផែនផ្សេងៗគ្នា ទៅតាមជំនាញរៀងៗខ្លួនដែលវាជាសិទ្ធិ និងភារកិច្ច របស់យើងទាំងអស់គ្នា[4]។

[4] អត្ថបទចុះផ្សាយថ្ងៃសុក្រ ទី២៦ខែតុលាឆ្នាំ២០១២ ដោយវេបសាយព័ត៌មានខ្មែរឡូត "តើត្រឹមត្រូវទេដែលយុវវ័យគិតថាការងារស្ម័គ្រចិត្តជាការងារឥតប្រយោជន៍?"

### ១.២.២. យុវជននិងការងារក្នុងវិស័យរដ្ឋ

ជារៀងរាល់ឆ្នាំ នៅតាមស្ថាប័នរដ្ឋនានាតែងតែមានមនុស្សចូលនិវត្តន៍ និងការប្រកាសជ្រើសរើសយុវជន ដែលមានសមត្ថភាពឲ្យមកធ្វើការងាររដ្ឋ តាមរយៈការប្រឡងប្រជែងជ្រើសរើស ។ យុវជនដែលចូលធ្វើការនៅក្នុងវិស័យរដ្ឋ មានឱកាសទទួលបានសិទ្ធិ និងអត្ថប្រយោជន៍ដូចជាៈ ទទួលបានប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់ហានិភ័យ ប្រាក់វិភាជន៍គ្រួសារ ប្រាក់លាភការបន្ថែម ការអនុវត្តកន្សោមអត្តិភាព សិទ្ធិដំឡើងថ្នាក់ និងឋានន្តរស័ក្តិ សិទ្ធិចូលនិវត្តន៍ សិទ្ធិទទួលបានងារ និងគ្រឿងឥស្សរយយសផ្សេងៗ និងសិទ្ធិសេរីភាពផ្សេងៗទៀត[5]។

### ១.២.៣. យុវជននិងការងារក្នុងវិស័យឯកជន

យុវជនដែលធ្វើការងារនៅក្នុងវិស័យឯកជន មានទាំងយុវជនមានកិច្ចសន្យាការងារ និងយុវជនមិនមានកិច្ចសន្យាការងារ។ ចំពោះយុវជនដែលមានកិច្ចសន្យាការងារគឺពួកគេទទួលបាន អត្ថប្រយោជន៍ច្រើនជាងយុវជនដែលធ្វើការងារមិនមានកិច្ចសន្យាការងារ និងមានឱកាសនៅក្នុងការស្វែងរកបទពិសោធន៍ការងារសង្គមជាដើម។ ចំណែកឯយុវជនដែលមិនមានកិច្ចសន្យាការងារច្បាស់លាស់ ធ្វើការងារសេដ្ឋកិច្ចក្រៅប្រព័ន្ធ មិនបានទទួលការការពារដោយច្បាប់ការងារ ឬក៏សហជីពចាំជួយគាំទ្រនោះគឺពួកគេប្រឈមមុខទៅនឹងបញ្ហាហានិភ័យចំពោះការងារខ្ពស់រួមទាំងជួបប្រទះនូវភាពអត់ការងារធ្វើជាញឹកញយ ហើយត្រូវធ្វើការលើសពី៦ថ្ងៃក្នុង១អាទិត្យ និងលើសពី៨ម៉ោងក្នុង១ថ្ងៃ ដែលការងារនោះស្ថិតនៅក្នុងបរិយាកាសមិនមានសុវត្ថិភាព ធ្វើឲ្យគ្រួសារជួបនឹងបញ្ហាកង្វះហិរញ្ញវត្ថុ។

### ១.២.៤ យុវជននិងការងារក្នុងវិស័យសង្គមស៊ីវិល

បច្ចុប្បន្ននេះយុវជនដែលធ្វើការ ស្វែងរកការងារធ្វើមានចំនួនច្រើន ប៉ុន្តែអ្នកចេះធ្វើការហើយធ្វើការប្រកបដោយភាពស្មោះត្រង់ ប្រកបដោយការទទួលខុសត្រូវខ្ពស់មានចំនួនតិច។ ប្រទេសកម្ពុជាកំពុងខ្វះធនធានមនុស្សដែលអាចជំរុញផលិតកម្មអោយឈានទៅមុខឆាប់រហ័ស។ មិនមែនគ្រប់យុវជនទាំងអស់គ្នានោះទេដែលគ្មានការងារធ្វើ អ្នកខ្លះ អាចរកការងារបានធ្វើភ្លាម អ្នកខ្លះត្រូវការរយៈពេល១ឆ្នាំ ឬ២ឆ្នាំទើបអាចទទួលបានការងារធ្វើជាប់លាប់។ អ្នកខ្លះទៀត ទទួលបានការងារធ្វើដែរ តែជាការងារមិនពេញម៉ោង និងទទួលបានប្រាក់បៀវត្សរ៍មិនសមរម្យ។ ដោយសារតែកង្វះការងារល្អនៅក្នុងប្រទេស និងដោយសារតែប្រាក់ខែនៅក្នុងប្រទេសមានកម្រិតទាប។ យុវជន

[5] នីតិមុខងារសាធារណៈ សាស្ត្រាចារ្យអនុបណ្ឌិត **ហៀង សាង**

ដែលធ្វើការនៅក្នុងវិស័យនេះ ក៏មិនសូវខុសពីយុវជនដែលធ្វើការនៅក្នុងវិស័យឯកជនប៉ុន្មានឡើយ គឺយុវជនដែលមានកិច្ចសន្យាការងារមួយដែលមានភាពច្បាស់លាស់ធ្វើឲ្យពួកគេទទួលបាននៅអត្ថប្រយោជន៍ជាច្រើន ឯយុវជនឬបុគ្គលិកដែលពុំមានកិច្ចសន្យាច្បាស់លាស់នោះនិងជួបប្រទះទៅនឹងបញ្ហាហានិភ័យចំពោះការងារខ្ពស់ ឯឱកាសទទួលបាននូវបទពិសោធន៍ការងារទាំងនៅក្នុងស្រុក និងនៅក្រៅស្រុកគឺមានតិចជាងបុគ្គលដែលមានកិច្ចសន្យាការងារច្បាស់លាស់។

## ១.៣. យុវជន និងនយោបាយ

ក្នុងការអភិវឌ្ឍប្រទេស គេមិនអាចទាត់ចោលតួនាទីយុវជនបានទេ ព្រោះយុវជនជាសសរទ្រូងរបស់ប្រទេសជាតិ។ ស្ថិតក្នុងន័យនេះ ប្រទេសជាតិមួយ ត្រូវយកចិត្តទុកដាក់ឱ្យបានមុតមាំ ក្នុងការដុះខាត់យុវជន ឱ្យក្លាយជាមនុស្សមានសមត្ថភាពគ្រប់គ្រាន់ពេញលេញ ដើម្បីបន្តតំណែងពីមនុស្សចាស់ក្នុងកិច្ចការដឹកនាំប្រទេស។ អ្នកដឹកនាំដែលល្អ ត្រូវផ្តល់ឱកាសដល់យុវជន ក្នុងការអភិវឌ្ឍភាពជាអ្នកដឹកនាំរបស់ខ្លួន និងផ្តល់កម្លាំងចិន្តានុភាព ក្នុងការចូលរួមចំណែកអភិវឌ្ឍប្រទេសដែលជាគន្លឹះសំខាន់ក្នុងការជំរុញសង្វាក់អភិវឌ្ឍឱ្យសន្ទុះលឿន និងមានស្ថេរភាព។ បើសិន ជានៅតាមស្ថាប័នអ្នកដឹកនាំ ពុំមានផ្តល់ឱកាស ឬក៏ជាការជម្រុញនៅកម្លាំងចិត្ត នោះយុវជនពិតជាមិនអាចសិក្សារៀនសូត្រប្រឹងប្រែងធ្វើការងារនិងមានឆន្ទះមុតមាំបង្ហាញឲ្យ អស់សក្តានុពលភាពរបស់ខ្លួន ដើម្បីសេចក្តីសង្ឃឹមអនាគត ក្នុងការប្រកួតប្រជែង ធ្វើជាអ្នកដឹកនាំឡើយ។ មិនតែប៉ុណ្ណោះ បើការតម្លើងតួនាទី ធ្វើជាអ្នកដឹកនាំមិនបានផ្អែកជាសំខាន់ ទៅលើសមត្ថភាពរបស់បុគ្គលនោះ វាកាន់តែមានសភាពធ្ងន់ធ្ងរថែមទៀតសម្រាប់យុវជន ពិសេសយុវជនក្រីក្រ។ យុវជន នឹងក្លាយជាមនុស្សចាស់ និងជាឪពុកម្តាយគេនាពេលអនាគត ដូច្នេះបើមានយុវជនចាប់អារម្មណ៍និងចូលរួមច្រើនក្នុងកិច្ចការនយោបាយ វាជាសញ្ញាណវិជ្ជមាន ព្រោះវាបង្ហាញពី សន្ទុះនៃការសាងភាពជាអ្នកដឹកនាំកាន់តែច្រើន ហើយឥទ្ធិពលនេះវាអាចបន្តដល់កូនគេថែមទៀត ហើយពេលនោះពាក្យ ″នយោបាយ″ លែងជាពាក្យដែលមានរូបារម្មណ៍គួរឱ្យភ័យខ្លាចទៀតហើយ។ អ្នកដឹកនាំដែលល្អ គឺជាអ្នកបង្កើតអ្នកដឹកនាំឱ្យបានច្រើន មិនមែនបង្កើតអ្នកដើរតាម ចូលចិត្តអែបអប ឬមនុស្សរង់ចាំតែទទួលបញ្ជានោះទេ។ មួយវិញទៀត អ្នកដឹកនាំមិនគួរប្រកាន់ និងរាំងខ្ទប់នឹងការយល់ឃើញផ្សេងៗរបស់យុវជនចំពោះការងារដឹកនាំទេ ព្រោះវាជារនាំងដែលបង្អាក់ការលូតលាស់ ផ្នែកគំនិតយល់ដឹងពីកិច្ចការអភិវឌ្ឍសង្គម ឬជំរុញយុវជន ឱ្យមើលឃើញតែពីទិដ្ឋភាព ដែលមានពន្លឺដែលអ្នកនយោបាយ ចុចពិលបំភ្លឺ ដោយមិនមានការយល់ដឹងទូលំទូលាយ គ្រប់ជ្រុងជ្រោយ ដែលករណីនេះវានឹងជំរុញឱ្យពួកគេ ក្លាយខ្លួនជាបោយរបស់នយោបាយប៉ុណ្ណោះ។ ជាការពិត បើយុវជនចាប់

អារម្មណ៍រឿងនយោបាយ ភាគច្រើនមិនមានពុតត្បុតទេ ដោយពួកគេព្យាយាមបង្ហាញចេញនូវទស្សនៈយល់ឃើញរបស់គេ ដោយស្មោះត្រង់។ ក្នុងន័យនេះ បើពួកគេ យល់ឃើញ យ៉ាងម៉េច គេនឹងបញ្ចេញមកយ៉ាងនោះ ដែលលក្ខណៈនេះ ខុសពីមនុស្សចាស់ ដែលមានភាពប្រយ័ត្នប្រយែងច្រើន ។ ជារួមភាពខ្លាំងរបស់យុវជន គឺយុវជនដែលមានភាពជាអ្នកដឹកនាំ និងចូលរួមចំណែកសកម្មក្នុងកិច្ចការអភិវឌ្ឍប្រទេស[6]។

[6] ការវិភាគបញ្ហាសង្គម ដោយវេបសាយ សាកល្បងវិភាគបញ្ហាសង្គមសេដ្ឋកិច្ចកម្ពុជា គំនិតយុវជនស្តីពីបញ្ហាសង្គម និងការអភិវឌ្ឍ អត្ថបទ យុវជន និងនយោបាយ ចុះផ្សាយថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៣

# ជំពូកទី២ ក្របខណ្ឌគតិយុត្តពាក់ព័ន្ធយុវជន

## ២.១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ជំពូកទី៣ អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ មាត្រា ៣៦ បានចែងថា "ប្រជាជនខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្រប តាមសមត្ថភាព របស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម។ ប្រជាពលរដ្ឋទាំងពីរភេទ មានសិទ្ធិទទួលបានប្រាក់ បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នា"។ ដូច្នេះវាបានបង្ហាញឲ្យឃើញថា យុវជនមានសិទ្ធិជ្រើសរើស យក មុខរបរ ឬជំនាញអាជីពការងារណាមួយទៅតាមសមត្ថភាពរបស់ខ្លួន ដោយការងារទាំងអស់ នោះយុវជនមានសិទ្ធិ ទទួលបាននូវ ការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដូច ដែលមានចែងនៅក្នុងច្បាប់ការងារ។ ក្រៅពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏មានច្បាប់ដែល បម្រើផលប្រយោជន៍ដល់យុវជនត្រូវបានគេតាក់តែងឡើងដូចជាៈ

## ២.២.គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជនកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ថា ការអប់រំគឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការអភិវឌ្ឍន៍សេដ្ឋ កិច្ចជាតិ និងធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចមួយប្រកបដោយចីរភាព ឆ្ពោះទៅរកការកាត់បន្ថយ ភាពក្រីក្រ។ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើយុវជនដែលជាសសរទ្រូងប្រទេសជាតិដោយផ្ត ល់ការសិក្សាប្រកបដោយគុណភាព និងមានសមត្ថភាពអាចឈានចូលទីផ្សារការងារដោយងាយ ស្រួល។ ដើម្បីលើកកម្ពស់សិទ្ធិ និងការទទួលខុសត្រូវរបស់យុវជន រាជរដ្ឋាភិបាលបានបង្កើតគោល ដៅដល់យុជនតាមរយៈគោលនយោបាយជាតិ ដូចជា ផ្តល់ឪកាសឲ្យយុជនទទួលបានការអប់រំ និង ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ លើកទឹកចិត្តឲ្យយុវជនមានគំនិតផ្តួចផ្តើម លើកកម្ពស់យេនឌ័រ អភិវឌ្ឍយុវជនឲ្យមានកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ លើកកម្ពស់ឲ្យយុវ ជនមានការយល់ដឹងទូលំទូលាយអំពីសង្គម រួមទាំងការបង្កបរិយាកាសឲ្យឪកាសឲ្យយុវជនបាន ចូលរួមបញ្ចេញមតិយោបល់ ទស្សនៈ និងធ្វើសេចក្តីសម្រេចចិត្តនានាក្នុងការអភិវឌ្ឍន៍សហគមន៍ និងសង្គមជាតិជាដើម។ មួយវិញទៀត ដើម្បីសម្រេចឲ្យបាននៅគោលបំណង និងគោលដៅ គោល នយោបាយនេះបានរៀបចំយុទ្ធសាស្ត្រសំខាន់ៗដូចជាៈ

- អភិវឌ្ឍន៍ក្របខណ្ឌច្បាប់ និង យន្តការ
- លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាព

- ការបង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព
- បណ្តុះស្មារតីសហគ្រិនភាពទីផ្សារការងារ
- លើកកម្ពស់កិច្ចការពារ សុវត្ថិភាព សន្តិសុខ និងយុត្តិធម៌
- បង្កើនការចូលរួមរបស់យុវជន
- លើកកម្ពស់ការសម្រាក ការកម្សាន្ត និងកីឡា
- លើកកម្ពស់សិល្បៈ និងវប្បធម៌
- លើកកម្ពស់ការយល់ដឹងពីបរិស្ថាន កសិកម្ម ទេសចរណ៍ និងធុរកិច្ច
- បង្កើនការងារស្ម័គ្រចិត្ត
- លើកកម្ពស់សមភាពយេនឌ័រ
- ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងស្តារយុវនីតិសម្បទា។

### ២.៣. ច្បាប់ស្តីពីការងារ

ជាច្បាប់ដ៏សំខាន់មួយ ដែលជួយសម្រួលដល់ទំនាក់ទំនងវិជ្ជាជីវៈ ការចរចាជាសមូហភាព ឬជាបុគ្គល និងការដោះស្រាយវិវាទការងារជារួម និងជាបុគ្គល អនាម័យ និងសន្តិសុខ ការងារ និងលក្ខខណ្ឌទូទៅនៃការងាររបស់កម្មករនិយោជិតទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះបង្កើតឡើងដំបូងក្នុងគោលបំនង លុបបំបាត់ទាសភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ១៨៩៨ ក្នុងន័យឲ្យទាសករទាំងអស់មានសេរីភាពឡើងវិញ ការផ្តល់ប្រាក់បៀវត្សទៅដល់កម្មករ ផ្តល់លក្ខខណ្ឌកិច្ចសន្យាការងារ និងការកំណត់ម៉ោងធ្វើការផងដែរ។ ក្រោយមកបន្ទាប់ពីឆ្លងកាត់សម័យ និងការវិវត្តន៍នៃផ្នែកច្បាប់ជាច្រើនដំណាក់កាល ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ បានប្រសូត្រឡើង ដោយច្បាប់នេះបានចែងយ៉ាងច្បាស់លាស់ពីការលើកទឹកចិត្តឲ្យយុវជនរកការងារធ្វើ ភាពស្មើគ្នាចំពោះមុខច្បាប់ ការលើកកម្ពស់យេនឌ័រ គ្មានការរើសអើងនៅកន្លែងការងារ ការការពារចំពោះសិទ្ធិកុមារ សិទ្ធិស្ត្រី សិទ្ធិជនពិការ ការហាមឃាត់អំពើជួញដូរ និងពេស្យាកម្ម កិច្ចសន្យាការងារ ការទទួលបាននូវកិច្ចធានាការងារពីហានិភ័យផ្សេងៗ រួមទាំងចែងអំពីថិរវេលាធ្វើការ និងប្រាក់បន្ថែមម៉ោងការងារផងដែរ។

### ២.៤. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺជាការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដោយបន្តពង្រឹងនូវសមិទ្ធផលនានាដែលរាជរដ្ឋាភិបាលសម្រេចបានក្នុងរយៈពេលកន្លងមក ដើម្បីធ្វើឲ្យសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ កែលម្អនិងបង្កើនសមត្ថភាពរបស់កំណើនសេដ្ឋកិច្ចសាធារណៈ

លើកស្ទួយអភិបាលកិច្ច និងធ្វើទំនើបកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិ ក្នុងទិសដៅលើកកម្ពស់កំណើនសេដ្ឋកិច្ច បង្កើតការងារជូនប្រជាពលរដ្ឋ ធានាសមធម៌ក្នុងសង្គម និងបង្កើនប្រសិទ្ធភាពនៃវិស័យសាធារណៈ ព្រមទាំងការពារសម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌ជាតិដែលទាំងអស់នេះ សុទ្ធជាកត្តាគន្លឹះដ៏សំខាន់បំផុតសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ការងារនៅក្នុងវិស័យឯកជន គឺជាក្បាលម៉ាស៊ីនដ៏សំខាន់មួយនៅក្នុងការបង្កើតការងារឲ្យយុវជន ប្រទេសកម្ពុជាខ្វះនូវប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈដ៏រឹងមាំមួយដែលធ្វើការជិតស្និតជាមួយផ្នែកឯកជន ស្ថាប័នអប់រំនៅកម្ពុជាមានការរីកចម្រើន មានអ្នកដែលបានបញ្ចប់មហាវិទ្យាល័យមានការកើនឡើងច្រើន ប៉ុន្តែកម្មវិធីសិក្សាថ្នាក់មហាវិទ្យាល័យមិនមានផ្សារភ្ជាប់ជំនាញ ដែលជាតម្រូវការទីផ្សារក្នុងស្រុកត្រូវការនោះទេ។ ប្រទេសកម្ពុជាខ្វះនៅប្រព័ន្ធព័ត៌មានទីផ្សារការងារ ដែលមានតម្លាភាពដើម្បីជួយដល់អ្នកអប់រំបណ្តុះបណ្តាល និងអ្នកស្វែងរកទីផ្សារការងារដើម្បីដឹងអំពីកន្លែងដែលត្រូវការការងារ និងជំនាញគេដែលត្រូវ ។ ដើម្បីដោះស្រាយនូវបញ្ហាអស់ទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើគោលដៅរយៈពេលវែង ក្នុងការធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជន ការកាត់បន្ថយភាពក្រីក្រ និងការពន្លឿនកំណើនសេដ្ឋកិច្ច។ ការធានាថាឲ្យអ្នកដែលចូលបម្រើការងារថ្មីមានជំនាញសមស្របទៅនឹងតម្រូវការរបស់ការងារថ្មី ដោយរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ ទៅលើការផ្តល់សេវារកការងារធ្វើដល់អ្នកស្វែងរកការងារធ្វើនៅក្នុងវិស័យឯកជនទាំងក្នុង និងក្រៅប្រទេស តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជា ការដំឡើងប្រាក់ឈ្នួលអប្បបរមាដល់កម្មករនិយោជិត រំដោះកុមារដែលមិនទាន់គ្រប់អាយុពីការជិះជាន់កម្លាំងពលកម្ម ការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់ ធានាឲ្យបាននូវប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារ ផ្តល់ការធានារ៉ាប់រងគ្រោះថ្នាក់ការងារដល់បុគ្គលិក ពង្រឹងនូវស្ថានភាពវិស័យពត៌មានទីផ្សារការងារជាដើម។

## ២.៥. គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥

ជាការពិតណាស់ការដាក់ចេញនូវគោលនយោបាយដ៏ត្រឹមត្រូវមួយ គឺជាកត្តាសំខាន់មួយក្នុងការអភិវឌ្ឍន៍ប្រទេសឲ្យកើនឡើងជាលំដាប់ ព្រមទាំងកំពុងប្រែក្លាយខ្លួនពីប្រទេស ដែលមានស្ថានភាពអន់ថយខាងសេដ្ឋកិច្ច មានអត្រាភាពក្រីក្រខ្ពស់ ក្លាយជាប្រទេសដែលស្ថិតនៅក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍជួរមុខ ប្រកបដោយចីរភាព និងក្តីសង្ឃឹមខ្ពស់នៅក្នុងតំបន់និងពិភពលោក។ បច្ចុប្បន្ននេះសេដ្ឋកិច្ចប្រទេសកម្ពុជា បានឈានដល់ដំណាក់កាលនៃការអភិវឌ្ឍន៍ថ្មីមួយ គឺកំពុងក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងកំពុងស្ថិតក្នុងដំណើរផ្លាស់ប្តូររចនាសម្ព័ន្ធពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសពឹងផ្អែកលើវិស័យឧស្សាហកម្ម។ ព្រម

ជាមួយគ្នានេះដែរ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ ២០១៥-២០២៥ មានចក្ខុវិស័យលើកកម្ពស់ជីវភាព ភាពថ្លៃថ្នូររបស់ពលរដ្ឋគ្រប់រូប ភាពសុខដុមរមនាសង្គម តាមរយៈការបង្កើតការងារសមរម្យ និងមានផលិតភាពការងារខ្ពស់ ជូនពលរដ្ឋកម្ពុជាគ្រប់រូប ប្រកបដោយសមធម៌។ គោលនយោបាយនេះ ក៏បានរៀបចំឡើងឲ្យមានភាពស៊ីចង្វាក់គ្នា ទៅនឹងគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ផងដែរ ដោយផ្តោតជាសំខាន់លើសសរស្តម្ភបី គឺ (ទី១) ការបង្កើនឪកាសការងារសមរម្យនិងមានផលិតភាពការងារខ្ពស់ (ទី២) ការជំរុញការអភិវឌ្ឍជំនាញនិងធនធានមនុស្ស និង (ទី៣) ការព្រឹងអភិបាលកិច្ចទីផ្សារការងារ។ ទន្ទឹមនឹងនេះ ដើម្បីធានាប្រសិទ្ធភាព នៃការអនុវត្តគោលនយោបាយនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្រគល់ភារកិច្ចនេះជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើជាស្ថប័ន ទទួលខុសត្រូវដឹកនាំសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំផែនការសកម្មភាព សម្រាប់អនុវត្តគោលដៅដែលបានកំណត់។

## ២.៦. ច្បាប់ស្តីពីមុខរបរ និងការងារកម្ពុជា

ជាច្បាប់មួយដែលបានបង្កើតឡើងដើម្បីបន្ថែមការយល់ដឹងទៅដល់យុវជន ឲ្យដឹងកាន់តែច្បាស់អំពីច្បាប់ជាតិ និងច្បាប់អន្តរជាតិដែលទាក់ទងទៅនឹងការងារ ផ្នែកដ៏សំខាន់មួយនៃច្បាប់នេះបានបរិយាយអំពី ILO ដែលជាអង្គការដែលទទួលខុសត្រូវលើច្បាប់អន្តរជាតិផងដែរ។ ILO គឺជាអង្គការពិសេសមួយ នៃអង្គការសហប្រជាជាតិ ដែលតំណាងឲ្យរដ្ឋាភិបាល និយោជក និងកម្មករនិយោជិតទាំងឡាយ ។ សព្វថ្ងៃនេះមានសន្ធិសញ្ញា ILO ជាង១៨០ ដែលបង្កើតបានជាមូលដ្ឋានសម្រាប់ច្បាប់ការងារ។

## ២.៧. ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងដំណើរការដោះស្រាយវិវាទការងារនៅកម្ពុជា

ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺជា ផ្នែកមួយនៃប្រព័ន្ធដោះស្រាយវិវាទការងារប្រកបដោយមិត្តភាព ដែលត្រូវបាន បង្កើតឡើងដោយយោងតាមជំពូក១២ នៃច្បាប់ស្តីពីការងារ។ ច្បាប់នេះអនុញ្ញាតឲ្យសហជីព និងនិយោជក បញ្ចូលនីតិវិធី ដោះស្រាយវិវាទទៅក្នុងអនុសញ្ញារួមរបស់ពួកគេមួយវិញទៀតនៅពេលបច្ចុប្បន្ននេះ អនុសញ្ញារួមស្ទើរតែទាំងអស់មិនទាន់បានបញ្ចូលនីតិវិធីនេះនៅឡើយ ដូច្នេះ ច្បាប់ការងារក៏បានចែងអំពីនីតិវិធីនេះ ដើម្បីដោះស្រាយវិវាទការងារសម្រាប់ពេលបច្ចុប្បន្ន។ ដំណើរការមួយចំនួនក្នុងការដោះស្រាយវិវាទ ផ្អែកលើគោលការណ៍ស្ម័គ្រចិត្តពីភាគីវិវាទ ហើយដំណើរការមួយចំនួនទៀត ដូចជាការដោះស្រាយតាមនីតិវិធីអាជ្ញាកណ្តាល មានលក្ខណៈបង្ខំចំពោះភាគីវិវាទ។

# ជំពូកទី៣ បញ្ហាប្រឈម និងដំណោះស្រាយបញ្ហាយុវជននៅកម្ពុជា

## ៣.១.បញ្ហាប្រឈម

### ៣.១.១បញ្ហាប្រឈមក្នុងការអភិវឌ្ឍលក្ខខណ្ឌការងារ

### ក.បញ្ហាប្រឈមការលើកកម្ពស់លក្ខខណ្ឌការងារឲ្យកាន់តែប្រសើរឡើង

- យន្តការតាមដាន និងវាយតម្លៃពុំទាន់ច្បាស់លាស់ ដោយក្រុមនីមួយៗចុះធ្វើការងារ និងប្រមូលទិន្នន័យ ដដែលនៅតាមសហគ្រាស គ្រឹះស្ថាន ដោយពុំបានយកទិន្នន័យរបស់ក្រុមចាស់មកធ្វើការពិនិត្យឡើងវិញ ដើម្បីធ្វើការត្រួតពិនិត្យបន្ត។
- ឃ្លាគម្រូសម្រាប់ដាក់កំហិត និងផាកពិន័យនៅមានភាពខ្វះចន្លោះ និងមិនទាន់មានបទបញ្ជាការងារ និងរបៀបរបបធ្វើការស្តីពីអធិការកិច្ចការងារ
- របាយការណ៍សម្រាប់អ្វើអធិការកិច្ចការងារមានភាពស្មុគស្មាញ និងចំណាយពេលច្រើនក្នុងការសរសេរ
- ខ្វះមធ្យោបាយធ្វើដំណើរ និងប្រាក់ឧបត្ថម្ភដល់ក្រុមអធិការកិច្ចការងារ
- ស្ថិតិសហគ្រាស គ្រឹះស្ថានមានភាពមិនច្បាស់លាស់នៅឡើយ
- ខ្វះថវិកា និងគ្រូឧទ្ទេសសម្រាប់បណ្តុះបណ្តាលអំពីច្បាប់ស្តីពីការងារ វិធីសាស្ត្រក្នុងការចុះធ្វើអធិការកិច្ចការងារ និងជំនាញទន់ ជាពិសេសនៅតាមបណ្តាខេត្ត
- ឆន្ទះ និងការប្តេជ្ញាចិត្ត ក្នុងការបំពេញការងាររបស់មន្ត្រីនៅមានកម្រិត
- បញ្ហាប្រឈមលើការពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ
- កង្វះមធ្យោបាយធ្វើដំណើរ និងថវិកាសម្រាប់ឧបត្ថម្ភ មន្ត្រីផ្សះផ្សាវិវាទក្នុងការបំពេញភារកិច្ច
- កង្វះខាតបន្ទប់ធ្វការ បន្ទប់ផ្សះផ្សារវិវាទការងារ និងបន្ទប់តម្កល់ឯកសារ
- យន្តការនៃការទប់ស្កាត់បញ្ហាកូដកម្ម និងការដោះស្រាយ វិវាទការងារឲ្យមានប្រសិទ្ធភាព ដើម្បីធានាបានសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ នៅកន្លែងអ្វើការនៅមានកម្រិត

### ខ.បញ្ហាប្រឈមលើការពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈមានដូចខាងក្រោម

- ការអនុវត្តបទបញ្ជានៅមានកម្រិត
- ការអនុវត្តច្បាប់ចំពោះជនល្មើសនិងជនដៃដល់ក្នុងសកម្មភាពកូដកម្មមិនទាន់បានគ្រប់ជ្រុងជ្រោយ

- ការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការផ្តល់.ឯកសារនិងភស្តុតាងនៅមានកម្រិត
- ការអនុវត្តច្បាប់ចំពោះជនល្មើស និងជនដែលដល់ក្នុសកម្មភាពកូដកម្ម បាតុកម្ម មិនទាន់បាន គ្រប់ជ្រុងជ្រោយ
- បញ្ហាប្រឈមលើការសិក្សាស្រាវជ្រាវ ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍របស់កម្មករ និយោជិត
- ការធ្វើអង្កេត ស្តីពីស្ថានភាពជីវភាពរបស់កម្មករនិយោជិតជួបប្រទះទាំងបញ្ហារដ្ឋបាល និង បច្ចេកទេស
- តម្រូវការឧត្តមមានភាពនៃលទ្ធផលអង្កេតទាមទារឲ្យមានគម្រូសំណាកធំ ដែលជាហេតុធ្វើ ឲ្យខ្វះខាតនូវលទ្ធភាពដើម្បីធ្វើអង្កេតឲ្យបានគ្រប់ជ្រុងជ្រោយ។

## គ.គោលចក្រសហគ្រាសដែលត្រូវចុះធ្វើអង្កេតមិនសូវសហការជាមួយក្រុមការងារ

- កង្វះខាតក្រុមការងារផ្នែកសេដ្ឋកិច្ច
- រយៈពេលធ្វើការអង្កេតមានរយៈពេលខ្លីពេក
- ការសិក្សាអំពីប្រាក់ឈ្នួលអប្បបរមា ទាមទារឲ្យមានការវិភាគបែបសេដ្ឋកិច្ចស្មុគស្មាញ ប៉ុន្តែ បច្ចុប្បន្នលេខធិការដ្ឋានគណៈកម្មការក្រុមប្រឹក្សាការងារ ខ្វះខាតនូវមន្ត្រីបច្ចេកទេសផ្នែក វិភាគសេដ្ឋកិច្ច
- តំណាងសហជីពមួយចំនួននៅមិនទាន់ឯកភាពគ្នាអំពីនិយមន័យពាក្យ "ប្រាក់ឈ្នួល អប្បបរមា"និង"ប្រាក់ឈ្នួលសមរម្យ"វិធីសាស្ត្រគណនាបម្រែបម្រួលនៃលក្ខណៈវិនិច្ឆ័យទាំង៧ អត្ថប្រយោជន៍ផ្សេងៗក្រៅ ពីប្រាក់ឈ្នួលអប្បបរមា និងបានបង្វែរការចរចាប្រាក់ឈ្នួល អប្បបរមាទៅជាការចរចាប្រាក់ឈ្នួលរស់នៅ។
- កម្មករនិយោជិត និងសាធារណៈជនមួយចំនួន នៅមិនទាន់បានយល់ដឹងច្បាស់ពីនិយម ន័យ យន្តការ និងលក្ខខណ្ឌវិនិច្ឆ័យ នៃការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា។
- មន្ត្រីជំនាញពាក់ព័ន្ធនឹងការលើកកម្ពស់លក្ខខណ្ឌការងារ មិនសូវយកចិត្តទុកដាក់ក្នុងការ សហការអនុវត្តគម្រោង ប្រឹក្សាយោបល់លើគោលនយោបាយដើម្បីពង្រឹងលក្ខខណ្ឌការងារ នៅកម្ពុជា ។

## ឃ.បញ្ហាប្រឈមលើការពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារ

- ការចងក្រងប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារនៅតាមសហគ្រាស គ្រឹះស្ថាននៅមានកម្រិត
- កង្វះខាតលិខិតបទដ្ឋានស្តីពីការងារ និងសុវត្ថិភាពការងារ មិនទាន់មានក្រុមការងារច្បាស់លាស់សម្រាប់ស្រាវជ្រាវ និងកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងសុខភាព និងសុវត្ថិភាពការងារនៅក្នុងអង្គភាព
- សមត្ថភាពមន្ត្រីអធិការពេទ្យការងារ និងការចុះអធិការកិច្ចការងារក្នុងវិស័យអង់រំ វិស័យរ៉ែ សំណង់ ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត និងសហគ្រាសខ្នាតតូចនៅមានកម្រិត
- សហគ្រាស និងគ្រឹះស្ថានមួយចំនួននៅតែមិនទាន់គោរព និអនុវត្តបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុត្តស្តីពីសុខភាព និងសុវត្ថិភាពការងារ
- សម្ភារៈបរិក្ខារវេជ្ជសាស្ត្រ ចំនួនវេជ្ជបណ្ឌិត គ្រូពេទ្យ និងអ្នកជំនាញមន្ទីរពិសោធន៍មិនទាន់ឆ្លើយតបនឹងទំហំការងារនិងមិនទាន់មានមន្ទីរពិសោធន៍ និងគ្រូពេទ្យឯកទេសវិជ្ជាជីវៈ
- ចំណេះដឹងនិយោជក និងកម្មករនិយោជិត ស្តីពីសុខភាព និងសុវត្ថិភាពការងារ និងការអនុវត្តសកម្មភាពការងារតាមបណ្តាគ្រឹះស្ថាន និងសហគ្រាសនៅមានកម្រិត
- បញ្ហាប្រឈមលើការពង្រឹង និងពង្រីកសេរីភាពសហជីព និងអង្គការវិជ្ជាជីវៈ កង្វះខាតការផ្សព្វផ្សាយអំពីច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យការងារ បទប្បញ្ញត្តិពាក់ព័ន្ធក្នុងការ ស្នើសុំចុះបញ្ជិការអង្គការវិជ្ជាជីវៈ នីតិវិធីនៃការចរចា ការចងក្រង និងការអនុវត្តអនុសញ្ញារួម។

## ង.បញ្ហាប្រឈមការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

- ការជំរុញការកសាង និងអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ
- កង្វះខាតគោលនយោបាយសំខាន់ៗ ទាក់ទនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ
- ការអនុវត្តក្របខណ្ឌគុណវឌ្ឍិជាតិកម្ពុជា នៅមិនទាន់បានទូលំទូលាយ
- ការរៀបចំស្តង់ដាសមត្ថភាពតាមវិស័យអាទិភាព មិនទាន់បានគ្រប់គ្រាន់ទៅតាមតម្រូវការទីផ្សារការងារ
- ពុំទាន់មានមជ្ឈមណ្ឌលធ្វើតេស្ត និងទទួលស្គាល់ជំនាញកម្មវិធីសិក្សា អប់រំ មិនទាន់ឆ្លើយតបនឹងតម្រូវការទីផ្សារការងារនៅឡើយការចូលរួមរបស់វិស័យឯកជន ក្នុងប្រព័ន្ធអប់រំនៅមានកម្រិតលក្ខខណ្ឌវិនិច្ឆ័យ និងការវាយតម្លៃទទួលស្គាល់គុណភាពគ្រឹះស្ថានអប់រំ មិនទាន់

បានអនុវត្តពេញលេញនៅឡើយ ការចូលរួមប្រកួតប្រជែងជំនាញថ្នាក់ជាតិ អាស៊ាន និងអន្តរជាតិនៅមានកម្រិត

- បញ្ហាប្រឈមលើការពង្រឹងយន្តការជុំរុញការចុះឈ្មោះចូលរៀនរបស់សិក្ខាកាម សិស្ស-និស្សិត ក្នុងផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- បញ្ហាប្រឈមលើយន្តការការគ្រប់គ្រងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

**ច.បញ្ហាប្រឈមក្នុងការអភិវឌ្ឍមុខរបរ និងការងារ**

- ប្រឈមនឹងការជំរុញការកសាង និងការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ
- បញ្ហាប្រឈមលើយន្តការគ្រប់គ្រងការងារ។

### ៣.១.២.កត្តាប្រវត្តិសាស្ត្រ

កម្ពុជា ជាប្រទេសមួយបានធ្លាក់នៅក្នុងសង្គ្រាមស៊ីវិលអូសបន្លាយជាង៣សតវត្ស មុននឹងទទួលបានសន្តិភាពក្នុងសតវត្សទី៩០។ បញ្ហាដែលចោទឡើង ក្រោយការដួលរលំរបប ប៉ុល ពត មានច្រើនឥតគណនា ដូចជា ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច និងវប្បធម៌ត្រូវបានបំផ្លាញ។ សង្គ្រាមបានសម្លាប់អ្នកចេះដឹងខ្មែរ ស្ទើរដល់ចំណុចសូន្យ ចំណែកអ្នកដែលនៅសេសសល់ បានមុឺម្នាខំប្រឹងកសាងប្រទេសចាប់ពីបាតដៃទទេ។ ការស្តាបនាប្រទេសដែលស្ទើរតែខ្ទេចខ្ទាំទាំងស្រុងនេះ មិនមែនចំណាយពេលខ្លីធ្វើបាននោះទេ វាទាមទាររយៈពេលវែងក្នុងការសម្រេចបាននូវគោលដៅនេះ។ ជាពិសេស ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និស្សិតបញ្ញាវន្ត និងអ្នកមានចំណេះដឹងជាច្រើនត្រូវបានសម្លាប់ សូម្បីតែនិស្សិតបញ្ញាវន្តនៅក្រៅប្រទេសក៏ត្រូវបានរដ្ឋាភិបាល ប៉ុល ពតអំពាវនាវឲ្យចូលមកក្នុងប្រទេស និងសម្លាប់ចោលដែរ។ ក្រោយពីរបបនេះដួលរលំ ការបាត់បង់ធនធានមនុស្សដែលមានជំនាញពិតប្រាកដ គឺពិតជាមានទំហំធំដែលពិបាកវាស់វែង។ ប្រទេសកម្ពុជា ត្រូវចាប់ផ្តើមចេញពីចំណុចមួយដ៏ពិបាក គឺការបណ្តុះបណ្តាលធនធានមនុស្ស។

### ៣.២.២អំពើពុករលួយ

អំពើពុករលួយ ជាជំងឺមហារីករបស់សង្គម[7]។ ជំងឺនេះធ្វើឲ្យបាត់បង់នូវថវិការរដ្ឋដែលជាកត្តាសំខាន់ខាងផ្នែកហិរញ្ញវត្ថុសម្រាប់ស្តារ និងកសាងប្រទេសកម្ពុជា ឲ្យមានការរីកចម្រើនទៅមុខ ក្នុងការលើកកម្ពស់ជីវភាពរបស់ប្រជាជន។ បញ្ហាពុករលួយនេះ ជាបញ្ហាសកលលោកទោះជាប្រទេស

[7] ការវិភាគលើបញ្ហាត្រូវដោះស្រាយនៅកម្ពុជា ដោយលោក កែវ នរិន្ទ សាស្ត្រាចារ្យបណ្ឌិតសេដ្ឋកិច្ច បោះពុម្ពផ្សាយ ខែមករា ឆ្នាំ១៩៩៩ អត្ថបទ អំពើពុករលួយ ទំព័រទី៦

នោះ ជាប្រទេសរីកចម្រើន ឬក៏ជាប្រទេសក្រីក្រក៏ដោយ។ បញ្ហាអំពើពុករលួយកើតឡើងស្ទើរគ្រប់ប្រទេស តាមសណ្ឋានតូច និងធំ។ សង្គមមួយ ឬប្រទេសណាមួយ ដែលកើតមាននូវអំពើពុករលួយ រមែងជួបនឹងមានភាពជា «អវិជ្ជមាន» ច្រើន។ រីឯប្រជាពលរដ្ឋនៃសង្គមនោះ ក៏នឹងត្រូវទទួលរងនូវផលប៉ះពាល់ផងដែរទោះតិចឬច្រើនក្តី ក្នុងកាលៈទេសៈណាមួយ ដែលនឹងប្រឈមមុខលើបញ្ហានៃអំពើពុករលួយនេះ។

**ក.អំពើពុករលួយជាអ្វី?**

អំពើពុករលួយ គឺជា ការសូកប៉ាន់ដល់មន្ត្រីរាជការ ដើម្បីអូសទាញយកផលប្រយោជន៍ផ្ទាល់ខ្លួនដោយខុសច្បាប់។ ដូចនេះមានន័យថា សកម្មភាពនៃការប្រព្រឹត្តអំពើពុករលួយ គឺមានអ្នកសូក និងអ្នកទទួលសំណូក។ ជារួមអ្នកសូកភាគច្រើន ជាឯកជន ឬក្រុមហ៊ុនឯកជន ហើយអ្នកទទួលសំណូកជាមន្ត្រីរាជការនៅក្នុងស្ថាប័នរដ្ឋ ពីថ្នាក់ទាបដល់ថ្នាក់កំពូល។ អំពើពុករលួយ មានប្រភពមកពី ការខ្វះខាតក្នុងជីវភាពរស់នៅ និងបណ្តាលមកពី ការលោភលន់របស់បុគ្គល។ រូបភាពនៃអំពើពុករលួយ នៃបណ្តាប្រទេសនានានៅលើពិភពលោក មានភាពខុសៗគ្នា ដែលជាហេតុធ្វើឱ្យមានការកំណត់ន័យនៃអំពើពុករលួយ សមស្របដោយអាស្រ័យទៅលើ«ហេតុផល»។ តាមទស្សនៈអង្គការតម្លាភាពអន្តរជាតិ «អំពើពុករលួយ ជាការរំលោភបំពានអំណាច ដែលទទួលបានពីពលរដ្ឋដើម្បីផលប្រយោជឯកជន»។ បើតាមទស្សនៈធនាគាពិភពលោក«អំពើពុករលួយ ជាការប្រើប្រាស់មុខ ដំណែងសាធារណៈដើម្បីផលប្រយោជផ្ទាល់ខ្លួន»។ និយមន័យជាទូទៅនៃអំពើពុករលួយ អាចចាត់ទុកថា «មានអំពើពុករលួយ កាលណាធ្វើអ្វីមួយទទួលផលមកវិញមិនសមស្រប ទៅនឹងអំពើដែលបានខ្លួនបានធ្វើ»។

**ខ.ប្រភេទនៃអំពើពុករលួយ**

ដែលអាចចាត់ទុកថាជាអំពើពុករលួយមានប្រាំចំណុចសំខាន់ៗ ដូចជាការស៊ីសំណូក ការគំរាមកំហែងដោយប្រើអំណាច ការកេងបន្លំ ការប្រកាន់នគ្គពួក និងការឧបត្ថម្ភក្រៅផ្លូវការ ដើម្បីទទួលបានការគាំទ្រអ្វីមួយ។ អំពើពុករលួយជាការកត់សម្គាល់មានបីសណ្ឋាន គឺ ពុករលួយ«ដើម្បីរស់» ពុករលួយ«ដើម្បីជាអ្នកមាន» និងពុករលួយ«ដើម្បីសន្សំសុខ»។

**គ.មូលហេតុកើតមានអំពើពុករលួយ**

មានមូលហេតុជាច្រើន ដែលបង្កឱ្យមានអំពើពុករលួយ ប៉ុន្តែអ្វីដែលសំខាន់ និងដែលតែងតែជួបប្រទះនោះរួមមានដូចជា អាត្មានិយម និងការកិតខ្លី ដោយមិនបានពិចារណាបានគ្រប់ជ្រុងជ្រោយ។ អំពើពុករលួយច្រើនស្តែងឡើងមានតាមរយៈ សម្ភារៈនិយម (ការឲ្យតម្លៃទៅលើសម្ភារៈ

ជ្រុល) ការលោភលន់។ ការអប់រំខុស និងយល់ឃើញខុស ខ្វះការយល់ដឹង អំពីផលប៉ះពាល់នៃអំពើពុករលួយ។ មានមនុស្សតិចដែលស្អប់អំពើពុករលួយ ឬមនុស្សភាគច្រើនសុខចិត្តអត់ធ្មត់នឹងអំពើពុករលួយ។ ខ្វះការស្រលាញ់កិត្តិយស និងភាពថ្លៃថ្នូរជាមនុស្ស និងការមិនឲ្យតម្លៃលើសុចរិតភាព។ បណ្តាលមកពី ការកើតមាននូវមហិច្ឆិតាដ៏លើសលប់ ការមិនគោរពច្បាប់ជាដើម។

### ឃ. ផលប៉ះពាល់នៃអំពើពុករលួយ

ផលប៉ះនៃអំពើពុករលួយបានជះឥទ្ធិពលជាអវិជ្ជមានលើវិស័យនានាជាច្រើន នៅក្នុងសង្គមនៃការអនុវត្ត ការងារប្រចាំថ្ងៃរួមមានដូចជាៈ វិស័យអប់រំ គុណភាពនៃការអប់រំមានកំរិតទាប មានការសូកប៉ាន់ និងលួចចំលងយ៉ាងអាណាធិបតេយ្យ។ វិស័យការងារ ដែលបានបង្កើតជាបក្សពួកនិយម ខ្សែរយៈឬបណ្តាញ ហើយផ្តល់ឱកាសការងារមិនស្មើភាពគ្នារវាងអ្នកមាន និងអ្នកក្រ។ វិស័យសុខាភិបាល ក៏បានធ្វើឲ្យគុណភាពនៃសេវាសុខភាពមានកំតិតទាប ឯប្រជាពលរដ្ឋត្រូវបង់ប្រាក់ក្រៅផ្លូវការ...។ វិស័យបរិស្ថាន មានអនុញ្ញាតិឲ្យកាប់ព្រៃឈើ សត្វព្រៃ និងធនធានធម្មជាតិ និងបញ្ហាបរិស្ថាននានាត្រូវបានធ្លាក់ចុះ។ វិស័យយុត្តិធម៌ តុលាការ ចៅក្រម និងព្រះរាជអាជ្ញាកាត់សេចក្តីដោយលំអៀង ដែលជាមូលហេតុធ្វើឲ្យប្រព័ន្ធយុត្តិធម៌ចុះអន់ខ្សោយ។ វិស័យសន្តិសុខ ក៏បានបង្កើតឲ្យមានឧក្រិដ្ឋកម្ម និងអសន្តិសុខសង្គម។ អំពើពុករលួយនៃហេដ្ឋារចនាសម្ព័ន ដែលបណ្តាលឲ្យគុណភាពនៃសំណង់ អាគារ ស្ពាន ផ្លូវ ថ្នល់ មានកំរិតទាប បាក់បែក និងឆាប់ខូចនិងអាចប៉ះពាល់ដល់ជីវិត និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាដើម។ វិស័យសេដកិច្ច ធ្វើឲ្យការប្រើប្រាស់ប្រាក់ចំណូលជាតិ ដោយមិនសមស្រប។ អ្នកក្រមិនទទួលបានផលចំណេញពីការរីកចំរើនសេដ្ឋកិច្ចបានសមរម្យ។ វិស័យសេវាសាធារណៈ រាល់ការប្រើប្រាស់ធនធាន និងការផ្តល់សេវាសាធារណៈមិនសូវមានប្រសិទ្ធិភាព ឯប្រជាពលរដ្ឋក្រីក្រមិនមានលទ្ធភាពស្មើគ្នា ក្នុងការទទួលបានសេវាទាំងនេះ។ ក្នុងរបាយការណ៍វាស់វែងអំពីអំពើពុករលួយជាសកល (GCB) ប្រចាំឆ្នាំ២០១៣ ដែលរៀបចំឡើងដោយអង្គការតម្លាភាពកម្ពុជា[8] (Transparency international) ក្នុងសន្និសីទសារព័ត៌មាន នៅសណ្ឋាគារឡឺរ៉ូយ៉ាល់នាព្រឹកថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៣ បានបង្ហាញថានៅកម្ពុជាមានស្ថាប័នបួនធំៗ ដែលបានប្រព្រឹត្តិអំពើពុករលួយខ្លាំងជាងគេ ក្នុងនោះរួមមាន ស្ថាប័នតុលាការ, ស្ថាប័ននគរបាល, ស្ថាប័នសាធារណៈ និងគណបក្សនយោបាយ។ ដូច្នេះអំពើពុករលួយ ជាមេរោគសកលដែលបំផ្លាញប្រព័ន្ធ«សុចរិតភាពសង្គម» និងជាហេតុធ្វើឲ្យ«ជម្ងឺសង្គម»ដទៃទៀត បំផ្លាញនូវការអភិវឌ្ឍន៍ជាតិ។ មួយវិញទៀត បច្ច័យអាក្រក់របស់អំពើពុករលួយទៅលើសង្គមនោះគឺអំពើពុករលួយ

[8] បទសម្ភាសន៍ជាមួយលោក **ព្រាប កុល** ប្រធានអង្គការតម្លាភាពកម្ពុជា ហៅកាត់ថា (TI)

ជំរុញឲ្យអ្នកមានលុយ មានអំណាចរំលោភលើច្បាប់រដ្ឋ ដោយបង្កើតនូវប្រព័ន្ធបម្រើវប្បធម៌ខ្មៅកខ្វក់ ដូចជា បនល្បែងពាលាអារ៉ាសែបនស្រីពេស្យា បនលក់គ្រឿងញៀន ដែលជាសកម្មភាពបំផ្លាញអារ្យធម៌ជាតិ និងវប្បធម៌ខ្មែរ។ ភាពងាយស្រួលក្នុងការរកចំណូល ដោយអំពើពុករលួយនេះធ្វើឲ្យខូចខាតប្រព័ន្ធអប់រំ ដោយយុវនិស្សិតខ្មែរយល់ថា ចាំបាច់រៀនធ្វើអ្វី ធ្វើការធ្វើអ្វី បើពួកអ្នកកេងប្រវ័ញ្ចរកតែមួយថ្ងៃ ប្រហែលអ្នកធ្វើការធម្មតារយៈពេលមួយជីវិត អយុត្តិធម៌សង្គម ដែលមានមូលហេតុមកពីអំពើពុករលួយនេះហើយ ដែលនាំឲ្យមានវិបត្តិសង្គម ហើយក៏មិនអាចឲ្យសង្គមជាតិយើងមានការលូតលាស់ទៅមុខដែរ។

**៣.១..៣កត្តាអប់រំ**

វិស័យអប់រំធនធានមនុស្សបានចាប់ផ្តើមរីកចម្រើន ចាប់តាំងពីសតវត្សទិ៦០មកម្ល៉េះ វាជាឆ្នាំដែលបានចាប់ផ្តើម កកើតដំបូងនូវសាកលវិទ្យាល័យ។ ធនធានមនុស្សជាច្រើន ត្រូវបានយកទៅបណ្តុះបណ្តាល ដែលប្រកបដោយជំនាញ ក្នុងការបំពេញការងារ។ ធនធានមនុស្សនាសម័យនោះត្រូវបានមើលឃើញថាពិតជាមានសន្ទុះខ្លាំងក្នុងចំណោមប្រទេសនៅអាស៊ីមួយចំនួន។ ប៉ុន្តែដោយសារ បញ្ហាភាពក្រីក្រ សង្គ្រាមស៊ីវិល ដែលបានអូសបន្លាយរហូតដល់ឆ្នាំ១៩៩៨ ក្រោយពីកម្ពុជាបានសន្តិភាពពេញលេញ កម្ពុជាត្រូវដោះស្រាយបញ្ហាជាច្រើន ដូចជាបញ្ហាមីន ជនពិការដោយសារសង្គ្រាម វិបត្តិដីធ្លី កង្វះសាលារៀនចំណេះដឹងទូទៅ និងជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈ កង្វះគ្រូបង្រៀន បញ្ហាអនក្ខរកម្ម ខ្វះជំនួយ និងបញ្ហាប្រាក់បៀវត្ស។ បញ្ហាទាំងអស់នេះហើយដែលធ្វើឲ្យវិស័យអប់រំនៅកម្ពុជានៅមានកម្រិត បញ្ហាទាំងនេះបានជះឥទ្ធិពលយ៉ាងខ្លាំង ដល់ការអភិវឌ្ឍវិស័យធនធានយុវជន ក៏ដូចជា ការកំណែទម្រង់វិស័យអប់រំ។ ប្រជាជនដែលរស់នៅតំបន់ដាច់ស្រយាល ខ្វះសាលារៀន ហើយគុណភាពនៃការអប់រំ ក៏មិនទាន់អាចទទួលបានការទទួលស្គាល់។ នៅពេលដែលមានការប្រឡងប្រជែង ប្រសិនបើយុជនទាំងនោះប្រឡងធ្លាក់ ពួកគេអាចបោះបង់ការសិក្សា ទៅធ្វើការដោយប្រើកម្លាំង ដើម្បីស្វែងរកចំណូលសម្រាប់គ្រួសារ យុវជនខ្លះបានសម្រេចបញ្ចប់ ការសិក្សារបស់ខ្លួនត្រឹមថ្នាក់ទី៩ ឬទី១២ ហើយទៅធ្វើការងាររោងចក្រកាត់ដេរ ដោយមិនបានចាប់យកជំនាញបច្ចេកទេស ឬបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោយពីការបោះបង់ការសិក្សា។ យុវជនជារៀងរាល់ឆ្នាំ ដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ និងថ្នាក់ទី១២ មានបរិមាណច្រើន ប៉ុន្តែគុណភាពនៅមានកម្រិត ម្យ៉ាងទៀត ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងជំនាញបច្ចេកទេសនៅមិនមានភាពរីកចម្រើន។ យុវជនដែលរស់នៅទីជនបទ ទទួលបានការបណ្តុះបណ្តាលតិចតួចលើភាសាបរទេស ចំពោះគ្រួសារដែលមានស្ថានភាពក្រីក្រ ពួកគេប្រឈមនឹងការបោះបង់ការសិក្សានៅថ្នាក់

ឧត្តមសិក្សា។ ទោះបីរាជរដ្ឋាភិបាល ក្រសួង មន្ទីរពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលជាច្រើនបាននិងកំពុងយកចិត្តទុកដាក់ជួយអភិវឌ្ឍកែលម្អជាច្រើនយ៉ាងណាក៏ដោយ ក៏បញ្ហាប្រឈមមួយចំនួនធំនៅតែជាបញ្ហាចោទនៅឡើយ ។ ជាការពិត វាមានផ្លាស់ប្ដូរអភិវឌ្ឍច្រើនណាស់មកដល់បច្ចុប្បន្ននេះ ដែលគួរឱ្យមានមោទនភាពបំផុត ចំពោះកិច្ចប្រឹងប្រែងយកអស់កម្លាំងកាយចិត្តទាំងនេះ ។ ទោះបីជាយ៉ាងណាក៏ដោយបញ្ហាប្រឈមមួយចំនួនធំ នៅតែចាំខ្ទាស់ជើងដំណើរការអភិវឌ្ឍវិស័យអប់រំផងដែរ ដូចជា៖ (១)ភាពបាត់បង់ព្រលឹងក្នុងការសិក្សារបស់សិស្សានុសិស្សខ្មែរមួយចំនួនធំ (២)ឥរិយាបថអវិជ្ជមានរបស់គ្រូបង្រៀនមួយចំនួន (៣)ឥរិយាបថអវិជ្ជមានឪពុកម្ដាយ អាណាព្យាបាលនាពេលបច្ចុប្បន្ន (៤)ឥទ្ធិពលវប្បធម៌ពាលាអាវ៉ាសែបរទេសនិងកង្វះការយកចិត្តទុករបស់សង្គម។

**ក-ការបាត់បង់ព្រលឹងក្នុងការសិក្សារបស់សិស្សានុសិស្សខ្មែរ**

ការសិក្សារបស់សិស្សានុសិស្សមួយចំនួនធំនាពេលបច្ចុប្បន្ន មិនបានពឹងផ្អែកលើសមត្ថភាពខ្លួនឯងទៀតទេ ដោយសារឥទ្ធិពលដ៏លើសលប់របស់លុយ និងអំពើពុករលួយស៊ីសំណូកសូកប៉ាន់សិស្សានុសិស្សមួយចំនួនទៀត ងាកទៅពឹងផ្អែកលើកម្លាំងក្រៅខ្លួនដើម្បីសម្រេចបានភាពជោគជ័យក្នុងការសិក្សាដូចជា៖ ចម្លងតាមព្រុយយ៉ុង ការសូកប៉ាន់ពេលប្រឡង បង់លុយដើម្បីទទួលបានពិន្ទុ និងដើម្បីឱ្យគ្រូលុបអវត្តមានជាដើម។ ចំណែកឯសិស្សមួយចំនួនទៀតបែរជាទៅបន់ស្រន់ដើម្បីឱ្យប្រឡងជាប់ទៅវិញ ។ ទាំងអស់នេះ បង្ហាញថា សិស្សលែងឱ្យតម្លៃលើចំណេះដឹងដែលនៅជាប់នឹងខ្លួនរបស់គេទៀតហើយ ដែលនេះបញ្ជាក់ថា មនុស្សខ្មែរជំនាន់ក្រោយកំពុងតែបាត់បង់ព្រលឹងរបស់ខ្លួន និងភាពជឿជាក់លើខ្លួនឯងហើយសកម្មភាពនេះកំពុងតែកើនឡើងយ៉ាងផុលផុសនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។ ស្ថានភាពទាំងនេះ តើធនធានមនុស្សខ្មែរទៅជាយ៉ាងណានាពេលអនាគត? វាពិតគួរឱ្យបារម្ភណាស់! មួយវិញទៀត ទំនុកចិត្តលើការសិក្សានៅក្នុងសង្គមខ្មែរកាន់តែខ្សោយទៅៗ ពិសេសសិស្សានុសិស្ស និងឪពុកម្ដាយ អាណាព្យាបាលនៅតាមជនបទដោយសារភាពអយុត្តិធម៌សង្គម និងដោយសារគំនិតបក្សនិយម គ្រួសារនិយម ខ្សែរនិយម និងអំពើពុករលួយ ដែលស្ថានភាពនេះធ្វើឱ្យសង្គមខ្មែរផុយស្រួយបំផុត។ សិស្សានុសិស្សនៅតាមជនបទភាគច្រើន មិនមានសេចក្ដីសង្ឃឹម និងមានជំនឿចិត្តលើការសិក្សាទេ ព្រោះកង្វះគោលនយោបាយជាក់លាក់ក្នុងការជួយ និងលើកទឹកចិត្ត ដល់ពួកគាត់ ។ ពួកគាត់ភាគច្រើនមើលមិនឃើញពីអនាគត តាមរយៈការសិក្សាទេ ព្រោះឥទ្ធិពលដ៏លើសលប់នៃអំពើអសកម្មទាំងអម្បាលម៉ានខាងលើនៅក្នុងសង្គម។

### ខ-ឥរិយាបថអវិជ្ជមានរបស់គ្រូបង្រៀន

តាមរយៈការអង្កេត សម្ភាសមិនផ្លូវការជាមួយសិស្សនៅថ្នាក់មធ្យមសិក្សាមួយចំនួនកន្លងមក បង្ហាញថាលោកគ្រូ-អ្នកគ្រូមួយចំនួននៅសម័យបច្ចុប្បន្ន មានឥរិយាបថអវិជ្ជមានច្រើនទាក់ទងនឹងសកម្មភាពអប់រំ ដែលជាសញ្ញាណបញ្ជាក់ពី សភាពគួរឱ្យព្រួយបារម្ភបំផុតសម្រាប់អនាគត។ ដោយហេតុផលគ្រូបង្រៀនមានប្រាក់បៀវត្សទាប លោកគ្រូ-អ្នកគ្រូ មួយចំនួនបានចាប់សិស្សជាចំណាប់ខ្មាំង ដើម្បីប្រាក់ តាមរយៈការបង្កើតការបង្រៀនគួរក្រៅម៉ោង និងការគៀបសិស្សតាមមធ្យោបាយផ្សេងៗ។ ការបង្រៀនគួរក្រៅម៉ោងមិនបាន ផ្តល់ភាពចំណេញដល់សិស្សទេ ព្រោះវាបានបន្ថែមម៉ោងសិក្សាដល់សិស្ស លើសកំណត់ និងមិនមានពេលវេលាគ្រប់គ្រាន់ សម្រាប់សិស្សក្នុងការសិក្សាស្រាវជ្រាវ រៀនសូត្រខ្លួនឯង ពិសេសគឺប៉ះពាល់ដល់សុខភាពសិក្សារបស់សិស្ស។ តាមរយៈការបង្រៀនគួក្រៅម៉ោង វាអាចឱ្យគ្រូបង្រៀនបែកបាក់ផ្ទៃ ក្នុងព្រោះទំនាស់ផលប្រយោជន៍ និងភាពច្រណែនគ្នា ពិសេសមិនមានមនសិការ ការងាររឹងមាំនៅក្នុងម៉ោងសិក្សារដ្ឋ ឬបង្រៀនសិស្សមិនច្បាស់លាស់ ដោយលាក់ទុកល្បិចសម្រាប់ការបង្រៀនក្រៅម៉ោង ។ ជាទូទៅយើងសង្កេត គ្រូយកចិត្តទុកដាក់បង្រៀនសិស្សខ្លាំងថ្នាក់គួរក្រៅម៉ោង ជាជាងបង្រៀននៅក្នុងម៉ោងរដ្ឋ ។ មួយវិញទៀត ការបង្រៀនគួនេះ វាអាចធ្វើឱ្យមានភាពអយុត្តិធម៌ក្នុងការដាក់ពិន្ទុ ដល់ការសិក្សារបស់សិស្ស។ ពិតណាស់ លោកគ្រូ-អ្នកគ្រូមួយចំនួនធំ នឹងមានភាពលម្អៀងទៅលើសិស្សដែលរៀនគួជាមួយខ្លួន ដែលអាចឱ្យសិស្សដទៃទៀតបាក់ទឹកចិត្ត ហើយការសិក្សាធ្លាក់ចុះ ។ ម្យ៉ាងទៀត ការបង្រៀនគួរនេះ ធ្វើឱ្យសិស្សមានទម្លាប់មិនល្អ មិនយកចិត្តទុកដាក់ក្នុងសិក្សារៀនសូត្រ និងមិនពឹងផ្អែកលើសមត្ថភាពខ្លួនឯងដើម្បីអភិវឌ្ឍន៍ចំណេះដឹង ហើយសម្លឹងឃើញគុណសម្បត្តិរបស់លុយក្នុងដំណើរការបង្រៀន និងរៀនទៅវិញ ពិសេសគឺឥទ្ធិពលដ៏លើសលុបរបស់វា ទៅលើដំណើរជីវិតរបស់គាត់។លើសពីនេះទៅទៀត វាបានបង្កើតជាវប្បធម៌ចំណាយប្រាក់ក្នុងការសិក្សា បើទោះបីការចុះចូលរៀនមិនបង់ប្រាក់ក៏ដោយក៏ការចំណាយក្នុងការរៀន សូត្រសម្រាប់សិស្សមួយឆ្នាំទៅ មួយឆ្នាំមានការកើនឡើង (មន្ត្រីអប់រំ អាចបង្កើតឧបករណ៍Survey បានដើម្បីបញ្ជាក់ភស្តុតាងពីបញ្ហានេះ ) ។ ករណីនេះ នៅពេលរាលដាលធំទៅៗ វាបង្កើតជារនាំងឧបសគ្គសម្រាប់គ្រួសារក្រីក្រ នាំទៅរកការបាក់ទឹកចិត្ត និងបាត់បង់ជំនឿលើការសិក្សា ឧទាហរណ៍ការឱ្យកូនឈប់រៀនទៅធ្វើការងាររោងចក្រជាដើម។ផលវិបាកមួយទៀតគឺវាធ្វើឱ្យសិស្សអសកម្ម មិនឱ្យតម្លៃការសិក្សា និងចេះពុករលួយសូកប៉ាន់ ។ ស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ចគ្រូបង្រៀននិងឪពុកម្តាយ អាណាព្យាបាលនៅតាមជនបទទាប គ្រូគ្មានជម្រើសដូចបង្ហាញខាងលើ ឡើយ ប៉ុន្តែ វាអាចចេញជាភាព

មិនសូវយកចិត្តទុកដាក់លើការបង្រៀននិងរៀន ដែលធ្វើឱ្យការសិក្សារបស់សិស្សធ្លាក់ចុះ ឬ សកម្មភាពនៃការលួចម៉ោងរដ្ឋជាដើម ។ ឧទាហរណ៍៖ គ្រូមួយចំនួនមានទម្លាប់មកធ្វើការយឺត ឬ ចេញមុនម៉ោង ឬបង្កើនម៉ោងចេញលេងជាដើម។ ខាងលើ យើងលើកចោទជាបញ្ហាសម្រាប់តែពីសាលាបឋមសិក្សា ចុះនៅមធ្យមសិក្សាយ៉ាងម៉េចដែរ ?(សូមបញ្ជក់ថាអ្នកវិភាគសូមលើកជាឧទាហរណ៍ប៉ុណ្ណោះព្រោះយើងមិនមាន ឧបករណ៍ស្រាវជ្រាវជាក់លាក់ទេ។) បើសិននៅតាមសាលាអនុវិទ្យាល័យ-វិទ្យាល័យមួយចំនួន មានលោកគ្រូ-អ្នកគ្រូមួយចំនួនផ្តោតទៅលើផលប្រយោជន៍ ផ្ទាល់ខ្លួនតាមរយៈការស្វះស្វែងរកឱកាសក្នុងការទាញយក ប្រយោជន៍ពីសិស្សនោះ វានាំឱ្យការអប់រំមានទិសដៅឆ្ពោះទៅរកការរកលុយ ទៅវិញ ដែលជះឥទ្ធិពលអាក្រក់បំផុតដល់សិស្ស។ បញ្ហានេះវាបានប្រែក្លាយសកម្មភាព អប់រំ ទៅជាការប្រកួតប្រជែងអាជីវកម្មយ៉ាងគគ្រឹកគគ្រេង ស្ទើរគ្រប់មុខវិជ្ជា ។ ប្រសិនបើសិស្សមិនចង់រៀនម៉ោងកាយសិក្សាអាចបង់លុយដើម្បីយកពិន្ទុ បង់លុយច្រើន បានពិន្ទុច្រើន ហើយបង្កើតឱ្យមានការបង្រៀនគួរក្រៅម៉ោងស្ទើរគ្រប់មុខវិជ្ជា ដែលវាគួរឱ្យអស់សំណើចបំផុត ។ បើសិស្សអាចទិញពិន្ទុបាន ចំណាត់ថ្នាក់បាន ទិញអវត្តមាន តើខំរៀនដើម្បី អ្វី ? តើសន្ទុះនៃការសិក្សារបស់យុវជនមានដំណើរវិវត្តទៅមុខខ្លាំងទេ ? តើអ្នកមានសង្ឃឹមថាកូនរបស់អ្នកនឹងក្លាយជាសិស្សពូកែបានទេ បើអ្នកមិនមានលុយគ្រប់គ្រាន់សម្រាប់ចំណាយដល់គាត់ក្នុងការរៀន សូត្រនោះ ? តើគ្រួសារក្រីក្រមានអារម្មណ៍បែបណាចំពោះស្ថានភាពសង្គមបែបនេះ ? តើសិស្សានុសិស្សដែលមកពី គ្រួសារក្រីក្រទទួលរងភាព អយុត្តិធម៌និងលំបាកប៉ុណ្ណា ? តើអ្នកមានសេចក្តីសង្ឃឹមលើអនាគតអ្នកទេ ? តើគោលនយោបាយ ការចុះឈ្មោះចូលរៀនមិនបង់ប្រាក់ មានប្រសិទ្ធភាពទេ ? ជារួមតើរយៈពេល១២ឆ្នាំ ក្នុងការអប់រំ សិស្សានុសិស្សរៀនពីអ្វីច្រើនជាងគេ ?ក្នុងប្រព័ន្ធគំនិតរបស់សិស្ស និស្សិតភាគច្រើននៅកម្ពុជា ផ្តោតតែទៅលើលុយជាសំខាន់ព្រោះគេទទួលឥទ្ធិពលនេះ ពីសាលារៀនរបស់គេ គេរៀនគឺដើម្បីមានការងារល្អប្រាក់ខែខ្ពស់ និងមានលុយច្រើន មុននឹងមានគំនិតស្នេហាជាតិមាតុភូមិ និងស្រឡាញ់សច្ចភាពយុត្តិធម៌។ មកដល់នាទីចុងក្រោយ នៃការបញ្ចប់ការសិក្សាគឺការប្រឡង ទាំងការប្រឡងបញ្ចប់មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិនៅ តែវត្តមានលុយសំខាន់ដដែល ហើយរលកនៃការចំណាយលុយសម្រាប់ការប្រឡងបានកើនឡើងពីមួយឆ្នាំទៅ មួយឆ្នាំ និងរាលដាលតាំងពីទីក្រុងរហូតដល់ជនបទប៉ុន្មានឆ្នាំចុងក្រោយ។ បើសិស្ស អាចទិញវិញ្ញាសាបាន តើប្រឡងដើម្បីអ្វី ? តើការប្រឡងជាការរកលុយមែនទេ សម្រាប់លោកគ្រូ-អ្នកគ្រូ ? តើនេះជាយុទ្ធសាស្ត្រ ដើម្បីបង្កើនសិស្សឱ្យបានច្រើនក្នុង ការបន្តការសិក្សាថ្នាក់មហាវិទ្យាល័យឬ ? បើវាដូច្នេះ មែន តើវាមានភាពចំណេញ

ទេបើទោះជាយើងបានរក្សាពួកគាត់រយៈ ពេល៤ឆ្នាំបន្ថែមទៀតនៅថ្នាក់មហាវិទ្យាល័យនោះ? បើមានករណីដូចរៀបរាប់ ទាំងនេះ មែន យើងកំពុងដេកបើកភ្នែក មើល ដំណើរឆ្ពោះទៅរកការបំផ្លាញខ្លួនឯងហើយ។គុណភាពអប់រំធ្លាក់ចុះហើយភាពអស់ជំនឿលើការសិក្សារបស់ស្រទាប់គ្រួសារក្រីក្របាននិងកំពុងកើនឡើង ហើយអត្រាឈប់រៀនដើម្បីធ្វើការងារកើនឡើង ផងដែរដូចជាចំណាកស្រុកទៅធ្វើការនៅប្រទេសជិតខាង ធ្វើកម្មកររោងចក្រ កម្មករសំណង់...ដែលភាគច្រើនជាការងារដែលមានកំរៃទាប និង មិនមានភាពជាម្ចាស់ លើការអភិវឌ្ឍ បង្កើតការងារ ដោយខ្លួនឯង ហើយអនាគតយើង ពិតជាដណ្តើមបានទីផ្សារការងារលើសលុប ក្នុងសហាគមអាស៊ានផ្នែក កម្មករប្រើកម្លាំង មិនមែនកម្មករជំនាញទេ។ តើអនាគត ធនធានមនុស្សរបស់ប្រទេសកម្ពុជាគ្រប់គ្រាន់ទេ ក្នុងបរិបទសហាគមអាស៊ាននោះ ? សម្រាប់ជីវភាពគ្រូបង្រៀន អ្នកវិភាគយល់ច្បាស់ណាស់ ថាពិតជានៅមានកម្រិតទាប ដែលទាមទារ ឱ្យមានការផ្តល់នូវប្រាក់កំរៃសមស្របសម្រាប់ដោះស្រាយជីវភាពរស់នៅសមរម្យ ។ ស្ថិតក្នុងស្ថានភាព គ្រូបង្រៀនបច្ចុប្បន្ន ឥរិយាបថអវិជ្ជមានរបស់លោកគ្រូ-អ្នកគ្រូ មួយចំនួនបានប្រែក្លាយទៅជាទម្លាប់ឆ្ពោះទៅ រកវប្បធម៌ហើយ ហើយបើទោះបី ជារាជរដ្ឋាភិបាលតំលើងប្រាក់បៀវត្សសមរម្យក៏ដោយ ក៏សកម្មភាព អសកម្មមួយចំនួនធំ នៅតែមានអត្ថិភាពដដែល ដូចជា៖ ការគៀបសិស្សដើម្បី រៀនគួរជាដើម ។ ជារួមយើងមិនគួរបណ្តោយវាទៅជាជម្ងឺមហារីកទេ គប្បីព្យាបាលឱ្យទាន់ពេលវេលានិងឆាប់បំផុត ។

### គ-ឥរិយាបថអវិជ្ជមានរបស់ឪពុកម្តាយ និងអាណាព្យាបាល

ជាទូទៅឪពុកម្តាយ អាណាព្យាបាលខ្មែរមួយចំនួនធំ មិនមានទម្លាប់អានសៀវភៅ ដែលធ្វើវប្បធម៌នៃការអាន នៅតិចតួចនៅឡើយ។ មួយវិញទៀត គេមិនសូវឃើញ មានទូតាំងសៀវភៅនៅតាមគ្រួសារខ្មែរ ដែលករណីនេះ វាបង្ហាញពីភាពមិនសូវចិត្តទុកដាក់ និងមិនយល់ពីគុណសម្បត្តិរបស់សៀវភៅដែលជាប្រភពសំខាន់ក្នុងការអភិវឌ្ឍចំណេះដឹង និងសមត្ថភាព។ ចំណុចអសកម្មមួយចំនួនទៀត គឺឪពុកម្តាយមួយចំនួន បានបំបាក់ទឹកចិត្តកូនដើម្បី ទាញយកផលប្រយោជន៍ពីកូនដោយជំរុញកូនឱ្យឈប់រៀនដើម្បី ចូលធ្វើការរកប្រាក់ សម្រាប់ជាចំណូលគ្រួសារ ពិសេសការលើកយកហេតុផលពីភាពអយុត្តិធម៌ ក្នុងសង្គមមកធ្វើឧបសគ្គ និងផ្តល់ភាពអស់សង្ឃឹមដល់កូន ដូចជា៖ រៀនបានប្រយោជន៍អី យើងគ្មានលុយសូកគេធ្វើការងារទេ ឬគ្មានលុយរៀនមហាវិទ្យាល័យទេ ឬបង្ហាញថា និស្សិតបញ្ចប់មហាវិទ្យាល័យច្រើនណាស់នៅភ្នំពេញ រកការងារធ្វើមិនបានផង កន្លែងការងារល្អៗ គេដាក់កូនគេអស់ហើយ... ពិសេសករណីនេះ កើតឡើងចំពោះគ្រួសារដែលមានជីវភាពក្រីក្រលំបាក។ ស្ថានភាពក្រីក្រលំបាក ធ្វើឱ្យពួកគាត់យល់ថា បញ្ហាក្រពះ សំខាន់ជាងការ

សិក្សា ហើយទង្វើនេះ បានរុញកូនគាត់ចូលទៅក្នុងវដ្តនៃភាពក្រីក្រ ព្រោះការដែលគាត់បោះបង់ការសិក្សា ធ្វើឱ្យទទួលបានការងារដែលប្រើកម្លាំង និងកំណត់ដោយការងារដែលទទួលបានប្រាក់បៀវត្សទាប ។ ដូច្នេះ គាត់បាត់បង់ឱកាសរំដោះខ្លួន ពីភាពក្រីក្រ ហើយមានការលំបាកច្រើន ក្នុងការគេចចេញពីនឹមនៃភាពក្រីក្រ ។ ថ្វីត្បិតតែការចុះឈ្មោះចូលរៀនមិនបង់ថ្លៃ តែគ្រួសារនីមួយៗមានការចំណាយច្រើន សម្រាប់ការសិក្សារបស់កូន ហើយគ្រួសារដែលក្រីក្រ ពិបាកលៃលក ឱ្យកូនបន្តការសិក្សា ពិសេសចំណាយសម្រាប់ការបង្រៀនគួរក្រៅម៉ោងរបស់គ្រូ ហើយបើកូនសិស្សមិនបានរៀនគួរបន្ថែមទេ សិស្សមានការលំបាកក្នុងការប្រកួតប្រជែងក្នុងទទួលបានជោគជ័យលើការសិក្សា។ លើសពីនេះទៅទៀត ស្ថានភាពអំពើហិង្សាក្នុងគ្រួសារ នៅតែកើតមានច្រើននៅឡើយនៅក្នុងប្រទេសកម្ពុជា ដែលវាប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការសិក្សារបស់កុមារនិងយុវជន។ ទង្វើរបស់ឪពុកម្តាយ អាណាព្យាបាលទាំងអស់នេះ ហើយធ្វើឱ្យការអប់រំនៅកម្ពុជាធ្លាក់ទាប។

**ឃ-ឥទ្ធិពលវប្បធម៌ពាលាអាវ៉ាសែបរទេស និងកង្វះការយកចិត្តទុករបស់សង្គម**

ប្រទេសកម្ពុជាមាន និស្សិតច្រើនណាស់ ដែលបានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ ប៉ុន្តែភាគច្រើនមានតែបរិមាណ មិនមានគុណភាពទេ។ មកដល់ពេលនេះ ស្ថានភាពធ្លាក់ចុះនៃទំនុកចិត្តលើការសិក្សារបស់សិស្សានុសិស្ស ពិសេសនៅតាមជនបទ ហាក់ដូចជា មិនទាន់ឃើញមានគោលនយោបាយច្បាស់លាស់សោះ ក្នុងដោះស្រាយបញ្ហានេះ ។ ការបណ្តែតបណ្តោយរបស់សង្គម ធ្វើឱ្យមានករធ្លាក់ចុះ កាន់តែធ្ងន់ធ្ងរទៅៗ ដោយគ្មានគតិបណ្ឌិតអភិវឌ្ឍ បង្ហាញពីកំសោយភាពរបស់ថ្នាក់ដឹកនាំ និងភាពកំសាក ការទទួលស្គាល់ការពិត។ ការមិនអើពើពីបញ្ហាទាំងនេះ និងមិនមានដំណោះស្រាយសមស្របទាន់ពេលវេលាទេ វានឹងពន្យឺតការអភិវឌ្ឍប្រទេសជាក់ជាមិនខាន និងសកម្មភាពអវិជ្ជមាន កាន់តែកើតមានច្រើនឡើងនៅក្នុងសង្គមកម្ពុជា នាពេលអនាគតដូចជា៖ ការកាប់បំផ្លាញព្រៃឈើ ការបំផ្លាញធនធានជលផល ធនធានរ៉ែ អំពើអសន្តិសុខសង្គម អំពើហិង្សាក្នុងគ្រួសារ។

## ៣.២. ដំណោះស្រាយ

### ៣.២.១. ដំណោះស្រាយរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឡើងនូវផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច៥ឆ្នាំម្តង តាមរយៈគោលនយោបាយយុទ្ធសាស្ត្រចតុកោណ ឈ្មះ ឈ្មះ ដើម្បីផ្តល់ការតម្រង់ទិសដល់ការបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច ព្រមទាំងអនុវត្តដោយជោគជ័យនូវ យុទ្ធសាស្ត្រត្រីកោណ ដែលបានផ្តោតលើគោលដៅចំនួនបី គឺ៖ ១ការធានាឲ្យមានសន្តិភាព ស្ថិរភាព

និង សន្តិសុខ ២ការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងការធ្វើឲ្យមានទំនាក់ទំនងល្អឡើងវិញជាមួយនឹងសហគមន៍អន្តរជាតិ និង៣ការជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច។ ដោយកត្តាទាំងនេះបានប្រែក្លាយប្រទេសកម្ពុជា ពីប្រទេសមួយដែលធ្លាប់មានអស្ថិរភាព សង្គ្រាម ជម្លោះផ្ទៃក្នុង និងភាពអន់ថយ ឲ្យក្លាយទៅជាប្រទេសមួយដែលមានសណ្តាប់ធ្នាប់សង្គម ការគោរពលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស កិច្ចសហប្រតិបត្តិការ និងកិច្ចអភិវឌ្ឍដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋានដែលមានការពាក់ព័ន្ធ។ ការធ្វើឲ្យការអភិវឌ្ឍន៍ជាតិ សម្រេចបានជោគជ័យ តម្រូវឲ្យរដ្ឋាភិបាលបន្តសម្រិតសម្រាំង កែលម្អ និងពង្រឹងនូវអាទិភាពគោលនយោបាយ បន្តកែលម្អនូវយុទ្ធសាស្ត្រតាមផ្ទៃក ឲ្យឆ្លុះបញ្ចាំងនូវសភាពការជាក់ស្តែងរបស់កម្ពុជាដោយឈរលើបទពិសោធន៍ជាក់ស្តែង នៃការអនុវត្តនាពេលកន្លងមក[១]។ តាមរយៈយុទ្ធសាស្ត្រចតុកោណនីតិកាលទី៥ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតសំខាន់ ទៅលើការអភិវឌ្ឍន៍ទីផ្សារការងារដោយផ្តល់អាទិភាពលើៈ

- ការរៀបចំ និងអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ដើម្បីអភិវឌ្ឍន៍វិស័យការងារឲ្យស្របតាមការវិវត្តន៍នៃស្ថានភាពសង្គម សេដ្ឋកិច្ច ដោយយកចិត្តទុកដាក់ ជាពិសេស លើការអភិវឌ្ឍការងារសម្រាប់យុវជន ការរៀបចំកម្លាំងពលកម្មឲ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការ នៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ព្រមទាំងការត្រៀមលក្ខណៈក្នុងការគ្រប់គ្រង និងទាញយកផលប្រយោជន៍ឲ្យបានជាអតិបរមា ពីការចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។
- ការពង្រឹងយន្តការ វេទិកាការងារ ដែលមានការចូលរួមពីសំណាក់អ្នកផ្តល់ការងារ អ្នកស្វែងរកការងារ និងអ្នកផ្តល់ការអប់រំ និងបណ្តុះបណ្តាល ក្រោមការសម្របសម្រួលរបស់រាជរដ្ឋាភិបាល សំដៅផ្លាស់ប្តូរពត៌មាន ប្រឹក្សាយោបល់ និងធ្វើសកម្មភាពរួមគ្នា ដើម្បីឆ្លើយតបទៅនឹងស្ថានភាពទីផ្សារការងារ។
- ការពង្រីកការផ្តល់សេវាការរកការងារ និងការផ្សព្វផ្សាយពត៌មាន អំពីកាលានុវត្តភាពការងារក្នុង និងក្រៅប្រទេស ឲ្យបានទូលំទូលាយ ដល់ប្រជាពលរដ្ឋគ្រប់មជ្ឈមណ្ឌលការងារនៃទីភ្នាក់ងារជាតិមុខរបរ និងការងាររបស់ក្រុមប្រឹក្សាជាតិបណ្តុះបណ្តាល នៅទូទាំងប្រទេស។

[១] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤២០១៨

- ការបន្តអភិវឌ្ឍប្រព័ន្ធពត៌មានទីផ្សារការងារឲ្យកាន់តែល្អ ជាពិសេសពង្រឹងការប្រមូល វិភាគ និងការផ្សព្វផ្សាយស្ថិតិការងារ ផ្សព្វផ្សាយពត៌មានស្តីពីការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ការផ្តល់ពត៌មានអំពីប្រាក់ឈ្នួល រួមទាំងអំពីការផ្គត់ផ្គង់ពលកម្ម និងសេចក្តីត្រូវការជំនាញ។
- ការបន្តអភិវឌ្ឍធនធានមនុស្សលើផ្នែកបច្ចេកទេស ឲ្យឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច ជាពិសេស តាមរយៈការជំរុញការបណ្តុះបណ្តាល និងវិក្រឹតភាពជំនាញវិជ្ជាជីវៈ ព្រមទាំងការហ្វឹកហ្វឺនកូនជាង ដោយផ្តល់ការលើកទឹកចិត្តដល់ការចូលរួមវិស័យឯកជន សំដៅលើកកម្ពស់ផលិតភាពការងារ និងបង្កើនចំណូលជូនពលករ និងនិយោជក។
- ការសម្របសម្រួលឲ្យស៊ីចង្វាក់គ្នា រវាងវិស័យអប់រំ និងវិស័យបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ការផ្តល់ពត៌មានអំពីប្រាក់ឈ្នួល រួមទាំងអំពីការផ្គត់ផ្គង់ពលកម្ម និងសេចក្តីត្រូវការជំនាញ។
- ការបន្តលើកកម្ពស់លក្ខខណ្ឌការងារឲ្យកាន់តែប្រសើរឡើង តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ រួមទាំងការបន្តគាំទ្រកម្មវិធីរោងចក្រល្អប្រសើរ និងការធ្វើឲ្យប្រសើរឡើងនូវបរិយាកាសទីផ្សារការងារ ។
- ការពង្រីកភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈរវាងកម្ម និយោជិត និងនយោជក តាមរយៈការជម្រុញអនុម័តច្បាប់ស្តីពីសហជីព ការធ្វើបច្ចុប្បន្នកម្មច្បាប់ស្តីពីការងារ ការពង្រឹងការគោរពវិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈ ការពង្រឹងនិងសម្របសម្រួលស្ថាប័នអនុវត្តយន្តការទប់ស្កាត់ និងដោះស្រាយវិវាទការងារ ដ៏ដូចជាយន្តការទប់ស្កាត់និងដោះស្រាយបាតុកម្មព្រមទាំងការពង្រឹងនិងសមត្ថភាព និងតួនាទីរបស់អធិការកិច្ចការងារ ក្នុងការផ្សះផ្សា ដោះស្រាយវិវាទ និងការបង្កើតតុលាការការងារ ។
- ការបង្កើតយន្តការសម្រាប់ធ្វើការសិក្សាជាទៀងទាត់ និងជាយថាហេតុលើកអនុសាសន៍សម្រាប់ការពិនិត្យ កំណត់ប្រាក់ឈ្នួលអប្បបរមា ស្របតាមស្ថានភាពសេដ្ឋកិច្ចជាតិ តាមវិស័យនិងតាមតំបន់ ព្រមទាំងការបង្កើតយន្តការធានារ៉ាប់រងផលប្រយោជន៍របស់កម្មករនិយោជិត នៅពេលរោងចក្រក្ស័យធន ។

- ការបន្តពង្រឹងគ្រប់គ្រងការជ្រើសរើស និងការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ព្រមទាំងការលើកកម្ពស់យន្តការការពារសិទ្ធិ សុខភាព និងសុវត្ថិភាពការងាររបស់ពលករកម្ពុជានៅក្រៅប្រទេស ។
- សកម្មភាព កម្មវិធី និងគម្រោងសំខាន់សម្រាប់អនុវត្តគោលនយោបាយអាទិភាពដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម :
    - ធានាលើកកម្ពស់លក្ខខណ្ឌការងារល្អប្រសើរ។
    - ពង្រឹងការអនុវត្តបទបញ្ញត្តិ និងច្បាប់ស្តីពីការងារ និងរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីសុខភាព និងសុវត្ថិភាព ។
    - ធ្វើវិសោធនកម្មបទប្បញ្ញត្តិ មួយចំនួននៃច្បាប់ស្តីពីការងារ និងរៀបចំបទប្បញ្ញត្តិឲ្យបានគ្រប់គ្រាន់ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តបទប្បញ្ញត្តិច្បាប់ស្តីពីការងារ ដើម្បីលើកកម្ពស់សិទ្ធិ និងសេរីភាព នៃទំនាក់ទំនងវិជ្ជាជីវៈ សុខភាព និងសុវត្ថិភាពការងារ និងលក្ខខណ្ឌការងារល្អប្រសើរ ។
    - ធ្វើសហការប្រតិបត្តិការជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងគោលដៅធានាឲ្យមានការអនុវត្តច្បាប់កាន់តែប្រសើរ និងចុះធ្វើអធិការកិច្ចតាមសហគ្រាសគ្រឹះស្ថានគ្រប់វិស័យក្នុងគោលបំណងធានាស្តង់ដាលក្ខខណ្ឌការងារអប្បបរមា ទប់ស្កាត់ និងលុបបំបាត់ពលកម្មកុមារ ។
    - ពង្រឹងការផ្សព្វផ្សាយ ឲ្យបានទូលំទូលាយដល់មូលដ្ឋាន ជាពិសេសអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ឲ្យមានការយល់ដឹងពីផលវិបាកចំពោះបញ្ហាពលកម្មកុមារ ជាពិសេសការបង្កើនការផ្សេព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗ ក៏ដូចជាការលើកកម្ពស់ការបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកអធិការកិច្ចពលកម្មកុមារ។
    - ដោយបង្កើតបរិយាកាសការងារ និងបង្កើនកាលានុវត្តភាពការងារដូចជា៖

- ផ្តើមអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ដើម្បីអភិវឌ្ឍន៍វិស័យការងារស្របតាមការវិវត្តនៃស្ថានភាពសង្គម សេដ្ឋកិច្ច ជាពិសេសដោយយកចិត្តទុកដាក់លើការបង្កើតការងារសម្រាប់យុវជន ដែលជាកម្លាំងពលកម្មស្នូលសម្រាប់ត្រៀមលក្ខណៈ ក្នុងការទប់ទល់លំហូរដោយសេរីនូវពលករជំនាញនាពេលសមាហរណកម្មសហគមន៍សេដ្ឋកិច្ច។
- រៀបចំបង្កើតវិទ្យាស្ថានការងារក្នុងគោលបំណងបណ្តុះបណ្តាលមន្ត្រី សិស្ស និស្សិត សិក្សាស្រាវជ្រាវ និងវិភាគលើស្ថានភាពកម្លាំងពលកម្មប្រាក់ឈ្នួល និងជំនាញដែលពាក់ព័ន្ធនឹងវិស័យការងារ។

- លើកទឹកចិត្តម្ចាស់សហគ្រាសគ្រឹះស្ថានឯកជន នៅតាមតំបន់ជនបទដាច់ស្រយាល ឲ្យគោរពលក្ខខណ្ឌការងារឲ្យកាន់តែប្រសើរឡើង ដើម្បីទាក់ទាញពលរដ្ឋខ្មែរឲ្យជ្រើសរើសការងារក្នុងស្រុក។
- កែលម្អកម្មវិធីក្នុងការគ្រប់គ្រងពលករខ្មែរ ដែលទៅធ្វើការនៅបរទេសទាំងស្របច្បាប់ទាំងមិនស្របច្បាប់។
- រៀបចំគោលការណ៍ស្នើសុំទៅរាជរដ្ឋាភិបាល ដើម្បីបង្កើតឲ្យមានអនុព័ន្ធការងារនៅតាមប្រទេស ដែលមានពលករខ្មែរទៅធ្វើការលើសពីចំនួន ៣០០០នាក់។
- ចាត់វិធានការជាក់ស្តែងដើម្បីគ្រប់គ្រង និងការពារពលករខ្មែរ ដែលបានឆ្លងដែន និងរស់នៅដោយខុសច្បាប់នៅបរទេស ពិសេសប្រទេសថៃ ដើម្បីធានាថាពលករទាំងនោះទទួលបានសិទ្ធិស្របច្បាប់ដើម្បីរស់នៅ និងធ្វើការ ឬត្រូវបានធ្វើមាតុភូមិនិវត្តន៍ដោយគោរពទៅតាមបទដ្ឋានអន្តរជាតិ។

• ពង្រឹងភាពសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ៖

- ផ្សព្វផ្សាយការយល់ដឹងអំពីសិទ្ធការងារជាមូលដ្ឋានដល់គ្រប់ភាគីពាក់ព័ន្ធ ដើម្បីឲ្យមានការអនុវត្តបទប្បញ្ញត្តិ និងច្បាប់ស្តីពីការងារឲ្យកាន់តែប្រសើរឡើង។
- ជំរុញឲ្យមានការចរចាជាសមូហភាពនៅថ្នាក់សហគ្រាសគ្រឹះស្ថាន ដើម្បីឲ្យមានការចុះអនុសញ្ញារួម។
- ពង្រឹងយន្តការដោះស្រាយវិវាទការងារ ដើម្បីលើកកម្ពស់សិទ្ធកម្មករនិយោជិត និយោជក និងសហជីព និងកាត់បន្ថយការធ្វើកូដកម្មទាំងស្របតាមនីតិវិធី និងមិនស្របតាមនីតិវិធី។
- ជំរុញឲ្យមានការដោះស្រាយ តាមរយៈយន្តការក្រុមប្រឹក្សាអាជ្ញាកណ្តាល ចំពោះសំណុំរឿងវិវាទការងាររួមណាដែលត្រូវបានដោះស្រាយអស់លទ្ធភាព តែនៅមិនទាន់សះជា។
- ពិនិត្យតាមឃ្លាំមើលអំពីស្ថានភាពជីវភាពរស់នៅរបស់កម្មករនិយោជិត ធៀបនឹងកំណើនសេដ្ឋកិច្ច ដើម្បីកែសម្រួលអត្រាបៀវត្សអប្បបរមាឲ្យសមស្របទៅតាមស្ថានភាពសេដ្ឋកិច្ច។

• លើកកម្ពស់ការផ្តល់សេវាការងារ និងពត៌មានទីផ្សារការងារប្រកបដោយគុណភាព និងប្រសិទ្ធភាព៖

- ពង្រីកបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធផ្នែកសេវាជួរមុខឲ្យបានយ៉ាងហោចមួយ នៅតាមបណ្តារាជធានី ខេត្ត។
- បង្កើនការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការផ្តល់សេវាដូចជា ការចុះឈ្មោះការស្វែងរកការងារ និងការផ្សព្វផ្សាយព័ត៌មានជ្រើសរើសបុគ្គលិក ដើម្បីជួយកាត់បន្ថយការចំណាយថវិកានិងពេលវេលា។
- អភិវឌ្ឍធនធានមនុស្សក្នុងក្របខណ្ឌ ឲ្យប្រកបដោយសីលធម៌វិជ្ជាជីវៈក្នុងការផ្តល់សេវា។

- ពង្រឹងការប្រមូលព័ត៌មានពីគ្រប់ប្រភព និងដោយផ្ទាល់ដល់ទីកន្លែងរបស់និយោជកអ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និងអាជ្ញាធរមូលដ្ឋាន។
- ផ្សព្វផ្សាយពីសេវាការងារ និងសិក្ខាសាលាផ្សព្វផ្សាយការចងក្រងព័ត៌មានទីផ្សារការងារ ពីទិន្នន័យដែលមានស្រាប់ពីប្រភពអង្គភាពស្ថិតិ ដែលបានចាត់តាំងនិងការអង្កេតប្រមូលទិន្នន័យ។
- ពង្រឹងយន្តការវេទិការការងារ ដែលមានការចូលរួមពីសំណាក់អ្នកផ្តល់ការងារ អ្នកស្វែងរកការងារ និងអ្នកផ្តល់ការអប់រំ និងបណ្តុះបណ្តាល ក្រោមការសម្របសម្រួលរបស់រាជរដ្ឋាភិបាល សំដៅផ្លាស់ប្តូរព័ត៌មានប្រឹក្សាយោបល់ និងធ្វើសកម្មភាពរួមគ្នាដើម្បីឆ្លើយតបទៅនឹងស្ថានភាពទីផ្សារការងារ។

• ពង្រឹងនិងពង្រីកសេវាអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈប្រកបដោយសមធម៌៖

- ពង្រីកប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីឲ្យការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ បានដល់ប្រជាពលរដ្ឋគ្រប់រូបនៅតាមបណ្តារាជធានី ខេត្តទូទាំងប្រទេសប្រកបដោយសមធម៌។
- បង្កើនការចុះឈ្មោះចូលរៀន ពង្រីការអប់រំ និងបំពាក់ឧបករណ៍សម្ភារៈមូលដ្ឋាន និងសង់អគារបន្ថែមសម្រាប់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រយៈពេលវែងដល់គ្រឹះស្ថានតាមខេត្តមួយចំនួនទៀត។
- បន្តអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញ តាមរយៈមូលនិធិពិសេសរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** សម្រាប់ជំហានបន្ថែមទៀត
- ពង្រឹងគុណភាពវិញ្ញាបនបត្រផ្អែកលើសមត្ថភាពជាមូលដ្ឋាន និងវគ្គសិក្សាសញ្ញាបត្រដើម្បីបណ្តុះបណ្តាលពលករឲ្យមានសមត្ថភាពជំនាញកម្រិតមធ្យម
- បង្កើនគុណភាពនៃកម្មវិធីអប់រំមានកម្រិត ដើម្បីធានាឲ្យពលករខ្មែរមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រកួតប្រជែង ជាមួយនឹងពលករនៃបណ្តាប្រទេសអាស៊ានផ្សេងៗទៀត ជាពិសេសនាពេលសមាហរណកម្មសហគមន៍សេដ្ឋកិច្ច
- ដាក់បញ្ចូលជំនាញសហគ្រិនភាព និងការប្រាស្រ័យទាក់ទង (ភាសាអង់គ្លេស) ទៅក្នុងកម្មវិធីសិក្សាឲ្យស្របតាមការប្រែប្រួលទៅនឹងតម្រូវការទីផ្សារការងារ។
- បញ្ចូលជំនាញ និងការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ស្តីពីគុណភាព និងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទៅក្នុងកម្មវិធីសិក្សានៃវិស័យអប់រំ ជាពិសេសថ្នាក់វិទ្យាល័យ និងថ្នាក់ឧត្តមសិក្សា។
- បញ្ចប់សេចក្តីព្រាងក្របខណ្ឌគុណវុឌ្ឍិកម្ពុជា និងក្របខណ្ឌគុណវុឌ្ឍិអាស៊ាន។

- រៀបចំករប្រកួតប្រជែងជំនាញថ្នាក់ជាតិ និងចូលរួមការប្រកួតប្រជែងជំនាញអាស៊ាន។
- បន្តអភិវឌ្ឍស្តង់ដាជាតិសមត្ថភាពឲ្យមានការប្រកួតប្រជែងខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងវិស័យសំណង់ មេកានិច សេវាធុរកិច្ច និងបច្ចេកវិទ្យាទូរគមនាគមន៍ព័ត៌មានវិទ្យា។
- កែលម្អលក្ខណវិនិច្ឆ័យ និងអនុវត្តការទទួលស្គាល់វគ្គកម្មវិធីសិក្សា និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ។
- ធ្វើអធិការកិច្ចការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ធ្វើតេស្តកូនជាង ដែលបានហ្វឹកហ្វឺនចប់វគ្គ និងផ្តល់វិញ្ញាបនបត្រ និងប័ណ្ណទទួលស្គាល់ជំនាញ។
- ពង្រឹងសមត្ថភាពតាមអង្គភាពនីមួយៗក្នុងការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការប្រតិបត្តិប្រចាំឆ្នាំ ការធានាគុណភាពការងារ និងការគ្រប់គ្រងត្រួតពិនិត្យតាមដាន និងវាយតម្លៃ។
- អភិវឌ្ឍថែទាំនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។
- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍមុខជំនាញឲ្យស្របតាម តម្រូវការទីផ្សារការងារ។
- បង្កើតវិធីសាស្ត្រក្នុងការគ្រប់គ្រងជំនាញ ដែលជាយន្តការមួយគ្រប់គ្រងក្នុងការសម្របសម្រួលការអភិវឌ្ឍជំនាញ ដោយយកចិត្តទុកដាក់ ជាពិសេសទៅលើការវិវត្តជំនាញនៅក្នុងតំបន់។ ការបង្កើតវិធីសាស្ត្រនេះ គឺផ្អែកលើចំណេះដឹងដែលមានស្រាប់និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍមូលធនមនុស្សដែលនេះអាចរួមបញ្ចូលទាំងការពង្រឹងតួនាទីរបស់ NTB ផង។
- ជំរុញវិធីសាស្ត្រពហុភាគីក្នុងការគ្រប់គ្រងជំនាញ តាមរយៈការចូលរួមយ៉ាងសកម្មពីសំណាក់រាជរដ្ឋាភិបាល វិស័យឯកជន និងសហជីពនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត។
- ភ្ជាប់យុទ្ធសាស្ត្រពាណិជ្ជកម្មទៅនឹងគោលនយោបាយឧស្សាហកម្ម ជាពិសេសឧស្សាហកម្មដែលមានសក្តានុពលខ្លាំង ដូចជាកសិកម្ម តម្លៃបន្ថែមអេគិចត្រូនិច និងវិស័យកម្មន្តសាលធនស្រាល និងការដំឡើង។
- បង្កើតការតភ្ជាប់ជាលក្ខណៈអន្តរវិស័យឲ្យបានច្បាស់លាស់ ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្ស ការតភ្ជាប់រវាងការអភិវឌ្ឍជំនាញ និងវិស័យដ៏ទៃទៀត ក៏គួរតែត្រូវធ្វើឡើងផងដែរ។
- ផ្តល់អាទិភាពចំពោះស្ត្រីភេទជនពិការ ជនបាត់បង់កាលានុវត្តភាព ជនងាយរងគ្រោះ និងសិស្សដែលបានបោះបង់ការសិក្សា ដើម្បីឲ្យពួកគេមានជំនាញ និងមុខរបរអាចរួមរស់បានសមរម្យ ក្នុងសង្គមដូចសមាជិកដទៃទៀត។

- កសាងអគារអន្តេវាសិដ្ឋានតាមបណ្តាគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទូទាំងរាជធានី ខេត្ត។
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន ដើម្បីបង្កើន គុណភាពការអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ។
  - ធានានិរន្តភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ
- ជំរុញនិងលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន ដើម្បីធានាថាកម្មវិធីអប់រំ បណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឆ្លើយតបទៅនឹងការវិវត្តនិងតម្រូវការទីផ្សារនៃវិស័យ ឧស្សាហកម្ម ក៏ដូចជាដើម្បីចូលរួមក្នុងការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទាំងធនធាន និងការបណ្តុះណ្តាល។
- សិក្សាស្រាវជ្រាវ និងការវិភាគទៅលើគម្លាតនៃជំនាញ ដើម្បីរកឲ្យឃើញពីកម្រិតជំនាញ ដែលត្រូវផ្តល់ឲ្យកម្លាំងពលកម្មនាពេលបច្ចុប្បន្ន ដោយធៀបទៅនឹងកម្រិតតម្រូវការ និង កម្រិតជំនាញដែលត្រូវផ្គត់ផ្គង់នាពេលអនាគត។
- រៀបចំគោលនយោបាយ បទប្បញ្ញត្តិនិងអភិបាលកិច្ច និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រង នៅតាមអង្គភាពនីមួយៗ។
- ថែរក្សាប្រព័ន្ធព័ត៌មានវិទ្យា គ្រប់គ្រងការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងប្រព័ន្ធ ព័ត៌មានទីផ្សារគ្រប់គ្រងការងារ ដែលជាប្រភពយោងមួយសម្រាប់គ្រប់ភាគីពាក់ព័ន្ធទៅនឹង ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងការសម្រេចចិត្ត និងការកសាងផែនការនា ពេលអនាគត។
- ពង្រីកសេវារបបសន្តិសុខសង្គមឲ្យបានដល់ផ្នែកធានារ៉ាប់រងសុខភាព និងរបបប្រាក់ សោធនជាដើម។

ព្រមជាមួយគ្នានេះដែរស្ថាប័នដែលពាក់ព័ន្ធមួយចំនួន ក៏បានរៀបចំជាផែនការ និងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន និងដោះស្រាយបញ្ហាដែលកើតមានឡើងដូចជា៖

### ក. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោះស្រាយបញ្ហាគ្មានការងារធ្វើរបស់យុវជនផង ដែរដោយក្រសួងបានបង្កើតទីភ្នាក់ងារជាតិមុខរបរ និងការងារ ដើម្បីជួយសម្រួល និងដោះស្រាយ បញ្ហាភាពគ្មានការងារធ្វើរបស់យុវជនដូចជា៖

- បង្កើតព័ត៌មានទីផ្សារការងារយ៉ាងទូលំទូលាយ
- រៀបចំការអប់រំនិងបណ្តុះបណ្តាលជំនាញទន់ និងជំនាញរឹង

- ទាក់ទាញឱ្យក្រុមហ៊ុន សហគ្រាស តូចធំក្នុង និងក្រៅប្រទេស ដែលមានបំណងចង់បានកម្មករ ពលករកម្ពុជាទៅធ្វើការងារដោយស្របច្បាប់
- លើកទឹកចិត្តឱ្យមានកាបង្កើតអាជីវកម្ម សហគ្រិនភាព ដល់យុវជន

## ខ. ក្រសួងអប់រំ យុវជន និងកីឡា

ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើក្រសួងអប់រំដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលបានដាក់ចេញ និងអនុវត្តនូវគោលនយោបាយរបស់ខ្លួនដូចខាងក្រោមៈ

**គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌**

- ពង្រីកការទទួលបានសេវាពីកម្មវិធីអភិវឌ្ឍយុវជន ដល់យុវជនបាត់បង់ឱកាស
- គោលនយោបាយជាតិយុវជនកម្ពុជា រៀបចំបាននៅឆ្នាំ ២០១០
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន រៀបចំបាននៅឆ្នាំ ២០១១
- ផែនការពង្រីកមជ្ឈមណ្ឌលយុវជននៅតាមរាជធានី ខេត្ត កសាងបាននៅឆ្នាំ ២០១២
- គោលការណ៍ស្តីពី ការបង្កើតមូលនិធិអប់រំសមធម៌ជាតិ សម្រាប់យុវជនក្រីក្របំផុត (កម្មវិធីអាហារូបត្ថម្ភ និងអន្តេវាសិកដ្ឋាន) រៀបចំបាននៅឆ្នាំ ២០១៣។

**គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ**

បង្កើនគុណភាពនិងប្រសិទ្ធភាពនៃកម្មវិធីអភិវឌ្ឍយុវជនតម្រង់ទៅរកការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ឯកសារគាំទ្រស្តីពី ការអនុវត្តក្រុមប្រឹក្សាយុវជនរៀបចំបាននៅឆ្នាំ២០១១។ ស្តង់ដាសម្រាប់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៅតាមមជ្ឈមណ្ឌលយុវជនកសាងបាននៅឆ្នាំ២០១២។

**គោលនយោបាយទី៣៖អភិវឌ្ឍស្ថាប័ននិងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ**

ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់កម្មវិធីអភិវឌ្ឍយុវជនដើម្បីដោះស្រាយតម្រូវការរបស់យុវជនក្នុងតំបន់។លិខិតបទដ្ឋានក្នុងការបង្កើត ព្រឹត្តិបត្តិយុវជននិងកុមារ រៀបចំបាននៅឆ្នាំ២០១១។

#### ខ.១ សកម្មភាពនិងកម្មវិធីផ្សេងៗ

ការផ្លាស់ប្តូរបទពិសោធន៍ តាមរយៈទស្សនៈកិច្ចសិក្សាបោះជំរំក្នុងប្រទេស និងការប្រជុំផ្សេងៗ ផ្តល់ការបណ្តុះបណ្តាលអំពីការងារស្ម័គ្រចិត្ត និងជំនាញវិជ្ជាជីវៈខ្លីៗ ដល់យុវជន ការគាំទ្រអង្គភាព និងអភិវឌ្ឍមជ្ឈមណ្ឌលយុវជនសិក្ខាសាលា ផ្សព្វផ្សាយការគាំទ្រដំណើរការ ការពង្រឹងសមត្ថភាព វគ្គបំប៉នសមត្ថភាព ស្តីពីការងារដឹកនាំគ្រប់គ្រងដល់មន្ត្រីគ្រប់គ្រងយុវជនពិនិត្យតាមដាន និងវាយតម្លៃការពិនិត្យតាមដាន និងវាយតម្លៃលើកម្មវិធីអភិវឌ្ឍយុវជន។

## ខ.២ ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

កម្មវិធីយុវជនត្រូវគ្រប់គ្រង និងពិនិត្យតាមដានតាមរយៈអគ្គនាយកដ្ឋានយុវជនដែលបានបង្កើត ក្នុងអគ្គនាយកដ្ឋានយុវជនដែលមាននាយកដ្ឋានយុវជន និងនាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌលយុវជន។ ការងារនេះនឹងមានការសម្របសម្រួលយ៉ាងជិតស្និទ្ធរវាងនាយកដ្ឋាន ទាំងពីរ និងនាយកដ្ឋានដទៃទៀត ដើម្បីធានាឱ្យការធ្វើសមាហរណកម្មយុទ្ធសាស្ត្រ និងកម្មវិធីមានប្រសិទ្ធភាពស្ថិតនៅក្នុងក្របខណ្ឌនៃអាណត្តិរបស់ ក្រសួង។ ការពិនិត្យតាមដានកម្មវិធី នឹងរួមបញ្ចូលទាំងសហប្រតិបត្តិការជាមួយ ស្ថាប័នយុវជន និងស្ថាប័នពាក់ព័ន្ធ ហើយនឹងប្រើប្រាស់លទ្ធផលអង្កេតពីមាតាបិតា យុវជន និងសហគមន៍ និងធ្វើការវិភាគលើផលប៉ះពាល់នៃការអភិវឌ្ឍសង្គមទៅលើយុវជន។អាទិភាពចម្បងមួយគឺការអភិវឌ្ឍក្របខណ្ឌពិនិត្យតាមដានរួមមានចំណុចដៅប្រព័ន្ធផ្សេងៗ និងការទទួលខុសត្រូវ ។

## ២.២. អ្នកពាក់ព័ន្ធ

## ក. អង្គការសង្គមស៊ីវិល

### ក.១ បង្កើតកម្មវិធីអប់រំនិងបណ្តុះបណ្តាល

ការបង្កើតគំនិតផ្តួចផ្តើម ឬការបង្រៀនបន្ថែមដែលផ្តោតលើគម្លាតជំនាញអាចផ្តោតលើអ្វីទាំងអស់ពីជំនាញការងារដល់ការប្រមាញ់ការងារ និងការសម្ភាសន៍ចំពោះយុវជននិងការអប់រំវិជ្ជាជីវៈ (រួមទាំងឱកាសការងារនៅក្នុងសេដ្ឋកិច្ចបៃតង)។ ក្នុងពេលអនាគតប្រភេទនៃការអប់រំទាំងនេះ នឹងត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សាជាតិដោះស្រាយកង្វះជំនាញ។ ឧទាហរណ៍នៃកម្មវិធីបណ្តុះបណ្តាលរួមបញ្ចូលទាំងគំនិតផ្តួចផ្តើមធ្វើការងារផ្លាស់ប្តូរ និងក្លាយទៅជាវិទ្យាស្ថានផ្លាស់ប្តូរដែល ផ្តល់ដល់យុវជននូវជំនាញដែលពួកគេត្រូវការដើម្បីទទួលបានជោគជ័យនៅក្នុងអាជីពរបស់ពួកគេ។

## ខ. វិស័យឯកជន

វិស័យឯកជន និងរាជរដ្ឋាភិបាលរួមជាមួយប្រព័ន្ធអប់រំត្រូវចាប់ផ្តើមសហការគ្នាដើម្បីកំណត់នូវចំណេះដឹង និងជំនាញដែលយុវជនត្រូវបង្រៀន ដើម្បីស្វែងរកការងារដែលមានប្រយោជន៍។ ពិចារណាលើភាពមិនស៊ីគ្នានៃជំនាញ ដែលពួកគេត្រូវដើរតួនាទីយ៉ាងសកម្មក្នុងការលើកកម្ពស់ការអប់រំសមស្រប និងការកសាងជំនាញសំរាប់យុវវ័យចាប់ពីវ័យក្មេង។ អ្នកតំណាងមកពីធនធានមនុស្ស អាចផ្តល់ដំបូន្មានពីអាជីព និងផ្តល់ដំបូន្មានពីការបរបាញ់ផងដែរ។ គំនិតផ្តួចផ្តើមសហគ្រាសសង្គម និងមិនរកប្រាក់ចំណេញ កំពុងជួយសម្រួលដល់ការតភ្ជាប់ទាំងនេះ ក៏ដូចជាសាលារៀនជាលក្ខណៈបុគ្គល។ ទោះជាយ៉ាងណាក៏ដោយ ការខិតខំប្រឹងប្រែងកាន់តែច្រើន ដើម្បីចូលរួមវិស័យឯកជនក្នុងវិស័យអប់រំគឺត្រូវការជាចាំបាច់។ ការសំរេចគោលដៅអភិវឌ្ឍន៍ប្រកបដោយ

និរន្តរភាព និងការធានាឱ្យគ្រប់គ្នាអាចទទួលបានការងារសមរម្យមានន័យថាបញ្ចប់វិបត្តិភាពអត់ការងារធ្វើរបស់យុវវ័យធ្វើការជាមួយមនុស្សវ័យក្មេង និងផ្តល់ឱ្យពួកគេនូវឱកាសដើម្បីបង្កើនសក្តានុពលរបស់ពួកគេ។

## សេចក្តីសន្និដ្ឋាន

យុវជន គឺជាកម្លាំងសេដ្ឋកិច្ច និងនយោបាយយ៉ាងសំខាន់ នៅកម្ពុជាបច្ចុប្បន្នហើយកាន់តែសំខាន់ខ្លាំងថែមទៀត នាពេលអនាគត។ យុវជនកម្ពុជា នឹងប្រឈមបញ្ហាច្រើន សម្រាប់ទីផ្សារការងារ ភាពអត់ការងារធ្វើ និងចំណាកស្រុក។ ឧស្សាហកម្ម និងសិប្បកម្ម គឺទាមទាររកម្មករ ដែលមានជំនាញ និងមានការអប់រំសមស្រប ក្នុងខណៈដែលដែលសាលារៀននិងសាកលវិទ្យាល័យ នៅកម្ពុជាកំពុងជួបប្រទះនូវការលំបាកក្នុងការបំពេញតាមតម្រូវការទាំងនេះ។ ចំពោះយុវជននៅតាមតំបន់ជនបទ និងដាច់ស្រយាលដែលបានបោះបង់ចោលការសិក្សា គឺរឹតតែមានជំនាញតិចតួច ដោយសារសេវាកម្មអប់រំក្នុងខេត្តមានភាពខ្សត់ខ្សោយជាងទីក្រុង និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ក៏មិនគ្រប់គ្រាន់។ ក្នុងពេលដែលវិស័យការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ កំពុងតែដោះស្រាយ និងកែសម្រួល នាពេលបច្ចុប្បន្ន វានឹងមិនអាចស្រូបយកអ្នកបោះបង់ការសិក្សាអស់ទាំងនោះបាននោះទេ។ ការយល់ដឹងរបស់យុវជន ស្តីពីបញ្ហាសេដ្ឋកិច្ចសង្គម និងនយោបាយ មានកម្រិតខ្ពស់សម្រាប់ប្រជាជនក្នុងក្រុង និងទីរួមខេត្ត ហើយវាមានកម្រិតទាប សម្រាប់តំបន់ជនបទ និងដាច់ស្រយាល និងតំបន់ជនជាតិដើមភាគតិច យោងតាមលទ្ធផលនៃការស្រាវជ្រាវថ្នាក់ជាតិពីតម្រូវការរបស់យុវជននៅឆ្នាំ២០១៥កន្លងមកនេះបានបង្ហាញថា ជាទូទៅយុវជនមានការយល់ដឹងខ្ពស់អំពីស្ថានភាពសេដ្ឋកិច្ចសង្គម និងនយោបាយនាពេលបច្ចុប្បន្ន ទោះបីជាសមត្ថភាពនៃការវិភាគបញ្ហាក្នុងចំណោមយុវជននៅតំបន់ជនបទ មានកម្រិតទាបជាងយុវជននៅទីប្រជុំជនក៏ដោយ។ កង្វះការផ្សាភ្ជាប់ទំនាក់ទំនងជាមួយបណ្តាញសង្គមធំៗ ការមិនទទួលបានព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយនានា និងគុណភាពនៃការអប់រំមានកម្រិតផងនោះ ជាហេតុធ្វើឱ្យយុវជននៅតំបន់ជនបទខ្វះព័ត៌មានដើម្បីជំរុញឱ្យពួកគេចូលរួមនៅក្នុងសកម្មភាពសង្គម។ កង្វះការងារធ្វើ ប្រាក់ខែតិច កង្វះសុវត្ថិភាពក្នុងសង្គម គុណភាពអប់រំមានកម្រិត គឺជាបញ្ហាគន្លឹះដែលយុវជននៅទីប្រជុំជនបានលើកឡើង។ គួរកត់សម្គាល់ថា បញ្ហាសុវត្ថិភាពសង្គម ត្រូវបានលើកឡើងដោយយុវជនជាច្រើននៅទីប្រជុំជន ប៉ុន្តែយុវជននៅតំបន់ជនបទវិញ ស្ទើរតែមិនបានលើកឡើងសោះឡើយ។

ការលើកឡើងរបស់យុវជននៅទីប្រជុំជន ក៏ខុសគ្នាពីយុវជននៅតំបន់ជនបទទៅលើបញ្ហាមួយចំនួនទៀត។ ឧទាហរណ៍ យុវជននៅទីប្រជុំជនបានចាត់ទុកថា បញ្ហាគ្មានការងារធ្វើ ប្រាក់ខែទាប ខ្វះជំនាញដែលស្របតាមតម្រូវការទីផ្សារ គឺជាបញ្ហាសំខាន់ រីឯយុវជននៅតំបន់ជនបទវិញ បង្ហាញនូវបញ្ហាប្លែកគ្នាបន្តិច ដោយគេបានលើកឡើងអំពីគុណភាពនៃការអប់រំមានកម្រិតទាប ការប្រើប្រាស់គ្រឿងញៀន និងចំណាកស្រុក គឺជាបញ្ហាគន្លឹះ ដែលជះឥទ្ធិពលដល់ជីវិតយុវជននៅ

តំបន់ជនបទ។ បញ្ហាសំខាន់មួយទៀតដែលយុវជនបានលើកឡើងគឺការខ្វះឱកាសការងារសមស្របបន្ទាប់ពីពួកគេបានបញ្ចប់ការសិក្សាពីមធ្យមសិក្សា ឬមហាវិទ្យាល័យ ដែលបញ្ហានេះត្រូវបានលើកឡើងដោយយុវជនស្ទើរតែទាំងអស់ ដែលបានចូលរួមក្នុងការសម្ភាសន៍ជាក្រុម។ ពួកគេបានរៀបរាប់បន្ថែមថា ដោយសារកង្វះខាតការងារ និងខ្វះជំនាញ យុវជនជាច្រើនបានសម្រេចចិត្តចេញទៅប្រកបការងារនៅទីប្រជុំជន ឬក៏ទៅក្រៅប្រទេស។

ព្រមជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាក៏បានអនុវត្តគោលនយោបាយអាទិភាពជាច្រើនដែលជាដំណោះស្រាយដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា ដែលអង្គភាពនៅក្រោមឱវាទក្រសួងកំពុងជួបប្រទះ។ ដោយយុទ្ធសាស្ត្រ និងគោលនយោបាយទាំងងស់នោះមានដូចជា ៖ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ គោលនយោបាយជាតិស្តីពីមុខរបរនិងការងារការបន្តការអភិវឌ្ឍធនធានមនុស្សលើផ្នែកបច្ចេកទេស ការបន្តអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារឲ្យកាន់តែល្អ ការពង្រីកការផ្តល់សេវាការរកការងារ ការបន្តលើកកម្ពស់លក្ខខណ្ឌការងារឲ្យកាន់តែប្រសើរឡើង ការពង្រីកភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈរវាងកម្មករនិយោជិត និងនិយោជក ធានាលើកកម្ពស់លកខខណ្ឌការងារឲ្យកាន់តែល្អ ធ្វើសហការប្រតិបត្តិជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងគោលដៅធានាឲ្យមានការអនុវត្តច្បាប់កាន់តែប្រសើរ បង្កើតបរិយាកាសការងារ និងបង្កើនកាលានុវត្តការងារ ពង្រឹងភាពសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ លើកកម្ពស់ការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារប្រកបដោយគុណភាព និងប្រសិទ្ធភាព ពង្រឹងនិងពង្រីកសេវាអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈប្រកបដោយសមធម៌ ធានានិរន្តភាពនៃការអប់រំអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ រួមទាំងការសហការជាមួយនឹងក្រសួងការងារ និងអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីជំនះនូវរាល់បញ្ហាប្រឈម និងឧបសគ្គទាំងឡាយ ឈានទៅរកការអនុវត្តប្រកបដោយជោគជ័យ និងទទួលបាននូវសមិទ្ធផលគួរជាទីមោទនៈ។

# អនុសាសន៍

ឆ្លងតាមការស្រាវជ្រាវតាមរយៈការលើកឡើងអំពីបញ្ហាប្រឈម និងសេចក្តីសន្និដ្ឋានខាងលើរួចមក យើងខ្ញុំសូមចូលរួមចំណែកនៅក្នុងការផ្តល់ជាសំណូមពរសំខាន់ៗមួយចំនួនទៅដល់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្តល់នូវអនុសាសន៍នៅក្នុងការរួមចំណែកការអភិវឌ្ឍធនធានមនុស្ស និងភាពមានការងារធ្វើរបស់យុវជននៅកម្ពុជាកាន់តែមានភាពឆ្លើយតមទៅនឹងគោលនយោបាយរបស់រដ្ឋាភិបាល ដើម្បីបង្កើននូវការអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែមានភាពរីកចម្រើនទៅមុខនោះព្រោះយុវជនជាអ្នកបន្តវេន និងជាមនុស្សដែលមានសក្តានុពល យើងខ្ញុំមានសំណូមពរដូចជា ៖

- សូមសំណូមពរឱ្យក្រសួងអប់រំ យុវជន និងកីឡា បន្តដំណើរការនៃផែនការអភិវឌ្ឍន៍យុវជនដើម្បីការអប់រំរបស់នៅកម្ពុជាអោយកាន់តែមានភាពរីវត្តន៍ទៅមុខបន្ថែមទៀត តាមរយៈការបង្កើនគុណភាពអប់រំដើម្បីឱ្យមានការឆ្លើយតប ទៅនឹងការប្រកួតប្រជែងជាមួយនឹងធនធាននៃសមាហរណកម្មអាស៊ានកាន់តែឆាប់កាន់តែល្អ។
- សូមសំណូមពរឱ្យក្រសួងធ្វើការពង្រឹងទៅលើគុណភាពអប់រំនៅកម្ពុជា ឱ្យកាន់តែមានភាពប្រសើរឡើងតាមរយៈការ ការផ្តល់ឪកាសឲ្យយុវជនបានចូលរួមកម្មវិធីផ្សេងៗ ដូចជាការអនុវត្ត និងធ្វើការយកចិត្តទុកដាក់បន្ថែមទៀត គោលសិក្សាឱ្យសមស្របតាមតម្រូវការជាក់ស្តែង។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បន្តយកចិត្តទុកដាក់លើការបណ្តុះបណ្តាល ក៏ដូចជាផ្តល់ឪកាសដល់យុវជនក្នុងការចូលរួមវគ្គបណ្តុះបណ្តាល់តម្រង់ទិសពាក់ព័ន្ធ នឹងឪកាសការងារ និងស្តីពីការជ្រើរើសការងារសមស្រប់។
- សំណូមពរឱ្យក្រសួងអប់រំ យុវជននិងកីឡានិងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើការលើកទឹកចិត្ត និងយកចិត្តទុកដាក់បំផុតទៅលើភាគីពាក់ព័ន្ធនានារបស់វិស័យអបើរំ និងការងារក៏ដូចជា ដៃគូរឯកជន អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍នានាជាដើមដើម្បីរួមគ្នាអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាអោយកាន់តែមានភាពរិកចម្រើន។

# ឯកសារយោង

## ១.លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៣)
- ច្បាប់ស្តីពីការងារ (១៩៩៧)
- ច្បាប់ស្តីពីមុខរបរ និងការងារកម្ពុជា បោះពុម្ពផ្សាយឡើងវិញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩
- ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨
- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា (បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនា ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១១)
- គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥
- ច្បាប់ និងសេចក្តីអត្ថាធិប្បាយ (ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងដំណើរការដោះស្រាយវិវាទការងារនៅកម្ពុជា) បោះពុម្ពផ្សាយលើកទី៣
- ប្រកាសលេខ ២៨៨ សកបយ. ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពី"សេចក្តីប្រកាសជូនដំណឹងបើក និងបិទសហគ្រាស គ្រឹះស្ថាន"
- ប្រកាសលេខ ០០៤ សកបយ. ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០០ ស្តីពី"ការហ្វឹកហ្វឺនកូនជាង"
- ប្រកាសលេខ ២៦៨ សកបយ. ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០០ ស្តីពី"ការផ្តល់វិញ្ញាបនបត្រអនុវត្តច្បាប់ស្តីពីការងារចំពោះសហគ្រាស គ្រឹះស្ថាន"
- សេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកលេខ ៦០
- សេចក្តីណែនាំពីលេខ ២៦ សកបយ. ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០០  ស្តីពីការផ្តល់ដំណឹងអំពីកន្លែងធ្វើការទំនេរ
- សេចក្តីណែនាំពីលេខ ២៨ សកបយ. ចុះឆ្នាំ២០០១  ស្តីពីការដាក់ពាក្យសុំរកការងារធ្វើ
- សេចក្តីប្រកាស ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង

## ២.សៀវភៅមេរៀន

- នីតិការងារ (ឯកសារមេរៀន លោកសាស្ត្រាចារ្យ ស៊ីវ យាង)
- នីតិការងារ ២០១៤ (ឯកសារមេរៀន អ្នកស្រីសាស្ត្រាចារ្យ ប៊ូយ ធីតា)
- នីតិមុខងារសាធារណៈ (លោកសាស្ត្រាចារ្យអនុបណ្ឌិត ហៀងសាង)
- វិធីសាស្ត្រស្រាវជ្រាវ (ឯកសារមេរៀន សាស្ត្រាចារ្យ ទូរ សុខុម៉ា)

## ៣.កម្រងទស្សនសង្គម និងការវិភាគបញ្ហា

- ការវិភាគលើបញ្ហាត្រូវដោះស្រាយនៅកម្ពុជា ភាគ១ (ដោយលោក កែវ នរិន្ទ សាស្ត្រាចារ្យបណ្ឌិតសេដ្ឋកិច្ច)
- កម្រងទស្សនសង្គម និងនយោបាយ ឆ្នាំ២០១៦ (បណ្ឌិត កែម ឡី)

## ៤.របាយការណ៍

- របាយការណ៍សារណាបញ្ចប់ឆ្នាំសិក្សា ស្តីពី"ការត្រៀមខ្លួនរបស់យុវជនកម្ពុយជាក្នុងសមាហរណកម្មអាស៊ាន" ស្រាវជ្រាវដោយនិស្សិតឈ្មោះ លឹម មីលី ឆ្នាំ២០១៥
- របាយការណ៍សារណាបញ្ចប់ឆ្នាំសិក្សា ស្តីពី"ទំនាក់ទំនងគតិយុត្តក្នុងវិស័យការងារនៅកម្ពុជា" ស្រាវជ្រាវដោយនិស្សិត យ៉េ រ៉ាណេត និង និស្សិត សេង កញ្ញារិទ្ធ
- របាយការណ៍លទ្ធផលការងារឆ្នាំ២០១៤ និងទិសដៅការងារការអនុវត្តឆ្នាំ២០១៥
- របាយការណ៍លទ្ធផលការងារឆ្នាំ២០១៥ និងទិសដៅការងារអនុវត្តន៍ឆ្នាំ២០១៦នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨
- របាយកាណ៍លទ្ធផលស្តីពីកិច្ចសន្ទនាយុវជន "យុវជន និងការអប់រំ" ដោយសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ "YCUD" ឆ្នាំ២០១៧
- របាយកាណ៍លទ្ធផលស្តីពីកិច្ចសន្ទនាយុវជន "បញ្ហាអាទិភាពរបស់យុវជន" ដោយសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ "YCUD" ឆ្នាំ២០១៧

## ៥.សុន្ទរកថា

- សុន្ទរកថា ឯកឧត្តម តូច ជឿន អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីអភិវឌ្ឍយុវជន និងជាអគ្គនាយយុវជន ក្រសួងអប់រំ យុវជន និងកីឡា ក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការអនុវត្ត និងការចូលរួមរបស់យុវជនក្នុងផែនការសកម្មភាពជាតិស្តីពី ការអភិវឌ្ឍយុវជនកម្ពុជា ២០១៦-២០១៨

## ៦.គេហទំព័រផ្សេងៗ

- អត្ថបទចុះផ្សាយថ្ងៃទី២ខែមិថុនាឆ្នាំ២០១៥ ដោយវេបសាយព័ត៌មានថ្មីថ្មី តើសិស្សប្រាជ័យក្នុងការសិក្សាបណ្តាលមកពីកត្តាអ្វីខ្លះ?
- អត្ថបទចុះផ្សាយថ្ងៃសុក្រ ទី២៦ខែតុលាឆ្នាំ២០១២ ដោយវេបសាយព័ត៌មានខ្មែរឡូត "តើត្រឹមត្រូវទេដែលយុវវ័យគិតថាការងារស្ម័គ្រចិត្តជាការងារឥតប្រយោជន៍?"
- ការវិភាគបញ្ហាសង្គម ដោយវេបសាយ សាកល្បងវិភាគបញ្ហាសង្គមសេដ្ឋកិច្ចកម្ពុជា គំនិតយុវជនស្តីពីបញ្ហាសង្គម និងការអភិវឌ្ឍ អត្ថបទ យុវជន និងនយោបាយ ចុះផ្សាយថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាល

# គោលនយោបាយជាតិ
# ស្តីពី
# ការអភិវឌ្ឍយុវជនកម្ពុជា

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១

*រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាល

# គោលនយោបាយជាតិ
# ស្តីពី
# ការអភិវឌ្ឍយុវជនកម្ពុជា

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១
*រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា*

## មាតិកា


១- សេចក្តីផ្តើម .................... ១

២- ចក្ខុវិស័យ .................... ២

៣- គោលបំណង .................... ២

៤- គោលដៅ .................... ២

៥- យុទ្ធសាស្ត្រ .................... ៣

៥.១- អភិវឌ្ឍក្របខ័ណ្ឌច្បាប់និងយន្តការ .................... ៣

៥.២- លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព .................... ៣

៥.៣-បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព .................... ៤

៥.៤- បណ្តុះស្មារតីសហគ្រិនភាព និងទីផ្សារការងារ .................... ៤

៥.៥- លើកកម្ពស់កិច្ចការពារ សុវត្ថិភាព សន្តិសុខ និងយុត្តិធម៌ .................... ៥

៥.៦- បង្កើនការចូលរួមរបស់យុវជន .................... ៦

៥.៧-លើកកម្ពស់ការសម្រាក ការកម្សាន្ត និងកីឡា .................... ៦

៥.៨- លើកកម្ពស់សិល្បៈនិងវប្បធម៌ .................... ៧

៥.៩- លើកកម្ពស់ការយល់ដឹងពីបរិស្ថាន កសិកម្ម ទេសចរណ៍ និងធុរកិច្ច .................... ៧

៥.១០-បង្កើនការងារស្ម័គ្រចិត្ត .................... ៧

៥.១១-លើកកម្ពស់សមភាពយេនឌ័រ .................... ៨

៥.១២-ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀននិងស្តារយុវនីតិសម្បទា .................... ៨

៦- ផែនការសកម្មភាព .................... ៩

៦.១-ការបង្កើតយន្តការ .................... ៩

៦.២-ការបង្កើតក្របខ័ណ្ឌគតិយុត្ត .................... ១០

៦.៣-ការគាំទ្រហិរញ្ញវត្ថុ .................... ១០

៦.៤-ការបណ្តុះបណ្តាលធនធានមនុស្ស .................... ១០

៦.៥-ដំណើរការអនុវត្តគម្រោង .................... ១០

៧- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ .................... ១១

៨- សេចក្តីសន្និដ្ឋាន .................... ១១

# ១-សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជាចាត់ទុកយុវជនជាធនធានគន្លឹះនិងមានតម្លៃបំផុតសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ បរិស្ថាន និងការរក្សាសន្តិភាព ទាំងបច្ចុប្បន្ន ទាំងអនាគត។

នៅក្នុងបរិបទសង្គម វប្បធម៌ និងនយោបាយរបស់កម្ពុជា "យុវជន" ជាបុរសនិងស្ត្រីដែលមានសញ្ជាតិខ្មែរពីអាយុ១៥ដល់៣០ឆ្នាំ នៅលីវឬរៀបការហើយ។ យោងតាមជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ យុវជនមាន៣៣ភាគរយនៃចំនួនប្រជារាស្ត្រសរុប។

រាជរដ្ឋាភិបាលបានកំណត់ថា ការអប់រំគឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចមួយប្រកបដោយចីរភាព ឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ។ ក្នុងឆ្នាំសិក្សា២០១០-២០១១ អត្រាពិតនៃការសិក្សានៅបឋមសិក្សាមាន ៩៦,១ភាគរយ មធ្យមសិក្សាបឋមភូមិមាន៣៣,៩ភាគរយ មធ្យមសិក្សាទុតិយភូមិមាន២០,៨ភាគរយ ចំនួនអក្ខរជនសរុប(អាយុ១៥-២៤ឆ្នាំ)មាន៨៧,៥ភាគរយ(ជំរឿនទូទៅនូវប្រជារាស្ត្រឆ្នាំ២០០៨) និងនិស្សិតនៅឧត្តមសិក្សាមាន ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតមាន២៦៣ ០០០នាក់(យោងតាមរបាយការណ៍បូកសរុបឆ្នាំសិក្សា ២០០៩-២០១០ របស់ក្រសួងអប់រំ យុវជន និងកីឡា)។

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើយុវជនដែលជាសសរទ្រូងប្រទេសជាតិដោយផ្តល់ការសិក្សាប្រកបដោយគុណភាព និងមានសមត្ថភាពអាចឈានចូលទៅក្នុងទីផ្សារការងារដោយងាយស្រួល។ ក្នុងនោះ ក៏នៅមានយុវជនមួយចំនួនពុំទាន់មានឱកាសទទួលបានការងារសមស្របនៅឡើយ។ រីឯយុវជនដែលមានចំណេះដឹងតិចតួច បានទទួលកម្រៃទាប ក្នុងនោះ ស្ត្រីមិនសូវទទួលបានការងារធ្វើដោយកម្រៃខ្ពស់នៅឡើយ។ យុវជនមួយចំនួនទៀតបានធ្វើចំណាកស្រុកទៅកាន់ទីក្រុង ទីប្រជុំជននានា និងក្រៅប្រទេសដើម្បីស្វែងរកឱកាសក្នុងការរកប្រាក់ចំណូល។ លើសពីនេះពួកគេបានប្រឈមនឹងការលំបាកឬធ្លាក់ចូលក្នុងស្ថានភាពងាយរងគ្រោះ ដែលរួមមានការបោះបង់ការសិក្សា ការបាត់បង់ជម្រើសរបស់ខ្លួន ការសេពគ្រឿងញៀន ការសេពគ្រឿងស្រវឹង និងគ្រោះថ្នាក់នៅតាមកន្លែងធ្វើការ។ល។

ដើម្បីលើកកម្ពស់សិទ្ធិនិងការទទួលខុសត្រូវរបស់យុវជនដែលជាកម្លាំងសកម្មរបស់ប្រទេសជាតិ ព្រមទាំងទប់ស្កាត់និងកាត់បន្ថយនូវភាពអសកម្មខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន សំដៅផ្តល់ឱកាសឲ្យយុវជនគ្រប់រូបអភិវឌ្ឍសមត្ថភាពប្រកបដោយឆន្ទៈ សេចក្តីព្យាយាមនិងមនសិការវិជ្ជាជីវៈ។

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា រៀបចំឡើងអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំ ច្បាប់ស្តីពីការងារ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងឯកសារអន្តរជាតិពាក់ព័ន្ធនានា ដើម្បីអភិវឌ្ឍយុវជនស្របតាមបរិបទកម្ពុជា។

## ២-ចក្ខុវិស័យ

ដើម្បីធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាមានធនធានមនុស្សសម្រាប់ការអភិវឌ្ឍប្រទេសជាតិ រាជរដ្ឋាភិបាលមានចក្ខុវិស័យរយៈពេលវែងដោយប្រមូលផ្តុំកម្លាំងគ្រប់មជ្ឈដ្ឋានក្នុងសង្គមជាតិ សំដៅរួមចំណែកអភិវឌ្ឍយុវជនឲ្យកាន់តែមានលក្ខណសម្បត្តិវិជ្ជមាន និងផ្តល់ឱកាសឲ្យពួកគេអភិវឌ្ឍសក្តានុពលនៅក្នុងការអប់រំ ការងារ សុខភាព ការចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងការចូលរួមចំណែកអភិវឌ្ឍគ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

## ៣-គោលបំណង

អភិវឌ្ឍយុវជនឲ្យមានបុគ្គលិកលក្ខណៈពេញលេញលើផ្នែករាងកាយ បញ្ញា ស្មារតី សីលធម៌ តម្លៃ និងបំណិន ដើម្បីឲ្យយុវជនក្លាយជាពលរដ្ឋល្អក្នុងសង្គមជាតិ។

## ៤-គោលដៅ

៤.១. ផ្តល់ឱកាសឲ្យយុវជនទទួលបានការអប់រំនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប្រកបដោយគុណភាពនិងសមធម៌។

៤.២. លើកទឹកចិត្តយុវជនឲ្យមានគំនិតផ្តួចផ្តើម គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព។

៤.៣. លើកកម្ពស់យេនឌ័រប្រកបដោយសមធម៌និងសមភាពដល់យុវជនទាំងពីរភេទ ពិសេសផ្តល់ឱកាសនិងសិទ្ធិអំណាចដល់ស្ត្រី។

៤.៤. អភិវឌ្ឍយុវជនឲ្យមានកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ ចេះរួមរស់ជាមួយគ្នាដោយសន្តិភាពនិងសុខដុម ព្រមទាំងមានស្មារតីស្នេហាជាតិ ស្នេហាប្រជាជន ប្រកបដោយជំនឿជាក់លើខ្លួនឯង សេចក្តីថ្លៃថ្នូរ ភាពជាអ្នកដឹកនាំ និងលើកកម្ពស់ការយល់ដឹងទូលំទូលាយអំពីសង្គម។

៤.៥. បង្កឱកាសឲ្យយុវជនបានចូលរួមបញ្ចេញមតិ ទស្សនៈ និងធ្វើសេចក្តីសម្រេចចិត្តនានាក្នុងការអភិវឌ្ឍសហគមន៍និងសង្គមជាតិ។

៤.៦. ប្រមូលផ្តុំកម្លាំងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល សហគមន៍ មាតាបិតាឬអ្នកអាណាព្យាបាល ដើម្បីអភិវឌ្ឍយុវជនកម្ពុជា។

## ៥-យុទ្ធសាស្ត្រ

ដើម្បីសម្រេចគោលបំណងនិងគោលដៅខាងលើ យុទ្ធសាស្ត្រសំខាន់ៗមានដូចខាងក្រោម៖

### *៥.១- អភិវឌ្ឍក្របខ័ណ្ឌច្បាប់និងយន្តការ*

- រៀបចំលិខិតបទដ្ឋាននិងយន្តការនានា ដើម្បីគាំទ្រនិងអនុវត្តគោលនយោបាយឲ្យមានប្រសិទ្ធភាព ដោយកំណត់ឲ្យមានកិច្ចសហការនិងភារកិច្ចរបស់ភាគីពាក់ព័ន្ធសំខាន់ៗ
- ធ្វើឲ្យប្រសើរឡើងនិងពន្លឿនការអនុវត្តគោលនយោបាយជាតិ ក្របខ័ណ្ឌច្បាប់យន្តការពាក់ព័ន្ធនានាដែលមានស្រាប់និងយន្តការថ្មីៗ
- កសាងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានិងកម្មវិធីនានា ដោយមានសកម្មភាពជាក់លាក់ ពេលវេលា ធនធាន និងក្រសួង ស្ថាប័នទទួលខុសត្រូវ។

### *៥.២ - លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព*

- ជំរុញនិងលើកទឹកចិត្តយុវជនឲ្យទទួលបាននូវការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈសមស្រប ជាពិសេស យុវជនដែលពុំសូវមានឱកាសនិងយុវជនដែលងាយរងគ្រោះ ក្នុងនោះយុវជនពិការ
- ជំរុញកម្មវិធីបំណិនជីវិតដែលឆ្លើយតបទៅនឹងតម្រូវការជីវភាពរស់នៅរបស់យុវជននិងទីផ្សារពលកម្ម
- ចូលរួមលើកកម្ពស់គុណភាពអប់រំបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងភាសាបរទេសនៅគ្រប់ភូមិសិក្សានៃប្រព័ន្ធអប់រំកម្ពុជាឲ្យស្របតាមតម្រូវការរបស់សង្គមជាតិ និងស្របតាមស្តង់ដាតំបន់និងអន្តរជាតិ
- បង្កឱកាសដល់យុវជនកម្ពុជាទាំងអស់ឲ្យទទួលបាននិងបញ្ចប់ការសិក្សាយ៉ាងហោចណាស់ត្រឹមការអប់រំកម្រិតមូលដ្ឋាន និងបង្កើនអត្រាគង់វង្សនៅគ្រប់ភូមិសិក្សានៃប្រព័ន្ធអប់រំ
- អភិវឌ្ឍមជ្ឈមណ្ឌលយុវជននិងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំរុញលើកទឹកចិត្តយុវជនឲ្យចូលរួមយ៉ាងសកម្មក្នុងការសិក្សានិងការបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមសហគមន៍របស់ខ្លួន

- ជំរុញគ្រឹះស្ថានសិក្សានិងបណ្តុះបណ្តាលវិជ្ជាជីវៈ សហគ្រាសសាធារណៈនិងឯកជន និងអាជ្ញាធរពាក់ព័ន្ធ ចូលរួមលើកទឹកចិត្ត និងផ្តល់ឱកាសឲ្យយុវជនចូលរួមក្នុងសកម្មភាពផ្សេងៗ
- ជំរុញការបណ្តុះបណ្តាលសហគ្រិនភាពដល់យុវជនដោយផ្សារភ្ជាប់ទៅនឹងឱកាសធ្វើជំនួញខ្នាតតូច មធ្យម និងធំ ឲ្យយុវជនចាប់ផ្តើមនិងពង្រីកមុខជំនួញ។

## ៩.៣ - បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព

- អភិវឌ្ឍនិងពង្រីកការអប់រំសុខភាព និងបង្កើនលទ្ធភាពទទួលបានព័ត៌មានអំពីការអប់រំ និងការបង្ការបញ្ហាមួយចំនួនដូចជា ផ្នែកសុខភាព សុខភាពបន្តពូជ គ្រោះថ្នាក់ចរាចរណ៍ និងគ្រោះថ្នាក់នៅកន្លែងធ្វើការ បញ្ហាអនាម័យនិងការប្រើប្រាស់ទឹកស្អាត សុខភាពផ្លូវចិត្ត ការធ្វើអត្តឃាត និងការទប់ស្កាត់រាល់អំពើហិង្សា
- បង្កើតយន្តការដោយមានយុវជនចូលរួមក្នុងសកម្មភាពអប់រំសុខភាព និងកម្មវិធីចុះដល់សហគមន៍ ដែលជាប្រយោជន៍ដល់យុវជន
- បង្កើនការទទួលសេវាសុខភាពដល់យុវជនប្រកបដោយភាពងាយស្រួល និងមានគុណភាព រួមទាំងសេវាសុខភាពផ្លូវកាយ ផ្លូវចិត្ត សេវាសង្គម ចំពោះយុវជនដែលជាអ្នករងគ្រោះពីអំពើហិង្សា ការជួញដូរ និងការកេងប្រវញ្ចផ្លូវភេទ
- ពង្រឹងបណ្តាញសុវត្ថិភាពផ្នែកសង្គម ធានាឲ្យយុវជនដែលក្រីក្របំផុតទទួលបានសេវាសុខភាព និងបន្តផ្តល់អាទិភាពលើអន្តរាគមន៍ផ្នែកការបង្ការ ការព្យាបាល និងការថែទាំចំពោះក្រុមយុវជនមុខសញ្ញាដែលងាយរងគ្រោះ
- អប់រំ គាំពារ និងថែរក្សាសុខភាពយុវតីមានគភ៌មុនវ័យរៀបការប្រកបដោយគុណភាពពីសំណាក់អ្នកផ្តល់សេវាសុខភាពដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធនិងសហគមន៍
- បង្កើនទំនាក់ទំនងជាមួយនឹងមាតាបិតាឬអ្នកអាណាព្យាបាល និងអ្នកប្រឹក្សាពីការផ្តល់សេវាសុខភាព ឥរិយាបថ និងការប្រព្រឹត្តខាងផ្លូវភេទ។

## ៩.៤ -បណ្តុះស្មារតីសហគ្រិនភាពនិងទីផ្សារការងារ

- ជំរុញកិច្ចសហការរវាងក្រសួង ស្ថាប័នសាធារណៈនិងផ្នែកឯកជននានា ដោយធ្វើឲ្យប្រសើរឡើងនូវបរិយាកាសទីផ្សារការងារនិងសហគ្រិនភាពសម្រាប់យុវជន ពិសេសយុវជនដែលបានកំណត់នៅក្នុងក្រុមគោលដៅអាទិភាព និងពង្រឹងភាពជាដៃគូជាមួយយុវជនក្នុងការអប់រំ បណ្តុះបណ្តាល ដើម្បីងាយស្រួលឈានទៅរកទីផ្សារការងារ

- លើកកម្ពស់ការបណ្តុះបណ្តាលជំនាញអាជីព ជំនាញប្រកបរបរចិញ្ចឹមជីវិត និងសម្របសម្រួលឲ្យអ្នកស្វែងរកការងារទទួលបានព័ត៌មានអំពីការងារ
- បង្កើតផែនការចម្រុះសម្រាប់តាមដាននិងឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ
- លើកកម្ពស់ការពារយុវជនពីការកេងប្រវ័ញ្ចការងារនិងប្រាក់ចំណូល សុវត្ថិភាពនៅកន្លែងធ្វើការ និងការគាំពារផ្នែកសង្គមសម្រាប់គ្រួសារ
- ផ្តល់ឱកាសសមស្របដល់យុវជនសម្រាប់ការអភិវឌ្ឍផ្ទាល់ខ្លួននិងទទួលបានការយកចិត្តទុកដាក់ស្មើភាពគ្នា និងសេរីភាពក្នុងការសម្តែងអំពីកង្វល់របស់ខ្លួន ការចាត់ចែង និងចូលរួមនៅក្នុងសេចក្តីសម្រេចចិត្តដែលមានឥទ្ធិពលដល់ជីវិតរបស់គេ
- ជំរុញការគាំទ្រយុវជនឲ្យមានស្មារតីសហគ្រិនភាពក្នុងការចាប់ផ្តើមនិងគ្រប់គ្រងអាជីវកម្មផ្ទាល់ខ្លួន និងផ្តល់សេវាគាំទ្រដល់យុវជនក្នុងមុខជំនួញឲ្យកាន់តែប្រសើរនិងមានការយល់ដឹងពីការប្រកួតប្រជែងក្នុងទីផ្សារ
- ជំរុញនិងផ្តល់ឱកាសឲ្យយុវជនធ្វើជំនួញខ្នាតតូច មធ្យម និងខ្នាតធំ និងផ្តល់ឥណទានក្នុងការចាប់ផ្តើមនិងពង្រីកមុខជំនួញ។

*៥.៥- លើកកម្ពស់កិច្ចការពារ សុវត្ថិភាព សន្តិសុខ និងយុត្តិធម៌*

- ជំរុញកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធទាំងអស់នៅក្នុងកិច្ចការពារយុត្តិធម៌សម្រាប់យុវជន និងដោះស្រាយបញ្ហាយុវជន
- លើកកម្ពស់ការយល់ដឹងរបស់យុវជនអំពីច្បាប់ សិទ្ធិ ផលប្រយោជន៍ កាតព្វកិច្ច រចនាសម្ព័ន្ធ និងការទទួលខុសត្រូវរបស់ខ្លួន និងផ្តល់មធ្យោបាយពិគ្រោះយោបល់ឆ្លើយតបជាមួយបញ្ហាប្រឈមនានា
- បង្កើតនិងអនុវត្តកិច្ចផ្តួចផ្តើមនៅថ្នាក់ឃុំ សង្កាត់ ដើម្បីទប់ស្កាត់បទល្មើសព្រហ្មទណ្ឌដែលអាចកើតមានឡើងនៅក្នុងមជ្ឈដ្ឋានយុវជន
- ចូលរួមកែលម្អប្រព័ន្ធយុត្តិធម៌ និងវិធានការស្តារនីតិសម្បទាយុវជនដែលបានប្រព្រឹត្តបទល្មើស កែលម្អលក្ខខណ្ឌក្នុងពន្ធនាគារ ការយកចិត្តទុកដាក់ និងការស្តារនីតិសម្បទាយុវជនដែលជាអ្នកទោសក្នុងពន្ធនាគារ ស្វែងរក និងជំរុញឲ្យមានការប្រើប្រាស់ជម្រើសជំនួសការឃុំឃាំង
- សម្របសម្រួលទំនាក់ទំនងរបស់មាតាបិតាឬអ្នកអាណាព្យាបាលនិងសមត្ថកិច្ចក្នុងប្រព័ន្ធយុត្តិធម៌ ដើម្បីទប់ស្កាត់អំពើហិង្សា បទល្មើសព្រហ្មទណ្ឌ និងការប្រឈមនឹងគ្រោះថ្នាក់របស់យុវជន។

### *៥.៦- បង្កើនការចូលរួមរបស់យុវជន*

- បង្កលក្ខណៈងាយស្រួលឲ្យយុវជនចូលរួមបានពេញលេញក្នុងសហគមន៍ មូលដ្ឋាន និងស្ថាប័ននានា
- ជំរុញយន្តការជាផ្លូវការឲ្យយុវជនចូលរួមប្រកបដោយប្រសិទ្ធភាពជាមួយសង្គមស៊ីវិល
- ជំរុញឲ្យមានតំណាងយុវជននៅក្នុងគណៈកម្មការឬក្រុមប្រឹក្សាថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងតំបន់ និងធានាការធ្វើសមាហរណកម្មរបស់ពួកគេទៅក្នុងដំណើរការរៀបចំផែនការ និងវិសហមជ្ឈការ
- ទាក់ទាញការគាំទ្រនិងការយកចិត្តទុកដាក់ពីអ្នកគាក់តែងគោលនយោបាយ អ្នករៀបចំកម្មវិធី អ្នកផ្តល់សេវានានា និងអ្នកដឹកនាំឲ្យទទួលស្គាល់សមត្ថភាពនិងគោរពសិទ្ធិរបស់យុវជន ក្នុងការចូលរួមដោយបញ្ចេញរាល់គំនិតផ្តួចផ្តើមដើម្បីអភិវឌ្ឍសហគមន៍ និងប្រទេសជាតិ
- រៀបចំកម្មវិធីឲ្យយុវជនចេះប្រមូល ពិភាក្សា វិភាគ ចែកចាយព័ត៌មាន និងមានសមត្ថភាពផលិតព័ត៌មានដែលមានលក្ខណៈសមស្របចំពោះយុវជន
- ជំរុញការចូលរួម ការសម្តែងមតិ និងការសម្រេចចិត្តរបស់យុវជននៅក្នុងវិស័យអប់រំ
- ទាក់ទាញការគាំទ្រឲ្យមានសំឡេងយុវជននៅក្នុងដំណើរការរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្តនានាដែលជាផលប្រយោជន៍របស់យុវជន។

### *៥.៧- លើកកម្ពស់ការសម្រាក ការកម្សាន្ត និងកីឡា*

- អភិវឌ្ឍនិងជំរុញឲ្យមានហេដ្ឋារចនាសម្ព័ន្ធកីឡា ពហុកីឡដ្ឋាន និងលើកស្ទួយការចូលរួមរបស់យុវជនក្នុងការបណ្តុះបណ្តាល និងកីឡាសម្រាប់សុខភាពរាងកាយនិងបញ្ញា និងដើម្បីឈានទៅពង្រឹងការប្រកួតកីឡាជាលក្ខណៈជាតិនិងអន្តរជាតិ
- លើកកម្ពស់ការយល់ដឹងពីតម្លៃកីឡា ការឧបត្ថម្ភគាំទ្ររបស់ឪពុកម្តាយ សហគមន៍ សាលារៀន ក្លឹប សហព័ន្ធកីឡា សប្បុរសជន អ្នកនយោបាយ និងការចូលរួមរបស់យុវជនក្នុងសកម្មភាពអប់រំកាយ ការលេង និងការប្រកួតកីឡា ដើម្បីអភិវឌ្ឍសកម្មភាពកីឡាគ្រប់ប្រភេទ
- លើកកម្ពស់ការចូលរួមកម្សាន្តសប្បាយជាបុគ្គល ជាក្រុម ជាក្លឹប ដែលមានលក្ខណៈថ្លៃថ្នូរ និងសម្បូរបែប (មានលក្ខណៈមិត្តភាពនិងការផ្លាស់ប្តូរវប្បធម៌)។

*៥.៨- លើកកម្ពស់សិល្បៈនិងវប្បធម៌*

- លើកកម្ពស់ការគោរពតម្លៃនៃចំណេះដឹងនិងការយល់ដឹងអំពីប្រពៃណីជាតិ ប្រវត្តិសាស្ត្រ ការគោរពសាសនា និងការថែរក្សាបេតិកភណ្ឌវប្បធម៌ជាតិ
- លើកកម្ពស់និងគាំទ្រដល់ការផ្តួចផ្តើមថ្មីៗខាងផ្នែកភ្លេង មហោស្រពគំនូរ ស្ថាបត្យកម្ម ភាពយន្ត អក្សរសាស្ត្រ និងទម្រង់ផ្សេងៗទៀតខាងសិល្បៈ
- លើកកម្ពស់ការអប់រំ ដោយផ្អែកលើគោលការណ៍ជាមូលដ្ឋាននៃសិល្បៈនិងវប្បធម៌ ការចូលរួមរបស់យុវជននៅក្នុងសកម្មភាពវប្បធម៌សហគមន៍និងសមិទ្ធផលខាងសិល្បៈ
- លើកកម្ពស់ឲ្យមានវិភាគទាន ការទទួលខុសត្រូវរួមក្នុងចំណោមស្ថាប័នសិល្បៈនិងវប្បធម៌ ការកៀរគរធនធានសម្រាប់ការចាត់ចែងបណ្តុះបណ្តាលយុវអ្នកនិពន្ធនិងយុវសិល្បករ និងជំរុញផលិតផលដែលមានភាពច្នៃប្រឌិត។

*៥.៩- លើកកម្ពស់ការយល់ដឹងពីបរិស្ថាន កសិកម្ម ទេសចរណ៍ និងធុរកិច្ច*

- លើកកម្ពស់ការយល់ដឹងរបស់យុវជនស្តីពីបរិស្ថាន ការថែរក្សា និងការយកចិត្តទុកដាក់ចំពោះបរិស្ថាន
- លើកកម្ពស់ការយល់ដឹងរបស់យុវជនរវាងការអភិវឌ្ឍនិងការថែរក្សាបរិស្ថានប្រកបដោយចីរភាព
- បង្កើនការផ្សព្វផ្សាយព័ត៌មានអំពីបរិស្ថាន កសិកម្ម និងទេសចរណ៍ តាមរយៈកម្មវិធីសិក្សានិងប្រព័ន្ធផ្សព្វផ្សាយ ដែលផ្តោតលើសកម្មភាពរបស់បុគ្គលនិងសមូហភាព
- លើកកម្ពស់ឲ្យមានសហប្រតិបត្តិការរវាងយុវជននិងគ្រឹះស្ថានជំនាញ ដើម្បីកែលម្អសមត្ថភាពរបស់យុវជនលើកិច្ចការពារនិងថែរក្សាបរិស្ថាន
- ជំរុញកិច្ចការពារបរិស្ថានធម្មជាតិនិងវប្បធម៌នៅគ្រប់ទីកន្លែង ជាពិសេសតំបន់ប្រាសាទ និងតំបន់ឆ្នេរ
- ចូលរួមចងក្រងឯកសារដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាពនិងការទទួលខុសត្រូវ
- លើកកម្ពស់ការយល់ដឹងរបស់យុវជនអំពីធុរកិច្ច និងវិស័យផ្សេងៗទៀត។

*៥.១០- បង្កើនការងារស្ម័គ្រចិត្ត*

- បង្កើនការយល់ដឹងអំពីសារៈសំខាន់និងអត្ថប្រយោជន៍នៃការងារស្ម័គ្រចិត្តដល់យុវជន និងអភិវឌ្ឍបណ្តាញស្ម័គ្រចិត្តពីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

- ជំរុញស្មារតីនិងចលនាស្ម័គ្រចិត្ត និងបញ្ជ្រាបទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងសកម្មភាពមនុស្សធម៌
- ជំរុញការទទួលស្គាល់ជាផ្លូវការ ឲ្យតម្លៃខ្ពស់ និងផ្តល់រង្វាន់លើកទឹកចិត្តចំពោះយុវជនដែលបានបំពេញការងារស្ម័គ្រចិត្ត
- គាំទ្ររាល់គំនិតផ្តួចផ្តើមរបស់អ្នកស្ម័គ្រចិត្តមូលដ្ឋាន អង្គការដែលពាក់ព័ន្ធនឹងការងារស្ម័គ្រចិត្ត និងគម្រោងរបស់ក្រុមយុវជនស្ម័គ្រចិត្ត
- បង្កើតយន្តការសម្របសម្រួលនិងបង្កើនកិច្ចសហប្រតិបត្តិការឲ្យមានប្រសិទ្ធភាពរវាងរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ និងវិស័យឯកជន ជួយយុវជនស្ម័គ្រចិត្ត។

*៥.១១- លើកកម្ពស់សមភាពយេនឌ័រ*

- លើកកម្ពស់និងអនុវត្តច្បាប់ គោលនយោបាយនិងក្របខ័ណ្ឌច្បាប់ដែលលើកកម្ពស់សមភាពយេនឌ័រនៅក្នុងគ្រប់ទិដ្ឋភាពនៃការរស់នៅ
- លើកទឹកចិត្តដល់សាធារណជន វិស័យឯកជន និងសង្គមស៊ីវិល ឲ្យយកចិត្តទុកដាក់ទៅលើបញ្ហាវិសមភាពយេនឌ័រនិងដោះស្រាយនូវបញ្ហាទាំងនោះ
- លើកកម្ពស់តួនាទីដឹកនាំនិងសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចដល់យុវតី នៅក្នុងគ្រួសារ សហគមន៍ និងសង្គម
- បញ្ជ្រាបយេនឌ័រនិងការវិភាគយ៉ាងលម្អិតអំពីបញ្ហាវិសមភាពយេនឌ័រនៅក្នុងគ្រប់ផែនការសកម្មភាពទាំងអស់នៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន និងបង្កើនចំណេះដឹងអំពីការងារនេះក្នុងចំណោមយុវជន ជាពិសេសយុវតី តាមរយៈកម្មវិធីអប់រំ និងកម្មវិធីបណ្តុះបណ្តាលនានា
- លើកកម្ពស់ការយល់ដឹងអំពីយេនឌ័រនៅក្នុងស្រទាប់យុវជន ដើម្បីជាមូលដ្ឋានដ៏រឹងមាំនៃការគោរពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា និងជាដៃគូដ៏មានប្រសិទ្ធភាពរវាងបុរស និងស្ត្រីក្នុងដំណើរការអភិវឌ្ឍប្រទេសជាតិប្រកបដោយសមភាព សមធម៌ក្នុងការទទួលបានផលប្រយោជន៍។

*៥.១២- ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀននិងស្ការយុវនីតិសម្បទា*

- រៀបចំយន្តការអនុវត្តវិធានការការពារនិងបង្ការទប់ស្កាត់យុវជនឲ្យផុតពីការពាក់ព័ន្ធនឹងការដាំដុះ ការផលិត ការជួញដូរ ការចរាចរ ការរក្សាទុក ការចែកចាយនិងការប្រើប្រាស់គ្រឿងញៀនគ្រប់ប្រភេទ

- រៀបចំយន្តការមិត្តអប់រំមិត្ត ដើម្បីលើកកម្ពស់ការយល់ដឹងពីគ្រោះថ្នាក់ និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន
- ជំរុញកិច្ចសហការរវាងក្រសួង ស្ថាប័នសាធារណៈ និងវិស័យឯកជន ដោយបង្កើត និងពង្រឹកកម្មវិធីអប់រំ ការពារ បង្ការ ទប់ស្កាត់យុវជនឲ្យចផុតពីការពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀនគ្រប់ប្រភេទ
- បង្កើននិងអភិវឌ្ឍមជ្ឈមណ្ឌលស្តារនីតិសម្បទា ដើម្បីព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលជំនាញផ្សេងៗដល់យុវជនរងគ្រោះ និងធ្វើសមាហរណកម្មចូលក្នុងសង្គមវិញ។

## ៦-ផែនការសកម្មភាព

ដើម្បីសម្រេចយុទ្ធសាស្ត្រខាងលើ ត្រូវយកចិត្តទុកដាក់លើសកម្មភាពមួយចំនួនដូចខាងក្រោម៖

### *៦.១- ការបង្កើតយន្តការ*

- បង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ដែលជាយន្តការសម្របសម្រួល តាមដាន វាយតម្លៃ និងជួយរាជរដ្ឋាភិបាលអំពីដំណើរការអភិវឌ្ឍយុវជន។ ក្រុមប្រឹក្សានេះ មានអគ្គលេខាធិការដ្ឋាននិងអនុគណៈកម្មការជាតិជំនាញមួយចំនួនដើម្បីអនុវត្តនិងទ្រទ្រង់សកម្មភាព
- បង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន ដែលជាយន្តការតាមដានវាយតម្លៃអំពីការអភិវឌ្ឍយុវជន និងរាយការណ៍ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- បង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត ដែលជាបណ្តាញរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន និងជាយន្តការថ្នាក់ក្រោមជាតិសម្រាប់សម្របសម្រួល និងជួយគណៈអភិបាលរាជធានី ខេត្ត អំពីដំណើរការអភិវឌ្ឍយុវជននៅរាជធានី ខេត្ត
- បង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌ ដែលជាយន្តការសម្របសម្រួលដំណើរការអភិវឌ្ឍយុវជននៅថ្នាក់ក្រុង ស្រុក ខណ្ឌ
- បង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនឃុំ សង្កាត់ដែលជាយន្តការសម្របសម្រួលដំណើរការអភិវឌ្ឍយុវជននៅមូលដ្ឋាន
- ពង្រឹងយន្តការដែលមានស្រាប់ដើម្បីគាំទ្រការអភិវឌ្ឍយុវជន។

### ៦.២- *ការបង្កើតក្រុមទ័ណ្ឌតនិយុត្ត*

- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនស្ថិតក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី។ សមាសភាពរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនត្រូវតែងតាំងដោយព្រះរាជក្រឹត្យ
- ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនត្រូវកំណត់ដោយអនុក្រឹត្យ
- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន អនុគណៈកម្មការជាតិជំនាញនានា និងក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត
- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនឃុំ សង្កាត់ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌ។

### ៦.៣- *ការគាំទ្រហិរញ្ញវត្ថុ*

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនប្រើប្រាស់ថវិកាដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា និងដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

### ៦.៤- *ការបណ្តុះបណ្តាលធនធានមនុស្ស*

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ត្រូវយកចិត្តទុកដាក់បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ ការរៀបចំផែនការ ការវិភាគទិន្នន័យជំនាញបច្ចេកទេស ដែលពាក់ព័ន្ធនឹងការងារយុវជន។

### ៦.៥- *ដំណើរការអនុវត្តគម្រោង*

រៀបចំផែនការអភិវឌ្ឍយុវជនរយៈពេលមធ្យម ដោយមានការពិគ្រោះយោបល់ពីគ្រប់ដៃគូពាក់ព័ន្ធ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ។ ផែនការនេះត្រូវបង្ហាញពីចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍយុវជនសម្រាប់រយៈពេលខាងមុខ និងត្រូវ

ឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។ ផែនការនេះ ក៏ត្រូវអនុវត្តនៅក្នុងក្របខ័ណ្ឌកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលផងដែរ។

## ៧-ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

ដើម្បីឲ្យគោលនយោបាយនេះមានវិសាលភាពអនុវត្តស្របតាមបរិបទកម្ពុជា ចាំបាច់ត្រូវមានប្រព័ន្ធតាមដានត្រួតពិនិត្យ វាយតម្លៃ ការពិនិត្យឡើងវិញ និងសំណើកែលម្អការអនុវត្តដោយផ្តោតលើៈ

- ចំណុចដៅនិងយុទ្ធសាស្ត្រនៃគោលនយោបាយជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា
- សូចនាករនៃផែនការជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- លទ្ធផលដែលទទួលបានធៀបទៅនឹងចំណុចដៅ
- ការចូលរួមរបស់យុវជនក្នុងការកសាងប្រទេសជាតិ
- ផលប្រយោជន៍ដែលយុវជនទទួលបានពីការអនុវត្តគោលនយោបាយ។

## ៨-សេចក្តីសន្និដ្ឋាន

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ទទួលស្គាល់ពីបំណងប្រាថ្នា តម្រូវការ និងលក្ខខណ្ឌរបស់យុវជន ដោយបានបញ្ជាក់ច្បាស់អំពីចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រមួយចំនួន ដើម្បីប្រមូលផ្តុំកម្លាំងយុវជនគ្រប់មជ្ឈដ្ឋាន និងកៀរគរធនធាន សំដៅអភិវឌ្ឍយុវជនឲ្យក្លាយទៅជាពលរដ្ឋមានកាយសម្បទា ចំណេះដឹង ចំណេះធ្វើ មានគំនិតផ្តួចផ្តើម គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព ដែលជាកត្តាកំណត់សក្តានុពលសេដ្ឋកិច្ចសង្គមជាតិទាំងមូល។

រាជរដ្ឋាភិបាលសង្ឃឹមនិងជឿជាក់ថា ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល សហគមន៍ គ្រួសារ បុគ្គល នឹងចូលរួមចំណែកជំរុញ ផ្សព្វផ្សាយ អនុវត្ត និងគាំទ្រគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឲ្យបានជោគជ័យ។

# រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ
# ស្តីពី
# មុខរបរនិងការងារឆ្នាំ២០១៥-២០២៥

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៥

# រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ
# ស្តីពី
# មុខរបរនិងការងារឆ្នាំ២០១៥-២០២៥

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី**
**ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៥**

# អារម្ភកថា

ក្នុងការដឹកនាំប្រទេសជាតិឆ្លងកាត់ដំណាក់កាលប្រែប្រួលដ៏សំខាន់ៗ ទាំងខាងនយោបាយ ទាំងខាងសេដ្ឋកិច្ចសង្គម រាជរដ្ឋាភិបាលកម្ពុជាពិតជាបានដាក់ចេញនូវគោលនយោបាយដ៏ត្រឹមត្រូវ ដែលនាំឱ្យប្រទេសជាតិទទួលបានការអភិវឌ្ឍជាលំដាប់ ព្រមទាំងកំពុងប្រែក្លាយខ្លួនពីប្រទេស ដែលមានស្ថានភាពអន់ថយខាងសេដ្ឋកិច្ច មានអត្រាភាពក្រីក្រខ្ពស់ ក្លាយទៅជាប្រទេសដែលស្ថិតនៅក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍជួរមុខ ប្រកបដោយជវភាព និងក្តីសង្ឃឹមខ្ពស់នៅក្នុងតំបន់និងពិភពលោក។

សមិទ្ធផលសេដ្ឋកិច្ចសង្គមដែលសម្រេចបានក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ សម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យម ៧,៧% ក្នុងរយៈពេលពីទសវត្សរ៍ចុងក្រោយ បានធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមានកំណើនសេដ្ឋកិច្ចលឿនបំផុតលំដាប់ទី៦ នៅលើពិភពលោក។ ផលទុនជាតិ ឬទំហំសេដ្ឋកិច្ច ដែលវាស់វែងដោយផលិតផលក្នុងស្រុកសរុប( ផសស )ប្រមាណពី ២ ៤៨០លានដុល្លារអាមេរិកនៅឆ្នាំ១៩៩៣ បានកើនឡើងដល់១៦ ៧០៩លានដុល្លារអាមេរិក នៅឆ្នាំ២០១៤ (កើនឡើងប្រមាណជាង៦ដង)។ ប្រាក់ចំណូលឬផលិតផលក្នុងស្រុកសរុប(ផសស) សម្រាប់ប្រជាជនម្នាក់ៗចំនួន២២៩ដុល្លារអាមេរិក ក្នុងម្នាក់ៗក្នុងមួយឆ្នាំនៅឆ្នាំ១៩៩៣ បានកើនឡើងដល់ប្រមាណជា ១ ១២៣ដុល្លារអាមេរិក ក្នុងម្នាក់ៗក្នុងមួយឆ្នាំ នៅឆ្នាំ២០១៤។ ចំណូលចរន្តនៃថវិកាជាតិ ដែលមានទំហំ ១០៣លានដុល្លារអាមេរិក ក្នុងឆ្នាំ១៩៩៣ បានកើនឡើងទៅដល់ប្រមាណ ២ ៧៧៩លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៤ (កើនឡើងជិត២៩ដង)។

បច្ចុប្បន្ននេះ សេដ្ឋកិច្ចកម្ពុជាបានឈានដល់ដំណាក់កាលនៃការអភិវឌ្ឍថ្មីមួយ គឺកំពុងក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងកំពុងស្ថិតក្នុងដំណើរផ្លាស់ប្តូររចនាសម្ព័ន្ធពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសពឹងផ្អែកលើវិស័យឧស្សាហកម្ម។ នៅក្នុងក្របខណ្ឌនេះ កម្ពុជាត្រូវធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំប្រកបដោយបរិយាប័ន្ននិងចីរភាព ដែលជាមូលដ្ឋានសម្រាប់ការបង្កើតការងារនិងឱកាសរកប្រាក់ចំណូលសមរម្យ ព្រមទាំងការបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ និងលើកតម្កើងជីវភាពរស់នៅរបស់ប្រជាជន។

នៅក្នុងបរិការណ៍ប្រជាសាស្ត្រដែលសម្បូរទៅដោយពលករវ័យក្មេង រួមផ្សំជាមួយនឹងការពង្រីកទីក្រុង និងការកើនយ៉ាងឆាប់រហ័សនូវសកម្មភាពពាណិជ្ជកម្ម និងវិនិយោគនៅតាមទីក្រុងនានា បាននិងកំពុងជំរុញឱ្យមានកំណើនចលនាកម្លាំងពលកម្មចេញពីជនបទចូលទៅក្នុងទីក្រុង។ ចលករនេះទាមទារឱ្យមានការបង្កើនការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈនិងជំនាញ សំដៅផ្តល់ភាគលាភខ្ពស់ដល់កំណើនសេដ្ឋកិច្ច។

ដោយវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រទៅដល់សកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគទុន រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ និងដាក់ចេញនូវ *«គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥»* ដែលមានចក្ខុវិស័យលើកកម្ពស់ជីវភាព ភាពថ្លៃថ្នូររបស់ពលរដ្ឋគ្រប់រូប ភាពសុខដុមរមនាសង្គម តាមរយៈការបង្កើតការងារសមរម្យនិងមានផលិតភាពការងារខ្ពស់ ជូនពលរដ្ឋកម្ពុជាគ្រប់រូប ប្រកបដោយសមធម៌។ គោលនយោបាយនេះក៏ត្រូវបានរៀបចំឡើងឱ្យមានភាពស៊ីចង្វាក់គ្នាទៅនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ផងដែរ ដោយផ្តោតជាសំខាន់លើសសរស្តម្ភបីគឺ *(ទី១) ការបង្កើនឱកាសការងារសមរម្យនិងមានផលិតភាពការងារខ្ពស់ (ទី២) ការជំរុញការអភិវឌ្ឍជំនាញនិងធនធានមនុស្ស* និង *(ទី៣) ការពង្រឹងអភិបាលកិច្ចទីផ្សារការងារ*។ ទន្ទឹមនឹងនេះ ដើម្បីធានាប្រសិទ្ធភាព នៃការអនុវត្តគោលនយោបាយនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្រគល់ភារកិច្ចជូនក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើជាស្ថាប័នទទួលខុសត្រូវដឹកនាំសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តនូវគោលដៅដែលបានកំណត់។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសំដែងការកោតសរសើរចំពោះក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានខិតខំរៀបចំកសាងឯកសារគោលនយោបាយដ៏មានសារៈសំខាន់នេះ និងសូមវាយតម្លៃខ្ពស់ចំពោះគ្រប់ក្រសួង ស្ថាប័ន ព្រមទាំងភាគីនិយោជក សហជីព និងដៃគូអភិវឌ្ឍន៍ ជាពិសេសអង្គការអន្តរជាតិខាងការងារ សហគមន៍អឺរ៉ុប ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែត និងធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានគាំទ្រ និងផ្តល់កិច្ចសហប្រតិបត្តិការចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំនិងតាក់តែងគោលនយោបាយនេះ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំ និងជឿជាក់ថា គ្រប់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ រួមទាំងដៃគូអភិវឌ្ឍន៍នឹងបន្តកិច្ចសហការប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការចូលរួមអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ ឱ្យទទួលបានជោគជ័យនូវរាល់គោលដៅដែលបានដាក់ចេញ សំដៅរួមចំណែកអភិវឌ្ឍប្រទេសកម្ពុជាឱ្យក្លាយជាប្រទេសមានចំណូលកាន់តែខ្ពស់ប្រកបដោយបរិយាប័ន្ននិងចីរភាព។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# មាតិកា


១- សេចក្តីផ្តើម ........ ១

២- ចក្ខុវិស័យ ........ ៤

៣- គោលបំណងនិងគោលដៅ ........ ៤

៣.១- គោលបំណង ........ ៥

៣.២- គោលដៅ ........ ៥

៤- យុទ្ធសាស្ត្រ ........ ៦

៤.១- គោលបំណងទី១: ការបង្កើនឱកាសការងារសមរម្យនិងមានផលិតភាពការងារខ្ពស់ ........ ៦

៤.២- គោលបំណងទី២: ការលើកកម្ពស់ការអភិវឌ្ឍជំនាញនិងធនធានមនុស្ស ........ ៩

៤.៣- គោលបំណងទី៣: ការពង្រឹងអភិបាលកិច្ចទីផ្សារការងារ ........ ១១

៥- ការតាមដានត្រួតពិនិត្យការអនុវត្ត និងការវាយតម្លៃ ........ ១៥

៦- សេចក្តីសន្និដ្ឋាន ........ ១៦

ឧបសម្ព័ន្ធ ១: សន្ទានុក្រម ........ ១៧

ឧបសម្ព័ន្ធ ២: តារាងវិធានការគោលនយោបាយ ........ ១៩

## ១- សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សន្តិភាពពេញលេញ ឯកភាពជាតិ និងស្ថិរភាពនយោបាយ សេដ្ឋកិច្ចកម្ពុជាកំពុងបន្តទទួលបាននូវការរីកចម្រើនលើគ្រប់វិស័យ និងបានឈានដល់ដំណាក់កាលនៃការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្មទៅជាប្រទេសដែលពឹងផ្អែកលើវិស័យឧស្សាហកម្ម ព្រមទាំងកំពុងឈានទៅសម្រេចឋានៈប្រទេសដែលមានកម្រិតចំណូលមធ្យមនាពេលដ៏ខ្លីខាងមុខ។ ទន្ទឹមនឹងនេះ ការបន្តពង្រីកទីក្រុង និងការកើនឡើងយ៉ាងឆាប់រហ័សនូវសកម្មភាពពាណិជ្ជកម្ម និងវិនិយោគនៅតាមទីក្រុងបានជំរុញឱ្យកើនឡើងនូវកម្លាំងពលកម្មចំណាកស្រុកពីជនបទមកកាន់ទីក្រុង ជាពិសេស ក្នុងខណៈដែលបរិការណ៍ប្រជាសាស្ត្រកម្ពុជាសម្បូរទៅដោយពលករវ័យក្មេង ការបណ្តុះបណ្តាលវិជ្ជាជីវៈជូនពលករទាំងនេះអាចនឹងផ្តល់ភាគលាភខ្ពស់ដល់កំណើនសេដ្ឋកិច្ច តាមរយៈការធានាបាននូវការងារសមរម្យ ដែលអាចធ្វើឱ្យប្រសើរឡើងនូវជីវភាព សេចក្តីថ្លៃថ្នូរ និងសុខដុមរមនាក្នុងសង្គម។ ការខកខាននៃការផ្តល់ជំនាញវិជ្ជាជីវៈប្រកបដោយគុណភាពជូនពលករវ័យក្មេងទាំងនេះអាចនឹងបង្កជាបញ្ហាសង្គមនិងនយោបាយ ដែលអាចរាំងដល់ដំណើរការកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

ឆ្លើយតបទៅនឹងបម្រែបម្រួលនៃបរិការណ៍សេដ្ឋកិច្ចនិងសង្គមខាងលើ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៥នៃរដ្ឋសភា បានដាក់ចេញនូវ *«យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣»* ដើម្បី *«កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា»* ដែលក្នុងនោះ ការបង្កើតការងារថ្មីកាន់តែច្រើនឡើងជូនប្រជាពលរដ្ឋត្រូវបានចាត់ទុកជាយុទ្ធសាស្ត្រអាទិភាពមួយក្នុងចំណោមគោលដៅយុទ្ធសាស្ត្រទាំងបួន។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវ *«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥»* ដែលមានចក្ខុវិស័យជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជា ពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ សំដៅផ្លាស់ប្តូរពីឧស្សាហកម្មដែលមានតម្លៃបន្ថែមទាបទៅជាឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ ព្រមទាំងដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងនិងផលិតភាពការងារ។ ការសម្រេចបាននូវចក្ខុវិស័យនេះនឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងលើកកម្ពស់កំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាពនិងបរិយាប័ន្ន ការបង្កើតការងារជូនប្រជាពលរដ្ឋកម្ពុជា ការបង្កើនតម្លៃបន្ថែមសម្រាប់សេដ្ឋកិច្ចជាតិ និងការបង្កើនប្រាក់ចំណូលសមរម្យជូនប្រជាពលរដ្ឋកម្ពុជា។

ទន្ទឹមនឹងជោគជ័យទាំងនេះ កម្ពុជាក៏ប្រឈមនឹងបញ្ហាមួយចំនួន ជាពិសេស ទាក់ទងនឹងការបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ និងការបង្កើតឱកាសការងារដែលផ្តល់ប្រាក់ចំណូលសមរម្យនៅតាមទីជនបទ ព្រមទាំងការខ្វះខាតធនធានមនុស្សប្រកបដោយគុណភាពនិងសមត្ថភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងលើកកម្ពស់ភាពប្រកួតប្រជែងរបស់ប្រទេស។ លើសពីនេះ វឌ្ឍនភាពសង្គម-សេដ្ឋកិច្ចក៏បានបណ្តាលឱ្យកើតនូវបញ្ហាប្រឈមថ្មីនៅក្នុងទីផ្សារការងារផងដែរ។

ដើម្បីចូលរួមចំណែកក្នុងការអនុវត្តប្រកបដោយភាពជោគជ័យនូវរបៀបវារៈគោលនយោបាយ យុទ្ធសាស្ត្រ និងឆ្លើយតបទៅនឹងបញ្ហាប្រឈម រាជរដ្ឋាភិបាលបានដាក់ចេញនូវ *«គោលនយោបាយជាតិស្តីពីមុខរបរនិង*

*ការងារឆ្នាំ២០១៥-២០២៥*។ សំដៅបង្កើនឱកាសការងារសមរម្យជូនដល់ប្រជាពលរដ្ឋកម្ពុជា និងលើកកម្ពស់ផលិតភាពការងារ ជំរុញការអភិវឌ្ឍជំនាញនិងធនធានមនុស្ស ព្រមទាំងពង្រឹងអភិបាលកិច្ចទីផ្សារការងារ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងការផ្លាស់ប្តូរនៃនិម្មាបនកម្មសេដ្ឋកិច្ចទាំងនៅក្នុងប្រទេស តំបន់ និងសកលលោក។

គោលនយោបាយនេះសំដៅដោះស្រាយបញ្ហាប្រឈមចម្បងៗ ដែលទីផ្សារការងារកម្ពុជាកំពុងជួបប្រទះដូចខាងក្រោម៖

ទី១- ពលរដ្ឋកម្ពុជាទាំងពីរភេទ ភាគច្រើនមានការងារធ្វើ ដែលនៅក្នុងឆ្នាំ២០០៨ អនុបាតពលរដ្ឋអាយុចាប់ពី១៥ឆ្នាំឡើងដែលមានការងារធ្វើមានចំនួន៨០%(បុរស) និង៧៥%(ស្ត្រី) ស្មើនឹងជាង៣/៤ (បីភាគបួន)។ នៅឆ្នាំ២០១២ អនុបាតនេះមានអត្រា៦៧% (យោងអង្កេតកម្លាំងពលកម្មប្រទេសកម្ពុជាឆ្នាំ២០១២) តែបើគិតតែពលរដ្ឋអាយុពី១៥ទៅ៦៤ឆ្នាំ មានអាត្រា៨៤% (យោងអង្កេតសង្គម-សេដ្ឋកិច្ចប្រទេសកម្ពុជាឆ្នាំ២០១២)។ ទោះបីសម្រេចបានលទ្ធផលដូចនេះក្តី ចាំបាច់ត្រូវធ្វើការកែលម្អប្រភេទការងារ ដែលប្រជាពលរដ្ឋកំពុងធ្វើ និងធានាស្ថិរភាពប្រាក់ចំណូលនៅគ្រប់រដូវ កាលទាំងអស់។ កន្លងមក កំណើនការងារភាគច្រើនត្រូវបានស្រូបយកដោយវិស័យកសិកម្មនិងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ រីឯកំណើនសេដ្ឋកិច្ចឈរលើមូលដ្ឋាននៃវិស័យសំណង់ កសិកម្ម វាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង និងទេសចរណ៍។ កំណើនសេដ្ឋកិច្ចពឹងផ្អែកលើមូលដ្ឋានតូចចង្អៀតនេះ បង្ហាញថាបទពិសោធន៍និងជំនាញការងារដែលកម្លាំងពលកម្មបានទទួលក៏នៅមានកម្រិតដែរ។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ បានកំណត់នូវភាពចាំបាច់ក្នុងការធ្វើពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ចជាតិ ទាំងក្នុងវិស័យកសិកម្មនិងវិស័យដទៃទៀត។ ការធ្វើពិពិធកម្មនេះចាំបាច់ត្រូវអមដោយយុទ្ធសាស្ត្រដែលមានលក្ខណៈសកម្ម និងលើកស្ទួយដល់ការអភិវឌ្ឍនិងការពង្រីកបន្ថែមនូវលក្ខណសម្បត្តិនៃកម្លាំងពលកម្ម ទាំងខាងជំនាញនិងទាំងបទពិសោធន៍ការងារ។

ទី២- ប្រជាពលរដ្ឋភាគច្រើនមានវ័យក្មេង អ្នកដែលចូលបំពេញការងារក៏សុទ្ធសឹងមានវ័យក្មេងផងដែរ។ នៅចន្លោះឆ្នាំ១៩៩៨ និងឆ្នាំ២០០៨ មានពលរដ្ឋចូលរួមក្នុងកម្លាំងពលកម្មប្រមាណ២៣០ ០០០នាក់ក្នុងមួយឆ្នាំ ហើយចំនួននេះបានកើនឡើងបន្តិច គិតមកដល់ឆ្នាំ២០១៥នេះ។ ភាគច្រើននៃកម្លាំងពលកម្មទាំងនេះមានការងារធ្វើ ដែលចំនួនប្រហែល២/៣(ពីរភាគបី)នៃកម្លាំងពលកម្មទាំងនេះរកការងារបានធ្វើនៅក្នុងវិស័យកសិកម្ម។ ជាទូទៅ កម្លាំងពលកម្មភាគច្រើនចូលធ្វើការក្នុងវិស័យកសិកម្ម ហើយបានចាកចេញទៅវិស័យឧស្សាហកម្មនិងសេវាកម្ម នៅពេលដល់អាយុចូលធ្វើការផ្លូវការ។ ដោយឡែក នៅឆ្នាំ២០០៨ ប្រមាណ៦៨%នៃអ្នកដែលធ្វើការក្នុងវិស័យឧស្សាហកម្ម ស្ថិតក្នុងវ័យក្រោម៣០ឆ្នាំ។ សម្រាប់វិស័យកសិកម្មនិងសេវាកម្មវិញ អ្នកធ្វើការដែលមានវ័យក្មេងបែបនេះ មានតែ៣៩%ប៉ុណ្ណោះ។ បើមើលពីសមាសភាពនៃជនដែលទើបនឹងចូលធ្វើការថ្មី គេឃើញថា មួយចំណែកគឺជាយុវជនដែលបោះបង់ចោលការសិក្សានៅកម្រិតមូលដ្ឋាន។ ក្នុងន័យនេះ ចាំបាច់ត្រូវការរៀបចំនិងកសាងធនធានមនុស្សឱ្យក្លាយជាកម្លាំងពលកម្មសមស្របសម្រាប់សេដ្ឋកិច្ច ដែលមានលក្ខណៈជវភាពនិងពិពិធកម្មខ្ពស់។ម្យ៉ាងទៀត ត្រូវធានាឱ្យពលរដ្ឋដែលបានចូលបំពេញការងារស្រាប់អាចមានឱកាសគ្រប់គ្រាន់ដើម្បីអភិវឌ្ឍនិងពង្រីកនូវជំនាញនិងបទពិសោធន៍ការងាររបស់ខ្លួនបាន។

ទី៣- របាយប្រជាពលរដ្ឋមិនស្មើគ្នា ធ្វើឱ្យដង់ស៊ីតេប្រជាពលរដ្ឋមានកម្រិតទាបនៅតំបន់ខ្លះដែលបណ្តាលឱ្យមានកង្វះការផ្គត់ផ្គង់កម្លាំងពលកម្មតាមរដូវ និងតម្រូវឱ្យមានការវិនិយោគ ដើម្បីបង្កើនផលិតភាពដីនិងបង្កើនទុន។ ប្រទេសសមាជិកអាស៊ានភាគច្រើន ក្រៅពីប្រ៊ុយណេ ឡាវ និងមីយ៉ាន់ម៉ា គឺមានដង់ស៊ីតេប្រជាពលរដ្ឋក្នុងមួយគីឡូម៉ែត្រក្រឡាខ្ពស់ជាងកម្ពុជា។ លើសពីនេះ កម្លាំងពលកម្មភាគច្រើនប្រមូលផ្តុំក្នុងវិស័យកសិកម្ម ទោះបីជាពលរដ្ឋមួយចំនួនបាននិងកំពុងធ្វើចំណាកស្រុកទៅកាន់បណ្តាទីប្រជុំជន( ជាពិសេសរាជធានីភ្នំពេញ )ក្នុងពេលបច្ចុប្បន្ន និងនៅទសវត្សរ៍ខាងមុខក្តី។ ដូច្នេះ ដើម្បីធ្វើពិពិធកម្មនិងធានាកំណើនសេដ្ឋកិច្ចនាពេលអនាគត ត្រូវផ្តល់សារៈសំខាន់លើការវិនិយោគ ពិសេស លើផ្នែកសុខាភិបាល អប់រំ និងជំនាញដែលអាចទទួលបានតាមរយៈការបំពេញការងារ។ កិច្ចសម្របសម្រួលខាងគោលនយោបាយទាំងតាមវិស័យនីមួយៗ ទាំងតាមភូមិសាស្ត្រក៏រឹតតែមានសារៈសំខាន់ខ្លាំងឡើងដែរ ពីព្រោះគេអាចធានាបានថា ពលរដ្ឋដែលមានជំនាញនិងបទពិសោធន៍ការងារខ្លះស្រាប់ហើយ នឹងមានលទ្ធភាពបង្កើនចំណូលរបស់ខ្លួនឬមានឱកាសស្វែងរកការងារប្រសើរជាងមុន នៅតាមបណ្តាវិស័យសេដ្ឋកិច្ចដែលជាអាទិភាពនានា។ ក្នុងបរិការណ៍នេះ កម្ពុជាជួបប្រទះនូវកត្តាប្រឈមជាច្រើនក្នុងការផ្សព្វផ្សាយការវិភាគ និងការធ្វើបច្ចុប្បន្នកម្មឱ្យបានទៀងទាត់នូវព័ត៌មានទីផ្សារការងាររួមទាំងការងារពាក់ព័ន្ធនឹងការកែលម្អស្ថានភាពការងារនៅក្នុងវិស័យដែលត្រូវការបន្ថែមកម្លាំងពលកម្ម។

ទី៤- ការធ្វើសមាហរណកម្មសេដ្ឋកិច្ចដែលបាននិងកំពុងបន្ត ហើយមានសន្ទុះខ្លាំងឡើងក្នុងចំណោមបណ្តាប្រទេសសមាជិកអាស៊ាននឹងនាំឱ្យមានបញ្ហាប្រឈមថ្មីចំពោះទីផ្សារការងារ។ ដំណើរការសមាហរណកម្មសេដ្ឋកិច្ចនេះនឹងផ្តល់ទាំងអត្ថប្រយោជន៍ ទាំងចំណាយលើការកែតម្រូវក្នុងទីផ្សារការងារ ព្រមទាំងភាពមិនប្រាកដប្រជាមួយចំនួន។ ជាងនេះទៀត សហគមន៍សេដ្ឋកិច្ចអាស៊ានក្នុងឆ្នាំ២០១៥ នឹងបើកឱកាសឱ្យមានបម្លាស់ទីដោយសេរី ចំពោះកម្លាំងពលកម្មជំនាញក្នុងមុខរបរនិងវិស័យជាក់លាក់មួយចំនួន ព្រមទាំងត្រូវបានប៉ាន់ស្មានថានឹងជំរុញឱ្យមានចល័តភាពកាន់តែខ្លាំងឡើងនៃកម្លាំងពលកម្មពាក់កណ្តាលជំនាញនិងជំនាញទាប ដោយសារអតុល្យភាពប្រជាសាស្ត្រនិងកម្រិតនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចក្នុងបណ្តាប្រទេសសមាជិកអាស៊ាន។ ហេតុនេះ ត្រូវគ្រប់គ្រងនូវផលអវិជ្ជមាន និងត្រូវចាប់ឱកាសថ្មីដែលកើតពីស្ថានភាពពាណិជ្ជកម្មនិងបម្លាស់ទីកម្លាំងពលកម្មដែលមានលក្ខណៈសេរីជាងមុននេះ មកលើទីផ្សារការងារក្នុងស្រុក។ ទន្ទឹមនឹងនេះ ត្រូវដាក់ចេញនូវវិធានការនានា ទាំងខាងទីផ្សារការងារ ទាំងកិច្ចគាំពារសង្គម សំដៅការពារដល់ពលករទេសន្តរប្រវេសន៍ និងកម្លាំងពលកម្មឯទៀត ដែលរងគ្រោះពីនិកម្មភាពនិងភាពមានការងារធ្វើមិនពេញលេញ។

ទី៥- ការអភិវឌ្ឍវិស័យឧស្សាហកម្មដោយឈរលើអតិពលកម្មនិងការធ្វើទេសន្តរប្រវេសន៍ទៅធ្វើការក្រៅប្រទេសនៃកម្លាំងពលកម្ម បានដាក់សម្ពាធកាន់តែខ្លាំងឡើងលើប្រាក់ឈ្នួលក្នុងប្រទេស ដែលអាចបណ្តាលឱ្យកម្ពុជាបាត់បង់ភាពប្រកួតប្រជែងយ៉ាងឆាប់រហ័ស។ ដើម្បីធានាបាននូវកំណើនប្រាក់ឈ្នួលនិងកំណើនផលិតភាពការងារឱ្យបានព្រមគ្នា ត្រូវតែមានការវិនិយោគ ដើម្បីបង្កើនផលិតភាពការងារ។ ប្រការនេះតម្រូវឱ្យមានការវិនិយោគនៅកម្រិតម៉ាក្រូ កម្រិតសហគ្រាស និងកម្រិតបុគ្គល។ បញ្ហាប្រឈមគឺការបង្កើនផលិតភាពការងារជាប្រចាំនៅកម្រិតបុគ្គល ដែលរួមទាំងការវិនិយោគលើវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការបណ្តុះបណ្តាលក្នុងពេលកំពុងធ្វើការងារ។/ ៗ

ទី៦- ទំនាក់ទំនងវិជ្ជាជីវៈនៅតែជាបញ្ហាប្រឈមដ៏ធំសម្រាប់ទីផ្សារការងារ។ ប្រទេសកម្ពុជាបានសម្រេចនូវវឌ្ឍនភាពក្នុងវិស័យទំនាក់ទំនងវិជ្ជាជីវៈជាច្រើន ដូចជាមានច្បាប់ស្ដីពីការងារដែលគ្រប់ជ្រុងជ្រោយស្របតាមបទដ្ឋានអន្តរជាតិ និងមានសេរីភាពពេញលេញក្នុងការបង្កើតសមាគមឬសហជីព។ ការអភិវឌ្ឍស្ថាប័នសម្រាប់ដោះស្រាយវិវាទការងារ ដូចជាយន្តការត្រីភាគីនិងក្រុមប្រឹក្សាអាជ្ញាកណ្ដាល ត្រូវបានរៀបចំឱ្យមានឡើង។ ទោះជាយ៉ាងនេះក្ដី បញ្ហាប្រឈមនៅតែមានក្នុងការរៀបចំយន្តការប្រកបដោយប្រសិទ្ធភាព សម្រាប់សំវាទសង្គមឱ្យបានទូទាំងប្រទេស។ ខណៈដែលកម្ពុជាកំពុងព្យាយាមធ្វើពិពិធកម្មមូលដ្ឋានឧស្សាហកម្ម ទៅរកវិស័យកម្មន្តសាលធុនស្រាល តម្រូវឱ្យមានទំនាក់ទំនងវិជ្ជាជីវៈដែលមានភាពសុខដុមនិងរឹងមាំ ដែលគាំទ្រដល់ការផ្លាស់ប្ដូររចនាសម្ព័ន្ធ និងបែងចែកអត្ថប្រយោជន៍ដែលកើតពីកំណើនសេដ្ឋកិច្ចរវាងកម្មករនិងនិយោជក។

បញ្ហាប្រឈមមានច្រើន ហើយមិនមែនរាល់បញ្ហាប្រឈមទាំងអស់សុទ្ធតែអាចដោះស្រាយបានដោយប្រើគោលនយោបាយរបស់រដ្ឋតែមួយមុខនោះទេ។ *«គោលនយោបាយជាតិស្ដីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥»* នេះ អាចអនុវត្តទៅបានប្រកបដោយប្រសិទ្ធភាពលុះត្រាតែមានការចូលរួមជំរុញ និងការផ្ដល់ធាតុចូលពីសំណាក់ដៃគូក្នុងសង្គមនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។ គោលនយោបាយនេះសង្ខេបពីសកម្មភាពនិងទម្រង់សម្រាប់អនុវត្តនិងគ្រប់គ្រងនូវលទ្ធផលនៃភាពមានការងារធ្វើសមរម្យ ដែលមានបង្ហាញនៅក្នុងផ្នែកបន្តបន្ទាប់ខាងក្រោម។

គោលនយោបាយនេះ គឺជាកិច្ចប្រឹងប្រែងរួមនៃភាគីពាក់ព័ន្ធទាំងអស់ ដើម្បីធានាឱ្យបាននូវឱកាសការងារដែលស្មើគ្នានិងសមរម្យសម្រាប់ពលរដ្ឋកម្ពុជាគ្រប់រូប ក្នុងគោលដៅបង្កើនសមត្ថភាពផលិតរបស់ជាតិ និងរក្សាបាននូវការប្រកួតប្រជែងនិងជវភាពក្នុងបរិការណ៍តំបន់ និងចូលរួមចំណែកប្រកបដោយប្រសិទ្ធភាពដើម្បីសម្រេចឱ្យបាននូវកំណើនប្រកបដោយចីរភាពនិងបរិយាប័ន្ន សំដៅធានាថា ប្រជាពលរដ្ឋ៖

- អាចទទួលបានការងារដែលមានចិត្តចង់ធ្វើនិងភាពទាក់ទាញ
- អាចទទួលបានការអប់រំ ជំនាញ និងបទពិសោធន៍ការងារដែលជាក្ដីប្រាថ្នារបស់ខ្លួន
- ទទួលបានប្រព្រឹត្តិកម្មស្មើគ្នានៅក្នុងទីផ្សារការងារ
- មានក្ដីសង្ឃឹមក្នុងការទទួលការងារនិងឱកាសរកប្រាក់ចំណូលកាន់តែប្រសើរទៅអនាគត។

## ២- ចក្ខុវិស័យ

ចក្ខុវិស័យរបស់គោលនយោបាយនេះផ្ដោតលើការលើកតម្កើងជីវភាព ភាពថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ភាពសុខដុមរមនាសង្គម តាមរយៈការបង្កើតឱកាសការងារសមរម្យ និងមានផលិតភាពការងារខ្ពស់ជូនប្រជាពលរដ្ឋកម្ពុជាគ្រប់រូបប្រកបដោយសមធម៌។

## ៣- គោលបំណងនិងគោលដៅ

គោលបំណងនៃ *«គោលនយោបាយជាតិស្ដីពីមុខរបរនិងការងារ»* នេះ គឺផ្ដល់នូវចក្ខុវិស័យ ក្របខណ្ឌគោលនយោបាយ យុទ្ធសាស្ត្រ និងវិធានការគោលនយោបាយ ក្របខណ្ឌសម្របសម្រួល ការអនុវត្ត និងការរៀបចំយន្តការស្ថាប័នសម្រាប់ជំរុញការអភិវឌ្ឍវិស័យមុខរបរនិងការងារ ដើម្បីសម្រេចចក្ខុវិស័យខាងលើ។/៕

### ៣.១- គោលបំណង

ទី១ ការបង្កើនឱកាសការងារសមរម្យនិងមានផលិតភាពការងារខ្ពស់
ទី២ ការលើកកម្ពស់ការអភិវឌ្ឍជំនាញនិងធនធានមនុស្ស
ទី៣ ការពង្រឹងអភិបាលកិច្ចទីផ្សារការងារ

### ៣.២- គោលដៅ

ដើម្បីសម្រេចបានគោលបំណងទី១ *«ការបង្កើនឱកាសការងារសមរម្យនិងមានផលិតភាពការងារខ្ពស់»* គោលនយោបាយនេះបានដាក់ចេញនូវគោលដៅដូចខាងក្រោម៖

១.១- លើកស្ទួយការបង្កើនឱកាសការងារសមរម្យនិងមានផលិតភាពការងារខ្ពស់ នៅក្នុងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច។

១.២- លើកស្ទួយការបង្កើនឱកាសការងារសមរម្យនិងមានផលិតភាពការងារខ្ពស់ នៅក្នុងគោលនយោបាយអភិវឌ្ឍន៍តាមវិស័យ។

១.៣- លើកកម្ពស់ការងារសមរម្យនិងមានផលិតភាពការងារខ្ពស់ តាមរយៈការបង្កលក្ខណៈឱ្យមានការប្រែក្លាយកម្មករនិយោជិតនិងអង្គភាពសេដ្ឋកិច្ច ពីសេដ្ឋកិច្ចក្រៅប្រព័ន្ធទៅក្នុងសេដ្ឋកិច្ចផ្លូវការ ដោយធានាបាននូវការកែលម្អ និងរក្សាបាននូវជីវភាពរស់នៅ ក្នុងអំឡុងពេលនៃដំណើរការប្រែក្លាយនេះ។

ដើម្បីសម្រេចបានគោលបំណងទី២ *«ការលើកកម្ពស់ការអភិវឌ្ឍជំនាញនិងធនធានមនុស្ស»* គោលនយោបាយនេះ បានដាក់ចេញនូវគោលដៅដូចខាងក្រោម៖

២.១- ពង្រឹង និងពង្រីកការអភិវឌ្ឍជំនាញទន់។

២.២- ពង្រឹងគុណភាពឱ្យស្របតាមស្តង់ដាជាតិ អន្តរជាតិ និងក្របខណ្ឌអាស៊ាន និងលទ្ធភាពទទួលបានការអប់រំ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

២.៣- ធ្វើឱ្យប្រសើរឡើងនូវភាពឆ្លើយតបនៃការអប់រំនិងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យស្របតាមតម្រូវការទីផ្សារការងារ។

ដើម្បីសម្រេចបានគោលបំណងទី៣ *«ការពង្រឹងអភិបាលកិច្ចទីផ្សារការងារ»* គោលនយោបាយនេះបានដាក់ចេញនូវគោលដៅដូចខាងក្រោម៖

៣.១- ពង្រឹងមូលដ្ឋានទិន្នន័យនិងប្រព័ន្ធព័ត៌មានទីផ្សារការងារ។

៣.២- ពង្រឹងប្រសិទ្ធភាពសេវាការងារនិងពង្រីកវិសាលភាព។

៣.៣- ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារនិងការការពារកម្មករនិយោជិត។

ទីស្តីការគណៈរដ្ឋមន្ត្រី

៣.៤- ធ្វើសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈនិងពង្រឹងយន្តការកំណត់ប្រាក់ឈ្នួល។

៣.៥- សិក្សាឈានទៅបង្កើតសេវាបេបនិកម្មភាព។

៣.៦- គ្រប់គ្រងនិងការពារពលករទេសន្តប្រវេសន៍ ក្នុងការទទួលបានការងារសមរម្យនិងការទទួលស្គាល់ជំនាញ។

# ៤- យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រចម្បងនៃគោលនយោបាយនេះគឺ រៀបចំបំពេញនូវតម្រូវការចំណុចខ្វះខាតនានាដែលពាក់ព័ន្ធនឹងតម្រូវការការងារនិងការបង្កើនឱកាសការងារសមរម្យ ដើម្បីជាមូលដ្ឋានក្នុងការអនុវត្តនិងសម្រេចឱ្យបាននូវគោលដៅ និងសកម្មភាពបង្កើនឱកាសការងារសមរម្យតាមវិស័យ និងទីតាំងភូមិសាស្ត្រនៅក្នុងក្របខណ្ឌគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

## ៤.១- គោលបំណងទី១: ការបង្កើនឱកាសការងារសមរម្យនិងមានផលិតភាពការងារខ្ពស់

ដើម្បីបង្កើនឱកាសការងារថ្មីដែលសមរម្យនិងមានផលិតភាពការងារខ្ពស់ រាជរដ្ឋាភិបាលចាំបាច់ត្រូវធ្វើ ឱ្យបរិយាកាសនៃការអភិវឌ្ឍសេដ្ឋកិច្ចមានលក្ខណៈអំណោយផលដល់ការបង្កើតឱកាសការងារបន្ថែម។ ហេតុនេះត្រូវសិក្សាស្វែងយល់អំពីឥទ្ធិពល ឬផលប៉ះពាល់នៃគោលនយោបាយអភិវឌ្ឍន៍តាមវិស័យ និងនៅកម្រិតម៉ាក្រូសេដ្ឋកិច្ចជាតិ ទៅលើរចនាសម្ព័ន្ធតម្រូវការនៅក្នុងទីផ្សារការងារ ពាក់ព័ន្ធនឹងការបង្កើតឱកាសការងារសមរម្យនិងមានផលិតភាពការងារខ្ពស់ ឱ្យបានគ្រប់គ្រាន់នៅក្នុងប្រទេស។ រាជរដ្ឋាភិបាលនឹងសិក្សាឱ្យបានច្បាស់លាស់អំពីគោលនយោបាយអភិវឌ្ឍន៍សហគ្រាស តាមវិស័យ និងនៅក្នុងកម្រិតម៉ាក្រូសេដ្ឋកិច្ច ដោយពិចារណាពីទិដ្ឋភាពនៃភាពមានការងារធ្វើសមរម្យ ដើម្បីធានាថា គោលនយោបាយទាំងនោះ លើកស្ទួយដល់ការបង្កើនការងារសមរម្យ និងដែលមានផលិតភាពការងារខ្ពស់។ គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ ២០១៥-២០២៥នេះ ក៏ឆ្លើយតបនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ផងដែរ។

### ៤.១.១- គោលដៅ១.១: លើកស្ទួយការបង្កើនឱកាសការងារសមរម្យនិងមានផលិតភាពការងារខ្ពស់នៅក្នុងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច សំដៅដល់ទិសដៅ និងវិធានការពាក់ព័ន្ធនឹងគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយសារពើពន្ធ។ ក្របខណ្ឌនេះជាកត្តាកំណត់នូវគន្លងកំណើនសេដ្ឋកិច្ច និងតម្រូវការសរុបនៅក្នុងសេដ្ឋកិច្ច ដែលនឹងជះឥទ្ធិពលលើឱកាសទទួលបានការងារធ្វើ និងលទ្ធភាពក្នុងការធ្វើឱ្យប្រសើរឡើងនូវលទ្ធផលនៃភាពមានការងារសមរម្យ (រាប់ទាំងកម្រិតប្រាក់ចំណូល និងកិច្ចការពារក្នុងការងារដែលមានលក្ខណៈសមរម្យ)។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ បានបញ្ជាក់យ៉ាងច្បាស់ថា រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់បន្ថែមទៀតក្នុងការពង្រីកលំហសារពើពន្ធ ហើយទន្ទឹមនឹងនោះធានាថា បំណុលរដ្ឋស្ថិតក្នុងកម្រិតដែល

អាចគ្រប់គ្រងបាន។ ហេតុនេះ ត្រូវមានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដែលមានលក្ខណៈអំណោយផលដល់កំណើនសេដ្ឋកិច្ច តាមរយៈការពង្រឹងការអភិវឌ្ឍវិស័យឯកជននិងទីផ្សារការងារ។ ដើម្បីធានាថា គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចបម្រើផលប្រយោជន៍ដល់ពលរដ្ឋកំពុងធ្វើការងារ រាជរដ្ឋាភិបាលនឹងតាមដាន និងវិភាគឱ្យបានទៀតទាត់អំពីឥទ្ធិពលនៃគោលនយោបាយទាំងនោះចំពោះសេដ្ឋកិច្ច ក្នុងការបង្កើតឱកាសការងារបន្ថែម។

វិធានការ៖

១- តាមដាននិងវិភាគជាទៀងទាត់ រៀងរាល់មួយឆ្នាំម្តង អំពីដំណើរការម៉ាក្រូសេដ្ឋកិច្ច ដោយផ្តោតលើការបង្កើតឱកាសការងារសមរម្យ និងដែលមានផលិតភាពការងារខ្ពស់។

២- ចូលរួមនៅក្នុងកិច្ចសន្ទនាគោលនយោបាយ តាមរយៈវេទិកាអន្តរក្រសួង ពាក់ព័ន្ធនឹងវឌ្ឍនភាពដែលសម្រេចបាន ក្នុងការបង្កើនឱកាសការងារសមរម្យ និងដែលមានផលិតភាពការងារខ្ពស់នៅក្នុងប្រទេស។

៣- ដាក់ចេញនូវគោលដៅ អំពីចំនួនឱកាសការងារដែលត្រូវបង្កើត (ដោយចែកដាច់ដោយឡែកពីគ្នារវាងចំនួនការងារសម្រាប់បុរសនិងស្ត្រី) និងតាមដានការអនុវត្តដោយផ្តោតលើបរិមាណនិងគុណភាព។

៤- កសាងសមត្ថភាពនិងជំនាញបច្ចេកទេស សម្រាប់គណៈកម្មការអន្តរក្រសួងក្នុងការកំណត់នូវគោលដៅអំពីចំនួនឱកាសការងារដែលត្រូវបង្កើត និងតាមដានការអនុវត្តជាប្រចាំ។

### ៤.១.២- គោលដៅ១.២: លើកស្ទួយការបង្កើនឱកាសការងារសមរម្យនិងមានផលិតភាពការងារខ្ពស់នៅក្នុងគោលនយោបាយអភិវឌ្ឍន៍តាមវិស័យ

ការអភិវឌ្ឍតាមវិស័យនិងការធ្វើពិពិធកម្មអនុវិស័យថ្មីៗដែលមានសក្តានុពលខ្ពស់សម្រាប់បង្កើតការងារអាចជួយបង្កើនផលិតភាពយ៉ាងច្រើន។ កិច្ចការនេះបានធ្វើឱ្យគោលនយោបាយនេះដើរតួនាទីសំខាន់យ៉ាងខ្លាំងក្នុងការកំណត់អាទិភាពចំពោះវិស័យដែលមានសក្តានុពលខ្ពស់សម្រាប់បង្កើតការងារ និងធានាឱ្យបានថា មានកម្លាំងពលកម្មជំនាញច្បាស់លាស់និងគ្រប់គ្រាន់សម្រាប់គាំទ្រការអភិវឌ្ឍវិស័យទាំងនោះ។

ការអនុវត្តយុទ្ធសាស្ត្រដែលស្ថិតក្នុងចតុកោណទី២ *«ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត»* នៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ជះឥទ្ធិពលយ៉ាងខ្លាំងដល់ការអភិវឌ្ឍវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម និងការពង្រឹងទំនាក់ទំនងអន្តរវិស័យ។ ការអភិវឌ្ឍនិងពិពិធកម្មវិស័យកសិកម្ម ដែលត្រូវបានដាក់ចេញក្នុងចតុកោណទី១ *«ការលើកកម្ពស់វិស័យកសិកម្ម»* និងការអភិវឌ្ឍវិស័យឧស្សាហកម្មនិងសេវាកម្ម ដែលត្រូវបានកំណត់នៅក្នុងចតុកោណទី២ និងទី៣ មានឥទ្ធិពលយ៉ាងខ្លាំងក្នុងការបង្កើតឱកាសការងារសមរម្យសម្រាប់ប្រជាជនកម្ពុជា។ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងក្របខណ្ឌគោលនយោបាយលើកកម្ពស់សហគ្រាសធុនតូចនិងមធ្យម ជះឥទ្ធិពលយ៉ាងខ្លាំងដល់ការបង្កើតការងារនៅតាមអនុវិស័យនានា។

វិធានការ៖

១- ប៉ាន់ប្រមាណតម្រូវការការងារសម្រាប់ស្ត្រីនិងបុរស នៅកម្រិតវិស័យនិងអនុវិស័យ។

២- កំណត់អនុវិស័យអាទិភាពដែលមានសក្តានុពលខ្ពស់សម្រាប់បង្កើតការងារ។

៣- ជំរុញការបង្កើតការងារនៅតាមអនុវិស័យអាទិភាពតាមរយៈការអភិវឌ្ឍសហគ្រាស និងផ្តល់កិច្ចគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យម នៅតាមទីក្រុងនិងជនបទ។

៤- ជំរុញការវិនិយោគក្នុងស្រុកនិងវិនិយោគទុនផ្ទាល់ពីបរទេស ឱ្យដល់អនុវិស័យអាទិភាពដែលមានសក្តានុពលខ្ពស់សម្រាប់បង្កើតការងារ។

៥- សម្របសម្រួលជាមួយនឹងសកម្មភាពនៅក្នុងគោលបំណងទី២ និងទី៣ សំដៅឆ្លើយតបសក្តានុពលនៃតម្រូវការការងារ។

**៤.១.៣- គោលដៅ ១.៣: លើកកម្ពស់ការងារសមរម្យនិងមានផលិតភាពការងារខ្ពស់ តាមរយៈការបង្កលក្ខណៈឱ្យមានការប្រែក្លាយកម្មករនិយោជិតនិងអង្គភាពសេដ្ឋកិច្ចពីសេដ្ឋកិច្ចក្រៅប្រព័ន្ធទៅក្នុងសេដ្ឋកិច្ចផ្លូវការ ដោយធានាបាននូវការកែលម្អ និងរក្សាបាននូវជីវភាពរស់នៅក្នុងអំឡុងពេលនៃដំណើរការប្រែក្លាយនេះ**

សកម្មភាពធុរកិច្ចនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ សំដៅដល់សកម្មភាពអាជីវកម្មដែលពុំបានចុះបញ្ជីផ្លូវការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។ លទ្ធផលវិភាគនៃជំរឿនសេដ្ឋកិច្ចឆ្នាំ២០១១ បង្ហាញថា មានអង្គភាពសេដ្ឋកិច្ចចំនួនតែ ៣,៤% (នៃអង្គភាពសេដ្ឋកិច្ចសរុបចំនួន ៥០៥.១៣៤) ប៉ុណ្ណោះ ដែលបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម រីឯការចុះបញ្ជីជាមួយក្រសួងឬស្ថាប័នពាក់ព័ន្ធផ្សេងទៀតវិញ មានអត្រាចុះបញ្ជីទាបជាងនេះទៅទៀត ភាគច្រើនគឺក្រោម១%។ កម្លាំងពលកម្មដែលស្ថិតក្នុងអង្គភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធទាំងនោះ ភាគច្រើនជាក្រុមងាយរងគ្រោះ ហើយត្រូវការលក្ខខណ្ឌការងារប្រសើរជាងមុន។ ការប្រែក្លាយសកម្មភាពធុរកិច្ចទាំងនោះឱ្យស្ថិតក្នុងវិស័យសេដ្ឋកិច្ចផ្លូវការ អាចធ្វើឱ្យមានឱកាសការងារសមរម្យជាងមុន និងមានផលិតភាពការងារខ្ពស់ជាងមុន ប្រសិនបើដាក់ចេញនូវវិធានការត្រឹមត្រូវនិងសមស្របសម្រាប់ពង្រីកអាជីវកម្ម។

គោលដៅនេះត្រូវតែអនុវត្តក្រោមកិច្ចសម្របសម្រួលជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងកិច្ចសម្របសម្រួលជាមួយគោលបំណងទី៣ នៃគោលនយោបាយនេះ។

វិធានការ៖

១- ជំរុញការចុះបញ្ជីអាជីវកម្មផ្លូវការ ដោយសម្រួលនីតិវិធីនៃការចុះបញ្ជី។

២- លើកកម្ពស់ការយល់ដឹងអំពីអត្ថប្រយោជន៍នៃការចុះបញ្ជីអាជីវកម្មផ្លូវការ ក្នុងចំណោមធុរជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។/.

៣- ផ្សព្វផ្សាយច្បាប់ស្តីពីការងារនិងបទប្បញ្ញត្តិពាក់ព័ន្ធ ជូនដល់កម្មករនិយោជិតនិងនិយោជក ទាំងក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនិងសេដ្ឋកិច្ចផ្លូវការ។

៤- ស្រាវជ្រាវ វាយតម្លៃ និងផ្សព្វផ្សាយ អំពីឥទ្ធិពលនៃការប្រែក្លាយសកម្មភាពធុរកិច្ចនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលកើតមានចំពោះការបង្កើតការងារ ប្រាក់ចំណូល និងផលិតភាព។

៥- លើកទឹកចិត្តដល់ការប្រែក្លាយពីសកម្មភាពធុរកិច្ចនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យចូលក្នុងប្រព័ន្ធសេដ្ឋកិច្ចផ្លូវការ ដើម្បីជំរុញឱ្យមានការចូលរួមក្នុងការបង្កើតការងារសមរម្យ។

៦- លើកកម្ពស់សហគ្រិនភាព។

## ៤.២- គោលបំណងទី២: ការលើកកម្ពស់ការអភិវឌ្ឍជំនាញនិងធនធានមនុស្ស

ដើម្បីសម្រេចបាននូវពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ច និងផលិតកម្មផលិតផលមានតម្លៃបន្ថែមខ្ពស់ រាជរដ្ឋាភិបាលចាំបាច់ត្រូវវិនិយោគលើការកសាងសមត្ថភាពជំនាញជូនប្រជាពលរដ្ឋកម្ពុជា ទាំងក្នុងពេលបច្ចុប្បន្ន ទាំងអនាគត។ កង្វះខាតជំនាញគឺជាកត្តារារាំងមួយដ៏ចម្បងដល់សហគ្រាសក្នុងការអភិវឌ្ឍខ្សែផលិតកម្មថ្មី ឬបង្កើនផលិតកម្ម។ ការកសាងសមត្ថភាពជំនាញជូនពលរដ្ឋវ័យក្មេង និងកម្មករដែលកំពុងធ្វើការងារហើយមានផលិតភាពទាប និងទទួលបានចំណូលតិច គឺជាទិសដៅដែលត្រូវធ្វើទៅថ្ងៃមុខ។ ក្នុងស្ថានភាពនេះ ស្ថាប័នទទួលបន្ទុកការអប់រំនិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវបង្រៀនមុខវិជ្ជាឬបណ្តុះបណ្តាលមុខជំនាញដែលមានតម្រូវការដោយផ្សារភ្ជាប់ជាមួយជំនាញទន់ប្រកបដោយគុណភាព។

ការអប់រំនិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើរតួយ៉ាងសំខាន់ក្នុងការផ្តល់កិច្ចគាំពារសង្គមដល់កម្មករងាយរងគ្រោះ និងលើកកម្ពស់ដល់ការបង្កើតការងារ និងការអភិវឌ្ឍសេដ្ឋកិច្ច។ មុខជំនាញនិងវិស័យដែលត្រូវផ្តោតការយកចិត្តទុកដាក់ សម្រាប់ដាក់ចូលទៅក្នុងយុទ្ធសាស្ត្រនៃគោលនយោបាយនេះ ត្រូវដកស្រង់ឬយោងតាមលទ្ធផលសិក្សាវាយតម្លៃ ដែលធ្វើឡើងនៅក្នុងគោលបំណងទី១ នៃគោលនយោបាយនេះ។ កិច្ចការទាំងនេះ ក៏ត្រូវផ្សារភ្ជាប់ ឬជាស្នូលនៃចតុកោណទី៤ ស្តីពី *«ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស»* ជាពិសេស គឺមុំទី១ *«ការពង្រឹង និងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស»*។

### ៤.២.១- គោលដៅ ២.១: ពង្រឹង និងពង្រីកការអភិវឌ្ឍជំនាញទន់

ដើម្បីសម្រេចឱ្យបាននូវការអភិវឌ្ឍនិងពិពិធកម្មសេដ្ឋកិច្ចក្នុងប្រទេស ប្រជាពលរដ្ឋត្រូវតែមានជំនាញបច្ចេកទេស និងជំនាញទន់ សម្រាប់បង្កើនលទ្ធភាពស្វែងរកការងារធ្វើ និងធ្វើឱ្យជីវភាពរស់នៅប្រសើរឡើង។ វិធានការជាយុទ្ធសាស្ត្រខាងក្រោម ត្រូវបានដាក់ចេញសំដៅសម្រេចគោលបំណងនេះ៖

វិធានការ៖

១- ធ្វើឱ្យសិក្ខាកាម សិស្ស និស្សិត និងកម្មករនិយោជិត មានឱកាសទទួលបានជំនាញទន់សម្រាប់ការងារពេញមួយជីវិតតាមរយៈកម្មវិធីអប់រំនិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

២- បញ្ជ្រាបជំនាញទន់ក្នុងកម្មវិធីសិក្សានៅមធ្យមសិក្សាចំណេះទូទៅនិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការបណ្តុះបណ្តាលជំនាញសហគ្រិនភាព។

៣- បង្កើននិងពង្រាយបន្ថែមនូវវគ្គបណ្តុះបណ្តាលខ្លីៗ អំពីជំនាញទន់ដល់សិក្ខាកាម សិស្ស និស្សិត និងកម្មករនិយោជិត ។

៤- ជំរុញនិងលើកទឹកចិត្តដល់ការចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍ជំនាញទន់ ទាំងនៅក្នុងវិស័យសាធារណៈ និងឯកជន។

**៤.២.២- គោលដៅ ២.២: ពង្រឹងគុណភាពឱ្យស្របតាមស្តង់ដាជាតិ អន្តរជាតិ និងក្របខណ្ឌអាស៊ាន និងលទ្ធភាពទទួលបានការអប់រំនិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ**

ដើម្បីឱ្យប្រជាពលរដ្ឋទទួលបានជំនាញសមស្របនិងឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ ទាមទារឱ្យមានការពង្រឹងគុណភាពនៃការអប់រំនិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ។

វិធានការ៖

១- លើកកម្ពស់ស្តង់ដាជាតិសមត្ថភាព ការធ្វើតេស្តបញ្ជាក់សមត្ថភាព និងប្រព័ន្ធផ្តល់វិញ្ញាបនបត្រឱ្យស្របតាមស្តង់ដាវិស័យឯកជន/ឧស្សាហកម្ម ដោយយកស្តង់ដាអាស៊ានជាគោល។

២- ពង្រឹងទំនាក់ទំនងនិងភាពស៊ីចង្វាក់គ្នារវាងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការអប់រំចំណេះទូទៅ និងគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥។

៣- បង្កើតមជ្ឈមណ្ឌលគំរូ (Centers of Excellence) និងមជ្ឈមណ្ឌលធ្វើតេស្តបញ្ជាក់សមត្ថភាពដើម្បីគាំទ្រដល់មុខរបរនិងជំនាញជាអាទិភាព។

៤- ផ្តល់កម្មវិធីស្ពានចម្លងបន្ត ដើម្បីកសាងសមត្ថភាពឱ្យសិស្សអាចចូលរៀនឡើងវិញ នៅតាមកម្រិតកម្មវិធីអប់រំចំណេះទូទៅនិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៥- បង្កើនលទ្ធភាពក្នុងការផ្តល់ការអប់រំនិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដល់ក្រុមជនងាយរងគ្រោះ (សិស្សបោះបង់ការសិក្សាចំណេះទូទៅ ជនក្រីក្រ កុមារកំព្រា និងជនពិការ ។ល។)។

៦- ពង្រឹងគម្រោងផ្តល់ឱកាសទី២ ក្នុងការទទួលបានការអប់រំសម្រាប់ពលរដ្ឋពេញវ័យ។

៧- បង្កើនបរិមាណ និងគុណភាពគ្រូ ដែលមានចំណេះដឹង ចំណេះធ្វើ និងបទពិសោធន៍ឱ្យបានគ្រប់គ្រាន់។

៨- ពង្រឹងគុណភាព និងបង្កើនចំនួនគ្រឹះស្ថានអប់រំ និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៩- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ទៅលើប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអប់រំនិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

១០- រៀបចំគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

### ៤.២.៣- គោលដៅ ២.៣: ធ្វើឱ្យប្រសើរឡើងនូវភាពឆ្លើយតបនៃការអប់រំនិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឱ្យស្របតាមតម្រូវការទីផ្សារការងារ

ដើម្បីឆ្លើយតបតម្រូវការជំនាញនៅក្នុងវិស័យនានា ដែលមានការវិនិយោគខ្នាតធំ នាពេលបច្ចុប្បន្ននិងអនាគត ទាមទារឱ្យមានការបង្កើតយន្តការសម្រាប់ឱ្យកម្លាំងពលកម្មមានឱកាសទទួលបានជំនាញពាក់ព័ន្ធនឹងការងារ ដោយមានការចូលរួមនិងគាំទ្រពីនិយោជក។

**វិធានការ៖**

១- រៀបចំអភិក្រមតាមវិស័យសម្រាប់កម្មវិធីអប់រំនិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីផ្តល់ជំនាញកម្រិតខ្ពស់ ក្នុងវិស័យអាទិភាព (ដោយផ្សារភ្ជាប់ជាមួយនឹងគោលដៅ១.២ នៃគោលបំណងទី១ របស់គោលនយោបាយនេះ)។

២- ពង្រឹងនិងពង្រីកទំនាក់ទំនងរវាងអ្នកផ្តល់សេវាអប់រំនិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ជាមួយវិស័យឯកជន ដើម្បីកាត់បន្ថយគម្លាតតម្រូវការជំនាញ។

៣- ជំរុញនិងលើកទឹកចិត្តដល់ការសិក្សា តាមរយៈធ្វើការងារ ការហាត់ការ និងការហ្វឹកហ្វឺនកូនជាង។

៤- ពង្រឹងនិងបន្តអភិវឌ្ឍយន្តការដែលមានស្រាប់និងបង្កើតយន្តការថ្មី ដើម្បីឱ្យមានកិច្ចសន្ទនាជាទៀងទាត់ និងល្អប្រសើរក្នុងចំណោមភាគីពាក់ព័ន្ធ។

៥- ជំរុញនិងលើកទឹកចិត្តវិស័យឯកជន ឱ្យដើរតួនាទីសកម្មក្នុងការផ្តល់ប្រឹក្សាយោបល់ផ្នែកគោលនយោបាយ ការអភិវឌ្ឍជំនាញ ការផ្តល់ការបណ្តុះបណ្តាលជំនាញ និងការចូលរួមវិភាគទានហិរញ្ញវត្ថុ។

៦- បង្កើតកម្មវិធីទទួលស្គាល់ជំនាញទៅវិញទៅមកក្នុងក្របខណ្ឌអាស៊ាន។

៧- ស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាថ្មី។

៨- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ទៅលើភាពឆ្លើយតបនៃការអប់រំនិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

## ៤.៣- គោលបំណងទី៣: ការពង្រឹងអភិបាលកិច្ចទីផ្សារការងារ

អភិបាលកិច្ចទីផ្សារការងារអាចអនុវត្តទៅបានតាមរយៈស្ថាប័នទីផ្សារការងារ និងសេវាទីផ្សារការងារ។ គោលនយោបាយនេះមានបំណងពង្រឹងស្ថាប័ននិងសេវាទីផ្សារការងារ។

### ៤.៣.១- គោលដៅ ៣.១: ពង្រឹងមូលដ្ឋានទិន្នន័យ និងប្រព័ន្ធព័ត៌មានទីផ្សារការងារ

ព័ត៌មានទីផ្សារការងារជួយកាត់បន្ថយឬលុបបំបាត់គម្លាតរវាងតម្រូវការនិងការផ្គត់ផ្គង់ការងារ ដែលកើតចេញពីការបណ្តុះបណ្តាលជំនាញនិងភាពខុសគ្នានៃទីតាំងភូមិសាស្ត្រ។ ប្រព័ន្ធព័ត៌មានទីផ្សារការងារដែលដំណើរការល្អ ទាមទារឱ្យមានការប្រមូល ការវិភាគ ការចងក្រង និងការផ្សព្វផ្សាយស្ថិតិដែលតំណាងឱ្យថ្នាក់ជាតិ និងប្រភេទទិន្នន័យពាក់ព័ន្ធឯទៀត។ គោលដៅនេះមានបំណងពង្រឹងដំណើរការសកម្មភាពនិងវិធានការ ដូចមានរៀបរាប់ខាងក្រោម៖

វិធានការ៖

១- ធ្វើអង្កេតកម្លាំងពលកម្មឱ្យបានទៀតទាត់រៀងរាល់មួយឆ្នាំម្តង។

២- ពង្រីកនិងពង្រឹងគុណភាពមូលដ្ឋានទិន្នន័យព័ត៌មានទីផ្សារការងារ។

៣- ពង្រឹងការអនុវត្តបទដ្ឋានគតិយុត្តស្តីពីការប្រមូលនិងចងក្រងព័ត៌មានទីផ្សារការងារជាមួយភាគីពាក់ព័ន្ធ។

៤- ធ្វើការវិភាគឱ្យបានទៀងទាត់រៀងរាល់មួយឆ្នាំម្តង ចំពោះព័ត៌មានទីផ្សារការងារដែលទទួលបានពីប្រភពទិន្នន័យថ្នាក់ជាតិនិងប្រភពផ្សេងទៀត។

៥- ផ្សព្វផ្សាយលទ្ធផលវិភាគទៅដល់ភាគីពាក់ព័ន្ធ(ដូចជាមន្ត្រីតាក់តែងគោលនយោបាយ អ្នកស្វែងរកការងារ និយោជក និងយុវជន។ល។)។

៦- ពង្រឹងសមត្ថភាពស្ថាប័នទទួលបន្ទុកក្នុងការប្រមូល គ្រប់គ្រង និងវិភាគទិន្នន័យ។

### ៤.៣.២- គោលដៅ ៣.២: ពង្រឹងប្រសិទ្ធភាពសេវាការងារនិងពង្រីកវិសាលភាព

ការផ្តល់សេវាការងារប្រកបដោយប្រសិទ្ធភាព ធ្វើឱ្យទីផ្សារការងារដំណើរការបានល្អ។ សេវាការងារនេះរួមមាន ការផ្តល់ជំនួយក្នុងការរកការងារ និងការដាក់ឱ្យចូលធ្វើការ ការផ្តល់ប្រឹក្សាការងារ និងការអនុវត្តកម្មវិធីទីផ្សារការងារឯទៀត។ សេវាការងារនេះជួយបំពេញតម្រូវការការងារ នៅក្នុងអនុវិស័យអាទិភាព។ វិធានការខាងក្រោមនឹងជួយពង្រឹងបន្ថែមទៀតនូវបណ្តាញទំនាក់ទំនងរវាងមជ្ឈមណ្ឌលការងារទាំងអស់នៅក្នុងប្រទេស។

វិធានការ៖

១- ពង្រឹងការផ្តល់សេវាការងារ។

២- ពង្រឹងការតម្រង់ទិសដល់ក្រុមគោលដៅអំពីគន្លងការងារ (អាជីព) វិជ្ជាជីវៈ និងការងារ ដោយសហការជាមួយភាគីពាក់ព័ន្ធ។

៣- សម្របសម្រួលការផ្គូផ្គងតម្រូវការការងារ រវាងនិយោជកនិងអ្នកស្វែងរកការងារនៅក្នុងអនុវិស័យអាទិភាព។/.

៤- រៀបចំវេទិកាការងារឱ្យបានទៀងទាត់ទាំងនៅថ្នាក់មូលដ្ឋាន ទាំងថ្នាក់ជាតិ ដើម្បីអនុញ្ញាតឱ្យនិយោជក និងអ្នកស្វែងរកការងារជួបគ្នា។

៥- ពង្រឹងបណ្តាញទំនាក់ទំនងរវាងស្ថាប័នអប់រំនិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និយោជកនិងអ្នកស្វែងរកការងារ។

៦- បង្កើតមជ្ឈមណ្ឌលការងារបន្ថែមទៀត។

៧- លើកកម្ពស់ការយល់ដឹងអំពីសេវាកម្មរបស់មជ្ឈមណ្ឌលការងារក្នុងចំណោមនិយោជកនិងអ្នកស្វែងរកការងារ។

៨- បង្កើតឱ្យមានទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក។

**៤.៣.៣- គោលដៅ ៣.៣: ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ និងការពារកម្មករនិយោជិត**

ការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ និងការការពារកម្មករនិយោជិត នឹងធ្វើឱ្យគុណភាពជីវិតរបស់កម្មករនិយោជិតមានភាពប្រសើរឡើង ហើយនឹងបង្កើនផលិតភាពរបស់សហគ្រាស។ កិច្ចការនេះទាមទារឱ្យពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងធ្វើនិយ័តកម្មលើលក្ខខណ្ឌការងារ។ ការចាំបាច់ ត្រូវដាក់បញ្ចូលនូវកិច្ចគាំពារសង្គមផងដែរ។

**វិធានការ៖**

១- ពង្រឹងយន្តការអធិការកិច្ចការងារ។

២- បង្កើតមូលដ្ឋានទិន្នន័យសហគ្រាស ដែលត្រូវតាមដាន ត្រួតពិនិត្យលក្ខខណ្ឌការងារ (និងកម្មករនិយោជិត)។

៣- សិក្សាលទ្ធភាពក្នុងការផ្តល់សច្ចាប័នលើអនុសញ្ញាពាក់ព័ន្ធនានាដែលត្រូវនឹងបរិបទកម្ពុជា។

៤- ធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ។

៥- ពង្រឹងកិច្ចសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ។

៦- ពង្រីកវិសាលភាពកិច្ចគាំពារសង្គម ដោយអនុលោមតាម«*យុទ្ធសាស្ត្រគាំពារសង្គមនៅក្នុងក្របខណ្ឌនៃយុទ្ធសាស្ត្រអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គម*» និងលើកកម្ពស់អនាម័យ និងសុវត្ថិភាពការងារនៅកន្លែងធ្វើការ។

**៤.៣.៤- គោលដៅ ៣.៤: ធ្វើសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ និងពង្រឹងយន្តការកំណត់ប្រាក់ឈ្នួល**

ការរៀបចំ ការធ្វើជាតំណាង និងសំវាទសង្គម សុទ្ធសឹងជាចំណុចស្នូលរបស់អភិបាលកិច្ចល្អនៃទីផ្សារការងារនិងការងារសមរម្យ។ កិច្ចអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច ទាំងសេដ្ឋកិច្ចផ្លូវការ ទាំងសេដ្ឋកិច្ចក្រៅប្រព័ន្ធ រមទាំង/

កម្លាំងពលកម្មផងនោះ អាចសម្រេចបានល្អ គឺដោយសារទំនាក់ទំនងវិជ្ជាជីវៈដែលមានលក្ខណៈសុខដុម និងដែលកើតចេញពីសំវាទសង្គមនិងការចរចាជាសមូហភាព (collective bargaining)។ ធ្វើឱ្យប្រសើរឡើងនូវភាពជាតំណាងរបស់សហជីព តាមរយៈការរួមគ្នាដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការអនុវត្តការងារមិនយុត្តិធម៌ (ទាំងខាងសហជីព ទាំងខាងនិយោជក) រាប់ទាំងការរើសអើងប្រឆាំងនឹងសហជីព។ ត្រូវលើកស្ទួយការទទួលស្គាល់សិទ្ធិធ្វើការចរចាជាសមូហភាព។ គាំទ្រដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនិងគណៈកម្មការប្រឹក្សាការងារ ដើម្បីសម្រេចបានទំនាក់ទំនងវិជ្ជាជីវៈដ៏សុខដុមទៅអនាគត។

វិធានការ៖

១- ពិនិត្យមើលឡើងវិញ និងវាយតម្លៃលើក្របខណ្ឌច្បាប់និងបទដ្ឋានគតិយុត្ត (រាប់ទាំងច្បាប់ស្តីពីការងារឆ្នាំ១៩៩៧) ដើម្បីធានាឱ្យបាននូវទំនាក់ទំនងវិជ្ជាជីវៈដ៏សុខដុមនិងតំណាងឱ្យគ្រប់ភាគីដោយអនុលោមតាមអនុសញ្ញាអង្គការអន្តរជាតិខាងការងារ។

២- ពង្រឹងប្រសិទ្ធភាពប្រឹក្សាយោបល់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនិងគណៈកម្មការប្រឹក្សាការងារដោយអនុលោមតាមបទដ្ឋានអន្តរជាតិ។

៣- កសាងប្រព័ន្ធកំណត់ប្រាក់ឈ្នួលដែលរឹងមាំ និងមានសត្យានុម័ត តាមរយៈការពិនិត្យ និងការវាយតម្លៃប្រចាំឆ្នាំនូវកម្រិតប្រាក់ឈ្នួលអប្បរមា។

៤- ពង្រឹងយន្តការដោះស្រាយវិវាទការងារ និងការបង្កើតតុលាការការងារ។

៥- កសាងសមត្ថភាពពាក់ព័ន្ធនឹងភាពជាតំណាង និងការចរចាជាសមូហភាពនៅតាមកម្រិតនានា (ថ្នាក់ជាតិ ថ្នាក់វិស័យ និងថ្នាក់សហគ្រាស)។

### ៤.៣.៥- គោលដៅ៣.៥: សិក្សាឈានទៅបង្កើតសេវារបបនិកម្មភាព

ប្រព័ន្ធសេវារបបនិកម្មភាពដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារកម្មករនិយោជិតនៅពេលមានវិបត្តិសេដ្ឋកិច្ច ហើយក៏ជាអ្នកក្សាលនឹងសេដ្ឋកិច្ចផងដែរ។ រាជរដ្ឋាភិបាលនឹងសិក្សាវាយតម្លៃឱ្យល្អិតល្អន់និងរៀបចំឱ្យបានគ្រប់ជ្រុងជ្រោយ មុននឹងឈានទៅបង្កើតប្រព័ន្ធសេវារបបនិកម្មភាពមួយដែលសមស្របសម្រាប់កម្ពុជា នៅក្នុងក្របខណ្ឌនៃយុទ្ធសាស្ត្រអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គម។

វិធានការ៖

១- សិក្សាវាយតម្លៃអំពីលទ្ធភាពបង្កើតប្រព័ន្ធសេវារបបនិកម្មភាព នៅក្នុងក្របខណ្ឌនៃយុទ្ធសាស្ត្រអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គម។

២- លើកកម្ពស់ការយល់ដឹងអំពីគុណសម្បត្តិនិងគុណវិបត្តិរបស់ប្រព័ន្ធសេវារបបនិកម្មភាព ក្នុងចំណោមភាគីពាក់ព័ន្ធ។

៣- ពិគ្រោះយោបល់បឋមជាមួយភាគីពាក់ព័ន្ធស្តីពីប្រព័ន្ធសេវារបបនិកម្មភាព។/.

៤.៣.៦- គោលដៅ៣.៦: គ្រប់គ្រងនិងការពារពលករទេសន្តរប្រវេសន៍ ក្នុងការទទួលបានការងារសមរម្យនិងការទទួលស្គាល់ជំនាញ

ដោយអនុលោមតាមអាទិភាពយុទ្ធសាស្ត្ររបស់គោលនយោបាយស្តីពីទេសន្តរប្រវេសន៍សម្រាប់កម្ពុជាឆ្នាំ២០១៤ ត្រូវផ្តល់កិច្ចគាំទ្រដល់គោលដៅទី៣ *«ការត្រួតពិនិត្យ និងប្រើប្រាស់ធនធាន ដែលទទួលបានពីទេសន្តរប្រវេសន៍ការងារ ដើម្បីការអភិវឌ្ឍ»* ជាពិសេសពាក់ព័ន្ធនឹងការធ្វើសមាហរណកម្មឡើងវិញ នៅពេលពលករទេសន្តរប្រវេសន៍វិលត្រឡប់មកវិញ។

វិធានការៈ

១- អភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ។

២- ការការពារនិងផ្តល់ភាពអង់អាច (Empowering)ដល់ពលករទេសន្តរប្រវេសន៍។

៣- ពង្រឹងការផ្តល់សេវាសម្រាប់ការធ្វើសមាហរណកម្មឡើងវិញ ទាំងខាងសេដ្ឋកិច្ច ទាំងខាងសង្គមកិច្ច ឱ្យដល់ពលករទេសន្តរប្រវេសន៍ដែលបានវិលត្រឡប់មកវិញ ដូចដែលបានស្នើក្នុងយុទ្ធសាស្ត្រទី៣ (ការផ្សារភ្ជាប់ទេសន្តរប្រវេសន៍ការងារសម្រាប់ការអភិវឌ្ឍ) នៃគោលនយោបាយស្តីពីទេសន្តរប្រវេសន៍សម្រាប់កម្ពុជាដែលបានប្រកាសដាក់ឱ្យប្រើប្រាស់នៅឆ្នាំ២០១៤។

៤- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានពលករទេសន្តរប្រវេសន៍ដែលត្រូវបានបញ្ជូនទៅធ្វើការនៅបរទេសនិងត្រឡប់មកវិញ។

៥- ពង្រឹងនិងជំរុញការអនុវត្តច្បាប់ស្តីពីការងារ ច្បាប់អន្តោប្រវេសន៍ និងបទប្បញ្ញត្តិគតិយុត្តដទៃទៀតដែលទាក់ទងនឹងការគ្រប់គ្រងហត្ថពលកម្មបរទេសដែលចូលមកប្រកបមុខរបរនៅកម្ពុជា។

# ៥- ការតាមដានត្រួតពិនិត្យការអនុវត្ត និងការវាយតម្លៃ

ដើម្បីធានានិរន្តរភាព ប្រសិទ្ធភាព និងសង្គតិភាពជាប្រចាំក្នុងការអនុវត្តគោលនយោបាយ រាជរដ្ឋាភិបាលប្រគល់ការកិច្ចជូន *«ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ»* ធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការសម្របសម្រួល តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្ត *«គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥»*។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មានភារកិច្ចសម្របសម្រួលក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាលស្តីពីវឌ្ឍនភាពនិងបញ្ហាប្រឈម នៅក្នុងការអនុវត្តគោលនយោបាយនេះ ដោយផ្អែកលើគោលដៅនិងសូចនាករដែលបានកំណត់ខាងលើ ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការសម្រេចចិត្តលើវិធានការបន្ទាន់ចាំបាច់ ក្នុងការដោះស្រាយបញ្ហាប្រឈមចំពោះមុខដែលកើតឡើងក្នុងពេលអនុវត្ត។

គណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្ត *«គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥»* នឹងត្រូវបង្កើតដោយអនុក្រឹត្យ។/.

វិធានការនីមួយៗត្រូវមានផែនការអនុវត្តន៍ដែលមានចីរវេលាជាក់លាក់ ដើម្បីអមជាមួយគោលនយោបាយនេះ។ លទ្ធផលនិងឥទ្ធិពលដែលកើតចេញពីការអនុវត្តផែនការនេះ ត្រូវមានលក្ខណៈអាចវាស់វែងជាលេខបាន ហើយផែនការអនុវត្តន៍នីមួយៗ ត្រូវមានភ្ជាប់មកជាមួយនូវការប៉ាន់ស្មានទំហំថវិកាដែលត្រូវការ។ ប្រភពថវិកាសម្រាប់អនុវត្តគោលនយោបាយនេះ អាចជាថវិកាជាតិ ឬជាធនធានទទួលបានពីអង្គការអន្តរជាតិខាងការងារ ដៃគូអភិវឌ្ឍ និងភាគីនិយោជក។

## ៦- សេចក្តីសន្និដ្ឋាន

ឯកសារ *«គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥»* គឺជាផែនទីចង្អុលផ្លូវរបស់រាជរដ្ឋាភិបាលដើម្បីអភិវឌ្ឍស្ថាប័នទីផ្សារការងារ និងធានាឱ្យមានឱកាសការងារសមរម្យនិងមានផលិតភាពការងារខ្ពស់សម្រាប់ពលរដ្ឋកម្ពុជាគ្រប់រូប។ គោលនយោបាយនេះជាវិធានការសមស្របនិងទាន់ពេលវេលាដើម្បីសម្រេចបាននូវប្រយោជន៍ដែលកើតចេញពីស្ថានភាពប្រជាសាស្ត្ររបស់កម្ពុជានាពេលបច្ចុប្បន្ន ពោលគឺមានប្រជាពលរដ្ឋជាច្រើនដែលមានវ័យក្មេងនិងជាវភាពនៅក្នុងបរិការណ៍នៃសេដ្ឋកិច្ចដែលមានពិពិធកម្មខ្ពស់ ហើយម្យ៉ាងទៀតដើម្បីផ្តល់បទពិសោធន៍ការងារដ៏មានគុណភាព និងការរៀបចំកន្លែងធ្វើការងារដ៏សមរម្យសម្រាប់យុវជនកម្ពុជាដែលអាចក្លាយទៅជាកម្លាំងពលកម្មដ៏មានសមត្ថភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយចីរភាពនិងបរិយាប័ន្ន។

គោលនយោបាយនេះ បានស្នើឡើងនូវវិធានការដែលគ្រប់ជ្រុងជ្រោយ ដោយរួមបញ្ចូលគោលបំណងចម្បងចំនួន៣នៃប្រព័ន្ធទីផ្សារការងារ៖ (១) *«បង្កើនឱកាសការងារសមរម្យនិងមានផលិតភាពការងារខ្ពស់»* (២) *«លើកកម្ពស់ការអភិវឌ្ឍជំនាញនិងធនធានមនុស្ស»* និង(៣) *«ពង្រឹងអភិបាលកិច្ចទីផ្សារការងារ»*។

ផ្អែកលើគោលនយោបាយនេះ រាជរដ្ឋាភិបាលប្តេជ្ញាអភិវឌ្ឍប្រទេសឱ្យឈានខ្ពស់មួយកម្រិតទៀត តាមរយៈការផ្តល់នូវការអប់រំនិងជំនាញឱ្យប្រសើរជាងមុន ដើម្បីទទួលបានឱកាសការងារល្អជាងមុន សំដៅធ្វើឱ្យពលរដ្ឋកម្ពុជាគ្រប់រូបអាចរស់នៅក្នុងជីវភាពសម្បូររុងរឿងក្នុងសង្គមមួយដ៏សុខដុម។

# យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៣

## សេចក្តីផ្តើម

1. រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តប្រកបដោយជោគជ័យនូវ **យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ១ និង ទី ២** ។ សមិទ្ធផលនៃកិច្ចអភិវឌ្ឍរបស់កម្ពុជា ក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅនេះ គឺជាសក្ខីភាពនៃការឈានឡើងរបស់កម្ពុជាឆ្ពោះទៅរកសន្តិភាពយូរអង្វែង និង ការអភិវឌ្ឍប្រកបដោយចីរភាព ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ និង ការពង្រឹងស្ថាប័នប្រជាធិបតេយ្យ, ការធានាបាននូវអធិបតេយ្យជាតិ និង បូរណភាពទឹកដី ព្រមទាំងការកែលម្អជីវភាពប្រជាជន ។ វឌ្ឍនភាពនេះ ក៏បង្ហាញឱ្យឃើញផងដែរ អំពីការសម្រេចបាននូវបំណងប្រាថ្នារបស់រាជរដ្ឋាភិបាលកម្ពុជាថា : «**មុនដំណាច់ទសវត្សរ៍ទីមួយនៃសតវត្សទី ២១ នេះ ប្រទេសកម្ពុជាមានបំណងនឹងដណ្តើមកាន់កាប់នូវជោគវាសនារបស់ខ្លួនឡើងវិញឱ្យបានពេញលេញ ហើយក្លាយខ្លួនជាដៃគូពិតប្រាកដក្នុងកិច្ចការតំបន់ និង ពិភពលោក ព្រមទាំងក្លាយខ្លួនជាប្រជាជាតិ ដែលមានសេរីភាពពិតប្រាកដ និង រួចចាកផុតពីភាពក្រីក្រ**» ។

2. ជាក់ស្តែង កម្ពុជាបានឆ្លងកាត់ដំណាក់កាលប្រវត្តិសាស្ត្រដ៏សំខាន់មួយ គឺដំណើរផ្លាស់ប្តូរស៊ីជម្រៅក្នុងគ្រប់ទិដ្ឋភាពនៃសង្គម ។ កាលពីម្ភៃឆ្នាំមុន កម្ពុជាគឺជាប្រទេស ដែលទទួលយកទាហានមួកខៀវរបស់អង្គការសហប្រជាជាតិ ដើម្បីមកធ្វើប្រតិបត្តិការរក្សាសន្តិភាពនៅលើទឹកដីដ៏កំសត់ ដែលពោរពេញដោយជម្លោះ និង ការហែកហួរគ្នា ។ ឥឡូវនេះ កម្ពុជាបានក្លាយជាប្រទេសដែលបញ្ជូនកងកម្លាំងរបស់ខ្លួន ឱ្យពាក់មួកខៀវទៅចូលរួមក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ នៅក្នុងប្រទេសមួយចំនួនដែលជាចំណុចក្តៅនៅលើសកលលោក ។ កម្ពុជាពីមុនដែលល្បីថាជាវាលពិឃាត, ជាតំបន់អសន្តិសុខ, ជាចម្ការមីន ដែលគេភ័យខ្លាចគ្រប់គ្នា, ឥឡូវនេះ បានក្លាយទៅជា «**កោះសន្តិភាព**» និង ជាតំបន់ទេសចរណ៍ប្រកបដោយប្រជាប្រិយភាព នៅក្នុងតំបន់អាស៊ីអគ្នេយ៍ ដែលទទួលបានភ្ញៀវទេសចរជាងបីលាននាក់ក្នុងមួយឆ្នាំ ។ កម្ពុជាពីមុន ដែលល្បីក្នុងការប្រើប្រាស់អាវុធ ដើម្បីដណ្តើមអំណាចគ្នា និង ក្នុងការផ្លាស់ប្តូររដ្ឋាភិបាល, ឥឡូវនេះ បានក្លាយទៅជាប្រទេសមួយ ដែលគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស តាមរយៈការរៀបចំយ៉ាងទៀងទាត់នូវការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និង យុត្តិធម៌ ដើម្បីឱ្យប្រជាពលរដ្ឋជ្រើសតាំងតំណាងដឹកនាំប្រទេស, ជានីតិរដ្ឋ ដែលគោរពគោលការណ៍ច្បាប់ដោយឥតងាករេ និង ជារដ្ឋអធិបតេយ្យ ដែលមានបូរណភាព

ទឹកដីពេញលេញ ហើយគោរពលើកតម្កើងយ៉ាងហ្មត់ចត់នូវសិទ្ធិ និង សេចក្ដីថ្លៃថ្នូររបស់មនុស្ស ។ កម្ពុជាពីមុនដែលជាប្រទេសត្រូវទទួលរងការហ៊ុមព័ទ្ធ និង ឯកោ ទាំងខាងនយោបាយ និង សេដ្ឋកិច្ច, ឥឡូវនេះ បានក្លាយជាប្រទេសមួយដែលកំពុងសមាហរណខ្លួនយ៉ាងសកម្ម ទៅក្នុងរចនាសម្ព័ន្ធ និង និម្មាបនកម្មតំបន់ និង ពិភពលោក និង ជាប្រទេសដែលកំពុងតែដើរតួនាទីយ៉ាងសកម្ម ដោយស្មើសិទ្ធិ និង ស្មើភាព ក្នុងគ្រប់កិច្ចការតំបន់ និង នៅលើឆាកអន្តរជាតិ ។ កម្ពុជាដែលពីមុនជាប្រទេសអន់ថយខាងផ្នែកសេដ្ឋកិច្ច និង គ្របដណ្ដប់ទៅដោយភាពក្រីក្រ, មានអសន្តិសុខស្បៀង, ឥឡូវនេះបានក្លាយជាប្រទេសនាំស្បៀងចេញ, ហើយស្ថិតនៅក្នុងចំណាត់ថ្នាក់ទី ១១[1] ដែលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់លើពិភពលោក ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ និង ជាប្រទេសស្ថិតក្នុងចំណាត់ថ្នាក់ទី ៥[2] ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ដែលអាចសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ព្រមទាំងជាប្រទេសជាប់ចំណាត់ថ្នាក់ទី ១[3] នៅតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលសម្រេចបាននូវវឌ្ឍនភាពដ៏ល្អប្រសើរ ក្នុងការកែលម្អសូចនាករផ្នែកសង្គមកិច្ច ហើយកំពុងតែធ្វើដំណើរយ៉ាងស្វាហាប់ ឆ្លងកាត់ពីចំណាត់ថ្នាក់នៃប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងអនាគតដ៏ខ្លីខាងមុខនេះ ។

3. សមិទ្ធផលដ៏ធំធេងនេះ សម្រេចបានមក តាមរយៈការអនុវត្តនយោបាយ «**ឈ្នះ-ឈ្នះ**» ដែលឈរលើមូលដ្ឋាននៃស្មារតីមហាសាមគ្គីជាតិ និង ឯកភាពជាតិ ក្នុងគោលដៅបង្រួបបង្រួមកម្លាំងប្រជាជាតិទាំងមូល ជាធ្លុងមួយ ក្រោមបាវចនា «**ជាតិ, សាសនា, ព្រះមហាក្សត្រ**» សម្រាប់ការស្ដារ និង ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកម្ពុជា ។

4. ដោយផ្អែកលើបទពិសោធន៍, លទ្ធផលសម្រេចបានក្នុងនីតិកាលទី ៤ និង «**កម្មវិធីនយោបាយ**» សម្រាប់នីតិកាលទី ៥ របស់ខ្លួន, រាជរដ្ឋាភិបាលយល់ឃើញថា **យុទ្ធសាស្ត្រចតុកោណ** ជាពិសេសគោលដៅសម្រាប់ **កំណើន, ការងារ, សមធម៌** និង **ប្រសិទ្ធភាព** នៅតែចាំបាច់ និង សមស្រប សម្រាប់កម្ពុជាបន្តអនុវត្ត នៅក្នុងនីតិកាលទី ៥ (២០១៣-២០១៨) ទៀត ដោយរក្សាទុកនូវចតុកោណទាំងបួនឱ្យនៅដដែល ប៉ុន្តែ ពង្រីកវិសាលភាព, សម្រិតសម្រាំង, ធ្វើអាទិភាវូបនីយកម្មមុំ ព្រមទាំងកែលម្អគោលនយោបាយ និង យន្តការមួយចំនួន ឱ្យកាន់តែសុក្រឹតឡើងថែមទៀត ។ «**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**» នឹងប្រកាសអំពីបេសកកម្ម និង ការប្ដេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាល ក្នុងការធានានិរភាពនៃការអភិវឌ្ឍ និង ការកាត់បន្ថយភាពក្រីក្រ ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន និង បរិការណ៍ថ្មីៗ ទាំងកម្រិតជាតិ ទាំង កម្រិតអន្តរជាតិ ។ ក្នុងន័យនេះ «**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា**» និង «**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**» រួមជាមួយគ្នា គឺជាឯកសារគ្របខណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយ សម្រាប់រៀបចំ «**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**» ដោយកំណត់

---

[1] *ចំណាត់ថ្នាក់ពិភពលោកស្ដីពីអត្រាកំណើនផលិតផលក្នុងស្រុកសរុប ២០០០-២០១០, សូចនាករការអភិវឌ្ឍពិភពលោក(WDI), ធនាគារពិភពលោក (WB), ខែ ឧសភា ឆ្នាំ ២០១៣*

[2] *របាយការណ៍ស្ដីពីសន្ទស្សន៍វឌ្ឍនភាពនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ថ្មី, ឯកសារការងារលេខ ២២២ របស់មជ្ឈមណ្ឌលសម្រាប់ការអភិវឌ្ឍសកល (CGD), ខែ សីហា ឆ្នាំ ២០១០*

[3] *របាយការណ៍ស្ដីពីសន្ទស្សន៍នៃការអភិវឌ្ឍមនុស្សឆ្នាំ ២០០០-២០១០, ឯកសាររបស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP)*

សូចនាករ និង ពេលវេលាច្បាស់លាស់សម្រាប់អនុវត្ត ដែលមានសង្គតិភាពជាមួយនឹងឯកសារគោលនយោបាយតាមវិស័យដទៃទៀតរបស់រាជរដ្ឋាភិបាល ។ បន្ថែមលើនេះ នៅក្នុងការរៀបចំ «**យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី៣**» នេះ រាជរដ្ឋាភិបាលក៏បានគិតគូរវែងឆ្ងាយផងដែរ អំពីការវិវត្តប្រែប្រួលនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច និង សង្គមកម្ពុជា នៅក្នុងរយៈពេលវែងខាងមុខ ។ ដូច្នេះ «**យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៣**» នឹងក្លាយទៅជាមគ្គុទេសក៍ ច្បាស់លាស់សម្រាប់តម្រែតម្រង់សកម្មភាពរបស់គ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងគោលដៅបន្ត និង ពង្រឹងកិច្ចអភិវឌ្ឍ ប្រកបដោយចីរភាពសម្រាប់រយៈពេលវែង សំដៅ **ជំរុញកំណើនសេដ្ឋកិច្ច, បន្តបង្កើតការងារ, បែងចែកផលនៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌** និង ធានាឱ្យបាននូវ **ប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និង ការគ្រប់គ្រងធនធានគ្រប់ប្រភេទ** ។

5. ក្នុងខ្លឹមសារនេះ **យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៣** គឺជា «**របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច**» នៃ «**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា**» ។

## ផ្នែកទី ១

## ១.១. សមិទ្ធផលសំខាន់ៗ របស់រាជរដ្ឋាភិបាលនីតិកាលទី ៤ នៃរដ្ឋសភា

6. កម្ពុជាសម្រេចបានសមិទ្ធផលសំខាន់ជាច្រើន ទាំងខាងនយោបាយ, សន្តិសុខ, សណ្តាប់ធ្នាប់សង្គម ទាំងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ដែលជាបុរេលក្ខខណ្ឌ សម្រាប់ដំណើរផ្លាស់ប្តូរស៊ីជម្រៅ ក្នុងគ្រប់ទិដ្ឋភាពនៃសង្គម- សេដ្ឋកិច្ចកម្ពុជា ទោះបីជាត្រូវប្រឈមនឹងវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ, ការធ្លាក់ចុះសេដ្ឋកិច្ចសកលលោក, ការគំរាមលើអធិបតេយ្យជាតិ និង បូរណភាពទឹកដី ព្រមទាំងគ្រោះធម្មជាតិផ្សេងៗក៏ដោយ ។ ការអនុវត្តយ៉ាងប្តូរផ្តាច់នូវ «**យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ២**» កន្លងមក បានបង្កើតបរិស្ថានអនុគ្រោះ និង លក្ខខណ្ឌចាំបាច់ សម្រាប់ឱ្យកម្ពុជាបោះជំហានទៅមុខយ៉ាងស្វាហាប់ និង មានជំនឿទុកចិត្តយ៉ាងមុតមាំ នៅលើមាគ៌ានៃកំណែទម្រង់ និង ការអភិវឌ្ឍ ដោយឈានឡើងពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ក្នុងអនាគតដ៏ខ្លីខាងមុខនេះ ហើយបន្តឆ្ពោះទៅសម្រេចឱ្យបានជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ ។

7. ជាក់ស្តែង ក្នុងនីតិកាលទី ៤ នៃរដ្ឋសភា កន្លងមកនេះ រាជរដ្ឋាភិបាលបានសម្រេចលទ្ធផលធំៗ ដូចតទៅ ÷

ទី១- ការបន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ, សណ្តាប់ធ្នាប់សង្គម និង កិច្ចដំណើរការនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និង ការបន្តពង្រឹងគោលការណ៍នីតិរដ្ឋ ជាពិសេស ការកសាងក្របខណ្ឌច្បាប់ និង ការលើកកម្ពស់ការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ និង មានប្រសិទ្ធភាព ព្រមទាំងការធានានូវការគោរពសិទ្ធិ, សេរីភាព និង សេចក្តីថ្លៃថ្នូររបស់មនុស្ស ។ សមិទ្ធផលនេះ ត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញជាពិសេស តាមរយៈ (១). ការលើកកម្ពស់ការគោរពសិទ្ធិសេរីភាពខាងនយោបាយ, សេរីភាពនៃការបញ្ចេញមតិ និង ការរៀបចំការបោះឆ្នោត ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ដែលមានលក្ខណៈសេរី, ត្រឹមត្រូវ និង យុត្តិធម៌, (២). ការអនុវត្តគោលនយោបាយ «**ភូមិ- ឃុំមានសុវត្ថិភាព**»

ដែលបានរួមចំណែកកាត់បន្ថយយ៉ាងច្រើន នូវបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ ទាំងនៅទីក្រុង ទាំងនៅជនបទ និង (៣)• ការបន្តអនុវត្តយ៉ាងសកម្ម និង ស៊ីជម្រៅ នូវកំណែទម្រង់រដ្ឋសំខាន់ៗ រួមមាន ការប្រយុទ្ធប្រឆាំងអំពើពុករលួយ, កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌, កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ, កំណែទម្រង់រដ្ឋបាលសាធារណៈ ព្រមទាំងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅលើកកម្ពស់អភិបាលកិច្ចល្អ ដើម្បីធានាថា រាល់ប្រតិបត្តិការ និង កិច្ចដំណើរការនៃស្ថាប័នរដ្ឋ ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ប្រព្រឹត្តទៅប្រកបដោយតម្លាភាព, គណនេយ្យភាព, ភាពអាចប៉ាន់ប្រមាណបាន, ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ ។

ទី២- ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ការគ្រប់គ្រងបាននូវអតិផរណា, ការធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ និង ការពង្រឹងសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ តាមរយៈការបង្កើនផលិតភាពនៃវិស័យកសិកម្ម, ការកសាងមូលដ្ឋានសេដ្ឋកិច្ចជនបទ, ការពន្លឿនពិពិធភាវូបនីយកម្មសេដ្ឋកិច្ច ដោយពង្រឹងបរិយាកាសអំណោយផលសម្រាប់ទាក់ទាញការវិនិយោគឯកជន ទាំងក្នុង និង ក្រៅប្រទេស ដើម្បីពង្រីកវិស័យឧស្សាហកម្ម ទាំងក្នុងវិស័យកាត់ដេរ និងវិស័យដទៃផ្សេងទៀត ឱ្យបន្តជាវភាពរបស់ខ្លួន ព្រមទាំងការពង្រឹង និង ពង្រីកវិស័យសេវា ឱ្យរីកលូតលាស់យ៉ាងឆាប់រហ័ស ដែលប្រការទាំងអស់នេះ បានបង្កើតការងារជូនប្រជាជនកម្ពុជា ពិសេស យុវជនជាច្រើនសែននាក់ ក្នុងមួយឆ្នាំៗ ។

ទី៣- ការសម្រេចបានកំណើនសេដ្ឋកិច្ចមធ្យម ៦,៧% ក្នុងមួយឆ្នាំ ដោយមិនគិតឆ្នាំ ២០០៩ ដែលជាឆ្នាំទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីវិបត្តិកលិយុគហិរញ្ញវត្ថុ និង ការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោក ។ ជាក់ស្តែង នៅឆ្នាំ ២០០៩ សេដ្ឋកិច្ចកម្ពុជារក្សាបាននូវកំណើនវិជ្ជមាន ក្នុងកម្រិត ០,១% ហើយហក់ងើបឡើងវិញភ្លាម ដោយសម្រេចបាននូវអត្រាកំណើន ៦% នៅក្នុងឆ្នាំ ២០១០, ៧,១% នៅក្នុងឆ្នាំ ២០១១ និង ៧,៣% នៅក្នុងឆ្នាំ ២០១២ ក្នុងខណៈដែលកលិយុគហិរញ្ញវត្ថុ ជាពិសេសវិបត្តិបំណុលអធិបតេយ្យ នៅបន្តយាយីសេដ្ឋកិច្ចពិភពលោកនៅឡើយ ។ ផលិតផលសរុបក្នុងស្រុក សម្រាប់ប្រជាជនម្នាក់ៗ បានកើនឡើងពី ៧៦០ ដុល្លារ[4] ក្នុងឆ្នាំ ២០០៨ ដល់ជិត ១ ០០០ ដុល្លារ ក្នុងឆ្នាំ ២០១២ ។ អតិផរណាក៏ស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន ពោលគឺប្រមាណ ៤,២% ជាមធ្យមក្នុងមួយឆ្នាំ ។ អត្រាប្តូរប្រាក់មានស្ថិរភាពល្អ ហើយតម្លៃប្រាក់រៀលបានកើនឡើង ប្រៀបធៀបនឹងប្រាក់ដុល្លារ ។ ទុនបម្រុងអន្តរជាតិបានកើនឡើងប្រមាណ ជាង ៦០% ពី ២,១៦ ពាន់លានដុល្លារ ក្នុងឆ្នាំ ២០០៨ ដល់ ៣,៥ ពាន់លានដុល្លារ ក្នុងឆ្នាំ ២០១២ ដែលធានាបាន ៤,១ ខែ នៃការនាំចូល ។ អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយយ៉ាងឆាប់រហ័ស និង ជាប្រចាំ ពី ៤៧,៨% ក្នុងឆ្នាំ ២០០៧ មកនៅត្រឹម ១៩,៨% ក្នុងឆ្នាំ ២០១១ ពោលគឺ ភាពក្រីក្រ ត្រូវបានកាត់បន្ថយជាមធ្យម ៧% ក្នុងមួយឆ្នាំ ដែលធ្វើឱ្យប្រទេសកម្ពុជាទទួលបានចំណាត់ថ្នាក់ទី ៤[5] ក្នុងពិភពលោក ខាងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

ទី៤- ការបន្តពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេសតាមរយៈការអនុវត្ត «**កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ- ដំណាក់កាលទី ២**» ដែលមានគោលដៅបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ។ ជាលទ្ធផល ការរៀបចំ និង ការអនុវត្តថវិកា ត្រូវបានកែលម្អ តាមរយៈការពង្រឹងការប្រមូល និង ការគ្រប់គ្រងចំណូល, ការគ្រប់គ្រងសាច់ប្រាក់ ព្រមទាំងការធ្វើវិចារណកម្មចំណាយ និង ការកែលម្អការអនុវត្តចំណាយ ដែលបានផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាល ដោះ-

[4] *នៅក្នុងឯកសារនេះ ពាក្យ «ដុល្លារ» គឺសំដៅដល់ «ដុល្លារសហរដ្ឋអាមេរិក»*

[5] *ចំណាត់ថ្នាក់នៃការកាត់បន្ថយភាពក្រីក្ររបស់បណ្តាប្រទេសក្នុងពិភពលោក, (PovcalNet), ធនាគារពិភពលោក (WB), ឆ្នាំ ២០១២*

ស្រាយបាននូវតម្រូវការចំណាយចាំបាច់ និង អាទិភាពនានា ដូចជាការដំឡើងបៀវត្ស, ការបង្កើនការវិនិយោគ ដើម្បីជំរុញកំណើន, ការទប់ទល់នឹងវិបត្តិកលិយុគហិរញ្ញវត្ថុសកលលោក និង ការធ្លាក់ចុះសេដ្ឋកិច្ច ព្រមទាំងការដោះស្រាយផលវិបាកនៃគ្រោះធម្មជាតិ ជាដើម ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានបង្កើនបៀវត្សមូលដ្ឋាន ២០% រៀងរាល់ឆ្នាំ និង បានវិនិយោគយ៉ាងគំហុក ទៅលើការស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធសង្គម- សេដ្ឋកិច្ច ។

ទី៥- ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ក្នុងនោះ ផ្លូវជាតិចំនួន ៧៧,៤% នៃប្រវែងសរុប ៥ ៦០០ គីឡូម៉ែត្រ ត្រូវបានកសាង ពង្រីក និង ចាក់កៅស៊ូរួចរាល់ ហើយការផ្គត់ផ្គង់អគ្គិសនីបានគ្របដណ្តប់ប្រមាណ ៦៨% នៃចំនួនភូមិសរុបនៅក្នុងប្រទេស ។ រីឯវិស័យធារាសាស្ត្រ, ថាមពល និង ទូរគមនាគមន៍ ក៏សម្រេចបាននូវការអភិវឌ្ឍគួរឱ្យកត់សម្គាល់ផងដែរ ។

ទី៦- ការអនុវត្តកំណែទម្រង់យ៉ាងស៊ីជម្រៅក្នុងវិស័យព្រៃឈើ និង នេសាទ ព្រមទាំងកំណែទម្រង់ក្នុងទ្រង់ទ្រាយធំ និង ជាប្រវត្តិសាស្ត្រ ក្នុងវិស័យគ្រប់គ្រងដីធ្លី តាមរយៈការផ្តល់កម្មសិទ្ធិស្របច្បាប់ជូនប្រជាពលរដ្ឋ ដែលជាបុរេលក្ខខណ្ឌដ៏ចម្បងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ។ ក្នុងវិស័យកំណែទម្រង់ដីធ្លី រាជរដ្ឋាភិបាលបានផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីចំនួនជាង ៣ លានប័ណ្ណ ជូនដល់ប្រជាជនកម្ពុជា និង បានផ្តល់សម្បទានដីសង្គមកិច្ចជូនដល់ប្រជាជនក្រីក្រ, យោធិន និង អតីតយុទ្ធជន ចំនួន ៣១ ពាន់គ្រួសារ ព្រមទាំងបានធ្វើប្រទានកម្ម ក្នុងក្របខណ្ឌ «**គោលនយោបាយចាស់- សកម្មភាពថ្មីលើវិស័យដីធ្លី**» ជូនប្រជាជនចំនួនប្រមាណ ៥ សែនគ្រួសារ ។

ទី៧- ការសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ នៅក្នុងការអនុវត្ត «**គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា**» ដែលក្នុងនេះ «**គោលដៅ**» ចំនួន ៤ ត្រូវបានសម្រេចរួចហើយមុនកាលបរិច្ឆេទកំណត់ គឺៈ **គោលដៅទី ៤ៈ** ការកាត់បន្ថយអត្រាមរណភាពកុមារ, **គោលដៅទី ៥ៈ** ការលើកកម្ពស់សុខភាពមាតា, **គោលដៅទី ៦ៈ** ការប្រយុទ្ធប្រឆាំងមេរោគអេដស៍, ជំងឺអេដស៍, ជំងឺគ្រុនចាញ់ និង ជំងឺរបេង និង **គោលដៅទី ៨ៈ** ការបង្កើនភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍ ។ ចំពោះ «**គោលដៅ**» ចំនួន ៤ ទៀត កម្ពុជាអាចនឹងសម្រេចបានតាមកាលបរិច្ឆេទកំណត់ នៅដំណាច់ឆ្នាំ ២០១៥ គឺៈ **គោលដៅទី ១ៈ** ការលុបបំបាត់ភាពក្រីក្រ និង ភាពអត់ឃ្លាន, **គោលដៅទី ២ៈ** ការសម្រេចឱ្យបាននូវការអប់រំបឋមសិក្សាជាសកល តាមរយៈការវិនិយោគយ៉ាងច្រើនក្នុងវិស័យអប់រំ, **គោលដៅទី ៣ៈ** ការលើកកម្ពស់សមភាពយេនឌ័រ និង ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី, និង **គោលដៅទី ៧ៈ** ការធានាចីរភាពបរិស្ថាន ។ ដោយឡែក **ចំពោះគោលដៅទី ៩** ដែលកម្ពុជាបានដាក់ចេញដោយខ្លួនឯង, ក៏កម្ពុជាសម្រេចបាននូវសមិទ្ធផលដ៏ធំធេងដែរ ជាអាទិ៍ : ការថយចុះយ៉ាងខ្លាំងនៃចំនួនគ្រោះថ្នាក់ ពីជាង ៣០០ ករណី នៅឆ្នាំ ២០០៨ មកត្រឹម ១៨៦ ករណី នៅឆ្នាំ ២០១២, ផ្ទៃដីដែលត្រូវបានបោសសម្អាតមីន និង សំណល់ជាតិផ្ទុះពីសង្គ្រាម ពីឆ្នាំ ២០០៨ ដល់ឆ្នាំ ២០១២ មានទំហំជាង ៥៣០ គីឡូម៉ែត្រក្រឡា រួមទាំងការបញ្ជូនកងកម្លាំងដោះមីនរបស់កម្ពុជា ចំនួនជាង ១ ៤០០ នាក់ ទៅចូលរួមក្នុងកងកម្លាំងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និង ការទទួលធ្វើជាម្ចាស់ផ្ទះរៀបចំ និង ដឹកនាំ កិច្ចប្រជុំលើកទី ១១ នៃរដ្ឋភាគីអនុសញ្ញាអូតាវ៉ា នៅចុងឆ្នាំ ២០១១ ផង ។ យ៉ាងណាក៏ដោយ ការសម្រេចឱ្យបាននូវគោលដៅទី ៩ នេះ ទាមទារឱ្យមានការប្រឹងប្រែងបន្ថែមទៀត ។

ទី៨- ការពង្រឹងភាពជាដៃគូបន្ថែមទៀត ជាមួយភាគីពាក់ព័ន្ធទាំងអស់ ពិសេសជាមួយដៃគូអភិវឌ្ឍន៍ផ្លូវការ, វិស័យឯកជន និង សង្គមស៊ីវិល តាមរយៈការដាក់ឱ្យដំណើរការប្រកបដោយប្រសិទ្ធភាពនូវយន្តការនៃភាពជាដៃគូនានា ។

ការវិនិយោគដោយថវិការដ្ឋ គួបផ្សំនឹងហិរញ្ញប្បទានសហប្រតិបត្តិការ និង លំហូរចូលយ៉ាងច្រើននៃការវិនិយោគឯកជន បានជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចកម្រិតខ្ពស់ និង ប្រកបដោយចីរភាព ។

ទី៩- ការសម្រេចបាននូវជោគជ័យក្នុងការធ្វើសមាហរណកម្មព្រះរាជាណាចក្រកម្ពុជា ទៅក្នុងសហគមន៍អន្តរជាតិ ទាំងក្នុងក្របខណ្ឌអនុតំបន់, តំបន់ និង ក្របខណ្ឌអន្តរជាតិ, ក៏ដូចជាការធានាបាននូវទំនាក់ទំនងមិត្តភាព និង កិច្ចសហ-ប្រតិបត្តិការល្អជាមួយគ្រប់ប្រទេស ដែលបាននាំមកនូវការឧបត្ថម្ភគាំទ្រយ៉ាងច្រើនសម្រាប់ការអភិវឌ្ឍប្រទេសជាតិ ។ ក្នុងឋានៈជាប្រធានអាស៊ាន កម្ពុជាបានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាន (នាខែ មេសា និង ខែវិច្ឆិកា ឆ្នាំ ២០១២) កិច្ចប្រជុំកំពូលអាស៊ីបូព៌ា, កិច្ចសន្ទនាអាស៊ានជាសកល ជាលើកទី ១ ក្នុងប្រវត្តិអាស៊ាន និង កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន ពាក់ព័ន្ធផ្សេងទៀត ព្រមទាំងកិច្ចប្រជុំសំខាន់ៗជាច្រើន ទាំងក្នុងក្របខណ្ឌតំបន់ និង អន្តរជាតិ ប្រកបដោយជោគជ័យ ដែលបានឆ្លុះបញ្ចាំងអំពីសមត្ថភាពរបស់កម្ពុជា ក្នុងការចូលរួមដោះស្រាយកិច្ចការតំបន់ និង ពិភពលោក និង បានធ្វើឱ្យកិត្យានុភាព និង កិត្តិនាមរបស់កម្ពុជា កាន់តែត្រូវបានលើកកម្ពស់លើឆាកអន្តរជាតិ ។ ជាមួយគ្នានេះ កម្ពុជាបានបំពេញការងារប្រកបដោយផ្លែផ្កា ក្នុងឋានៈជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក និង អង្គការអន្តរជាតិផ្សេងៗទៀត ព្រមទាំងបានចូលរួមយ៉ាងសកម្ម ក្នុងការបំពេញបេសកកម្មថែរក្សាសន្តិភាពនៅប្រទេសមួយចំនួន ក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ ។ កម្ពុជាបានចុះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅឆ្នាំ ២០០៨ បន្ទាប់ពីការចុះក្នុងបញ្ជីនេះ នូវរមណីយដ្ឋានអង្គរ និង សម្បត្តិវប្បធម៌អរូបិយនៃមនុស្សជាតិមួយចំនួនទៀត និង បានធ្វើជាម្ចាស់ផ្ទះក្នុងការទទួលរៀបចំ ព្រមទាំងបានដឹកនាំសម័យប្រជុំលើកទី ៣៧ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៅឆ្នាំ ២០១៣ ដោយជោគជ័យ ក្នុងឋានៈជាប្រធាននៃគណៈកម្មាធិការនេះ ។

## ១.២. បញ្ហាប្រឈម និង ការលានុវត្តភាពរបស់កម្ពុជា

8. ទន្ទឹមនឹងទទួលបានជោគជ័យក្នុងការអនុវត្ត «**យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ២**» កម្ពុជានៅបន្តជួបនឹងបញ្ហាប្រឈមសំខាន់ៗមួយចំនួនដូចតទៅ ÷

ទី១- ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពិភពលោក នៅបន្តគំរាមដល់កំណើនសេដ្ឋកិច្ច ដោយសារសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកលើទីផ្សារខាងក្រៅ ហើយមូលដ្ឋានសេដ្ឋកិច្ចក៏មិនទាន់ត្រូវបានធ្វើពិពិធកម្មទូលំទូលាយនៅឡើយ ។ ម្យ៉ាងទៀត ទោះបីជាក្នុងរយៈពេលកន្លងមក កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និង បានកាត់បន្ថយភាពក្រីក្រលឿនក៏ដោយ ក៏អត្រាភាពក្រីក្រនៅតំបន់ជនបទនៅមានកម្រិតខ្ពស់ ហើយសមិទ្ធផលក្នុងការកាត់បន្ថយគម្លាតរវាងអ្នកមាន និង អ្នកក្រ និង រវាងទីក្រុង និង ជនបទ ដែលសម្រេចបានមក ក៏នៅមានភាពផុយស្រួយនៅឡើយដែរ ។

ទី២- ដុល្លាវូបនីយកម្មខ្ពស់នៃសេដ្ឋកិច្ចកម្ពុជា បានដាក់កម្រិតមួយចំនួនទៅលើការអនុវត្តគោលនយោបាយរូបិយវត្ថុ ។ ម៉្យាងវិញទៀត ទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការគ្រប់គ្រងវិស័យធនាគារ និង ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារក្តី, ក៏បញ្ហាប្រឈមនៅតែមាន ពិសេសក្នុងការពង្រឹងក្របខណ្ឌគតិយុត្ត និងយន្តការត្រួតពិនិត្យ ។

ទី៣- ការផ្តល់សេវាសាធារណៈ និង សេវាយុត្តិធម៌ នៅមិនទាន់ទទួលបានជំនឿទុកចិត្តពេញលេញ ពីសំណាក់មហាជន ។ ការងារកសាងក្របខណ្ឌច្បាប់ នៅមិនទាន់គ្រប់ជ្រុងជ្រោយ ហើយការយល់ដឹង និង សមត្ថភាពក្នុងការអនុវត្ត

ច្បាប់ ក៏នៅតែមិនទាន់ដល់កម្រិតដែលរាជរដ្ឋាភិបាលចង់បាននៅឡើយ ។ ទន្ទឹមនេះ ការរៀបចំ និង កំណត់រចនាសម្ព័ន្ធ និង មុខងាររបស់ស្ថាប័នថ្នាក់ក្រោមជាតិ ក៏នៅមិនទាន់អាចឆ្លើយតបបានទាំងស្រុង ទៅនឹងតម្រូវការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិផងដែរ ។

ទី៤- ថ្លៃដឹកជញ្ជូនខ្ពស់ធៀបនឹងប្រទេសជិតខាង និង ការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនគ្រប់ប្រភេទ ឱ្យក្លាយជាប្រព័ន្ធឡូជិស្ទីកមួយដ៏រស់រវើក នៅក្នុងក្របខណ្ឌទូទាំងប្រទេស ដើម្បីបង្កើនប្រសិទ្ធភាពនៃសេដ្ឋកិច្ច និង ភាពប្រកួតប្រជែងរបស់កម្ពុជា នៅតែជាបញ្ហាប្រឈមនៅឡើយ ។ ទន្ទឹមនេះ ការជួសជុល និង ការថែទាំប្រព័ន្ធផ្លូវគមនាគមន៍ ឱ្យបានទាន់ពេលវេលា, បញ្ហាការដឹកជញ្ជូនលើសទម្ងន់កំណត់, បញ្ហាសុវត្ថិភាព និង ការកកស្ទះចរាចរណ៍ ក៏ទាមទារឱ្យមានការគ្រប់គ្រងកាន់តែមានប្រសិទ្ធភាពថែមទៀត ។

ទី៥- ថ្វីត្បិតតែវិស័យថាមពលអគ្គិសនីមានវឌ្ឍនភាពច្រើនគួរឱ្យកត់សម្គាល់ក្តី ថ្លៃថាមពលអគ្គិសនីនៅតែមានកម្រិតខ្ពស់ធៀបនឹងប្រទេសជិតខាង ហើយការធានាភាពទុកចិត្តពេញលេញក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនី នៅតែជាឧបសគ្គ សម្រាប់ពង្រឹងភាពប្រកួតប្រជែង និង ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាសម្រាប់ការទាក់ទាញការវិនិយោគ និង ការលើកកម្ពស់ជីវភាពប្រជាជន ។ ទន្ទឹមនេះ សេចក្តីត្រូវការក្នុងការផ្តល់សេវាអគ្គិសនីទូទាំងប្រទេស, ការពង្រីកវិសាល-ភាពនៃការផ្គង់ផ្គង់ថាមពលអគ្គិសនី នៅតំបន់ដែលមានដង់ស៊ីតេអ្នកប្រើប្រាស់តិច ពិសេស នៅទីជនបទ ក៏អាចជះឥទ្ធិពលអវិជ្ជមានដល់ការខិតខំប្រឹងប្រែង ក្នុងការបញ្ចុះថ្លៃថាមពលអគ្គិសនីផងដែរ ។

ទី៦- ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រនៅមិនទាន់ឆ្លើយតបពេញលេញនៅឡើយ ទៅនឹងសេចក្តីត្រូវការ ពិសេសការបង្កើនរដូវដាំដុះ ដែលចាំបាច់ទាមទារនូវការវិនិយោគបន្ថែមទៀត ហើយការថែទាំ និង ប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ ដែលមានស្រាប់ ក៏នៅតែជាបញ្ហាប្រឈម ។ ចំពោះបញ្ហាទឹកស្អាត ក៏ទាមទារឱ្យមានការអភិវឌ្ឍ និង ពង្រីកវិសាលភាពបន្ថែមទៀត ដើម្បីផ្តល់សេវានេះ ក្នុងថ្លៃសមរម្យ ជូនដល់ប្រជាជន ជាពិសេសនៅតំបន់ជនបទ ក្រៅរាជធានីភ្នំពេញ និង ក្រៅទីប្រជុំជនធំៗ ។

ទី៧- ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និង សមត្ថភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចកម្ពុជា ដែលជាកត្តាគន្លឹះ សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និង ភាពប្រកួតប្រជែងរបស់ប្រទេសទាំងក្នុងពេលចំពោះមុខ និង សម្រាប់អនាគតរយៈពេលវែង នៅតែជាបញ្ហាប្រឈមដ៏ចម្បងមួយរបស់រាជរដ្ឋាភិបាល ។ ជាក់ស្តែង ក្នុងវិស័យអប់រំ រាជរដ្ឋាភិបាលត្រូវបន្តផ្តោតអាទិភាពលើការពង្រឹងគុណភាព, ភាពអាចឆ្លើយតបបានទៅនឹងសេចក្តីត្រូវការនៃទីផ្សារពលកម្ម និង ការអភិវឌ្ឍជំនាញបច្ចេកទេសសម្រាប់យុវជន ដើម្បីបង្កើនឱកាសការងារ និង ប្រើប្រាស់ឱ្យអស់នូវសក្តានុពលនៃផលលាភប្រជាសាស្ត្ររបស់កម្ពុជា ក៏ដូចជាដើម្បីធានាការបន្តវេនក្នុងការដឹកនាំ និង អភិវឌ្ឍប្រទេស ។ ចំពោះវិស័យសុខាភិបាល ការពង្រីកវិសាលភាពបន្ថែមទៀត, ការបន្តពង្រឹងគុណភាព និង ការធានាថ្លៃសមរម្យនៃសេវាសុខាភិបាល នៅបន្តជាកង្វល់ចម្បងមួយ ដែលរាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ដោះស្រាយ រួមជាមួយនឹងការពង្រឹង និង ពង្រីកប្រព័ន្ធសុវត្ថិភាពសង្គម, ការលើកកម្ពស់អនាម័យ ព្រមទាំងការបន្តកែលម្អស្ថានភាពអាហារូបត្ថម្ភ និង ការលើកស្ទួយសមភាពយេនឌ័រ ។

ទី៨- ថ្វីត្បិតតែការគ្រប់គ្រងបរិស្ថាន និង ធនធានធម្មជាតិត្រូវបានកែលម្អ តាមរយៈការពង្រឹងការគ្រប់គ្រងធនធានរ៉ែ និង ការអនុវត្តកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យព្រៃឈើ, វិស័យជលផល រួមទាំងការអភិរក្សមច្ឆជាតិ, វិស័យដីធ្លី, ការគ្រប់គ្រងធនធានទឹក រួមបញ្ចូលទាំងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីនៃបឹងទន្លេសាប និង ទន្លេមេគង្គផង, បញ្ហាប្រឈមនៅតែមានច្រើននៅឡើយ ហើយប្រការនេះ ទាមទារឱ្យមានការខិតខំប្រឹងប្រែង និង ការផ្ដួចផ្ដើមគំនិតថ្មីបន្ថែមទៀត ដើម្បីធានាឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ។ ទន្ទឹមនេះ ការប្រែប្រួលអាកាសធាតុ បាន និង កំពុងជះឥទ្ធិពលអវិជ្ជមានលើប្រព័ន្ធអេកូឡូស៊ី និង លើការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចកម្ពុជា ។

ទី៩- ការធ្វើសមាហរណកម្មក្នុងតំបន់ និង សកលលោក ជាអាទិ៍ សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥ និង សមាជិកភាពនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក តម្រូវឱ្យមានកិច្ចសម្របសម្រួល និង ការបង្កើនសមត្ថភាពធនធានមនុស្ស និង ស្ថាប័ន ព្រមទាំងការធ្វើកំណែទម្រង់រចនាសម្ព័ន្ធផ្ទៃក្នុងនានា ឱ្យបានប្រកបដោយប្រសិទ្ធភាព និង ទាន់ពេលវេលា ដើម្បីធានាឱ្យកម្ពុជាអាចទទួលបានប្រយោជន៍ពីសមាហរណកម្មនេះ ។

9. ជាមួយនេះ បរិការណ៍សកល និង ក្នុងប្រទេស នាពេលបច្ចុប្បន្ន បានផ្ដល់ឱ្យកម្ពុជានូវកាលានុវត្តភាពសំខាន់ៗ ដូចតទៅ ÷

ទី១- ស្ថានភាពភូមិសាស្ត្រ- នយោបាយ និង ភូមិសាស្ត្រ- សេដ្ឋកិច្ចក្នុងពិភពលោក បានបង្ហាញឱ្យឃើញអំពីតួនាទីកាន់តែសំខាន់ឡើងរបស់ទ្វីបអាស៊ី ជាពិសេស អាស៊ីបូព៌ា ក្នុងការអូសទាញកំណើនសេដ្ឋកិច្ចពិភពលោក ទន្ទឹមនឹងនិន្នាការនៃការងាកពីការប្រើប្រាស់ប្រភពក្រៅស្រុក មកប្រើប្រាស់ប្រភពក្នុងស្រុក ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច ។ ប្រការនេះបានធ្វើឱ្យតំបន់អាស៊ីក្លាយទៅជាគោលដៅវិនិយោគផង និង ជាទីផ្សារទំនិញប្រើប្រាស់ផង ដែលនឹងផ្ដល់ «**ឱកាសមាស**» សម្រាប់ការអភិវឌ្ឍ និង ទំនើបកម្មនៃវិស័យឧស្សាហកម្ម, ផលិតកម្ម និង សេវា នៅក្នុងតំបន់ ។ កម្ពុជាស្ថិតនៅចំកណ្ដាលនៃតំបន់ ដែលកំពុងមានកំណើនប្រកបដោយជវភាពនេះ និង មានសក្ដានុពលដើម្បីក្លាយទៅជាផ្នែកមួយនៃខ្សែចង្វាក់ផលិតកម្មក្នុងតំបន់អាស៊ីបូព៌ា ។

ទី២- ការកើនឡើងគួរឱ្យកត់សម្គាល់នៃការប្រកួតប្រជែងរវាងតំបន់ពាណិជ្ជកម្មពីរនៅអាស៊ី- ប៉ាស៊ីហ្វិក គឺភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ និង ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក នឹងបង្កើតឡើងនូវចលនការសេរីភាវូបនីយកម្មពាណិជ្ជកម្មទំនិញ, សេវា និងការវិនិយោគ ដ៏ធំសម្បើមមួយនៅក្នុងតំបន់ ។ ចលនការនេះ កើតឡើងចំពេលដែលអាស៊ានកំពុងធ្វើសមាហរណកម្មយ៉ាងស៊ីជម្រៅ ពោលគឺការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ ២០១៥ និង ក្នុងខណៈដែលអាស៊ានកំពុងបន្តខិតខំដើរតួនាទីស្នូលនៅក្នុងនិម្មាបនកម្មតំបន់ ។ ក្នុងបរិការណ៍នេះ អាស៊ាននឹងក្លាយជាតំបន់មួយ ដែលកាន់តែមានភាពទាក់ទាញចំពោះការវិនិយោគ ។ ប្រការនេះ នឹងផ្ដល់ឱកាសដល់កម្ពុជាក្នុងការស្រូបយកការវិនិយោគ និង ការពង្រីកទីផ្សារនាំចេញរបស់ខ្លួន ឱ្យកាន់តែធំទូលាយ ដោយផ្សារភ្ជាប់ឧស្សាហកម្ម និង ពាណិជ្ជកម្ម ក៏ដូចជាការតភ្ជាប់ជារូបវន្ត និង ស្ថាប័ន ជាមួយនឹងខ្សែចង្វាក់ផលិតកម្ម និង បណ្ដាញផ្គត់ផ្គង់នៅក្នុងតំបន់ និង អន្តរតំបន់ ។

ទី៣- ផលលាភប្រជាសាស្ត្រ និង អត្រាទាបនៃអ្នករស់នៅក្នុងបន្ទុក គួបផ្សំនឹងការកើនឡើងនៃចំនួនប្រជាជនដែលមានចំណូលមធ្យម និង វណ្ណៈកណ្ដាល នឹងបង្កើតកាលានុវត្តភាពសម្រាប់កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ច

កម្រិតខ្ពស់ ក្នុងរយៈពេលប្រមាណបីទសវត្សរ៍ខាងមុខ ។ ដូច្នេះ កម្ពុជាអាចប្រើប្រាស់កាលានុវត្តភាពនេះ ដើម្បីជំរុញការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ប្រកបដោយចីរភាពក្នុងរយៈពេលវែង ។

ទី៤- ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា បានចាប់ផ្តើមឡើងពីមូលដ្ឋានមួយទាប ។ អាស្រ័យហេតុនេះ កម្ពុជានៅមានសក្តានុពលយ៉ាងច្រើន, នៅក្នុងគ្រប់ផ្នែក គ្រប់វិស័យ, សម្រាប់ប្រើប្រាស់ដើម្បីបន្តការឈានឡើងរបស់ខ្លួន, ទាំងក្នុងផ្នែកសេដ្ឋកិច្ចរូបវន្ត រួមមាន វិស័យកសិកម្ម, ឧស្សាហកម្ម និង សេវា, ទាំងក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ រួមមាន ការបន្តបង្កើនភាពស៊ីជម្រៅនៃអន្តរការីយកម្មហិរញ្ញវត្ថុ, ការទើបងើបឡើងនៃវិស័យធានារ៉ាប់រង និង ការបង្កើតឡើងនូវទីផ្សារមូលបត្រ ជាដើម, ដែលនឹងចូលរួមជំរុញ និង ធានាចិរភាពនៃកំណើនសេដ្ឋកិច្ចជាតិ សម្រាប់រយៈពេលមធ្យម និងរយៈពេលវែងខាងមុខ ។

## ១.៣. ភាពចាំបាច់ក្នុងការបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណ

10. ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាល គឺកសាងសង្គមកម្ពុជាមួយ ដែលមានសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ, សណ្តាប់ធ្នាប់សង្គម, កំណើនសេដ្ឋកិច្ចរយៈពេលវែង, ការអភិវឌ្ឍប្រកបដោយចីរភាព និង សមធម៌, ការកែលម្អជីវភាព និង ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន, ការការពារបរិស្ថាន, ការលើកស្ទួយវប្បធម៌ និង អត្តសញ្ញាណជាតិ ជាមួយនឹងការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ព្រមទាំងការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស និង មានកោសិកាផ្សារភ្ជាប់គ្នា, មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់ និង វប្បធម៌ជ្រៅជ្រះ, មានជីវភាពសមរម្យ និង មានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងសង្គមជាតិ ទាំងក្នុងក្រុមគ្រួសារ ព្រមទាំងមានកិត្យានុភាពខ្ពស់លើឆាកអន្តរជាតិ ក្នុងឋានៈជាសមាជិកពេញសិទ្ធិ និង ស្មើសិទ្ធិ នៅក្នុងសហគមន៍អន្តរជាតិ ។ ស្របតាមចក្ខុវិស័យនេះ យុទ្ធសាស្ត្រចតុកោណបានដាក់ចេញនូវទិសដៅចម្បងបួន ដែលស្តែងឡើងតាមរយៈបាវចនាៈ **កំណើន**, **ការងារ**, **សមធម៌** និង **ប្រសិទ្ធភាព** ។

11. ទន្ទឹមនឹងនេះ កម្ពុជាមានមហិច្ឆតាប្រែក្លាយខ្លួន ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ ហើយឈានឡើងទៅជាប្រទេសមានចំណូលខ្ពស់ក្នុងឆ្នាំ ២០៥០ ។ ដើម្បីសម្រេចបាននូវមហិច្ឆតានេះ រាជរដ្ឋាភិបាលនឹងរៀបចំ «**ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០**» ព្រមទាំង «**គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម**» និង ឯកសារគោល-នយោបាយគួបផ្សំផ្សេងទៀត ដែលជាកញ្ចប់គោលនយោបាយ និង ជាយុទ្ធសាស្ត្រនៃដំណើរផ្លាស់ប្តូររបស់កម្ពុជា ទាំងបរិមាណ ទាំងគុណភាព ។ ដូច្នេះ «**យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៣**» គឺជាឧបករណ៍គោលនយោបាយប្រកបដោយប្រសិទ្ធភាពមួយ ក្នុងការឈានទៅសម្រេចនូវចក្ខុវិស័យខាងលើ ។ ក្នុងគោលបំណងធានាសម្រេចបាននូវចក្ខុវិស័យនេះ រាជរដ្ឋាភិបាលនីតិកាលទី ៥ នឹងបន្តពង្រឹង និង ពង្រីកសមិទ្ធផលនានា ដែលរាជរដ្ឋាភិបាលសម្រេចបានក្នុងនីតិកាលទី ៤ កន្លងមក តាមរយៈការបន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម, ការលើកកម្ពស់កម្រិតជីវភាព និង សុខុមាលភាពរបស់ប្រជាជន ដោយអនុវត្តវិធានការជាក់ស្តែងនានា សំដៅលើកស្ទួយនីតិរដ្ឋ, ការគោរពសិទ្ធិសេរីភាព និង សេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សម្រាប់ពង្រឹងបរិស្ថាននយោបាយ និង សន្តិសុខ ដែលអនុគ្រោះដល់ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងរយៈពេលវែង ។ លើមូលដ្ឋាន

នេះ រាជរដ្ឋាភិបាលបានកំណត់ «**គោលដៅជាយុទ្ធសាស្ត្រ ៤**» និង «**វិស័យអាទិភាព ៤**» ដើម្បីឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តក្នុងការបន្តអនុវត្ត «**យុទ្ធសាស្ត្រចតុកោណ**» ។

12. «**គោលដៅជាយុទ្ធសាស្ត្រ ៤**» រួមមាន ÷

ទី១- ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ ៧% ប្រកបដោយចីរភាព, បរិយាប័ន្ន, សមធម៌ និង ធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ចឱ្យបានទូលាយ និង មានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អតិផរណាមានកម្រិតទាបអាចគ្រប់គ្រងបាន, អត្រាប្តូរប្រាក់មានស្ថិរភាព និង ទុនបម្រុងមានកំណើនជាប្រចាំ ។

ទី២- បង្កើតការងារឱ្យបានកាន់តែច្រើនឡើង ជូនដល់ប្រជាជន ពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈការបន្តខិតខំកែលម្អ និង បង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងការទាក់ទាញ និង ការជំរុញលើកទឹកចិត្តដល់សកម្មភាពវិនិយោគ ទាំងវិនិយោគក្នុងប្រទេស ទាំងវិនិយោគមកពីក្រៅប្រទេស ។

ទី៣- សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង ១% ក្នុងមួយឆ្នាំ ក៏ដូចជាគោលដៅផ្សេងៗទៀត ដែលត្រូវបានកំណត់ក្នុង «**គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា**» ទន្ទឹមនឹងការផ្តោតអាទិភាពកាន់តែខ្លាំងឡើងលើការអភិវឌ្ឍធនធានមនុស្ស, ការគ្រប់គ្រងបរិស្ថាន និង ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព ។

ទី៤- បន្តពង្រឹងសមត្ថភាព និង អភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឱ្យកាន់តែប្រសើរឡើង ។

13. ក្នុងនីតិកាលកន្លងមក នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលបានកំណត់អាទិភាពចម្បងចំនួន ៤ គឺ **ផ្លូវ**, **ទឹក**, **ភ្លើង** និង **មនុស្ស** ។ ការពិត អាទិភាពទាំង ៤ នេះ ធ្លាប់ត្រូវបានកំណត់តាំងពីទសវត្សរ៍ឆ្នាំ ១៩៨០ មកម្ល៉េះ ។ តទៅមុខ កម្ពុជានៅត្រូវផ្តោតការយកចិត្តទុកដាក់លើអាទិភាពទាំង ៤ នេះ យូរថែមទៀត ដោយគ្រាន់តែផ្លាស់ប្តូរការសង្កត់ធ្ងន់ទៅលើវិស័យណាមួយ ទៅតាមកាលៈទេសៈ និង សភាពការណ៍ជាក់ស្តែងរបស់កម្ពុជាប៉ុណ្ណោះ ។ ក្នុងនីតិកាលទី ៣ និងទី ៤ កន្លងទៅនេះ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង លើការវិនិយោគក្នុងវិស័យផ្លូវ, ទឹក និង ភ្លើង ។ ក៏ប៉ុន្តែ ក្នុងយុគសម័យសេដ្ឋកិច្ចពុទ្ធិ និង បច្ចេកវិទ្យាព័ត៌មាន ឧត្តមភាពប្រកួតប្រជែងរបស់ប្រជាជាតិមួយ អាស្រ័យជាសំខាន់លើកត្តាធនធានមនុស្ស ដែលមានចំណេះដឹងខ្ពស់, ទូលំទូលាយ, មានភាពច្នៃប្រឌិត និងមានជំនាញច្បាស់លាស់ ។ ប្រការនេះ តម្រូវឱ្យរាជរដ្ឋាភិបាលផ្តល់ការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងៗ ទៅលើការអភិវឌ្ឍ «**មូលធនមនុស្ស**» ចាប់ពីពេលនេះទៅមុខ ទន្ទឹមនឹងការបន្តបង្កើនការវិនិយោគទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ផ្លូវ, ទឹក និង ភ្លើង ។

14. ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនីតិកាលទី ៥ នឹងផ្តោតការយកចិត្តទុកដាក់លើ «**វិស័យអាទិភាព ៤**» ដូចខាងក្រោម ÷

ទី១- ការអភិវឌ្ឍធនធានមនុស្ស ដែលនឹងធានាបាននូវការប្រកួតប្រជែងក្នុងទីផ្សារពលកម្មក្នុងតំបន់ ដែលកាន់តែបើកចំហ តាមរយៈ (១) • ការបណ្តុះបណ្តាលពលករឱ្យមានជំនាញ និង ផលិតភាពខ្ពស់ តាមសេចក្តីត្រូវការនៃទីផ្សារ និងអាចបង្កើតតម្លៃបន្ថែមខ្ពស់, (២) • ការរៀបចំក្របខណ្ឌគតិយុត្ត និង កសាងស្ថាប័នអប់រំ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដែល

ឆ្លើយតបទៅនឹងចំណុចទី ១ ខាងលើ, (៣)• ការលើកទឹកចិត្តវិស័យឯកជនឱ្យចូលរួមនៅក្នុងកិច្ចការនេះ និង (៤)• ការពង្រឹងគុណភាពនៃការអប់រំ និង ការលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រ, បច្ចេកវិទ្យា និង នវានុវត្តន៍ ។

ទី២- ការបន្តវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និង ការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម ដើម្បីកសាងប្រព័ន្ធឡូជីស្ទិកដ៏រស់រវើក តាមរយៈការសាងសង់បណ្ដាញដឹកជញ្ជូនពហុសណ្ឋាន ក្នុងគោលដៅធានាឱ្យបាននូវការតភ្ជាប់ផ្ទៃក្នុងប្រទេស និង ការតភ្ជាប់ជាមួយប្រទេសក្នុងតំបន់ និង ពិភពលោក ព្រមទាំងឆ្លើយតបបានទៅនឹងការរីកចម្រើនផ្នែកនគរូបនីយកម្ម ដែលនឹងនាំមកនូវៈ (១)• ការកាត់បន្ថយថ្លៃដឹកជញ្ជូន, (២)• ការបង្កើនភាពអាចទុកចិត្តបាន និង ភាពស័ក្តិសិទ្ធិ, (៣)• ការពង្រឹងភាពប្រកួតប្រជែង និង (៤)• ការបង្កើនការវិនិយោគ និងពាណិជ្ជកម្ម ។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលនឹងបន្តផ្ដល់អាទិភាពក្នុងការពង្រីកសមត្ថភាពផលិត និង ផ្គត់ផ្គង់ថាមពល ពីប្រភពកាន់តែថោក និង ពង្រីកបណ្ដាញចែកចាយ សំដៅធានាសន្តិសុខថាមពល, ភាពអាចទុកចិត្តបានក្នុងការផ្គត់ផ្គង់ថាមពល ព្រមទាំងថ្លៃសមរម្យ ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការនៃការអភិវឌ្ឍ ។

ទី៣- ការបន្តអភិវឌ្ឍ និង បង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្ម តាមរយៈ(១)• ការបង្កើនតម្លៃបន្ថែមនៃការផលិត និង ការនាំចេញអង្ករ ជាពិសេសការផ្ដោតលើអង្ករក្រអូប, អង្ករសរីរាង្គ និង កសិផលមានតម្លៃខ្ពស់ឯទៀត ដូចជា កៅស៊ូ, ស្វាយចន្ទី, ពោត, សណ្ដែកបាយ, សណ្ដែកសៀង, ល្ង, ម្រេច, ស្ករត្នោត, ផ្លែឈើ, កាហ្វេ, បន្លែបង្ការ និង ផ្កា ជាដើម, (២)• ការជំរុញការចិញ្ចឹមសត្វ និង វារីវប្បកម្ម ដែលទីផ្សារត្រូវការ ដូចជា សាច់, ត្រី, ផលិតផលទឹកដោះគោ ជាដើម, (៣)• ការជំរុញលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យកសិ-ឧស្សាហកម្ម និង(៤)• ការបង្កើនផលិតភាព, ទំនើបកម្មកសិកម្ម និង ការលើកកម្ពស់ពាណិជ្ជូបនីយកម្ម ។

ទី៤- ការពង្រឹងអភិបាលកិច្ច និង សមត្ថភាពនៃស្ថាប័នរដ្ឋ សំដៅបង្កើនប្រសិទ្ធភាពនៃសេវាសាធារណៈ និងកែលម្អបរិយាកាសវិនិយោគ តាមរយៈ (១)• ការបន្តអនុវត្តកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ដើម្បីធានាយុត្តិធម៌សង្គម ព្រមទាំងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ, សុចរិតភាព, តម្លាភាព និង គណនេយ្យភាព, (២)• ការបន្តអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ, កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ព្រមទាំងពង្រឹងស្ថាប័នត្រួតពិនិត្យ ដើម្បីបង្កិតសេវាសាធារណៈឱ្យជិតប្រជាជន, លើកកម្ពស់កិច្ចដំណើរការប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង ធានាបាននូវតុល្យភាពក្នុងការអនុវត្តអំណាច, (៣)• ការបន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាប្រសិទ្ធភាពក្នុងការវិភាជ និង ការប្រើប្រាស់ថវិកា និង(៤)• ការបង្កើនភាពទាក់ទាញចំពោះការវិនិយោគ ក្នុងនោះមានការកាត់បន្ថយថ្លៃដើម និង របាំងធុរកិច្ច, ការពិនិត្យឡើងវិញនូវរបបលើកទឹកចិត្តដល់ការវិនិយោគ, ការពង្រឹងភាពជឿទុកចិត្ត និង ភាពអាចប៉ាន់ប្រមាណបានក្នុងការធ្វើធុរកិច្ច ព្រមទាំងការផ្ដោតការយកចិត្តទុកដាក់លើកិច្ចដំណើរការនៃតំបន់សេដ្ឋកិច្ចពិសេស ។

**15.** ជារួម រាជរដ្ឋាភិបាលនីតិកាលទី ៥ ពិនិត្យឃើញនូវកត្តាជាក់ស្ដែងមួយចំនួនដែលកំណត់អំពីភាពចាំបាច់ក្នុងការបន្តអនុវត្ត «**យុទ្ធសាស្ត្រចតុកោណ**» រួមមាន ÷

ទី១- ភាពចាំបាច់ក្នុងការបន្តពង្រីក និង ពង្រឹងសមិទ្ធផលនានា ដែលរាជរដ្ឋាភិបាលសម្រេចបាន តាមរយៈការអនុវត្ត «**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ២**» ក្នុងនីតិកាលទី ៤ កន្លងមក ។

ទី២- ដូចបានគូសរំលេចខាងលើ ការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ២** នៅក្នុងនីតិកាលទី ៤ កន្លងទៅ បានបង្ហាញឱ្យឃើញនូវបញ្ហាប្រឈម និង កាលានុវត្តភាពសំខាន់ៗមួយចំនួន ដែលទាមទារឱ្យរាជរដ្ឋាភិបាលបន្តសម្រិតសម្រាំង, កែលម្អ និង ពង្រឹងអាទិភាពគោលនយោបាយរបស់ខ្លួន ហើយជំរុញអនុវត្តរបៀបវារៈគោលនយោបាយនេះក្នុងដំណាក់កាលបន្ទាប់ទៀត ។

ទី៣- ការបន្តអនុវត្ត «**យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៣**» គឺជាការបោះជំហានទៅមុខដ៏សំខាន់របស់កម្ពុជា ដើម្បីឈានឡើងទៅកាន់ដំណាក់កាលថ្មីនៃការអភិវឌ្ឍ ពោលគឺការឆ្លងកាត់ពីឋានៈនៃប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយបន្ថែមលើនេះ បន្តរៀបចំកសាងមូលដ្ឋានគ្រឹះ សម្រាប់ការសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់ខ្លួន ពិសេសគឺមហិច្ឆតាក្នុងការប្រែក្លាយខ្លួនទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ និង ជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។

ទី៤- ឆន្ទៈ និង បំណងប្រាថ្នារបស់ប្រជាពលរដ្ឋកម្ពុជា ដែលជាម្ចាស់ឆ្នោត គួបផ្សំនឹងការប្រែប្រួលសភាពការណ៍ពិភពលោក និង សភាពការណ៍ក្នុងប្រទេស គឺជាកត្តាកំណត់សំខាន់មួយទៀត ដែលទាមទារឱ្យរាជរដ្ឋាភិបាលកែលម្អ និង សម្រិតសម្រាំងបន្ថែមនូវ «**យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ២**» ហើយជំរុញអនុវត្ត ក្នុងដំណាក់កាលទី ៣ ទៀត ។

# ផ្នែកទី ២

## ២.១. រចនាសម្ព័ន្ធនៃយុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៣

16. ជោគជ័យក្នុងការអនុវត្ត «**យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ១** និង **ទី ២** កន្លងមក គឺជាសក្ខីភាពឆ្លុះបញ្ចាំងឱ្យឃើញពីសមត្ថភាពដ៏រឹងមាំរបស់រាជរដ្ឋាភិបាលក្នុងការដឹកនាំប្រទេស ។ ក្នុងបរិការណ៍បច្ចុប្បន្ននេះ ផ្អែកលើភាពចាំបាច់ ដូចបានបញ្ជាក់ពីខាងដើម កម្ពុជាបានត្រៀមលក្ខណៈសម្បត្តិយ៉ាងហ្មត់ចត់ និង គ្រប់ជ្រុងជ្រោយ ដើម្បីដោះស្រាយបញ្ហាប្រឈមនានា និង ប្រើប្រាស់ឱ្យអស់នូវកាលានុវត្តភាព និង សក្តានុពលរបស់ខ្លួន ក្នុងដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍជាតិ ។

17. «**យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៣**» នៅរក្សាជារូមនូវរចនាសម្ព័ន្ធដើមរបស់ខ្លួន ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានកែសម្រួលលំដាប់អាទិភាពតាមការដ្ឋាន និង មុំមួយចំនួននៃយុទ្ធសាស្ត្រនេះ ព្រមទាំងបញ្ចូលអាទិភាពថ្មីមួយចំនួន ហើយបានសម្រិតសម្រាំង និង សម្រួចសកម្មភាពមួយចំនួនថែមទៀត ដើម្បីឱ្យស្របតាមសេចក្តីត្រូវការជាក់ស្តែង និង បរិការណ៍ថ្មីៗរបស់កម្ពុជា ដូចបានគូសបញ្ជាក់ខាងលើ និង ដែលត្រូវបានរំលេចក្នុង «**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា**» ។ ការកែសម្រួលលំដាប់អាទិភាពដែលមានស្រាប់ និង ការបន្ថែមអាទិភាពថ្មី ក៏មានគោលដៅលើកកម្ពស់កិច្ចអភិវឌ្ឍ តាមរយៈការពង្រឹងទំនាក់ទំនង ឬ អន្តរសកម្មរវាងបណ្តាទិសដៅទាំង ៤ នៃយុទ្ធសាស្ត្រ គឺ **កំណើន, ការងារ, សមធម៌** និង **ប្រសិទ្ធភាព** ដែលជាកញ្ចប់នៃសមីការតែមួយ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញច្បាស់អំពីការប្តេជ្ញារបស់រាជរដ្ឋាភិបាល ក្នុងការលើកស្ទួយសុខុមាលភាពរួមរបស់ប្រជាជន ។

18. លើមូលដ្ឋាននេះ «**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣**» មានរចនាសម្ព័ន្ធដូចតទៅ: (ក). បរិស្ថានគ្រប ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល, (ខ). ស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺអភិបាលកិច្ចល្អ, (គ). ចតុកោណ យុទ្ធសាស្ត្រទាំងបួន និង (ឃ). មុំយុទ្ធសាស្ត្រនៃចតុកោណនីមួយៗ ។

## ២.២. បរិស្ថានគ្របដណ្តប់ និង ស្នូល នៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣

### ២.២.១. បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល

19. បរិស្ថានគ្របដណ្តប់ល្អប្រសើរ គឺជាមូលដ្ឋានគ្រឹះសម្រាប់អនុវត្តប្រកបដោយជោគជ័យនូវអាទិភាពគោលនយោ-បាយតាមផ្នែកនៃ «**ចតុកោណយុទ្ធសាស្ត្រ**» ទាំងបួន ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យរយៈពេលវែងក្នុងការអភិវឌ្ឍ សង្គមកម្ពុជា ។ ក្នុងន័យនេះ ការបន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ, សណ្តាប់ធ្នាប់សាធារណៈ, ការបន្ត ធានាបរិស្ថានម៉ាក្រូសេដ្ឋកិច្ចដែលមានលក្ខណៈអនុគ្រោះ និង ចីរភាពនៃបរិស្ថាន, ការបន្តពង្រឹងភាពជាដៃគូ ក្នុងការ អភិវឌ្ឍ និង ការបន្តធ្វើសមាហរណកម្មប្រកបដោយប្រសិទ្ធភាព ទៅក្នុងតំបន់ និង ពិភពលោក គឺជាបុរេលក្ខខណ្ឌចាំបាច់ សម្រាប់អនុវត្តដោយជោគជ័យនូវ «**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣**» នេះ ។

#### ទី១. សន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ, សណ្តាប់ធ្នាប់សាធារណៈ

20. រាជរដ្ឋាភិបាលសម្រេចបានជោគជ័យតាមគោលដៅយុទ្ធសាស្ត្រ ដែលត្រូវបានដាក់ចេញមកក្នុងនីតិកាលកន្លងទៅ តាមរយៈ ការការពារអធិបតេយ្យជាតិ និង បូរណភាពទឹកដី, ការពង្រឹងស្ថិរភាពនយោបាយ, នីតិរដ្ឋ, លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស, សណ្តាប់ធ្នាប់សាធារណៈ រួមជាមួយនឹងវឌ្ឍនភាពល្អ ក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេស ជិតខាង ដើម្បីកសាងព្រំដែនមួយច្បាស់លាស់, សន្តិភាព, មិត្តភាព, សហប្រតិបត្តិការ និង ការអភិវឌ្ឍ ។ វឌ្ឍនភាពនេះ បានក្លាយទៅជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍ និង កាត់បន្ថយភាពក្រីក្រសម្រាប់រយៈពេលវែង ។ លើមូលដ្ឋាននេះ កម្ពុជា បានបង្កើនជំនឿទុកចិត្តពីសំណាក់វិនិយោគិន និង ទេសចរ ដែលត្រូវបានឆ្លុះបញ្ចាំងឡើង តាមរយៈការកើនឡើងនៃលំហូរ ទុនវិនិយោគ និង ចំនួនភ្ញៀវទេសចរមកកម្ពុជា ។

21. ផ្អែកលើសមិទ្ធផលខាងលើ នៅក្នុងនីតិកាលទី ៥ នេះ រាជរដ្ឋាភិបាលដាក់ចេញគោលដៅបន្តពង្រឹងថែមទៀត នូវកិច្ចការពារអធិបតេយ្យភាពជាតិ, បូរណភាពទឹកដី, ឯកភាពជាតិ និង ឯកភាពទឹកដី, សន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ, សណ្តាប់ធ្នាប់សាធារណៈ, ការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស និង ភាពសុខដុមក្នុងសង្គម ។

22. ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ : (១). ការបន្តពង្រឹងនីតិរដ្ឋ, លទ្ធិប្រជាធិបតេយ្យ, វប្បធម៌ សន្តិភាព, សីលធម៌សង្គម និង ការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងការបន្តប្រឆាំងដាច់ខាតរាល់ សកម្មភាព ឬ ការញុះញង់ណាមួយ ដែលបង្កអស្ថិរភាពនយោបាយ ឬ ចលាចលក្នុងសង្គម, (២). ការបន្តដោះស្រាយ បញ្ហាព្រំដែនគោក និង សមុទ្រជាមួយប្រទេសជិតខាង ដោយឈរលើគោលការណ៍ទាំងឡាយដែលបានគូសបញ្ជាក់ខាងលើ រួមជាមួយនឹងការបន្តរៀបចំ និង ជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ព្រំដែន ទន្ទឹមនឹងការបន្តមិនអនុញ្ញាតឱ្យប្រើ-ប្រាស់ទឹកដីកម្ពុជា ដើម្បីប្រឆាំងនឹងប្រទេសជិតខាង, (៣). ការទប់ស្កាត់ និង ការបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់

ប្រភេទ រួមទាំងការប្រឆាំងភេរវកម្ម និង ហិរញ្ញប្បទានភេរវកម្ម, ការប្រឆាំងការសម្អាតប្រាក់, ការប្រយុទ្ធប្រឆាំងសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងគ្រឿងញៀន និង ការជួញដូរមនុស្ស, ក៏ដូចជាការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទផ្សេងទៀត ព្រមទាំងការបន្តជំរុញអនុវត្តគោលនយោបាយ«**ភូមិ-ឃុំមានសុវត្ថិភាព**», និង(៤)• ការបន្តពង្រឹងសុវត្ថិភាពចរាចរណ៍ និង សណ្តាប់ធ្នាប់សាធារណៈ រួមទាំងការលុបបំបាត់បុស្តិ៍ត្រួតពិនិត្យមិនស្របច្បាប់ ។

## ទី២• បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានលក្ខណៈអនុគ្រោះ និង ចីរភាពបរិស្ថាន

23. ក្នុងនីតិកាលកន្លងទៅនេះ ទោះបីកម្ពុជាបានទទួលឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងពីវិបត្តិកលិយុគហិរញ្ញវត្ថុ និង ការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោក ដែលរហូតមកដល់បច្ចុប្បន្ននេះ នៅមិនទាន់ចប់នៅឡើយក៏ដោយ, ក៏រាជរដ្ឋាភិបាលទទួលបានជោគជ័យក្នុងការថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ហើយសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាខ្ពស់ជាង ៧% ឡើងវិញ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ បន្ទាប់ពីការធ្លាក់ចុះនៅឆ្នាំ ២០០៩ ។ ការបន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ- ដំណាក់កាលទី ២ បានពង្រឹងភាពជឿទុកចិត្តនៃថវិកា ហើយគណនេយ្យភាពហិរញ្ញវត្ថុក៏ត្រូវបានកែលម្អកាន់តែប្រសើរឡើង ។

24. ទោះជាយ៉ាងណាក៏ដោយ ភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចពិភពលោកដែលនៅមានបន្ត និង ការប្រកួតប្រជែងយ៉ាងស្វិតស្វាញក្នុងតំបន់ និង ក្នុងសកលលោក អាចនឹងបង្កើតបញ្ហាប្រឈមសម្រាប់កំណើនសេដ្ឋកិច្ចកម្ពុជា នាពេលអនាគត ។

25. ក្នុងបរិការណ៍នេះ ដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រខាងម៉ាក្រូសេដ្ឋកិច្ច ដូចបានគូសបញ្ជាក់ខាងលើ រាជរដ្ឋាភិបាលនីតិកាលទី ៥ នឹងផ្តោតអាទិភាពលើ ÷

ទី១- ការធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ភាពធន់នៃសេដ្ឋកិច្ចជាតិ តាមរយៈការបន្តអនុវត្តគោលនយោបាយថវិកាដែលមានលក្ខណៈទន់ភ្លន់ សម្របសម្រួល និង ប្រទាក់ក្រឡាគ្នា ជាមួយនឹងគោលនយោបាយរូបិយវត្ថុ, ការពង្រីកមូលដ្ឋាននាំចេញនៃសេដ្ឋកិច្ចកម្ពុជាឱ្យរីកចម្រើន ស្របជាមួយនឹងសេចក្តីត្រូវការក្នុងតំបន់ និង ពិភពលោក, ការពង្រីក **«លំហថវិកា»** រួមទាំងការរក្សាបំណុលសាធារណៈឱ្យនៅកម្រិតដែលអាចគ្រប់គ្រងបាន និង ការពង្រឹងការសម្របសម្រួលរវាងស្ថាប័ន ក្នុងក្របខណ្ឌយន្តការបង្ការ និង ដោះស្រាយវិបត្តិ ។

ទី២- ការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចបុរេសកម្ម (pro-active) សម្រាប់ទ្រទ្រង់កំណើន តាមរយៈការលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន, ការជំរុញអភិវឌ្ឍទីផ្សារការងារ, ការជំរុញការវិនិយោគក្នុងវិស័យគន្លឹះនានាសំដៅធ្វើពិពិធកម្មសេដ្ឋកិច្ច និង ធានាបាននូវសន្ទុះកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយសមធម៌, ការបន្តអនុវត្តកំណែទម្រង់រចនាសម្ព័ន្ធចាំបាច់នានា រួមទាំងការបន្តជំរុញអនុវត្ត **«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១- ២០២០»** ដើម្បីធានាប្រសិទ្ធភាពសេដ្ឋកិច្ច ព្រមទាំងភាពប្រកួតប្រជែង ទាំងក្នុងការទាក់ទាញការវិនិយោគ ទាំងក្នុងការជំរុញការនាំចេញ ។

ទី៣- ការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពទន់ភ្លន់ និង ប្រុងប្រយ័ត្ន រួមទាំងការពង្រឹងអប្បមាទក្នុងការគ្រប់គ្រងលំហូរមូលធន ដើម្បីរួមចំណែកដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង បង្កើតបរិស្ថានអំណោយផល

ដល់ការអភិវឌ្ឍ, ការធានាបង្កើនទុនបម្រុងអន្តរជាតិ, ការបន្តអនុវត្តរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ដើម្បីរក្សាស្ថិរភាពប្រាក់រៀល និង ពង្រឹងជំនឿទុកចិត្តរបស់សាធារណជន និង វិនិយោគិនមកលើប្រាក់រៀល ព្រមទាំងការជំរុញការប្រើប្រាស់ប្រាក់រៀលសំដៅកាត់បន្ថយដុល្លារូបនីយកម្ម, ការពង្រឹង និង រក្សាស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុ ពិសេសការ-ពង្រឹងប្រព័ន្ធធនាគារឱ្យកាន់តែមានប្រសិទ្ធភាព, សមាហរណកម្ម និង មានភាពប្រកួតប្រជែង តាមរយៈការពង្រឹងការត្រួតពិនិត្យ និង ការគ្រប់គ្រងហានិភ័យសន្ទនីយភាព, ហានិភ័យឥណទាន និង ហានិភ័យទីផ្សារ ដោយអនុលោមតាមស្តង់ដារអន្តរជាតិ ។

ទី៤- ការបន្តជំរុញអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឱ្យស្របតាមស្តង់ដារអន្តរជាតិ តាមរយៈ (១). ការបន្តបង្កើនភាពជឿទុកចិត្តនៃថវិកា ដោយបន្តពង្រឹងការគ្រប់គ្រង និង ការប្រមូលចំណូល ពិសេសការអនុម័ត និង ការដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ព្រមទាំងការកែលម្អការអនុវត្តថវិកា និង ការគ្រប់គ្រងសាច់ប្រាក់, (២). ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ដោយរៀបចំ និង ដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី, ប្លង់គណនេយ្យថ្មី និង អង្គភាពថវិកា ព្រមទាំងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមបច្ចេកវិទ្យាព័ត៌មាន, (៣). ការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង គណនេយ្យភាពសមិទ្ធកម្ម ដោយបន្តពង្រឹង និង ពង្រីកការអនុវត្តថវិកាកម្មវិធី ព្រមទាំងការកែលម្អការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ដោយដាក់ឱ្យអនុវត្តនូវឯកសារទស្សនាទានស្តីពីទិសដៅយុទ្ធ-សាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកា និង (៤). ការបន្តបង្កើនសមត្ថភាព និង ការចូលរួមប្រកបដោយភាពជាម្ចាស់ និង បុរេសកម្មរបស់ក្រសួងស្ថាប័ន ដើម្បីធានាជោគជ័យនៃការអនុវត្តកម្មវិធីកំណែទម្រង់ ។

**26.** ការគ្រប់គ្រងបរិស្ថាន និង ការប្រែប្រួលអាកាសធាតុ បានក្លាយជាបញ្ហាប្រឈមមួយទៀត សម្រាប់ចីរភាពនៃកំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍសង្គមកម្ពុជា ដោយសារសម្ពាធពីកំណើនប្រជាជន, ចរន្តនគរូបនីយកម្ម, វិបុលកម្ម និង ប្រពលកម្មកសិកម្ម ក៏ដូចជាការអភិវឌ្ឍវិស័យដឹកជញ្ជូន, ថាមពល និង វិស័យដទៃទៀត ។ បញ្ហាប្រឈមផ្នែកបរិស្ថានភាគច្រើនមានលក្ខណៈអន្តរវិស័យ ដែលទាមទារឱ្យមានការសម្របសម្រួលរវាងស្ថាប័នរដ្ឋ, ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ, ព្រមទាំងកិច្ចសហការជាមួយនឹងគ្រប់ភាគីពាក់ព័ន្ធ ។

**27.** ក្នុងន័យនេះ រាជរដ្ឋាភិបាលបន្តប្រកាន់យកនូវអភិក្រមគ្រប់ជ្រុងជ្រោយ សម្រាប់ការគ្រប់គ្រងបរិស្ថាននៅកម្ពុជា តាមរយៈ ÷

ទី១- ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ។

ទី២- ការខិតខំកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ តាមរយៈការពង្រឹងសមត្ថភាពបន្សាំ និង ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសការអនុវត្ត **«គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង»** និង **«ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ ២០១៣-២០៣០»** ។

ទី៣- ការបន្តពង្រឹងសមត្ថភាពបច្ចេកទេស និង ស្ថាប័ន ដើម្បីជំរុញការបញ្ជ្រាបប្រធានបទស្តីពីការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ, ច្បាប់ និង ផែនការ ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។

ទី៤- ការបន្តដាក់ចេញនូវវិធានការនានា ដើម្បីគ្រប់គ្រងការបំពុលបរិស្ថាន និង ប្រព័ន្ធអេកូឡូស៊ី ។

### ទី៣. ភាពជាដៃគូក្នុងការអភិវឌ្ឍ

**28.** គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី ៤ គឺពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍ តាមរយៈការ-ដាក់ឱ្យអនុវត្ត និង កែលម្អជាបន្តបន្ទាប់នូវក្របខណ្ឌគោលនយោបាយ, យន្តការខាងស្ថាប័ន និង លិខិតបទដ្ឋានចាំបាច់ជាច្រើន សម្រាប់គាំទ្រ និង បង្កើនប្រសិទ្ធភាពនៃដំណើរការពង្រឹងភាពជាដៃគូ ដើម្បីសម្រេចគោលដៅនៃកិច្ចអភិវឌ្ឍជាតិ ។

**29.** ក្នុងការពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ រាជរដ្ឋាភិបាលទទួលបានជោគជ័យគួរកត់សម្គាល់ ក្នុងការដឹកនាំ «**វេទិកានៃកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍកម្ពុជា**» ចាប់ពីឆ្នាំ ២០០៧ ជំនួសឱ្យយន្តការ «**កិច្ចប្រជុំពិគ្រោះយោបល់**» ។ ជាក់ស្តែង ដៃគូអភិវឌ្ឍន៍បានបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ប្រមាណ ១ ០០០ លានដុល្លារ ក្នុងមួយឆ្នាំ ពោលគឺខ្ពស់ជាងការសន្យា ក្នុងរយៈពេល ៥ ឆ្នាំកន្លងមក ។ លើសពីនេះ កម្ពុជាត្រូវបានទទួលស្គាល់ថា ជាប្រទេសដៃគូគំរូ និងឈានមុខក្នុងការអនុវត្ត «**សេចក្តីប្រកាសទីក្រុងប៉ារីស**» និង «**ផែនការសកម្មភាពទីក្រុងអាក្រា**» ស្តីពីការបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅតំបន់អាស៊ី- ប៉ាស៊ីហ្វិក ។ ក្នុងការពង្រឹងភាពជាដៃគូ ជាមួយវិស័យឯកជន រាជរដ្ឋាភិបាលបានកែលម្អជាបន្តបន្ទាប់នូវបរិស្ថាន សម្រាប់ជំរុញ និង ទាក់ទាញវិនិយោគ ។ ជាក់ស្តែង ក្នុងនីតិកាលទី ៤ នេះ ទំហំទុនវិនិយោគផ្ទាល់ពីបរទេសសម្រេចបានក្នុងមួយឆ្នាំប្រមាណ ៧០០ លានដុល្លារ ។ លើសពីនេះ ការប្រជុំដោយទៀងទាត់នៃ «**វេទិការាជរដ្ឋាភិបាល- ផ្នែកឯកជន**» បានដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវបញ្ហាប្រឈមនានាដែលវិស័យ ឯកជនជួបប្រទះ ។

**30.** ក្នុងកិច្ចការនេះ អាទិភាពរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី ៥ គឺ÷

ទី១- បន្តពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ដើម្បីប្រមូលធនធានហិរញ្ញប្បទានពីគ្រប់ប្រភពសម្រាប់អភិវឌ្ឍប្រទេស ដោយឈរលើគោលការណ៍នៃភាពជាម្ចាស់ និង ភាពជាអ្នកដឹកនាំរបស់រាជរដ្ឋា-ភិបាល ។

ទី២- រៀបចំ និង អនុវត្ត «**យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និង ភាពជាដៃគូឆ្នាំ ២០១៤- ២០១៨**» ។ គោលដៅចម្បងនៃយុទ្ធសាស្ត្រនេះ គឺការពង្រឹង «**ភាពជាដៃគូទូលំទូលាយជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់**» ក្នុងបរិការណ៍ថ្មីដែលកម្ពុជានឹងត្រូវដោះស្រាយបញ្ហាប្រឈមធំៗ ២ គឺ: (១). ភាពចាំបាច់ក្នុងការកំណត់ឡើងវិញ នូវតួនាទីនៃហិរញ្ញប្ប-ទានសហប្រតិបត្តិការ ដោយសារនិន្នាការថយចុះនៃហិរញ្ញប្បទានឥតសំណងលើសកលលោក និង ការវិវត្តនៃភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍នីមួយៗ (២). ការធ្លាក់ចុះនៃប្រភពហិរញ្ញប្បទានសម្បទាន នៅពេលដែលកម្ពុជាសម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប នាអនាគតដ៏ខ្លីខាងមុខ ។ បន្ថែមលើនេះ យុទ្ធសាស្ត្រនេះ ក៏នឹងរំលេចអំពីការប្តេជ្ញារបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តឱ្យបានពេញលេញនូវគោលការណ៍សកលចម្បងៗ ដែលត្រូវបានឯកភាពក្នុងវេទិកាកំពូលនានា ។

ទី៣- បន្តលើកកម្ពស់ និង បង្កើនប្រសិទ្ធភាពនៃយន្តការ «**វេទិការាជរដ្ឋាភិបាល- ផ្នែកឯកជន**» សំដៅពង្រឹងតួនាទីនៃយន្តការនេះ ក្នុងការផ្តល់ជម្រើស និង អនុសាសន៍គោលនយោបាយនានា ដើម្បីបង្កើនតួនាទីរបស់វិស័យឯកជនក្នុងកិច្ចការអភិវឌ្ឍន៍ ទន្ទឹមនឹងការបន្តពង្រឹងតួនាទីនៃការដោះស្រាយឧបសគ្គ និង កង្វល់នានារបស់វិស័យឯកជនពាក់ព័ន្ធនឹងធុរកិច្ចរបស់ខ្លួននៅកម្ពុជា ។

ទី៤- រៀបចំជាទៀងទាត់នូវកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំរវាងរាជរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាល ទន្ទឹមនឹងការបន្តជំរុញបង្កើតច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល ដោយមានការពិគ្រោះយោបល់ជាមួយនឹងបណ្តាភាគីពាក់ព័ន្ធទាំងអស់ ដើម្បីធានាប្រសិទ្ធភាព, តម្លាភាព និង គណនេយ្យភាពនៃកិច្ចប្រតិបត្តិការ ។

ទី៥- បន្តពង្រឹងយន្តការ **«វេទិកាកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍកម្ពុជា»**, **«វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន»**, **«កិច្ចពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាល»** និង **«កិច្ចពិគ្រោះយោបល់ទ្វេភាគី»** ក្នុងទិសដៅជំរុញឱ្យយន្តការទាំងនេះ ឈានក្លាយទៅជា **«វេទិកាអភិវឌ្ឍន៍កម្ពុជា»** ដែលជាយន្តការសម្រាប់រាជរដ្ឋាភិបាល និង ដៃគូអង្គអភិវឌ្ឍន៍ទាំងអស់ មានជាអាទិ៍ ដៃគូអភិវឌ្ឍន៍, វិស័យឯកជន និង អង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជា បណ្តាភាគីពាក់ព័ន្ធ ចូលរួមពិភាក្សាលើបញ្ហានានា ក្នុងការអភិវឌ្ឍប្រទេស ។

## ទី៤. សមាហរណកម្មកម្ពុជា កាន់តែស៊ីជម្រៅទៅក្នុងតំបន់ និង ពិភពលោក

31. ក្នុងនីតិកាលទី ៤ កន្លងមក គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការបន្តធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និង សហគមន៍អន្តរជាតិ ជាពិសេស តាមរយៈការចូលរួមក្នុងកិច្ចសហប្រតិបត្តិការក្នុងកម្រិតអនុតំបន់នានា, ការកសាងសហគមន៍អាស៊ាន និង ការបំពេញតួនាទីជាសមាជិកក្នុងអង្គការពាណិជ្ជកម្មពិភពលោក និង អង្គការអន្តរជាតិផ្សេងទៀត ។

32. ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលគួរឱ្យកត់សម្គាល់ ក្នុងការតភ្ជាប់ខាងផ្នែករូបវន្តជាមួយនឹងបណ្តាប្រទេសក្នុងតំបន់ និង បានធ្វើឱ្យកាន់តែស៊ីជម្រៅនូវសេរីភាវូបនីយកម្មសេដ្ឋកិច្ច និង ពាណិជ្ជកម្ម តាមរយៈការកែទម្រង់យ៉ាងទូលំទូលាយលើក្របខណ្ឌគតិយុត្ត ដែលបានធ្វើឱ្យកាន់តែប្រសើរនូវបរិយាកាសវិនិយោគ និង កិច្ច-សម្រួលពាណិជ្ជកម្ម ព្រមទាំងបានលើកតម្កើងរបបពាណិជ្ជកម្មកម្ពុជា ឱ្យមានសង្គតិភាពជាមួយនឹងវិធាន និង បទដ្ឋានអន្តរជាតិ ។ លើសពីនេះ រាជរដ្ឋាភិបាលបានចូលរួមយ៉ាងសកម្ម តាមរយៈការអនុវត្តតួនាទីស្មើភាព និង ស្មើសិទ្ធិរបស់ខ្លួននៅលើឆាកអន្តរជាតិ និង ក្នុងកិច្ចការសមាហរណកម្មតំបន់ ពិសេស ការចូលរួមលើកកម្ពស់តួនាទីមជ្ឈភាពរបស់អាស៊ានក្នុងការរៀបចំនិម្មាបនកម្មតំបន់ ។

33. ទន្ទឹមនេះ កម្ពុជានៅមានបញ្ហាប្រឈមជាច្រើន ដែលត្រូវដោះស្រាយ ក្នុងការបំពេញតួនាទីរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាពក្នុងសហគមន៍អន្តរជាតិ និង តំបន់ ពិសេស ក្នុងក្របខណ្ឌនៃការបង្កើតសហគមន៍អាស៊ាន នៅឆ្នាំ២០១៥ មានជាអាទិ៍ ការបន្តបង្កើនការតភ្ជាប់ផ្នែករូបវន្ត, កំណែទម្រង់ក្របខណ្ឌច្បាប់ និង ស្ថាប័ន ព្រមទាំងការកសាងសមត្ថភាពធនធានមនុស្ស ដើម្បីកម្ពុជាអាចចូលរួមអនុវត្ត និង ទាញយកប្រយោជន៍ប្រកបដោយប្រសិទ្ធភាព ពីកិច្ចការសមាហរណកម្មនេះ ។

34. ដូច្នេះ ក្នុងនីតិកាលទី ៥ រាជរដ្ឋាភិបាលនឹងបន្តបង្កើនការទាក់ទាញវិនិយោគ ទាំងក្នុង និង ក្រៅប្រទេស, ធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម, ពង្រីកទីផ្សារពាណិជ្ជកម្ម, ជំរុញការតភ្ជាប់បណ្តាញគមនាគមន៍ដឹកជញ្ជូន និង ការកែលម្អប្រព័ន្ធឡូជីស្ទីក, កែលម្អក្របខណ្ឌគតិយុត្ត, ពង្រឹងយន្តការស្ថាប័ន រួមទាំងយន្តការដោះស្រាយវិវាទ ព្រមទាំងបន្តលើកកម្ពស់កិច្ចការកសាងសមត្ថភាព ដើម្បីធានានូវបរិស្ថានអនុគ្រោះ សម្រាប់ការអភិវឌ្ឍកម្ពុជា ។

35. ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១. ការបន្តចូលរួមបំពេញតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ក្នុងរាល់កិច្ចការតំបន់ និង កិច្ចការអន្តរជាតិ ។

ទី២. ការដាក់ចេញនូវគោលនយោបាយចាំបាច់នានា ពិសេស «**គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម**» ដើម្បីឈានឡើងមួយកម្រិតទៀត ក្នុងខ្សែចង្វាក់តម្លៃនៃសេដ្ឋកិច្ចតំបន់ និង ពិភពលោក ពិសេស ក្នុងទីផ្សារអាស៊ី ដែលកំពុងមានកំណើនខ្ពស់ គួបផ្សំនឹងការផ្តោតការយកចិត្តទុកដាក់បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សម្រាប់ពលករកម្ពុជាគ្រប់ស្រទាប់ ។

ទី៣. ការបន្តកែលម្អក្របខណ្ឌគតិយុត្ត សំដៅធ្វើឱ្យកាន់តែប្រសើរឡើងថែមទៀត នូវបរិស្ថានធុរកិច្ច, ពាណិជ្ជកម្ម និង ការវិនិយោគ ។

ទី៤. ការចាត់វិធានការពង្រឹង និង ពង្រីកទីផ្សារនាំចេញរបស់កម្ពុជា ពិសេស តាមរយៈការចរចាបើកទីផ្សារជាមួយប្រទេសក្នុងតំបន់ និង ក្រៅតំបន់, ការបន្តជំរុញកែលម្អហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និង ប្រព័ន្ធឡូជិស្ទិក រួមទាំងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ដើម្បីសម្រួលលំហូរទំនិញ និង សេវា រាប់ទាំងសេវាហិរញ្ញវត្ថុផង ព្រមទាំងការកាត់បន្ថយរបាំងមិនមែនពន្ធនានា មានជាអាទិ៍ ការកែលម្អស្តង់ដារ, បទដ្ឋានអនាម័យ និង ភូតគាមអនាម័យ ។

ទី៥. ការចាត់វិធានការគោលនយោបាយចាំបាច់នានា ដើម្បីចូលរួមក្នុងសហគមន៍អាស៊ានឆ្នាំ ២០១៥ ពិសេស តាមរយៈការអនុវត្តដោយប្រសិទ្ធភាពនូវកិច្ចព្រមព្រៀង ដែលមានការពាក់ព័ន្ធទាំងឡាយរបស់អាស៊ាន ។

ទី៦. ការរៀបចំបង្កើតក្របខណ្ឌចាំបាច់នានា ដើម្បីគ្រប់គ្រងការប្រែប្រួលដែលកើតចេញមកពីសហគមន៍អាស៊ានឆ្នាំ ២០១៥ ក្នុងគោលដៅធានាផលប្រយោជន៍របស់កម្ពុជា ជាពិសេស ការគ្រប់គ្រងទីផ្សារពលកម្ម និង លំហូរពលករ ។

### ២.២.២. ស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺអភិបាលកិច្ចល្អ

**36.** អភិបាលកិច្ចល្អ នៅតែជាស្នូលនៃយុត្តិធម៌សង្គម និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាព និង សមធម៌ ។ ដើម្បីបន្តពង្រឹងអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលបន្តអនុវត្តកំណែទម្រង់ដោយឥតរាថយ ក្នុងវិស័យសំខាន់ៗ រួមមាន : (១). ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ, (២). កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌, (៣). កំណែទម្រង់រដ្ឋបាលសាធារណៈ និង (៤). កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ។ ទិសដៅសំខាន់បំផុតនៃកំណែទម្រង់ទាំងនេះ, រួមជាមួយនឹងកំណែទម្រង់ដទៃទៀត ដូចជា កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កំណែទម្រង់ដីធ្លី, កំណែ-ទម្រង់ព្រៃឈើ និង កំណែទម្រង់ជលផល, គឺការលើកកម្ពស់សមត្ថភាព និង ប្រសិទ្ធភាពការងារ និង ពង្រឹងគុណភាពនៃសេវាសាធារណៈ ឱ្យកាន់តែប្រសើរឡើង ដើម្បីបង្កើនជំនឿទុកចិត្ត និង ឆ្លើយតបទៅនឹងសេចក្តីត្រូវការ និង បំណងប្រាថ្នារបស់ប្រជាជន ព្រមទាំងសហគមន៍ធុរកិច្ច ។

### ទី១. ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

**37.** គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ គឺការអនុវត្តវិធានការប្រទាក់ក្រឡាគ្នា តាមរយៈការអប់រំ, បង្ការទប់ស្កាត់ជាមុន, ការពង្រឹងគណនេយ្យភាព និង ពង្រឹងសមត្ថភាពស្ថាប័ន, ការគាំទ្រ និង ការចូលរួមពីសាធារណជន, ការចូលរួមពីវិស័យឯកជន និង ការពង្រឹងការអនុវត្តច្បាប់ ។

38. រាជរដ្ឋាភិបាលសម្រេចបានលទ្ធផលជាក់ស្តែងជាច្រើន ដូចជាការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ នៅក្នុងខែមេសា ឆ្នាំ ២០១០, ការបង្កើតស្ថាប័នប្រឆាំងអំពើពុករលួយ ដែលរួមមានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង អង្គភាពប្រឆាំងអំពើពុករលួយ និង ការដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាពនូវយន្តការប្រឆាំងអំពើពុករលួយ ទាំងស្ថាប័ន និង បទប្បញ្ញត្តិនានា ដូចជា :(១)• ការផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ឱ្យជ្រួតជ្រាបនៅគ្រប់មជ្ឈដ្ឋាន ពិសេស នៅតាមក្រសួង និង ស្ថាប័នរដ្ឋ, (២)• ការរៀបចំក្រុមជនបង្គោលសម្រាប់សម្របសម្រួលការងារជាមួយអង្គភាពប្រឆាំងអំពើពុករលួយ, (៣)• ការរៀបចំប្រកាសទ្រព្យសម្បត្តិចំនួនពីរដង ដែលជាវិធានការបង្ការ និង បញ្ជាក់ពីសុចរិតភាពនៃមន្ត្រីសាធារណៈ, (៤)• ការកំណត់តារាងតម្លៃសេវាសាធារណៈ និង រយៈពេលសម្រាប់ការផ្តល់សេវា ដែលក្រសួង និង ស្ថាប័នរដ្ឋត្រូវអនុវត្ត និង ផ្តល់ជូនសាធារណជន ដើម្បីលុបបំបាត់ការបង់ប្រាក់ក្រៅផ្លូវការ និង ធានាឱ្យមានតម្លាភាព, គណនេយ្យភាព និង ការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ឱ្យកាន់តែប្រសើរឡើង និង(៥)• ការចាប់បញ្ជូនជនល្មើសដែលប្រព្រឹត្តអំពើពុករលួយ ទៅកាន់តុលាការជាបន្តបន្ទាប់ ជាមួយនឹងភស្តុតាងរឹងមាំ ។

39. ដើម្បីបន្តការងារប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធភាពក្នុងនីតិកាលទី ៥ នេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹង និង បង្កើនប្រសិទ្ធភាពនៃវិធានការស្នូលទាំង ៣ គឺ ÷

**ទី១- ការពង្រឹងការអប់រំមិនឱ្យប្រព្រឹត្តអំពើពុករលួយ:** រាជរដ្ឋាភិបាលបន្តជំរុញការផ្សព្វផ្សាយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយតាមគ្រប់រូបភាព ទាំងក្នុងវិស័យសាធារណៈ និង វិស័យឯកជន ឱ្យកាន់តែទូលំទូលាយថែមទៀត ដើម្បីលើកកម្ពស់ការយល់ដឹងពីផលវិបាកនៃអំពើពុករលួយ សំដៅធ្វើឱ្យម្នាក់ៗមិនចង់ប្រព្រឹត្តអំពើពុករលួយ ។ ការផ្សព្វផ្សាយនេះ នឹងត្រូវធ្វើឡើងតាមគ្រប់មធ្យោបាយ រួមមាន : ការចុះទៅពន្យល់ដល់ទីកន្លែងផ្ទាល់, ការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទ, ការបន្តប្រារព្ធទិវាជាតិប្រឆាំងអំពើពុករលួយជារៀងរាល់ឆ្នាំ និង ការបញ្ជ្រាបការយល់ដឹងអំពីផលវិបាកនៃអំពើពុករលួយ ព្រមទាំងអំពីច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ក្នុងកម្មវិធីសិក្សាគ្រប់កម្រិត ក្នុងគោលបំណងឱ្យយុវជនដែលជាទំពាំងស្នងឫស្សី ប្រកាន់ខ្ជាប់នូវសីលធម៌ស្អាតស្អំ និង ស្អប់ខ្ពើមអំពើពុករលួយ ។

**ទី២- ការបង្ការទប់ស្កាត់ការប្រព្រឹត្តអំពើពុករលួយ:** រាជរដ្ឋាភិបាលបន្តជំរុញការលើកទឹកចិត្តមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ឱ្យប្រកាន់ខ្ជាប់នូវសេចក្តីថ្លៃថ្នូរ សីលធម៌ស្អាតស្អំ មនសិការវិជ្ជាជីវៈ និង អនុវត្តឱ្យមានប្រសិទ្ធភាពនូវគោល-ការណ៍បញ្ចៀសវិសមិតភាពមុខងារ និង ទំនាស់ផលប្រយោជន៍ ដែលកំណត់ដោយច្បាប់ និង លិខិតបទដ្ឋានពាក់ព័ន្ធ តាមរយៈការបង្កើនការរៀបចំ និង អនុវត្តវិធានផ្ទៃក្នុងបន្ថែមលើច្បាប់ និង បទប្បញ្ញត្តិជាធរមាន ដូចជាការកសាងផែនការយុទ្ធសាស្ត្រ, ផែនការសកម្មភាព, បទបញ្ជាផ្ទៃក្នុង, ក្រមសីលធម៌វិជ្ជាជីវៈ និង បទប្បញ្ញត្តិផ្សេងៗទៀត ដើម្បីកសាងអង្គភាពស្អាតស្អំ និង ជាគំរូក្នុងការគ្រប់គ្រងការងារឱ្យបានជោគជ័យ និង ប្រសិទ្ធភាព ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងចាត់វិធានការជាក់ស្តែងថែមទៀត ដើម្បីពង្រឹងស្ថាប័នត្រួតពិនិត្យ និង កែលម្អឱ្យកាន់តែប្រសើរឡើងនូវការគ្រប់គ្រងចំណូល និង ចំណាយសាធារណៈ ក៏ដូចជាការពង្រីកវិសាលភាពនៃការប្រើប្រាស់តារាងតម្លៃសេវាសាធារណៈ ។

**ទី៣- ការបង្ក្រាបបទល្មើសបញ្ជូនទៅតុលាការៈ** រាជរដ្ឋាភិបាលនឹងបន្តចាត់វិធានការម៉ឺងម៉ាត់, តឹងរ៉ឹង និង គ្មានការលើកលែងចំពោះជនល្មើសនៃអំពើពុករលួយ ។ ដើម្បីប្រសិទ្ធភាពនៃកិច្ចការនេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងសមត្ថភាពរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ ពិសេសការងារដែលពាក់ព័ន្ធនឹងការស៊ើបអង្កេត និង ការអនុវត្តច្បាប់ ។

### ទី២. កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌

40. ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ ក្នុងការកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ គឺការសម្រេចឱ្យបាននូវប្រព័ន្ធច្បាប់ និង ប្រព័ន្ធយុត្តិធម៌មួយ ដែលអាចជឿទុកចិត្តបាន និង មានស្ថិរភាព សម្រាប់ការលើកស្ទួយការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស, ការពង្រឹងគោលការណ៍នីតិរដ្ឋនៅក្នុងលទ្ធិប្រជាធិបតេយ្យសេរី, ការធានាយុត្តិធម៌សង្គម ព្រមទាំងការបង្កើតបរិយាកាសជឿទុកចិត្តសម្រាប់ទាក់ទាញការវិនិយោគ ។

41. ឆ្លើយតបទៅនឹងចក្ខុវិស័យនេះ ក្នុងនីតិកាលកន្លងទៅ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលធំៗជាច្រើន រួមមាន : (១). ការធ្វើទំនើបកម្មក្របខណ្ឌច្បាប់ ពិសេស ការអនុម័ត និង ការប្រកាសឱ្យប្រើនូវក្រមព្រហ្មទណ្ឌ បន្ថែមលើក្រមសំខាន់ៗ ចំនួន ៣ ផ្សេងទៀត គឺក្រមរដ្ឋប្បវេណី, ក្រមនីតិវិធីរដ្ឋប្បវេណី និង ក្រមនីតិវិធីព្រហ្មទណ្ឌ, (២). ការបង្កើនការយល់ដឹង និង លើកកម្ពស់ការអនុវត្តច្បាប់ តាមរយៈការអប់រំ, ផ្សព្វផ្សាយ និង បណ្តុះបណ្តាលច្បាប់ដល់មន្ត្រីផ្តល់សេវាយុត្តិធម៌ និង មន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធផ្សេងទៀត, (៣). ការកែលម្អប្រព័ន្ធតុលាការ តាមរយៈការពង្រឹងសមត្ថភាព និង ការទទួលខុសត្រូវវិជ្ជាជីវៈរបស់ចៅក្រម និង ព្រះរាជអាជ្ញា, (៤). ការផ្តល់មធ្យោបាយបន្ថែមទៀតដល់ស្ថាប័នតុលាការ តាមរយៈការបង្កើនថវិកាជាបណ្តើរៗសម្រាប់វិស័យនេះ និង (៥). ការពង្រីក និង លើកកម្ពស់យន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈការដាក់ឱ្យដំណើរការមណ្ឌលសេវាកម្មយុត្តិធម៌ និង ការបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្ម ។

42. ក្នុងនីតិកាលទី ៥ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តឱ្យកាន់តែសកម្ម និង កាន់តែស៊ីជម្រៅថែមទៀត នូវបណ្តាសកម្មភាពសំខាន់ៗ ស្របតាមកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និង តុលាការ ដោយផ្តោតអាទិភាពពិសេសទៅលើ : (១). ការបន្តជំរុញអនុម័តច្បាប់គោលសំខាន់ៗពាក់ព័ន្ធនឹងស្ថាប័នតុលាការ ជាអាទិ៍ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា, ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គការតុលាការ និង អង្គការអយ្យការ, ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, ព្រមទាំងការកសាងច្បាប់ថ្មីៗតាមការចាំបាច់នៃការគ្រប់គ្រងរដ្ឋ និង ស្របតាមដំណើរការនៃការបង្កើតសហគមន៍អាស៊ានឆ្នាំ ២០១៥ និង កាតព្វកិច្ចរបស់កម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក, (២). ការបន្តពង្រឹងសមត្ថភាព និង ការទទួលខុសត្រូវវិជ្ជាជីវៈរបស់ចៅក្រម និង ព្រះរាជអាជ្ញា, (៣). ការជំរុញបង្កើតឱ្យមានរដ្ឋបាលតុលាការតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់, (៤). ការបន្តផ្តល់មធ្យោបាយសមស្របដល់សាលាជម្រះក្តីសម្រាប់ប្រតិបត្តិការអនុវត្តច្បាប់, (៥). ការបន្តអនុវត្តកម្មវិធីផ្សព្វផ្សាយ និង បណ្តុះបណ្តាលច្បាប់ឱ្យបានទូលំទូលាយថែមទៀត, (៦). ការបន្តសហការ និង ជួយដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ ដើម្បីការពារសិទ្ធិ និង ផលប្រយោជន៍ តាមផ្លូវតុលាការ និង (៧). ការបន្តជំរុញលើកកម្ពស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ។

### ទី៣. កំណែទម្រង់រដ្ឋបាលសាធារណៈ

43. ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺការកសាងរដ្ឋបាលសាធារណៈកាន់តែមានភាពឆ្លើយតបប្រសិទ្ធភាព, ប្រសិទ្ធផល និង ជំនឿទុកចិត្ត ហើយលើកកម្ពស់វប្បធម៌សេវាសាធារណៈ, ឆន្ទៈម្ចាស់ការ, ភក្តីភាព និង មនសិការវិជ្ជាជីវៈរបស់មន្ត្រីរាជការ ដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈ ឱ្យទៅជាអ្នកផ្តល់សេវាសាធារណៈដ៏មានប្រសិទ្ធភាព ដែលបម្រើប្រជាជនកាន់តែល្អប្រសើរឡើង ។ ចំណែកឯកម្មវិធីកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ មានគោលដៅបង្កើតប្រព័ន្ធ និង រចនាសម្ព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ និង ធានាការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព, តម្លាភាព និង គណនេយ្យភាព សំដៅឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាជននៅមូលដ្ឋាន ។

44. ក្នុងនេះ រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនរួមមាន : (១). ការគ្រប់គ្រងទំហំមន្ត្រីរាជការស៊ីវិលឱ្យបានសមស្រប និង ការបង្កើនបៀវត្សមធ្យមប្រចាំខែរបស់មន្ត្រីរាជការជិតទ្វេដង, (២). ការដាក់ឱ្យដំណើរការនូវទីភ្នាក់ងារប្រតិបត្តិការពិសេស, ការដាក់ឱ្យអនុវត្តនូវកម្រងព័ត៌មានស្តីពីសេវាសាធារណៈ និង ការពង្រីកវិសាលភាពនូវយន្តការ **«ច្រកចេញ- ចូលតែមួយ»** នៅថ្នាក់ក្រុង- ស្រុក- ខណ្ឌ ចំនួន ២៤, (៣). ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, (៤). ការរៀបចំ និង ដាក់ឱ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនៃរដ្ឋបាលថ្នាក់ក្រោមជាតិ អនុលោមតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំង(៥). ការរៀបចំលិខិតបទដ្ឋានចាំបាច់នានាជាច្រើន ដើម្បីគាំទ្រដល់កិច្ចដំណើរការកែទម្រង់នេះ ។

45. ក្នុងនីតិកាលទី ៥ នេះ រាជរដ្ឋាភិបាលនឹងបន្តផ្តោតលើការអនុវត្តយុទ្ធសាស្ត្រទាំងបី នៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាល គឺ÷

ទី១. ការពង្រឹងគុណភាព និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ តាមរយៈការបង្កើត និង ដាក់ឱ្យអនុវត្តនូវស្តង់ដារសេវាសាធារណៈ ដោយផ្តោតលើសូចនាករគោលសំខាន់ៗចំនួន ៥ គឺ : (១). គុណភាពព័ត៌មាន, (២). ភាពងាយស្រួលក្នុងការទទួលយកសេវា, (៣). ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា, (៤). សេវាផ្តល់តាមគោលការណ៍កំណត់ និង មានអភិបាលកិច្ចល្អ និង(៥). យន្តការទទួលព័ត៌មានត្រឡប់ និង បណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា ។

ទី២. ការអភិវឌ្ឍសមត្ថភាព, ការកែលម្អការគ្រប់គ្រង និង ការអភិវឌ្ឍធនធានមនុស្ស តាមរយៈការជំរុញអនុវត្តគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ពិសេស ការបន្តពង្រឹងការគ្រប់គ្រង និង ចាត់ចែងការងារ, ការកែលម្អការគ្រប់គ្រងជំនាញ និង ចំនួនមន្ត្រី, ការអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល និង ការទទួលខុសត្រូវរបស់មន្ត្រី, ការពង្រឹងសមត្ថភាពការងារ, សីលធម៌ និង វិន័យរបស់មន្ត្រី ព្រមទាំងការរៀបចំផែនការធនធានមនុស្ស និង ការបន្តវេន ។

ទី៣. ការកែទម្រង់ប្រព័ន្ធបៀវត្ស និង ប្រាក់បន្ថែមផ្សេងៗ ដោយឈរលើគោលការណ៍សំខាន់ៗ រួមមាន : ការដំឡើងបៀវត្ស ស្របតាមស្ថានភាពនៃកំណើនសេដ្ឋកិច្ច និង លទ្ធភាពទ្រទ្រង់បាននៃថវិកាជាតិ, ការធានាបាននូវសមធម៌, ការបង្កើនផលិតភាព និង ប្រសិទ្ធភាពការងារ, និង ការធានាសង្គតភាព រវាងក្របខណ្ឌមន្ត្រីរាជការស៊ីវិល និង ក្របខណ្ឌកងកម្លាំងប្រដាប់អាវុធ ។

**46.** ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញអនុវត្តកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ តាមរយៈ«**កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩**» ដោយផ្តោតការយកចិត្តទុកដាក់លើ÷

ទី១- ការបន្តពង្រីកវិសាលភាពនៃការអនុវត្តការិយាល័យ«ច្រកចេញ- ចូលតែមួយ» ឱ្យមាននៅគ្រប់ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស និង ការបន្តជំរុញធ្វើប្រតិភូកម្មមុខងារ ឱ្យបានកាន់តែទូលំទូលាយថែមទៀត ។

ទី២- ការពង្រឹងការអនុវត្តច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេស គឺការផ្ទេរជាជំហានៗនូវមុខងារ និង ធនធាន ក្នុងវិស័យអាទិភាពនានា ពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ទី៣- ការអភិវឌ្ឍធនធានមនុស្ស និង ស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការពង្រឹងតួនាទី និង ការ-ទទួលខុសត្រូវរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹង និង ការកែលម្អប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការកំណត់ឱ្យបានច្បាស់លាស់នូវយន្តការតាមដានត្រួតពិនិត្យលទ្ធផល និង វាយតម្លៃ និង ការត្រួតពិនិត្យនីត្យានុកូលភាព ។

ទី៤- ការពង្រឹងប្រសិទ្ធភាពនៃរដ្ឋបាលឯកភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមរយៈការបន្តផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលរបស់ក្រសួង- ស្ថាប័ននានា ដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ ។

### ទី៤. កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

**47.** គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី ៤ គឺជំរុញអនុវត្តកម្មវិធីកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ដើម្បីធានាបាននូវកិច្ចការពារប្រកបដោយប្រសិទ្ធភាពខ្ពស់នូវអធិបតេយ្យជាតិ និង បូរណភាពទឹកដី សន្តិសុខ និង សណ្តាប់ធ្នាប់សង្គមនៃព្រះរាជាណាចក្រកម្ពុជា ។

**48.** ឆ្លើយតបនឹងគោលដៅនេះ រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ជាច្រើន ក្នុងកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ រួមមាន÷

ទី១- ការពារបានប្រកបដោយប្រសិទ្ធភាពនូវអធិបតេយ្យជាតិ និង បូរណភាពទឹកដី ក្នុងខណៈដែលមានការឈ្លានពានពីខាងក្រៅ ។

ទី២- បានបង្កើត«**ឧត្តមក្រុមប្រឹក្សាការពារជាតិ**» និង បានកែសម្រួលការរៀបចំកងយោធពលខេមរភូមិន្ទ, ទាំងនៅថ្នាក់ជាតិ, ទាំងនៅថ្នាក់យោធភូមិភាគ, ថ្នាក់កងពល, ថ្នាក់ខេត្ត ស្រុកនីមួយៗ, ព្រមទាំងបានកែសម្រួលបណ្តាប្រភេទកងទ័ពទាំងបីប្រភេទ, ជើងគោក, ជើងទឹក, ជើងអាកាស និង អង្គភាពជំនាញ ពិសេសពង្រឹង និង ពង្រីកកង-វិស្វកម្ម ដើម្បីចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តជូនប្រជាជន ។

ទី៣- បានចូលរួមកសាង និង ការពារសន្តិភាពពិភពលោក ក្នុងក្របខណ្ឌប្រតិបត្តិការថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ។

ទី៤- បានអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ «**យុទ្ធសាស្ត្រ ៣, សកម្មភាពប្រតិបត្តិការ និង ការអភិវឌ្ឍ ១០**» ។

ទី៥- បានជំរុញអនុវត្ត «**ផែនការយុទ្ធសាស្ត្រនគរបាលជាតិកម្ពុជាឆ្នាំ ២០០៨-២០១៣**» ។

ទី៦- បានធានាប្រកបដោយប្រសិទ្ធភាពនូវការថែរក្សាសន្តិសុខ, សុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈ នៅក្នុងព្រឹត្តិការណ៍ជាតិ និង អន្តរជាតិធំៗ និង សំខាន់ៗជាប្រវត្តិសាស្ត្រ ដែលបានកើតមានក្នុងព្រះរាជាណាចក្រកម្ពុជា រួមមាន : ការបោះឆ្នោត, ការកាន់មរណទុក្ខ ក៏ដូចជាព្រះរាជពិធីដង្ហែ និង ថ្វាយព្រះភ្លើងព្រះបរមសពនៃព្រះបរមរតនកោដ្ឋ, កិច្ចប្រជុំកំពូលអាស៊ាន និង កិច្ចប្រជុំពាក់ព័ន្ធនានា ព្រមទាំងកិច្ចប្រជុំអន្តរជាតិផ្សេងទៀត ។

ទី៧- បានអនុវត្តកិច្ចការបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ និង សម្រេចបានលទ្ធផលល្អ ក្នុងការថែរក្សាសន្តិសុខ, សណ្តាប់ធ្នាប់សាធារណៈ និង សុវត្ថិភាពជូនប្រជាជន ពិសេស តាមរយៈការអនុវត្តគោលនយោបាយ«**ភូមិ- ឃុំមានសុវត្ថិភាព**» ។

ទី៨- បានចូលរួមចំណែកក្នុងកិច្ចការអភិវឌ្ឍសេដ្ឋកិច្ច និង ការងារសង្គមកិច្ច តាមសមត្ថភាពរៀងៗខ្លួន ពិសេសក្នុងកិច្ចការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ក្នុងបេសកកម្មសង្គ្រោះប្រជាជនក្នុងពេលជួបគ្រោះធម្មជាតិ ។

49. លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនីតិកាលទី ៥ នឹងបន្តការកែទម្រង់កងកម្លាំងប្រដាប់អាវុធ សំដៅធ្វើទំនើបកម្ម និង បង្កើនសមត្ថភាពវិជ្ជាជីវៈនៃកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដើម្បីបន្តធានាកិច្ចការពារប្រកបដោយប្រសិទ្ធភាព នូវអធិបតេយ្យជាតិ, បូរណភាពទឹកដី, សន្តិសុខ, សុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈ ។

50. ដើម្បីគោលដៅនេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈរបស់កងយោធពលខេមរភូមិន្ទ និង កងកម្លាំងនគរបាលជាតិ តាមរយៈការបន្តអនុវត្ត«**យុទ្ធសាស្ត្រ ៣, សកម្មភាពប្រតិបត្តិការ និង ការអភិវឌ្ឍ ១០**» ព្រមទាំងធ្វើបច្ចុប្បន្នកម្ម និង ជំរុញអនុវត្តផែនការយុទ្ធសាស្ត្រនគរបាលជាតិកម្ពុជា ក្នុងទិសដៅលើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញតួនាទីរបស់កងកម្លាំងប្រដាប់អាវុធ ពិសេស តាមរយៈការបង្កើត និង ការពង្រឹងការអនុវត្តច្បាប់ និង លិខិតបទដ្ឋានគតិយុត្តចាំបាច់នានា ។

ទី២- ការអភិវឌ្ឍធនធានមនុស្ស និង ការបង្កើនសមត្ថភាពកងកម្លាំងប្រដាប់អាវុធ តាមរយៈការធ្វើទំនើបកម្ម និង បំពាក់បច្ចេកវិទ្យាសមស្រប, ការបង្កើនគុណភាពហ្វឹកហ្វឺន ពិសេស ការបណ្តុះបណ្តាលយោធិនអាជីព, ការកសាងជួរកងកម្លាំងប្រដាប់អាវុធវ័យក្មេង ដើម្បីគោលដៅបន្តវេន និង ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាមិត្ត ។

ទី៣- ការពង្រឹងខ្សែរយៈចាត់តាំងក្នុងកងកម្លាំងប្រដាប់អាវុធ ពិសេស ក្នុងជួរកងទ័ព នៅគ្រប់ថ្នាក់ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងកងកម្លាំង ។

ទី៤- ការផ្តល់សម្ភារៈបច្ចេកទេសគ្រប់ប្រភេទ និង ការលើកកម្ពស់សុខុមាលភាពរបស់កងកម្លាំងប្រដាប់អាវុធ, ពិសេសការបង្កើនប្រសិទ្ធភាពក្នុងការផ្គត់ផ្គង់ និង ការគ្រប់គ្រងភស្តុភារ និង ហិរញ្ញវត្ថុ ពិសេសសម្រាប់បណ្តាកងឯកភាពឈរជើងនាខ្សែត្រៀមជួរមុខ និង កងការពារដែនកោះ ។

ទី៥- ការបន្តផ្តល់ការយកចិត្តដល់អតីតយុទ្ធជន, យោធិនពិការ, គ្រួសារយោធិនពលី មរណៈ និង គ្រួសារនៃកងកម្លាំងប្រដាប់អាវុធ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេស តាមរយៈការបន្តផ្តល់ និង ការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងសម្បទានដីសង្គមកិច្ច និង គម្រោងអភិវឌ្ឍសម្រាប់សហគមន៍នៃគ្រួសារកងកម្លាំងប្រដាប់អាវុធនៅតាមព្រំដែន ។

ទី៦- ការលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និង រវាងកងកម្លាំងប្រដាប់អាវុធជាមួយនឹងក្រសួង និង ស្ថាប័ន ព្រមទាំងបន្តពង្រឹងប្រពៃណីនៃទំនាក់ទំនងស្អិតរមួតរវាងកងកម្លាំងប្រដាប់អាវុធ និង ប្រជាជន ពិសេស តាមរយៈការធ្វើអន្តរាគមន៍ក្នុងពេលមានគ្រោះធម្មជាតិ, ការបំពេញប្រតិបត្តិការមនុស្សធម៌ និង ការជួយបង្កបង្កើនផលកសិកម្ម ព្រមទាំងការរួមចំណែកកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង កិច្ចការពារបរិស្ថាន និង ធនធានធម្មជាតិ ។

ទី៧- ការពង្រឹង និង ពង្រីកទំនាក់ទំនង និង កិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការអភិវឌ្ឍកងកម្លាំងប្រដាប់អាវុធ លើគ្រប់ផ្នែក រួមទាំងការបន្តចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិផងដែរ ។

## ២.៣. ចតុកោណយុទ្ធសាស្ត្រទាំងបួន

### ចតុកោណទី ១. ការលើកស្ទួយវិស័យកសិកម្ម

51. វិស័យកសិកម្មនៅតែមានតួនាទីសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច, ធានាសមធម៌, ធានាសន្តិសុខស្បៀង និង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជាតាមអភិក្រម និង ក្នុងវិសាលភាព និង ល្បឿនថ្មី ដើម្បីប្រែក្លាយវិស័យនេះ ពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបវិបុលកម្ម (បើកទូលាយ) ពោលគឺពឹងផ្អែកជាសំខាន់លើធនធានមានស្រាប់ (ធនធានដី និង ធនធានធម្មជាតិផ្សេងទៀត) និង ពឹងផ្អែកលើការប្រើប្រាស់ធាតុចូលកសិកម្មតាមបែបប្រពៃណី ឈានទៅរកដំណាក់កាលថ្មី ដែលផ្តោតលើផលិតកម្មតាមបែបប្រពលកម្ម (ស៊ីជម្រៅ) ពោលគឺពឹងផ្អែកជាសំខាន់លើការប្រើប្រាស់បច្ចេកទេស, បច្ចេកវិទ្យាថ្មី, ការស្រាវជ្រាវ និង ការអភិវឌ្ឍ, យន្តូបនីយកម្ម ព្រមទាំងការបង្កើនសមត្ថភាពស្រោចស្រព ដើម្បីលើកកម្ពស់ផលិតភាព, ពិពិធភាវូបនីយកម្មមុខដំណាំ និង ផលិតផលកសិកម្មផ្សេងទៀត រួមទាំងការចិញ្ចឹមសត្វ និង វារីវប្បកម្មផង ដោយគិតគូរផងដែរ អំពីភាព-ចាំបាច់ ក្នុងការគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព និង ការធានាចីរភាពបរិស្ថាន និង ធនធានធម្មជាតិ ។ ទន្ទឹមនេះ ការបន្តជំរុញការធ្វើពាណិជ្ជូបនីយកម្ម និង ការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម នឹងជួយបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាជួយបង្កើនចំណូលជូនប្រជាកសិករ ។

#### មុំទី ១. ការលើកកម្ពស់ផលិតភាព, ពិពិធភាវូបនីយកម្ម និង ពាណិជ្ជូបនីយកម្ម

52. គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី ៤ គឺការលើកកម្ពស់ផលិតភាព និង ការធ្វើពិពិធ-ភាវូបនីយកម្មកសិកម្ម តាមរយៈការពង្រីកសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ ដោយផ្តោតលើអន្តរាគមន៍ប្រទាក់ក្រឡាក្នុងវិស័យពាក់ព័ន្ធ ដូចជា ការប្រើប្រាស់ធាតុចូលកសិកម្មតាមបច្ចេកទេស, ការស្រាវជ្រាវ និង ការអភិវឌ្ឍ, ប្រព័ន្ធសេវាបច្ចេកទេសកសិកម្ម, ការសាងសង់ និង ថែទាំហេដ្ឋារចនាសម្ព័ន្ធជនបទ, ការផ្តល់ឥណទានជនបទ និង មីក្រូហិរញ្ញវត្ថុ, ការពង្រីកទីផ្សារកសិកម្ម, ការរៀបចំសហគមន៍កសិកម្ម និង ការគ្រប់គ្រងដីធ្លីកសិកម្ម ។

53. ក្នុងការអនុវត្តគោលដៅខាងលើនេះ រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ រួមមាន: (ទី១). កំណើនក្នុងវិស័យដំណាំជាមធ្យមប្រចាំឆ្នាំសម្រេចបានប្រមាណ ៥% សម្រាប់រយៈពេលឆ្នាំ ២០០៨-២០១២ ដែលក្នុងនោះ

ទិន្នផលស្រូវជាមធ្យមបានកើនឡើងពី ២,៧៤ តោន នៅឆ្នាំ ២០០៨ ដល់ ៣,១៣ តោន ក្នុងមួយហិកតា នៅឆ្នាំ ២០១២ ជាមួយនឹងបរិមាណផលិតកម្មសរុបកើនឡើងពី ៧,១៧ លានតោន នៅឆ្នាំ ២០០៨ ដល់ ៩,៣១ លានតោន នៅឆ្នាំ ២០១២, (ទី២)• ពិពិធកម្មមុខដំណាំក្រៅពីស្រូវ ដូចជា ពោត, ដំឡូងមី, អំពៅ, ស្វាយចន្ទី, ម្រេច និង ដំណាំផ្សេងទៀត ដោយអនុវត្តបានលើផ្ទៃដីសរុបកើនពី ២៧០ ពាន់ហិកតា នៅឆ្នាំ ២០០៨ ដល់ ៧៧០ ពាន់ហិកតា នៅឆ្នាំ ២០១២, ដោយឡែក ការដាំដុះដំណាំកៅស៊ូ សម្រេចបានលើផ្ទៃដីសរុបប្រមាណ ជាង ២៧០ ពាន់ហិកតា គឺកើនឡើងជិតពីរដង ធៀបនឹងឆ្នាំ ២០០៨ និង (ទី៣) • ទន្ទឹមនឹងការធានាបាននូវសន្តិសុខស្បៀង, ការនាំចេញអង្ករជាផ្លូវការសម្រេចបានប្រមាណ ២០០ ពាន់តោន ក្នុងឆ្នាំ ២០១២ ធៀបនឹងឆ្នាំ ២០០៨ ដែលមានការនាំចេញតែបន្តិចបន្តួច, រីឯការនាំចេញកៅស៊ូមានប្រមាណ ៥០ ពាន់តោន ក្នុងឆ្នាំ ២០១២ គឺកើន ៣,៥ ដង ធៀបនឹងឆ្នាំ ២០០៨ ហើយការនាំចេញកសិផលផ្សេងទៀត កើនដល់ជិត ៥០ ពាន់តោន នៅឆ្នាំ ២០១២ ធៀបនឹងជាង ៣ ពាន់តោន នៅឆ្នាំ ២០០៨ ។ ការដាក់ចេញ និង ជំរុញអនុវត្ត ***«គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករ»*** និង ***«យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជាឆ្នាំ ២០១១-២០២០»*** បានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការសម្រេចបាននូវសមិទ្ធផលទាំងអស់នេះ ។

**54.** ទោះបីយ៉ាងនេះក្តី កម្ពុជានៅបន្តជួបបញ្ហាប្រឈមមួយចំនួនទៀត ពិសេស ភាពងាយរងគ្រោះនៃប្រព័ន្ធដាំដុះ, ផលិតភាព និង តម្លៃបន្ថែមនៅទាប ដែលឆ្លុះបញ្ចាំងពីសេចក្តីត្រូវការក្នុងការកែលម្អថែមទៀត នូវប្រព័ន្ធដាំដុះ រួមមាន ប្រព័ន្ធធារាសាស្ត្រ, បច្ចេកទេសដាំដុះ, ការប្រើប្រាស់ធាតុចូលតាមបច្ចេកទេស, ប្រព័ន្ធប្រមូល និង ទុកដាក់កសិផល, សមត្ថភាពកែច្នៃ, ប្រព័ន្ធឡូជីស្ទីក និង ស្តង់ដារគុណភាព, អនាម័យ និង ភូតគាមអនាម័យ ព្រមទាំងហិរញ្ញប្បទាន ជា-ដើម ។

**55.** ដើម្បីដោះស្រាយបញ្ហាខាងលើ រាជរដ្ឋាភិបាលនីតិកាលទី ៥ នឹងខិតខំរក្សាកំណើនក្នុងវិស័យកសិកម្មនេះ ឱ្យបាន ក្នុងរង្វង់ ៥% ក្នុងមួយឆ្នាំ ដោយបន្តលើកកម្ពស់ផលិតភាព, ធ្វើពិពិធភាវូបនីយកម្ម និង ធ្វើពាណិជ្ជូបនីយកម្ម ។

**56.** លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការបន្តបង្កើនផលិតភាពស្រូវ និងដំណាំផ្សេងទៀត តាមរយៈ ការពង្រឹង, ការពង្រីក និង ការធានាចីរភាពនៃប្រព័ន្ធសេវាបច្ចេកទេស និង ព័ត៌មានទីផ្សារកសិកម្ម ដោយជំរុញសេវាទាំងនេះ ឱ្យមានរចនាសម្ព័ន្ធទៅដល់មូលដ្ឋាន ហើយផ្សារភ្ជាប់ជាមួយនឹងបណ្តាញអ្នកស្ម័គ្រចិត្ត និង ដៃគូ ដែលមានការពាក់ព័ន្ធ, ការលើកកម្ពស់ការស្រាវជ្រាវ និង ការអភិវឌ្ឍដើម្បីបង្កើនផលិតភាព និង បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ, ការផលិត និង ការប្រើប្រាស់ពូជ ដែលមានគុណភាព និង ឆ្លើយតបនឹងសេចក្តីត្រូវការទីផ្សារ, ការបន្តវិនិយោគ និង ការធ្វើវិចារណកម្មការប្រើប្រាស់ហេដ្ឋារចនា-សម្ព័ន្ធស្រោចស្រព, ការបន្តកែលម្អប្រព័ន្ធប្រមូល និង ទុកដាក់កសិផល, ការរៀបចំ និង កែសម្រួលក្របខណ្ឌគតិយុត្ត សម្រាប់គ្រប់គ្រងការផលិតពូជ, ការនាំចូលធាតុចូលកសិកម្ម, ប្រព័ន្ធកសិកម្មតាមកិច្ចសន្យា, ដីកសិកម្ម, សហគមន៍កសិកម្ម និង សហគមន៍ប្រើប្រាស់ទឹក ព្រមទាំងការអភិវឌ្ឍធនធានមនុស្ស សម្រាប់វិស័យកសិកម្ម ។

ទី២- ការបន្តជំរុញពិពិធកម្ម តាមរយៈការលើកកម្ពស់ការស្រាវជ្រាវ និង ការអភិវឌ្ឍ, ការផ្សព្វផ្សាយមុខដំណាំថ្មីៗ ដែលមានសក្តានុពលសម្រាប់ការដាំដុះ និង ការនាំចេញ, ការពង្រឹងបរិស្ថានអនុគ្រោះ សម្រាប់ទាក់ទាញការវិនិយោគឯកជន ពិសេស ក្នុងការស្រាវជ្រាវ, ការផលិត, ការចែកចាយពូជ និង ការកែច្នៃកសិកម្ម, ការបង្កើនកិច្ចសហប្រតិបត្តិការ

ជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់ ក្នុងការផ្ទេរចំណេះដឹង ចំណេះធ្វើ និង បច្ចេកវិទ្យាថ្មីៗដល់កសិករ និង ការជំរុញការប្រើប្រាស់គ្រឿងយន្តកសិកម្ម ។

ទី៣- ការបន្តលើកកម្ពស់ពាណិជ្ជូបនីយកម្ម តាមរយៈ ការជំរុញការអនុវត្តច្បាប់ និង គោលនយោបាយ ព្រមទាំងការពង្រឹងយន្តការស្ថាប័ន ដើម្បីជំរុញការធ្វើពាណិជ្ជកម្ម និង ការនាំចេញកសិផល រួមមានការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវច្បាប់ស្តីពីសហគមន៍កសិកម្ម, ការលើកកម្ពស់សមត្ថភាពកែច្នៃ, ការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម រួមបញ្ចូលនូវយន្តការ **«ច្រកចេញ- ចូលតែមួយ»** ផង, ការពង្រឹងប្រព័ន្ធឡូជីស្ទីក, ការលើកស្ទួយគុណភាពកសិផលឱ្យស្របតាមស្តង់ដារអន្តរជាតិ, ការបង្កើនសមត្ថភាពក្នុងការផ្តល់ហិរញ្ញប្បទានតាមថ្លៃសមរម្យ, ការលើកស្ទួយភាពជាដៃគូរវាងកសិករ និង ពាណិជ្ជករ ក៏ដូចជារវាងកសិ- ឧស្សាហកម្មខ្នាតធំ និង កសិកម្មលក្ខណៈគ្រួសារ ។

ទន្ទឹមនឹងអាទិភាពខាងលើនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញអនុវត្ត«**គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករ**» និង «**យុទ្ធសាស្រ្តសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជាឆ្នាំ ២០១១-២០២០**» ឱ្យបានសម្រេចជោគជ័យតាមការគ្រោងទុក ។

### មុំទី២. ការលើកកម្ពស់ការចិញ្ចឹមសត្វ និង វារីវប្បកម្ម

57. រាជរដ្ឋាភិបាលនីតិកាលទី ៤ បានផ្តោតការយកចិត្តទុកដាក់ទៅលើកំណែទម្រង់ជលផល ក្នុងគោលដៅបំពេញតម្រូវការអាហារូបត្ថម្ភ និង ថែរក្សាធនធានមច្ឆជាតិឱ្យបានគង់វង្ស តាមរយៈការរៀបចំសហគមន៍នេសាទ, ការកែទម្រង់ការគ្រប់គ្រងឡូតិ៍នេសាទ, ការអភិរក្សព្រៃលិចទឹក, ការប្រយុទ្ធនឹងការនេសាទខុសច្បាប់ និង ការបំផុសវារីវប្បកម្ម ។

58. រាជរដ្ឋាភិបាលបានអនុវត្តកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យជលផល ដោយលុបចោលឡូតិ៍នេសាទទាំងស្រុង ហើយផ្តល់ជូនប្រជាជនធ្វើការនេសាទជាលក្ខណៈគ្រួសារ ទន្ទឹមនឹងការពង្រឹង និង ពង្រីកការរៀបចំសហគមន៍នេសាទ និង តំបន់អភិរក្សជលផល ព្រមទាំងបានអនុវត្តយ៉ាងសកម្មនូវវិធានការការពារព្រៃលិចទឹក ជាពិសេសនៅជុំវិញបឹងទន្លេសាប ដែលជាជម្រកដ៏សំខាន់ សម្រាប់ការរស់នៅ និង ជាកន្លែងបន្តពូជរបស់មច្ឆជាតិជាច្រើនប្រភេទ ។

59. យ៉ាងណាក៏ដោយ ក៏កម្ពុជានៅបន្តជួបបញ្ហាប្រឈមមួយចំនួននៅក្នុងវិស័យនេះ ពិសេស ក្នុងការបង្កើនផលិតផល និង ក្នុងការធានាចីរភាពនៃធនធានជលផល ទាំងក្នុងដែនទឹកសាប និង សមុទ្រ ។ បន្ថែមលើនេះ កម្ពុជាក៏នៅមានសក្កា- នុពលច្រើនថែមទៀត ក្នុងការបំពេញសេចក្តីត្រូវការផ្នែកអាហារូបត្ថម្ភ, ការបង្កើនចំណូលរបស់ប្រជាជន និង ការបម្រើសេចក្តីត្រូវការទីផ្សារ ទាំងក្នុងស្រុក និង ក្រៅស្រុក ពិសេសតាមរយៈការលើកកម្ពស់ការចិញ្ចឹមសត្វ និង វារីវប្បកម្ម ។

60. ក្នុងន័យនេះ រាជរដ្ឋាភិបាលនីតិកាលទី ៥ មានគោលដៅជំរុញលើកកម្ពស់ចលនាចិញ្ចឹមសត្វ និង វារីវប្បកម្ម ឱ្យកាន់តែទូលំទូលាយថែមទៀត តាមរយៈការបង្កើតក្របខណ្ឌគោលនយោបាយដោយផ្អែកលើគោលការណ៍ខ្សែចង្វាក់តម្លៃ ដើម្បីដោះស្រាយជាកញ្ចប់នូវបញ្ហាជាឧបសគ្គដល់ការអភិវឌ្ឍវិស័យទាំងនេះ ដោយគិតគូរផងដែរដល់បញ្ហាសុវត្ថិភាពចំណីអាហារ និង កិច្ចដំណើរការទីផ្សារ ពិសេសអនាម័យ និង ភូតគាមអនាម័យ ទន្ទឹមនឹងការបន្តអនុវត្តវិធានការមុតស្រួចនានា សំដៅធានារក្សាចីរភាពនៃធនធានជលផល ទាំងក្នុងដែនទឹកសាប និង សមុទ្រ ។

61. ឆ្លើយតបនឹងគោលដៅនេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការបន្តជំរុញអនុវត្តក្របខណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផល ២០១០-២០១៩ សំដៅបង្កើនផលិតផលត្រី ដើម្បីធានាសេចក្តីត្រូវការរបស់ប្រជាជន និង ទីផ្សារនាំចេញ ដោយផ្តោតជាសំខាន់លើសសរស្តម្ភបី គឺៈ (១). ជលផលទឹកសាប និង សមុទ្រ, (២). វារីវប្បកម្មទឹកសាប និង សមុទ្រ និង (៣). ការកែច្នៃ និង ពាណិជ្ជកម្ម ។

ទី២- ការជំរុញរៀបចំ និង ដាក់ឱ្យអនុវត្តនូវគោលនយោបាយ និង យុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការចិញ្ចឹមសត្វ ។

ទី៣- ការជំរុញការលើកកម្ពស់ការស្រាវជ្រាវ និង ការអភិវឌ្ឍលើការបង្កាត់ពូជ, ការគ្រប់គ្រងសុខភាពសត្វ, ការផលិតចំណីសត្វ និង ប្រព័ន្ធកសិដ្ឋាន ទាំងក្នុងវិស័យបសុសត្វ និង វារីវប្បកម្ម ។

ទី៤- ការជំរុញអនុម័តច្បាប់ស្តីពីសុខភាពសត្វ និង ផលិតកម្មសត្វ ដើម្បីជាមូលដ្ឋានសម្រាប់រៀបចំស្ថាប័ន និង គ្រប់គ្រងវិស័យនេះ ក្នុងគោលដៅពង្រឹងការអនុវត្តស្តង់ដារអនាម័យលើផលិតផលពីសត្វ, ការពង្រឹង និង ជំរុញអនុវត្តវិធានការអនាម័យសត្វ, ភូតគាមអនាម័យ ដើម្បីបង្ការ ទប់ស្កាត់ និង លុបបំបាត់ការឆ្លងរាលដាលជំងឺសត្វ ក៏ដូចជា ដើម្បីការពារសុខភាពសាធារណៈ ។

ទី៥- ការជំរុញលើកទឹកចិត្តការវិនិយោគលើការផលិតចំណីសត្វ ក្នុងទ្រង់ទ្រាយមធ្យម និង ធំ ដើម្បីគាំទ្រដល់ចលនាចិញ្ចឹមសត្វ រួមជាមួយនឹងការលើកកម្ពស់ប្រព័ន្ធផ្តល់សេវាបច្ចេកទេស, ពូជ, ឥណទាន និងការរកទីផ្សារជូនកសិករ, ការ-លើកទឹកចិត្តការវិនិយោគឯកជនក្នុងការកែច្នៃផលិតផលបសុសត្វ និង ផលិតផលជលផល, ការបង្កើតសត្តឃាតដ្ឋានទំនើប ព្រមទាំងការសម្រួលពាណិជ្ជកម្មលើបសុសត្វ និង ផលិតផលមានដើមកំណើតពីសត្វ និង ផលិតផលជលផល ។

### មុំទី ៣. កំណែទម្រង់ដីធ្លី, ការបោសសម្អាតមីន និង សំណល់ជាតិផ្ទុះពីសង្គ្រាម

62. គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ គឺការបន្តធ្វើកំណែទម្រង់ដីធ្លី ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រង, បែងចែក និង ប្រើប្រាស់ដីធ្លី, ធានាសុវត្ថិភាពនៃកម្មសិទ្ធិដី, លុបបំបាត់ភាពអនាធិបតេយ្យ ក្នុងការកាន់កាប់ដីដោយខុសច្បាប់ និង ទប់ស្កាត់ការប្រមូលដីទុកដោយមិនបានប្រើប្រាស់ និង មិនផលិត ព្រមទាំងបន្តបោសសម្អាតមីន និង សំណល់ជាតិផ្ទុះពីសង្គ្រាម ដែលត្រូវបានកំណត់ជាគោលដៅទី ៩ នៃ **គោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា** ។

63. ក្នុងនីតិកាលកន្លងទៅ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលធំៗជាច្រើនគួរឱ្យកត់សម្គាល់ មានជាអាទិ៍ ការអនុម័តច្បាប់ស្តីពីអស្សាមិករណ៍ និង លិខិតបទដ្ឋានគតិយុត្តសំខាន់ៗពាក់ព័ន្ធនឹងវិស័យនគរូបនីយកម្ម សំណង់ និង វិស័យដីធ្លី, ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ចំនួនជាង ៣ លានប័ណ្ណ តាមរយៈការចុះបញ្ជីក្នុងក្របខណ្ឌផែនការទូទៅ និង ការអនុវត្ត **«គោលនយោបាយចាស់-សកម្មភាពថ្មីលើវិស័យដីធ្លី»**, ការបែងចែកដី ក្រោមរូបភាពសម្បទានដីសង្គមកិច្ច និង ការធ្វើប្រទានកម្ម ដែលមានចំនួនសរុបជាង ៥៣ ពាន់គ្រួសារ, ការចុះបញ្ជីដីរដ្ឋទំហំធំៗ, ការចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច, ការចុះបញ្ជីសិទ្ធិជួលរយៈពេលវែង និង ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ និង កាត់បន្ថយវិវាទដីធ្លី តាមរយៈយន្តការដែលមានស្រាប់ និង ក្នុងក្របខណ្ឌ **«គោលនយោបាយចាស់-សកម្មភាពថ្មីលើវិស័យដីធ្លី»** ។ ដោយឡែក លទ្ធផលក្នុងការបោសសម្អាតមីន និង សំណល់ជាតិផ្ទុះពីសង្គ្រាម ដើម្បីគោលដៅនៃការបង្កើនផ្ទៃដីសម្រាប់ការអភិវឌ្ឍ ត្រូវបានរំលេច តាមរយៈការកើនឡើងគួរឱ្យកត់សម្គាល់នៃទំហំផ្ទៃដី ដែលត្រូវបានបោសសម្អាតរួចពីមីន និង សំណល់ជាតិផ្ទុះពីសង្គ្រាម ។ បន្ថែមលើនេះ រាជរដ្ឋា-

ភិបាលបានធ្វើការវិនិយោគយ៉ាងច្រើនទៅលើការបោសសម្អាតមីន និង សំណល់ជាតិផ្ទុះពីសង្គ្រាម សម្រាប់គម្រោងវិនិយោគសាធារណៈលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង គម្រោងវិនិយោគពាក់ព័ន្ធផ្សេងទៀត ។

**64.** ទន្ទឹមនឹងការសម្រេចបានសមិទ្ធផលដូចខាងលើ កម្ពុជានៅមានភាពចាំបាច់ក្នុងការបន្តដោះស្រាយបញ្ហាប្រឈមមួយចំនួន ជាអាទិ៍ ភាពមិនទាន់ស៊ីសង្វាក់គ្នាលើការធ្វើបច្ចុប្បន្នកម្មប្រព័ន្ធព័ត៌មានដីធ្លី, ការសម្របសម្រួលខាងស្ថាប័ន, ការដោះស្រាយវិវាទដីធ្លី, សេចក្តីត្រូវការក្នុងការបង្កើនមធ្យោបាយ និង ធនធានមនុស្សសម្រាប់ការវាស់វែងដីធ្លី ព្រមទាំងសេចក្តីត្រូវការក្នុងការបន្តបោសសម្អាតមីន និង សំណល់ជាតិផ្ទុះពីសង្គ្រាម ។

**65.** លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនីតិកាលទី ៥ នឹងបន្តអនុវត្តកាន់តែសកម្ម និង ស៊ីជម្រៅថែមទៀត នូវកំណែទម្រង់ដីធ្លី ដោយផ្តោតលើការពង្រឹងការគ្រប់គ្រង, ការរៀបចំ, ការប្រើប្រាស់ និង ការបែងចែកដីធ្លី ដើម្បីរួមចំណែកធ្វើឱ្យសម្រេចគោលដៅជាតិ ក្នុងការកាត់បន្ថយភាពក្រីក្រ, ការធានាសន្តិសុខស្បៀង, ការការពារបរិស្ថាន និង ធនធានធម្មជាតិ និង ការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ក្នុងបរិការណ៍នៃសេដ្ឋកិច្ចទីផ្សារ ។

**66.** ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពទៅលើ÷

ទី១- ការបន្តជំរុញរៀបចំគោលនយោបាយដីធ្លីទូលំទូលាយ «**សៀវភៅសដីធ្លី**»។

ទី២- ការជំរុញរៀបចំច្បាប់ស្តីពីការរៀបចំដែនដី និង នគរូបនីយកម្ម និង ច្បាប់ស្តីពីដីកសិកម្ម ។

ទី៣- ការបន្តជំរុញល្បឿននៃការចុះបញ្ជី និង ការផ្តល់បណ្ណកម្មសិទ្ធិដីធ្លី ទាំងដីរដ្ឋ ដីឯកជន និង ដីសហគមន៍ជនជាតិដើមភាគតិច តាមរយៈការចុះបញ្ជីក្នុងក្របខណ្ឌផែនការទូទៅ និង ការបន្តអនុវត្ត«**គោលនយោបាយចាស់- សកម្មភាពថ្មីលើវិស័យដីធ្លី**» ដោយផ្តល់អាទិភាពលើតំបន់ដែលគ្មានវិវាទ ដើម្បីធានាសុវត្ថិភាព និង ទំនុកចិត្តក្នុងការកាន់កាប់ដីធ្លី ។

ទី៤- ការបន្តជំរុញកសាងទិន្នន័យអំពីការគ្រប់គ្រង និង ប្រើប្រាស់ដីធ្លី ដើម្បីជាមូលដ្ឋានច្បាស់លាស់ ក្នុងការរៀបចំផែនការប្រើប្រាស់ និង បែងចែកដីធ្លីឱ្យបានត្រឹមត្រូវ ជាអាទិ៍ ដីសម្រាប់កសិកម្ម, ឧស្សាហកម្ម, ទេសចរណ៍, ជនបទ, ទីក្រុង, លំនៅដ្ឋាន និង តំបន់អភិរក្ស សំដៅធ្វើវិចារណកម្មនៃការប្រើប្រាស់ដី, ចៀសវាងការប្រើប្រាស់ដី និង ការបំប្លែងការប្រើប្រាស់ដីមិនចំសក្តានុពល ។ ការយកចិត្តទុកដាក់នឹងត្រូវផ្តោតទៅលើការបន្តជំរុញកិច្ចការស្រាវជ្រាវ និង ការរៀបចំចំណាត់ថ្នាក់ដីទៅតាមប្រភេទមានសក្តានុពលអំណោយផលដល់ផលិតកម្មកសិកម្ម តាមតំបន់ភូមិសាស្ត្រនីមួយៗ ។

ទី៥- ការបន្តធានាការគ្រប់គ្រង, ការការពារ និង ការប្រើប្រាស់ដីធ្លី និង ធនធានធម្មជាតិ ប្រកបដោយតម្លាភាព និង ប្រសិទ្ធភាព ដើម្បីរក្សាចីរភាពបរិស្ថាន និង ការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ព្រមទាំងការទប់ស្កាត់រាល់ការកាប់ទន្ទ្រានដីព្រៃ និង ការចាត់វិធានការតឹងរ៉ឹងចំពោះបុគ្គល ដែលរំលោភកាន់កាប់ដីគ្រប់ប្រភេទដោយខុសច្បាប់ និង ប្រមូលដីទុកមិនផលិត រួមទាំងការបន្តដកហូតមកវិញនូវសម្បទានដីសេដ្ឋកិច្ច ដែលក្រុមហ៊ុនមិនគោរពតាមកិច្ចសន្យា និង បទដ្ឋានគតិយុត្តជាធរមាន ទន្ទឹមនឹងការឈប់ផ្តល់ថែមទៀតនូវសម្បទានដីសេដ្ឋកិច្ច ។

ទី៦- ការបន្តបែងចែក និង ប្រើប្រាស់ដីរដ្ឋ ជាពិសេសដីសម្បទានសេដ្ឋកិច្ច ដែលត្រូវបានដកហូតមកវិញ និង ផ្ទៃដីដែលត្រូវបានបោសសម្អាតរួចពីមីន និង សំណល់ជាតិផ្ទុះពីសង្គ្រាម ដើម្បីបម្រើប្រយោជន៍នៃការអភិវឌ្ឍ ប្រកបដោយតម្លាភាព និង សមធម៌, ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជនក្រីក្រ, យោធិនពិការ, គ្រួសារយោធាពលី និង មរណៈ និង អតីតកងកម្លាំងប្រដាប់អាវុធ ដែលគ្មាន ឬ ខ្វះដីពិតប្រាកដ តាមរយៈការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច និង ការធ្វើប្រទានកម្ម ។

ទី៧- ការបន្តអនុវត្តគោលនយោបាយមិនយកពន្ធលើដីកសិកម្មជាលក្ខណៈគ្រួសារ និង ការបន្តជួយប្រជាកសិករ ក្នុងការលើកកម្ពស់ផលិតភាពនៃការប្រើប្រាស់ដី តាមរយៈការសាងសង់ប្រព័ន្ធគមនាគមន៍ផ្លូវថ្នល់, ធារាសាស្ត្រ និង ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ផ្សេងទៀត ។

ទី៨- ការបន្តដោះស្រាយវិវាទដីធ្លី ប្រកបដោយប្រសិទ្ធភាព, តម្លាភាព និង យុត្តិធម៌ ស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន តាមរយៈយន្តការដោះស្រាយវិវាទដីធ្លី ទាំងក្នុង និង ក្រៅប្រព័ន្ធតុលាការ ។

ទី៩- ការបន្តជំរុញអនុវត្ត «**ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១០-២០១៩**» ជាពិសេស ការបន្តបោសសម្អាតមីន និង សំណល់ជាតិផ្ទុះពីសង្គ្រាម ដើម្បីបង្កើនផ្ទៃដីដាំដុះ, ធានាសុវត្ថិភាពក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ព្រម- ទាំងកាត់បន្ថយបន្ថែមទៀតនូវអត្រាគ្រោះថ្នាក់ដោយសារមីន និង សំណល់ជាតិផ្ទុះពីសង្គ្រាម ។

### មុំទី ៤. ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព

67. គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ បានផ្តោតលើការគ្រប់គ្រង និង អភិរក្សធនធានព្រៃឈើ និង ជលផល ដើម្បីធានាចីរភាពនៃកំណើនសេដ្ឋកិច្ចជាតិ និង លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន នៅតំបន់ជនបទ តាមរយៈការជំរុញអនុវត្តកម្មវិធីព្រៃសហគមន៍, ការត្រួតពិនិត្យតាមដានការធ្វើអាជីវកម្មព្រៃឈើ, ការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និង ការអនុវត្តវិធានការម៉ឺងម៉ាត់ចំពោះបទល្មើសព្រៃឈើ, ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងព្រៃបម្រុង, ការអនុវត្តស៊ីជម្រៅនូវកំណែទម្រង់ឡូតិ៍នេសាទ និង ជលផល ។

68. ឆ្លើយតបទៅនឹងគោលដៅនេះ ក្នុងនីតិកាលកន្លងទៅ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ រួមមាន :(១). ក្នុងវិស័យព្រៃឈើ បានរក្សាគម្របព្រៃឈើ សរុបប្រមាណ ១០ លាន ហិកតា ឬ ប្រមាណជិត ៦០% នៃផ្ទៃប្រទេស ព្រមទាំងបានបោះបង្គោលព្រំដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ប្រវែង ២ ០២០ គីឡូម៉ែត្រ និង បានបង្កើតសហគមន៍ព្រៃឈើចំនួន ៤៥៣ នៅក្នុងខេត្តចំនួន ១៩ លើផ្ទៃដីចំនួន ៣៩៩ ៨៨០ ហិកតា និង (២). ក្នុងវិស័យជលផល ទន្ទឹមនឹងបានលុបឡូតិ៍នេសាទប្រគល់ជូនប្រជាជន រាជរដ្ឋាភិបាលបានរៀបចំសហគមន៍នេសាទចំនួន ៥១៦ និង បានបង្កើតតំបន់អភិរក្សចំនួន ៣៥៤ កន្លែង ក្នុងដែននេសាទសហគមន៍, តំបន់អភិរក្សថ្មីចំនួន ៥០ កន្លែង និង តំបន់អភិរក្សជលផលបឹងទន្លេសាបចំនួន ៨ កន្លែង មានទំហំ ២២ ៥០០ ហិកតា ពិសេសបានការពារព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាបដែលមានទំហំប្រមាណ ៦៤៧ ពាន់ហិកតា ។

69. ទោះបីយ៉ាងនេះក្តី កម្ពុជានៅបន្តជួបបញ្ហាប្រឈមមួយចំនួនទៀត ក្នុងការធានាចីរភាពនៃធនធានធម្មជាតិ ពិសេសអភិបាលកិច្ច និង ប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិនៅមិនទាន់រឹងមាំ, ភាពមិនទាន់គ្រប់ជ្រុងជ្រោយនៃក្របខណ្ឌគតិយុត្ត, ភាពចាំបាច់ក្នុងការបន្តពង្រឹងការសម្របសម្រួលរវាងស្ថាប័ន និង ដៃគូពាក់ព័ន្ធ, ក៏ដូចជាប្រសិទ្ធភាពក្នុងការអនុវត្តវិធានការកែទម្រង់ចាំបាច់នានា, ព្រមទាំងការគ្រប់គ្រងផលប៉ះពាល់បណ្តាលមកពីការប្រែប្រួលអាកាសធាតុ និង ប្រព័ន្ធអេកូឡូស៊ី ។

70. ដូច្នេះ ក្នុងនីតិកាលទី ៥ នេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹង និង ពង្រីកថែមទៀតនូវការគ្រប់គ្រងធនធានធម្មជាតិសំដៅរក្សា «**តុល្យភាពរវាងការអភិវឌ្ឍ និង ការអភិរក្ស**» ពិសេសលើកកម្ពស់វិភាគទាននៃធនធានធម្មជាតិ ចំពោះការអភិវឌ្ឍវិស័យកសិកម្ម តាមរយៈ(១). ការធានាគម្របបៃតង, ការអភិរក្សព្រៃឈើ និង សត្វព្រៃ, (២). ការធានាចីរភាព

នៃធនធានជលផល, និង (៣) • ការរក្សាចីរភាពប្រព័ន្ធអេកូឡូស៊ី ដើម្បីធានាគុណភាពដី និង ចីរភាពនៃប្រភពទឹក ដោយផ្តោតលើការការពារជីវៈចម្រុះ, តំបន់ដីសើម និង តំបន់ឆ្នេរ ។

71. ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលនឹងប្រកាន់យកអភិក្រម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង ប្រទាក់ក្រឡាគ្នា សំដៅលើកកម្ពស់ប្រសិទ្ធភាព និង សមធម៌ ក្នុងការប្រើប្រាស់ធនធានធម្មជាតិ តាមរយៈ (១) • ការកំណត់ច្បាស់លាស់នូវកម្មសិទ្ធិលើធនធានធម្មជាតិ, (២) • ការពង្រឹងប្រព័ន្ធលើកទឹកចិត្តត្រឹមត្រូវ ក្នុងការងារអភិរក្សធនធានធម្មជាតិ និង ការផ្តល់សិទ្ធិអំណាចដល់អាជ្ញាធរថ្នាក់ក្រោមជាតិ, សហគមន៍ និង ប្រជាជនម្នាក់ៗ ក្នុងការចូលរួមអភិរក្សធនធានធម្មជាតិ ដោយផ្តោតលើការបណ្តុះបណ្តាល, ការផ្តល់ព័ត៌មាន ព្រមទាំងការពង្រឹងមូលធនសង្គម, គណនេយ្យភាព និង តម្លាភាពនៃស្ថាប័ន និង (៣) • ការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយតួអង្គអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងក្របខណ្ឌកំណើនបៃតង និង ការប្រែប្រួលអាកាសធាតុ ។

72. ផ្អែកលើអភិក្រមនេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការបន្តគ្រប់គ្រងធនធានព្រៃឈើ និង សត្វព្រៃ ប្រកបដោយចីរភាព និង សមធម៌ ស្របតាម «**កម្មវិធី ព្រៃឈើជាតិ ២០១០-២០២៩**» ពិសេសតាមរយៈការពង្រឹងការអនុវត្តច្បាប់ និង អភិបាលកិច្ច, ការកំណត់ព្រំប្រទល់, ចំណាត់ថ្នាក់ និង ការចុះបញ្ជីដែនព្រៃឈើ, ការគ្រប់គ្រង និង ប្រើប្រាស់ឱ្យមានប្រសិទ្ធភាពនូវព្រៃឈើរដ្ឋ និង ឯកជន, ការអនុវត្តវិធានការលើកកម្ពស់ជីវភាព និង ការចូលរួមរបស់សហគមន៍ដែលរស់នៅអាស្រ័យព្រៃឈើ, ការលើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រង និង ការអភិរក្ស, ការកាត់បន្ថយនូវការបាត់បង់ និង វិចរិលព្រៃឈើ, ការបង្កើនការដាំ និង ស្តារព្រៃឈើឡើងវិញ, ការពង្រឹងកិច្ចអភិរក្សសត្វព្រៃ និង ជម្រកសត្វព្រៃ, ការកសាងសមត្ថភាពស្ថាប័ន និង ការអភិវឌ្ឍធនធានមនុស្ស, ការជំរុញការងារស្រាវជ្រាវ និង ផ្សព្វផ្សាយ ។

ទី២- ការបន្តពង្រឹងការគ្រប់គ្រង និង អភិរក្សធនធានជលផលប្រកបដោយចីរភាព ស្របតាម «**ក្របខណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផល ២០១០-២០១៩**» និង «**សេចក្តីថ្លែងការណ៍ស្តីពីគោលនយោបាយវិស័យជលផលជាតិ**» ពិសេសតាមរយៈការប្រយុទ្ធប្រឆាំងនឹងបទល្មើសនេសាទគ្រប់ប្រភេទ ជាអាទិ៍ ការពង្រឹងការគ្រប់គ្រងឧបករណ៍ និង រដូវនេសាទ, ការលុបបំបាត់ការនេសាទហួសកម្រិត, ការពង្រឹងសមត្ថភាពសហគមន៍នេសាទ ក្នុងការគ្រប់គ្រង, ប្រើប្រាស់ និង អភិរក្សធនធានជលផល, ការការពារជីវចម្រុះ និង ទីជម្រកវារីសត្វ, ការគ្រប់គ្រងគុណភាពទឹកសាប និង សមុទ្រ ដោយកាត់បន្ថយសារធាតុពុលជាអតិបរមា, ការថែរក្សា និង ជំរុញការដាំព្រៃលិចទឹក និង ព្រៃកោងកាង, ការកំណត់ព្រំប្រទល់ព្រៃលិចទឹក និង តំបន់អភិរក្សជលផល ព្រមទាំងការកសាងសមត្ថភាពស្ថាប័ន, ការអភិវឌ្ឍធនធានមនុស្ស, ការសិក្សាស្រាវជ្រាវ និង ការផ្សព្វផ្សាយ ។

ទី៣- ការបន្តជំរុញអនុវត្តវិធានការនានា ដើម្បីរក្សាចីរភាពនៃប្រព័ន្ធអេកូឡូស៊ី សំដៅធានាគុណភាពដី និង ទឹកធម្មជាតិ រួមទាំងទឹកក្រោមដីផង សម្រាប់បម្រើឱ្យវិស័យកសិកម្ម និង ជីវភាពរស់នៅរបស់ប្រជាជន តាមរយៈការជំរុញការរៀបចំ និង អនុវត្តគោលនយោបាយ និង បទដ្ឋានគតិយុត្ត ព្រមទាំងផែនការសកម្មភាព និង កម្មវិធីនានា ឱ្យមានប្រសិទ្ធភាពសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដូចជា ឧទ្យានជាតិ, ជម្រកសត្វព្រៃ, តំបន់ការពារទេសភាព, តំបន់ប្រើប្រាស់ច្រើនយ៉ាង, «តំបន់រ៉ាមសារ», តំបន់អភិរក្សជីវសាស្ត្រ, តំបន់អភិរក្សមរតកធម្មជាតិ, តំបន់ឧទ្យានសមុទ្រ, ពិសេសពង្រឹង

ការអនុវត្ត«**ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ**», «**ច្បាប់ស្តីពីតំបន់ការពារ ធម្មជាតិ**» និង «**សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា**» ។

ទី៤- ការបន្តជំរុញអនុវត្តកិច្ចសហប្រតិបត្តិការជាមួយតួអង្គអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងក្របខណ្ឌ«**គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង**» និង «**ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ ២០១៣-២០៣០**» តាមរយៈ ការ-អភិវឌ្ឍក្របខណ្ឌគតិយុត្ត និង យន្តការសម្រាប់ការធ្វើពាណិជ្ជកម្មកាបូន, ការពង្រឹងសមត្ថភាព, ការរៀបចំ និង អនុវត្តវិធានការសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ, ការសិក្សាពីលទ្ធភាពក្នុងការប្រើប្រាស់យន្តការហិរញ្ញប្បទានផ្នែកបរិស្ថាន ដូចជា ការទូទាត់កម្រៃបរិស្ថាន និង មូលនិធិបរិស្ថាន, ការពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ រួមទាំងជីវៈចម្រុះ, តំបន់ផ្ទៃរងទឹកភ្លៀង និង តំបន់ដីសើម ព្រមទាំងការពង្រឹងយន្តការតាមដាន និង ត្រួតពិនិត្យបរិស្ថាន និង ប្រព័ន្ធអេកូឡូស៊ី ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។

## ចតុកោណទី ២. ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

73. ការអភិវឌ្ឍ និង ទំនើបកម្មវិស័យហេដ្ឋារចនាសម្ព័ន្ធ គឺជាកត្តាដ៏សំខាន់ សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច, បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច ព្រមទាំងពង្រឹងភាពប្រកួតប្រជែង និង ជំរុញពិពិធកម្មសេដ្ឋកិច្ចកម្ពុជា ពិសេស សម្រាប់កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ក្នុងន័យនេះ ដើម្បីឆ្លើយតបទៅនឹងដំណាក់កាលថ្មីនៃការអភិវឌ្ឍ សម្រាប់រយៈពេលវែងខាងមុខ រាជរដ្ឋាភិបាលនឹងរៀបចំនូវផែនការមេនៃការតភ្ជាប់មួយ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ទាំងផ្នែករឹង ទាំងផ្នែកទន់ ដែលគ្របដណ្តប់លើវិស័យគមនាគមន៍ដឹកជញ្ជូន, វិស័យថាមពលអគ្គិសនី ព្រមទាំងវិស័យបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ទន្ទឹមនឹងការបន្តជំរុញអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ និង វិស័យទឹកស្អាត ។ ជាមួយនេះ រាជរដ្ឋាភិបាលនឹងបង្កើនការយកចិត្តទុកដាក់លើការរៀបចំហេដ្ឋារចនាសម្ព័ន្ធទីក្រុង ។ កិច្ចការទាំងអស់នេះ នឹងត្រូវបានធ្វើ ដោយធានាសង្គតិភាពជាមួយនឹងក្របខណ្ឌនៃការរៀបចំដែនដី និង នគរូបនីយកម្ម ។

### មុំទី ១. ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង

74. គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ គឺការបន្តស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធគមនា-គមន៍ ជាអាទិ៍ ការបន្តសាងសង់ផ្លូវ, ការថែទាំផ្លូវ, ការពង្រឹងសមត្ថភាពកំពង់ផែ, ការស្តារ និង ការអភិវឌ្ឍវិស័យផ្លូវដែក, ការពង្រីកសេវាអាកាសយានដ្ឋាន និង ការពង្រឹងសុវត្ថិភាពហោះហើរ និង សុវត្ថិភាពចរាចរ ។ រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពល្អប្រសើរក្នុងការស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ដើម្បីសមាហរណកម្មផ្ទៃក្នុងប្រទេស និង ការតភ្ជាប់ទៅនឹងតំបន់ ។ ជាក់ស្តែង គិតត្រឹមឆ្នាំ ២០១២ ផ្លូវជាតិប្រវែងប្រមាណ ៤ ៣៥០ គីឡូម៉ែត្រ នៃបណ្តាញផ្លូវជាតិសរុបប្រមាណ ៥ ៦១៦ គីឡូម៉ែត្រ ត្រូវបានស្តារ និង កែលម្អ ហើយផ្លូវខេត្តប្រវែងប្រមាណជាង ១ ១០០ គីឡូម៉ែត្រ នៃផ្លូវខេត្តសរុបប្រវែងប្រមាណ ៦ ៦៤០ គីឡូម៉ែត្រ ត្រូវបានស្តារ និង កែលម្អ ដោយចាក់កៅស៊ូ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានផ្តល់

អាទិភាពខ្ពស់លើការជួសជុល និង សាងសង់ផ្លូវជនបទ ព្រមទាំងផ្លូវក្រវាត់ព្រំដែន ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាជន, ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និង បម្រើកិច្ចការពារបូរណភាពទឹកដី ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលបានកែលម្អហេដ្ឋារចនាសម្ព័ន្ធ និង បានលើកម្ពស់សេវានៃអាកាសយានដ្ឋាន និង កំពង់ផែផងដែរ ។

75. ទោះបីយ៉ាងនេះក្តី កម្ពុជានៅបន្តជួបនឹងបញ្ហាប្រឈមមួយចំនួន ដូចជា ថ្លៃដឹកជញ្ជូនខ្ពស់ធៀបនឹងប្រទេសជិតខាង, ការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនគ្រប់ប្រភេទផ្ទៃក្នុងប្រទេស, ការជុសជួល និងថែទាំផ្លូវ, ការដឹកជញ្ជូនលើសទម្ងន់កំណត់, សុវត្ថិភាពចរាចរ និង ការកកស្ទះចរាចរណ៍ ព្រមទាំងការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធ ។

76. ក្នុងបរិការណ៍នេះ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍក្នុងដំណាក់កាលថ្មី រាជរដ្ឋាភិបាលនីតិកាលទី ៥ ដាក់ចេញនូវគោលដៅបន្តអភិវឌ្ឍបណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដឹកជញ្ជូនគ្រប់ប្រភេទ រួមជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធទីក្រុង ឱ្យក្លាយទៅជាប្រព័ន្ធឡូជិស្ទីកមួយដ៏រស់រវើក, មានសុវត្ថិភាព និងមានប្រសិទ្ធភាព សំដៅរួមចំណែកលើកកម្ពស់ភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ព្រមទាំងជួយលើកស្ទួយសុខុមាលភាពរបស់ប្រជាជន ។

77. លើមូលដ្ឋាននេះ  រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពលើ ÷

ទី១- ការបន្តជំរុញកសាងបណ្តាញផ្លូវជាតិ, ផ្លូវខេត្ត និង ផ្លូវជនបទ ពិសេសការខិតខំក្រាលកៅស៊ូ និង ចាក់បេតុងផ្លូវជនបទ ឱ្យបានពី ៣០០ ទៅ ៤០០ គីឡូម៉ែត្រ ក្នុងមួយឆ្នាំ ។

ទី២- ការបង្កើនការយកចិត្តទុកដាក់លើការជួសជុល និង ការថែទាំប្រព័ន្ធគមនាគមន៍ដឹកជញ្ជូន ពិសេសផ្លូវថ្នល់តាមរយៈការពង្រឹងយន្តការ និង ការកែលម្អប្រព័ន្ធជួសជុល និង ថែទាំផ្លូវ រួមទាំងការចាត់វិធានការតឹងរ៉ឹងប្រកបដោយប្រសិទ្ធភាព និង ភាពម៉ឺងម៉ាត់ ចំពោះការដឹកជញ្ជូនលើសទម្ងន់កំណត់ ។

ទី៣- ការបន្តផ្តោតការយកចិត្តទុកដាក់ខ្ពស់ លើសុវត្ថិភាពចរាចរណ៍ តាមរយៈការកែលម្អ និង ការពង្រឹងការអនុវត្ត«**ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក**» រួមបញ្ចូលនូវការអនុវត្តវិធានការតឹងរ៉ឹងបំផុតចំពោះបទល្មើសចរាចរណ៍, ការពង្រឹងការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត និង ការផ្តល់ការអនុញ្ញាតឱ្យយានយន្តធ្វើចរាចរណ៍, ការពង្រឹងយន្តការផ្តល់ប័ណ្ណបើកបរ, ការដាក់សញ្ញាចរាចរណ៍ផ្លូវគោក, ការរៀបចំសម្រួលលំហូរចរាចរណ៍, ការពង្រឹងសមត្ថភាព និង សីលធម៌វិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់  ក៏ដូចជាការលើកកម្ពស់ការអប់រំ និង ការផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍ ស្របតាមពាក្យស្លោក «**ថ្ងៃនេះ, ថ្ងៃស្អែក, កុំឱ្យមានគ្រោះថ្នាក់ចរាចរណ៍**» ។

ទី៤- ការរៀបចំ និង ការអនុវត្តផែនការមេនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដឹកជញ្ជូន ដើម្បីតភ្ជាប់ផ្ទៃក្នុងប្រទេសផង និង ជាមួយប្រទេសជិតខាងផង តាមរយៈការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនគ្រប់ប្រភេទឱ្យក្លាយជាប្រព័ន្ធឡូជិស្ទីកមួយដ៏រស់រវើក និង មានភាពប្រកួតប្រជែង ទាំងក្នុងទិដ្ឋភាពនៃការតភ្ជាប់ការដឹកជញ្ជូនពហុសណ្ឋាន និង ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ក្នុងគោលដៅលើកកម្ពស់ការវិនិយោគ, ពាណិជ្ជកម្ម, ទេសចរណ៍ និង ការអភិវឌ្ឍជនបទ ដោយក្នុងនោះការយកចិត្តទុកដាក់នឹងត្រូវបានផ្តោតទៅលើការបញ្ចប់ទាំងស្រុងនូវការស្តារ  និង  ការអភិវឌ្ឍផ្លូវដែក,  ការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន និង កំពង់ផែ, ការសិក្សាអំពីសក្តានុពល និង ការវិនិយោគលើការដឹកជញ្ជូនតាមផ្លូវទឹក ព្រមទាំងការកែសម្រួលសេវាពាក់ព័ន្ធនឹងការដឹកជញ្ជូនមួយចំនួន ដែលមានលក្ខណៈផ្តាច់មុខ និង  ការបន្តជំរុញអនុវត្តកិច្ចព្រមព្រៀង និង ពិធីសារទាំងឡាយពាក់ព័ន្ធនឹងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដែលកម្ពុជាជាប្រទេសហត្ថលេខី ។

ទី៥- ការរៀបចំគោលនយោបាយ និង ក្របខណ្ឌគតិយុត្តចាំបាច់សម្រាប់ការគ្រប់គ្រង និង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជា ច្បាប់ស្តីពីផ្លូវថ្នល់ និង លិខិតបទដ្ឋានពាក់ព័ន្ធ រួមបញ្ចូលនូវការកំណត់ស្តង់ដារ និង គុណភាពផ្លូវ, ច្បាប់ស្តីពីកំពង់ផែ និង ច្បាប់ស្តីពីការដឹកជញ្ជូនផ្លូវគោកជាដើម ដើម្បីជួយសម្រួលដល់ការអនុវត្តផែនការមេនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ។

ទី៦- ការរៀបចំផែនការមេនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង ពិសេសប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនអ្នកដំណើរក្នុងទីក្រុង ព្រមទាំងការតភ្ជាប់រវាងតំបន់មូលដ្ឋានផលិតកម្មជុំវិញក្រុង, ប៉ូលសេដ្ឋកិច្ចសំខាន់ៗ, តំបន់ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស ជាដើម ដែលនឹងជួយកាត់បន្ថយការកកស្ទះចរាចរណ៍, លើកកម្ពស់ប្រសិទ្ធភាព និង ភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ព្រមទាំងជួយលើកស្ទួយសុខុមាលភាពប្រជាជន និង ធានាចីរភាពបរិស្ថាន ដោយធានាសង្គតិភាពជាមួយនឹងក្របខណ្ឌនៃការរៀបចំដែនដី និង នគរូបនីយកម្ម រួមមានជាអាទិ៍ គោលនយោបាយជាតិស្តីពីលំនៅដ្ឋាន, ច្បាប់ពាក់ព័ន្ធនឹងការរៀបចំដែនដី នគរូបនីយកម្ម និង សំណង់, យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍតំបន់ទីក្រុង និង ទីប្រជុំជន, ការរៀបចំប្រព័ន្ធគ្រប់គ្រងសំណល់រាវ និង សំណល់រឹង ព្រមទាំងប្រព័ន្ធការពារ និង ពន្លត់អគ្គិភ័យ ។

ទី៧- ការបន្តជំរុញការចូលរួមរបស់វិស័យឯកជន ក្នុងការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ តាមរយៈការពង្រឹង និង ការកែលម្អយន្តការ «**ភាពជាដៃគូរវាងវិស័យសាធារណៈ និង វិស័យឯកជន**» ដោយដាក់ចេញនូវឯកសារគោលនយោបាយស្តីពីការលើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និង វិស័យឯកជននៅកម្ពុជា ដើម្បីបង្កើនភាពទាក់ទាញ និង សម្រួលដល់ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលហិរញ្ញប្បទានដោយវិស័យឯកជន ។

### មុំទី ២. ការគ្រប់គ្រងធនធានទឹក និង ប្រព័ន្ធធារាសាស្ត្រ

**78.** គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ គឺការជំរុញកសាង ថែទាំ និង គ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ និង ការផ្គត់ផ្គង់ទឹកស្អាត ។

**79.** រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ រួមមាន : (១). ការស្តារ និង កសាងប្រព័ន្ធធារាសាស្ត្រសម្រេចបានលើផ្ទៃដីស្រោចស្រពចំនួនប្រមាណ ២៥០ ពាន់ហិកតា ពីឆ្នាំ ២០០៨-២០១២ ដោយបានបង្កើនសមត្ថភាពស្រោចស្រពសរុបដល់ប្រមាណជាង ១ លានហិកតា រួមមានផ្ទៃដីស្រូវវស្សាជាង ៧២០ ពាន់ហិកតា និង ផ្ទៃដីស្រូវប្រាំងជាង ២៩០ ពាន់ហិកតា, (២). ការរៀបចំសហគមន៍កសិករអ្នកប្រើប្រាស់ទឹកសម្រេចបានជាង ១០០ សហគមន៍, (៣). ការជួសជុលទំនប់ការពារទឹកជំនន់ដែលមានលទ្ធភាពការពារផ្ទៃដីដាំដុះបានជាង ៣ ពាន់ហិកតា, (៤). ការដំឡើងស្ថានីយ៍ជលសាស្ត្រ និង ស្ថានីយ៍ឧតុនិយមនៅតាមដងទន្លេ និង ស្ទឹងសំខាន់ៗ និង (៥). ការផ្គត់ផ្គង់ទឹកស្អាតសម្រេចបាន ៤៤% នៃគ្រួសារនៅទីជនបទ និង ៧៦% នៃគ្រួសារនៅទីប្រជុំជន ។

**80.** ទន្ទឹមនឹងនេះ កម្ពុជានៅមានសេចក្តីត្រូវការចាំបាច់ក្នុងការបន្តដោះស្រាយបញ្ហាប្រឈមមួយចំនួន ដូចជា ការបង្កើនសមត្ថភាពស្រោចស្រព ដើម្បីបង្កើនវដ្តវដាំដុះ សំដៅលើកកម្ពស់ផលិតភាពកសិកម្ម និង ប្រពលកម្មនៃការដាំដុះ, ការពង្រឹងយន្តការថែទាំ និង ជួសជុលហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ, ការលើកកម្ពស់ស្តង់ដារ និង គុណភាពនៃសំណង់ធារាសាស្ត្រ និង សំណង់សិល្បការ្យ, ការធ្វើវិចារណកម្មនៃការប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាព និង ចីរភាព, ការគ្រប់គ្រង និង ទប់ទល់នឹងគ្រោះទឹកជំនន់, ការបង្កើនសមត្ថភាព និង វិសាលភាពគ្របដណ្តប់ សម្រាប់ការផ្គត់ផ្គង់

ទឹកស្អាត, ការអភិវឌ្ឍក្របខណ្ឌគតិយុត្ត ក៏ដូចជាសមត្ថភាពស្ថាប័ន និង ធនធានមនុស្សសម្រាប់វិស័យទឹក ព្រមទាំងតម្រូវការសម្របសម្រួលរវាងការប្រើប្រាស់ទឹក ក្នុងវិស័យកសិកម្ម, ថាមពលអគ្គិសនី និង គមនាគមន៍ ។

**81.** ក្នុងន័យនេះ រាជរដ្ឋាភិបាលនីតិកាលទី ៥ នឹងបន្តលើកកម្ពស់ការគ្រប់គ្រងធនធានទឹក និង ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ, បង្កើនប្រសិទ្ធភាពនៃការថែទាំ និង ជួសជុលហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ, ជំរុញសមាហរណកម្មប្រព័ន្ធធារាសាស្ត្រជាមួយនឹងការអភិវឌ្ឍវារីអគ្គិសនី និង ប្រព័ន្ធដឹកជញ្ជូន ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍក្របខណ្ឌគតិយុត្ត, ស្ថាប័ន និង ធនធានមនុស្ស ។

**82.** ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការជំរុញវិត្ថារកម្មប្រព័ន្ធធារាសាស្ត្រ តាមរយៈការកៀរគរធនធានសាធារណៈ និង ធនធានពីប្រភពផ្សេងទៀត ដើម្បីបង្កើនសមត្ថភាពស្រោចស្រពប្រកបដោយវិចារណភាព ដោយយកចិត្តទុកដាក់លើការលើកកម្ពស់ស្តង់ដារ និង គុណភាពនៃហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ក៏ដូចជាប្រសិទ្ធភាពនៃការវិនិយោគ គួបផ្សំនឹងការកសាងអាងស្តុកទឹកបម្រុង និង ការបន្តរៀបចំប្រព័ន្ធប្រឡាយស្រោចស្រពឱ្យបានពេញលេញ ដោយយកចិត្តទុកដាក់ផងដែរ ដល់ភាពចាំបាច់ក្នុងការត្រៀមខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ។

ទី២- ការលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ ដោយផ្តោតលើការពង្រឹងក្របខណ្ឌគោល-នយោបាយ, ក្របខណ្ឌគតិយុត្ត និង យន្តការនៃការប្រើប្រាស់ទឹក, ការថែទាំ និង ហិរញ្ញប្បទាន តាមរយៈការជំរុញរៀបចំ និង អនុវត្តផែនការមេ សម្រាប់ការគ្រប់គ្រងធនធានទឹក និង ប្រព័ន្ធធារាសាស្ត្រ, ការបន្តពង្រឹងយន្តការថែទាំ, ជួសជុល និង ស្តារប្រព័ន្ធធារាសាស្ត្រ ព្រមទាំងការជំរុញរៀបចំ និង អនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសហគមន៍កសិករអ្នកប្រើប្រាស់ទឹក, ការគ្រប់គ្រងអាងទន្លេ, ការគ្រប់គ្រងគុណភាពទឹក និង ការអភិវឌ្ឍស្ថាប័ន និង ធនធានមនុស្ស ។

ទី៣- ការជំរុញការសម្របសម្រួលស្ថាប័ន សំដៅធ្វើសមាហរណកម្មការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រជាមួយនឹងការអភិវឌ្ឍវារីអគ្គិសនី និង ប្រព័ន្ធគមនាគមន៍ដឹកជញ្ជូន ដើម្បីបង្កើនប្រសិទ្ធភាពនៃការវិនិយោគ និង ការប្រើប្រាស់ធនធានទឹក ។

ទី៤- ការលើកកម្ពស់ចីរភាពនៃការប្រើប្រាស់ធនធានទឹក តាមរយៈការអនុវត្តឱ្យបានម៉ឺងម៉ាត់នូវ «**ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា**» និង ច្បាប់ពាក់ព័ន្ធផ្សេងទៀត ។

ទី៥- ការលើកកម្ពស់ការគ្រប់គ្រង និង ទប់ទល់នឹងទឹកជំនន់ តាមរយៈការសាងសង់ប្រព័ន្ធដោះទឹក, ទំនប់ការ-ពារទឹក, អាងស្តុកទឹក និង ប្រឡាយបង្វែរទឹក ដើម្បីកាត់បន្ថយផលប៉ះពាល់ពីគ្រោះធម្មជាតិ ។

ទី៦- ការបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ និង ទីប្រជុំជន តាមរយៈការជំរុញអនុវត្ត «**យុទ្ធសាស្ត្រជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និង អនាម័យជនបទ ២០១១-២០២៥**» ព្រមទាំងការរៀបចំផែនការជាក់-លាក់ និង ការលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ។

ទី៧- ការបន្តខិតខំពង្រឹង និង ពង្រីកយន្តការតាមដាន, ព្យាករណ៍ និង ផ្សព្វផ្សាយព័ត៌មានជលសាស្ត្រ និង ឧតុនិយមឱ្យបានទាន់ពេលវេលា និង ឱ្យកាន់តែមានសុក្រឹតភាព ពិសេសសំដៅធានាសុវត្ថិភាពនៃការដាំដុះ និង ត្រៀមទប់ទល់នឹងបច្ច័យនៃគ្រោះមហន្តរាយជាយថាហេតុ ។

ទី៨- ការបន្តចូលរួមក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យទឹក ដើម្បីធានានិរន្តរភាព និង ប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានទឹក ក៏ដូចជាក្នុងការដោះស្រាយបច្ច័យអាក្រក់បណ្តាលមកពីគ្រោះទឹកជំនន់ និង រាំងស្ងួត ព្រមទាំងពីការប្រែប្រួលអាកាសធាតុ ។

### មុំទី ៣. ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី

83. គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ គឺការបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់, ការបញ្ចុះថ្លៃអគ្គិសនីឱ្យបានសមរម្យ និង ការពង្រឹងយន្តការស្ថាប័ន និង សមត្ថភាពគ្រប់គ្រង ។

84. ដើម្បីគោលដៅនេះ រាជរដ្ឋាភិបាលបានបង្កើនសមត្ថភាពផ្គត់ផ្គង់ និង ធ្វើពិពិធភាវូបនីយកម្មប្រភពថាមពល ដើម្បីងាកចេញពីការពឹងផ្អែកជាសំខាន់លើការប្រើប្រាស់ប្រេង ក្នុងការផលិតថាមពលអគ្គិសនី មកជាការសាងសង់ស្ថានីយ៍វារីអគ្គិសនី និង រោងចក្រអគ្គិសនីប្រើធ្យូងថ្ម ដែលមានសមត្ថភាពផលិតធំ និង ថ្លៃដើមផលិតកម្មទាប ទន្ទឹមនឹងការនាំចូលអគ្គិសនីពីប្រទេសជិតខាង ក្នុងគោលដៅកាត់បន្ថយថ្លៃអគ្គិសនី ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់លើការពង្រីកបណ្តាញបញ្ជូន និង ចែកចាយ ព្រមទាំងកាត់បន្ថយការបាត់បង់ថាមពលតាមប្រព័ន្ធ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការអគ្គិសនីដែលមានកំណើនប្រមាណ ២៥% ក្នុងមួយឆ្នាំ ដោយសារការរីកលូតលាស់នៃសេដ្ឋកិច្ច និង ការកើនឡើងនៃចំនួនអ្នកប្រើប្រាស់នៅតាមគេហដ្ឋាន, អាជីវកម្ម និង រោងចក្រឧស្សាហកម្ម ។

85. ក៏ប៉ុន្តែ កម្ពុជានៅបន្តជួបបញ្ហាប្រឈមសំខាន់ៗមួយចំនួន រួមមាន ភាពមិនទាន់អាចឆ្លើយគ្នាបានរវាងការផ្គត់ផ្គង់ និង សេចក្តីត្រូវការ, ភាពចាំបាច់ក្នុងការពង្រឹងសមត្ថភាពធានាសន្តិសុខថាមពល, ការធានាឱ្យបានពេញលេញនូវភាពអាចទុកចិត្តបានក្នុងការផ្គត់ផ្គង់, ថ្លៃអគ្គិសនីនៅមិនទាន់ឆ្លើយតបទៅនឹងការចង់បានរបស់រាជរដ្ឋាភិបាលនៅឡើយ ព្រមទាំងភាពចាំបាច់ក្នុងការបន្តពង្រឹងសមត្ថភាពគ្រប់គ្រង ។

86. លើមូលដ្ឋាននេះ គោលដៅរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ ក្នុងវិស័យថាមពលអគ្គិសនី គឺការបន្តពង្រឹងសមត្ថភាព និង សុវត្ថិភាពក្នុងការផ្គត់ផ្គង់ ព្រមទាំងការពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ ដើម្បីបង្កើនភាពប្រកួតប្រជែងសេដ្ឋកិច្ច, ទ្រទ្រង់កំណើនសេដ្ឋកិច្ចរយៈពេលវែង, ពង្រឹងសមត្ថភាពធានាសន្តិសុខថាមពលអគ្គិសនី និង លើកកម្ពស់ជីវភាពរបស់ប្រជាជន ។

87. ដើម្បីសម្រេចបានតាមគោលដៅនេះ រាជរដ្ឋាភិបាលនឹងផ្តោតលើអាទិភាព ដូចតទៅ ÷

ទី១- ការបន្តបង្កើនសមត្ថភាពផលិតថាមពលអគ្គិសនី ដែលមានថ្លៃដើមថោក និង ប្រើប្រាស់បច្ចេកវិទ្យាទំនើបពិសេស ប្រភពថាមពលថ្មី និង ថាមពលស្អាត ទន្ទឹមនឹងការបន្តអភិវឌ្ឍបណ្តាញបញ្ជូនអគ្គិសនីគ្រប់កម្រិត សំដៅពង្រឹងសន្តិសុខថាមពល ព្រមទាំងធានាប្រសិទ្ធភាព, សុវត្ថិភាព, គុណភាព, ភាពអាចទុកចិត្តបាន និង ថ្លៃសមរម្យក្នុងការផ្គត់ផ្គង់ និង ចែកចាយថាមពលអគ្គិសនី ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍ ។

ទី២- ការបន្តទាក់ទាញឱ្យមានការចូលរួមរបស់វិស័យឯកជន ក្នុងការវិនិយោគលើការផលិត និង លើហេដ្ឋារចនាសម្ព័ន្ធបញ្ជូន និង ចែកចាយថាមពលអគ្គិសនី ដោយយកចិត្តទុកដាក់លើប្រសិទ្ធភាពបច្ចេកទេស- សេដ្ឋកិច្ច និង ការកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់លើបរិស្ថានធម្មជាតិ និង សង្គម ។

ទី៣- ការបន្តអនុវត្តយុទ្ធសាស្ត្រអគ្គិសនីភាវូបនីយកម្ម ដើម្បីឈានទៅសម្រេចគោលដៅ«**នៅឆ្នាំ ២០២០ គ្រប់ភូមិទាំងអស់នៃព្រះរាជាណាចក្រកម្ពុជានឹងមានការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិ និង ប្រភពផ្សេងៗ**» ។

ទី៤- ការបន្តគាំទ្រមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ សំដៅធានាសមធម៌ ក្នុងការទទួលបានសេវាអគ្គិសនីក្នុងចំណោមប្រជាជន ។

ទី៥- ការជំរុញអនុវត្តវិធានការវិចារណកម្មនៃការប្រើប្រាស់ថាមពលអគ្គិសនី តាមរយៈការលក់អគ្គិសនីក្នុងថ្លៃទាបជូនអតិថិជន ដែលប្រើអគ្គិសនីក្នុងរយៈពេលមានសេចក្តីត្រូវការទាប ក្នុងគោលដៅបម្រើប្រព័ន្ធផលិតកម្ម និង ការស្រោចស្រព សំដៅលើកកម្ពស់ផលិតភាពកសិកម្ម និង ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម និង សិប្បកម្ម ។

ទី៦- ការបន្តជំរុញការរុករក និង ធ្វើអាជីវកម្មវិស័យប្រេង និង ឧស្ម័ន ដែលជាសក្តានុពលដ៏សំខាន់មួយ សម្រាប់សន្តិសុខថាមពល និង ជាប្រភពធនធានដ៏មានតម្លៃ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជារយៈពេលវែង ។

ទី៧- ការបន្តពង្រឹងសមត្ថភាពស្ថាប័ន, ធនធានមនុស្ស ព្រមទាំងការធ្វើផែនការ និង ការគ្រប់គ្រង ក្នុងវិស័យថាមពល ។

ទី៨- ការបន្តសកម្មចូលរួមក្នុងកិច្ចសហប្រតិបត្តិការវិស័យថាមពលក្នុងក្របខណ្ឌតំបន់ ។

### មុំទី ៤. ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍

88. គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ គឺជំរុញការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ទំនើប និង ប្រកបដោយគុណភាព តាមរយៈការពង្រឹងក្របខណ្ឌគតិយុត្ត, ការកសាងសមត្ថភាពស្ថាប័ន, ការធ្វើទំនើបកម្មមូលដ្ឋានសម្ភារៈបច្ចេកទេស, ការលើកស្ទួយការប្រកួតប្រជែង, ការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និង រដ្ឋបាលអេឡិចត្រូនិច ព្រមទាំងការជំរុញសាងសង់ និង បង្កើនប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នង សម្រាប់វិស័យបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ។

89. ក្នុងការអនុវត្តគោលដៅខាងលើ រាជរដ្ឋាភិបាលបានកែទម្រង់វិស័យនេះ ដោយបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ដែលជាអង្គភាពមានស្វ័យភាព ក្នុងការត្រួតពិនិត្យ និង គ្រប់គ្រងខាងផ្នែកបច្ចេកទេស និង រដ្ឋបាលនៃវិស័យទូរគមនាគមន៍, បង្កើតប្រៃសណីយ៍កម្ពុជា ជាសហគ្រាសសាធារណៈ ដើម្បីបន្តពង្រីក និង អភិវឌ្ឍវិស័យប្រៃសណីយ៍ ប្រកបដោយគុណភាពខ្ពស់តាមស្តង់ដារអន្តរជាតិ និង បង្កើតមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ ក្នុងគោលដៅពង្រឹងការគ្រប់គ្រង និង ប្រមូលចំណូលពីវិស័យទូរគមនាគមន៍ ។ ការអនុវត្តកំណែទម្រង់នេះ បានផ្តល់វឌ្ឍនភាពគួរឱ្យកត់សម្គាល់ រួមមាន : (១). ចំនួនលេខទូរស័ព្ទចល័តដែលអតិថិជនបានជាវ បានកើនឡើងពី ៣,៨ លានលេខ នៅឆ្នាំ ២០០៨ ដល់ប្រមាណ ១៩ លានលេខ នៅឆ្នាំ ២០១២ ស្មើនឹងអត្រាប្រមាណ ១៣០ លេខ ក្នុងប្រជាជន ១០០ នាក់ និង គ្របដណ្តប់ទីប្រជុំជនប្រមាណ ៩០%, (២). អតិថិជនប្រើប្រាស់សេវាអ៊ិនធឺណេតបានកើនឡើងពី ២ ម៉ឺននាក់ នៅឆ្នាំ ២០០៨ ដល់ ២,៧ លាននាក់ នៅឆ្នាំ២០១២ (៣). គុណភាពនៃបណ្តាញ និង សេវាទូរគមនាគមន៍ ត្រូវបានពង្រឹងជាបន្តបន្ទាប់ ទន្ទឹមនឹងការបន្តអភិវឌ្ឍប្រភេទទូរស័ព្ទអចល័ត និង (៤). បណ្តាញ និង សេវាគ្របដណ្តប់របស់ខ្សែកាប្លិ៍អុបទិក ត្រូវបានពង្រីកឥតឈប់ឈរ ដោយតភ្ជាប់ពីរាជធានីភ្នំពេញទៅគ្រប់ស្រុក និង ឃុំមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាតភ្ជាប់កម្ពុជាជាមួយប្រទេសជិតខាងក្នុងតំបន់ ។

**90.** ទោះបីយ៉ាងនេះក្តី កម្ពុជានៅបន្តជួបប្រទះបញ្ហាប្រឈមមួយចំនួន ជាអាទិ៍ (១). ភាពមិនទាន់ពេញលេញគ្រប់ជ្រុងជ្រោយនៃក្របខណ្ឌគោលនយោបាយ, យុទ្ធសាស្រ្ត និង ក្របខណ្ឌគតិយុត្ត ដើម្បីគ្រប់គ្រងវិស័យនេះប្រកបដោយប្រសិទ្ធភាព, (២). ភាពចាំបាច់ក្នុងការពង្រឹង និង សម្របសម្រួលយន្តការស្ថាប័ន, (៣). ភាពមិនទាន់ឆ្លើយតបប្រកបដោយប្រសិទ្ធភាពនៃធនធានមនុស្ស និង អក្ខរកម្មបច្ចេកវិទ្យាព័ត៌មាន ទៅនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាទំនើប, (៤). ភាពចាំបាច់ក្នុងការពង្រឹងភាពប្រកួតប្រជែងនៃសេវាទូរស័ព្ទចល័ត និង អ៊ីនធឺណេត ធៀបនឹងប្រទេសជិតខាង, (៥). សេចក្តីត្រូវការពង្រឹងកិច្ចសហការ និង ការសម្របសម្រួល រវាងប្រតិបត្តិករ និង ប្រតិបត្តិករ ក៏ដូចជារវាងប្រតិបត្តិករ និង ស្ថាប័នទទួលខុសត្រូវ និង (៦). ភាពចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាពនៃការវិនិយោគ និង ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរបវ័ត្ត ក៏ដូចជាការពង្រីកវិសាលភាព និង ការពង្រឹងប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នង ។

**91.** នៅក្នុងបរិការណ៍នេះ ក៏ដូចជាក្នុងគោលដៅត្រៀមរៀបចំមូលដ្ឋានសម្រាប់ការឈានឡើងរបស់កម្ពុជាទៅកាន់ដំណាក់កាលថ្មីនៃការអភិវឌ្ឍ ពិសេសការធានាភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុង **«សេដ្ឋកិច្ចពុទ្ធិ»** នាពេលអនាគត, រាជរដ្ឋាភិបាលនីតិកាលទី ៥ នឹងបន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ឱ្យមានលក្ខណៈទំនើប, ទាន់សម័យ, មានគុណភាពខ្ពស់ស្របតាមស្តង់ដារអន្តរជាតិ, មានថ្លៃប្រកួតប្រជែង និង មានសេវាគ្របដណ្តប់នៅទូទាំងប្រទេស ដែលប្រជាជនទូទៅអាចប្រើប្រាស់បាន និង ទទួលបានផលប្រយោជន៍គ្រប់ៗគ្នាពីសេវានេះ ។

**92.** ដូច្នេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ÷

ទី១- ការរៀបចំគោលនយោបាយជាតិ សម្រាប់ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាព័ត៌មាននិង គមនាគមន៍ ដោយយកចិត្តទុកដាក់លើគ្រប់ទិដ្ឋភាពសេដ្ឋកិច្ច និង សង្គម ។

ទី២- ការជំរុញអនុម័តច្បាប់ស្តីពីទូរគមនាគមន៍ និង ការរៀបចំច្បាប់ពាក់ព័ន្ធផ្សេងទៀត មានជាអាទិ៍ ច្បាប់ស្តីពីការបង្ក្រាបឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍, ច្បាប់ស្តីពីពាណិជ្ជកម្មអេឡិកត្រូនិក ដែលចាំបាច់សម្រាប់គ្រប់គ្រងវិស័យបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ប្រកបដោយប្រសិទ្ធភាព ។

ទី៣- ការពង្រឹងការអនុវត្ត និង ការជំរុញរៀបចំបំពេញបន្ថែមនូវបញ្ញត្តិកម្មលើវិស័យទូរគមនាគមន៍ និង វិស័យបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ។

ទី៤- ការពង្រឹងតួនាទីស្ថាប័នគ្រប់គ្រង និង ការជំរុញការសម្របសម្រួលស្ថាប័ន ដើម្បីអភិវឌ្ឍ និង គ្រប់គ្រងវិស័យនេះ ឱ្យមានប្រសិទ្ធភាព និង តម្លាភាព ។

ទី៥- ការរៀបចំ និង ដាក់ឱ្យប្រើប្រាស់ផែនការជាតិ សម្រាប់ប្រព័ន្ធអ៊ីនធឺណេតល្បឿនលឿន ដើម្បីរួមចំណែកដល់ការលើកកម្ពស់នវានុវត្តន៍, ការអភិវឌ្ឍធនធានមនុស្ស, ការពង្រឹងភាពប្រកួតប្រជែង និង ការបង្កើនផលិតភាពសេដ្ឋកិច្ច ក៏ដូចជាដើម្បីបង្កើនការចូលរួមរបស់ប្រជាជន ឱ្យកាន់តែទូលំទូលាយឡើងនៅក្នុងកិច្ចការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ។

ទី៦- ការពង្រីកវិសាលភាព និង ការពង្រឹងប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នង ពិសេសតាមរយៈការជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នងរួម ទន្ទឹមនឹងការបន្តពង្រីកហេដ្ឋារចនាសម្ព័ន្ធនេះ ឱ្យបានដល់តំបន់ ដែលមានសក្តានុពលខាងសេដ្ឋកិច្ច និង ទេសចរណ៍ ក៏ដូចជាតំបន់ជនបទដាច់ស្រយាលដែលគ្មាន ឬ មានសេវាទូរគមនាគមន៍មិនគ្រប់គ្រាន់ ។

ទី៧- ការជំរុញអភិវឌ្ឍធនធានមនុស្ស ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាទំនើប និង ការលើកកម្ពស់កម្រិតអក្ខរកម្មបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ សំដៅធានាប្រសិទ្ធភាពនៃការប្រើប្រាស់ និង ស្រូបយកឱ្យអស់លទ្ធភាពនូវសក្ដានុពលពីវិស័យនេះ តាមរយៈការពង្រឹងកម្មវិធីសិក្សានៅគ្រប់កម្រិត ក៏ដូចជាការបណ្ដុះបណ្ដាលមន្ត្រីរាជការ ព្រមជាមួយនឹងការជំរុញលើកទឹកចិត្តដល់វិស័យឯកជនចូលរួមលើកកម្ពស់អក្ខរកម្មបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ។

ទី៨- ការបន្តអភិវឌ្ឍប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិច ។

ទី៩- ការជំរុញលើកទឹកចិត្តដល់វិស័យឯកជនឱ្យវិនិយោគលើបច្ចេកវិទ្យាទំនើប, ទាន់សម័យ ដូចជា ប្រព័ន្ធអ៊ីនធឺណេតល្បឿនលឿន, បច្ចេកវិទ្យាពពក និងការអភិវឌ្ឍសូហ្វវែរ (software) ដើម្បីលើកកម្ពស់គុណភាព និង ប្រសិទ្ធភាពនៃសេវាបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ។

## ចតុកោណទី ៣. ការអភិវឌ្ឍវិស័យឯកជន និង ការងារ

93. រាជរដ្ឋាភិបាលបានកំណត់ថា «**វិស័យឯកជន គឺជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច**» ។ ជាការពិតវិស័យឯកជនមានតួនាទីគន្លឹះ ក្នុងការជំរុញកំណើន និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ពិសេស ការធ្វើឱ្យសម្រេចនូវគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម, ការបញ្ចូលបច្ចេកវិទ្យាទំនើប និង គំនិតច្នៃប្រឌិត សំដៅបង្កើនប្រសិទ្ធភាព និង ពង្រឹងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ព្រមទាំងការបង្កើតការងារ ដើម្បីកាត់បន្ថយភាពក្រីក្រ និង លើកស្ទួយជីវភាពរបស់ប្រជាជន ។ ក្នុងន័យនេះ ដើម្បីឆ្លើយតបនឹងសេចក្ដីត្រូវការនៃការអភិវឌ្ឍក្នុងដំណាក់កាលថ្មី រាជរដ្ឋាភិបាលនឹងបន្តជំរុញអភិវឌ្ឍវិស័យឯកជន តាមរយៈវិធានការជាកញ្ចប់ និង គ្រប់ជ្រុងជ្រោយ សំដៅរៀបចំ និង កែលម្អគោលនយោបាយ, ក្របខណ្ឌគតិយុត្ត, ក្របខណ្ឌអភិបាលកិច្ច និង ស្ថាប័ន ព្រមទាំងសេវា និង មធ្យោបាយសម្រួល និង គាំទ្រពាក់ព័ន្ធផ្សេងទៀត រួមទាំងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង ធនាគារ និង ទីផ្សារការងារផង ។ ក្នុងកិច្ចដំណើរការនេះ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវ «**គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម**» ដែលមានតួនាទីស្នូល ក្នុងការនាំសេដ្ឋកិច្ចកម្ពុជាឈានឡើងទៅកាន់កម្ពស់ថ្មីមួយទៀត ក្នុងខ្សែចង្វាក់នៃតម្លៃបន្ថែម ក្នុងតំបន់ និង សកលលោក ។

### មុំទី ១. ការពង្រឹងវិស័យឯកជន និង ការជំរុញការវិនិយោគ និង ធុរកិច្ច

94. គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ គឺការបន្តទាក់ទាញទុនវិនិយោគឯកជន ទាំងក្រៅប្រទេស ទាំងក្នុងស្រុក តាមរយៈការបន្តពង្រឹងបរិស្ថានអំណោយផលដល់ការវិនិយោគ និង ធុរកិច្ច, ការបន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ការជំរុញធ្វើពិពិធកម្មឧស្សាហកម្ម, ការលើកស្ទួយសហគ្រាសធុនតូច និង មធ្យម និង ការធ្វើទំនើបកម្មសហគ្រាស, ការបន្តពង្រឹងក្របខណ្ឌគតិយុត្ត, ការបន្តអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និង កិច្ចសម្រួលពាណិជ្ជកម្ម និង ការបន្តពង្រីកច្រកចូលទៅកាន់ទីផ្សារអន្តរជាតិ ព្រមទាំងការពង្រឹងភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ។

95. ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលសំខាន់ៗជាច្រើន ជាអាទិ៍ ការកែលម្អក្របខណ្ឌគតិយុត្ត, ការកែលម្អកិច្ចសម្រួលពាណិជ្ជកម្ម រួមមាន ការកាត់បន្ថយចំណាយធុរកិច្ច, ការកំណត់កម្រៃ និង ស្តង់ដារនៃសេវាសាធារណៈ ក៏ដូចជាការកាត់បន្ថយ និង សម្រួលនីតិវិធីរដ្ឋបាល ព្រមទាំងការពង្រីកទីផ្សារអន្តរជាតិ តាមរយៈការចូលរួមក្នុងតំបន់ពាណិជ្ជកម្មសេរី និង កិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្ម ។ ទន្ទឹមនឹងនេះ តំបន់សេដ្ឋកិច្ចពិសេសចំនួន ៨ បានដំណើរការ ហើយបានទាក់ទាញការវិនិយោគមកពីប្រភពថ្មី និង ក្នុងវិស័យថ្មីៗ រួមមាន រោងចក្រកែច្នៃម្ហូបអាហារ, រោងចក្រផ្គុំដំឡើង, រោងចក្រគ្រឿងអេឡិចត្រូនិច ជាដើម ។ លើសពីនេះ ភាពជាដៃគូរវាងរាជរដ្ឋាភិបាល និង វិស័យឯកជន ត្រូវបានពង្រឹង និង លើកកម្ពស់ថែមទៀត តាមរយៈកិច្ចដំណើរការប្រកបដោយប្រសិទ្ធភាពនៃ«**វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន**» និង យន្តការពាក់ព័ន្ធ ។ ជាតួលេខ បើគិតតែការវិនិយោគផ្ទាល់ពីបរទេស កម្ពុជាទទួលបានក្នុងទំហំជាមធ្យមប្រមាណ ៧០០ លានដុល្លារ ក្នុងមួយឆ្នាំ ជាមួយនឹងការបង្កើតការងារថ្មីជាមធ្យម ក្នុងមួយឆ្នាំ ប្រមាណ ២ សែនកន្លែង ។ ទន្ទឹមនេះ ការនាំចេញរបស់កម្ពុជាមានការកើនឡើងជាបន្តបន្ទាប់ ហើយនៅឆ្នាំ ២០១២ សម្រេចបាន ៥ ៥០០ លានដុល្លារ ខណៈដែលមុខទំនិញនាំចេញក៏មានចំនួនកាន់តែច្រើនជាងមុន ។

96. ទោះជាយ៉ាងនេះក្តី ក្នុងការអភិវឌ្ឍវិស័យឯកជន កម្ពុជានៅបន្តជួបប្រទះបញ្ហាប្រឈមមួយចំនួន ពិសេសប្រសិទ្ធភាពនៃប្រព័ន្ធឡូជីស្ទិក និង ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ, ចំណាយធុរកិច្ចនៅតែខ្ពស់នៅឡើយ ធៀបជាមួយនឹងប្រទេសក្នុងតំបន់, ផលិតភាព និង សមត្ថភាពជំនាញរបស់ពលករនៅមិនទាន់ឆ្លើយតបនឹងសេចក្តីត្រូវការរបស់ទីផ្សារ, ភាពចាំបាច់ក្នុងការពង្រឹងសមត្ថភាពរបស់សហគ្រាសធុនតូច និង មធ្យម ព្រមទាំងភាពចាំបាច់ក្នុងការបន្តពង្រឹងក្របខណ្ឌគតិយុត្ត និង ស្ថាប័ន ។

97. នៅលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនីតិកាលទី ៥ ដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្រពីរ គឺ : (១) • ការបន្តជំរុញអភិវឌ្ឍវិស័យឯកជនឱ្យកាន់តែមានភាពរស់រវើក និង មានជីវភាពខ្លាំងថែមទៀត ក្នុងតួនាទីជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច និង (២) • ការប្រែក្លាយកម្ពុជាឱ្យទៅជាគោលដៅវិនិយោគ ប្រកបដោយភាពទាក់ទាញ និង ភាពប្រកួតប្រជែងនៅក្នុងតំបន់ ពិសេសក្នុងក្របខណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន ។

98. ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការជំរុញលើកទឹកចិត្តការវិនិយោគក្នុងវិស័យឧស្សាហកម្មទំនើប ដែលមានតម្លៃបន្ថែមខ្ពស់ ក្នុងទិសដៅលើកកម្ពស់ពិពិធកម្មមូលដ្ឋានផលិតកម្ម ។

ទី២- ការជំរុញលើកទឹកចិត្តការវិនិយោគនៅទីជនបទ ដែលនឹងចូលរួមដល់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ, ការកាត់បន្ថយគម្លាតរវាងទីក្រុង និង ជនបទ ក៏ដូចជាការលើកស្ទួយជីវភាពរបស់ប្រជាជន និង កាត់បន្ថយចំណាកស្រុកពីជនបទមកទីប្រជុំជន និង ចំណាកស្រុករកការងារធ្វើនៅក្រៅប្រទេស ។

ទី៣- ការបន្តធ្វើទំនើបកម្មសហគ្រាសក្នុងស្រុក និង ការលើកកម្ពស់គំនិតច្នៃប្រឌិត ព្រមទាំងការផ្សារភ្ជាប់គ្នារវាងសហគ្រាស និង ឧស្សាហកម្មក្នុងស្រុក ជាមួយនឹងគម្រោងវិនិយោគមកពីក្រៅប្រទេស ក្នុងគោលដៅស្រូបយកបច្ចេកវិទ្យា, ចំណេះដឹង ចំណេះធ្វើ, បង្កើនផលិតភាព, បង្កើនភាពទាក់ទាញ និង ភាពប្រកួតប្រជែងរបស់កម្ពុជា ។

ទី៤- ការបន្តពង្រឹងបរិស្ថានអនុគ្រោះសម្រាប់ការវិនិយោគ និង ធុរកិច្ច តាមរយៈការបន្តកែលម្អក្របខណ្ឌគតិយុត្ត, ការធ្វើវិចារណកម្មរបបលើកទឹកចិត្តសម្រាប់គម្រោងវិនិយោគ, ការបន្តពង្រឹងក្របខណ្ឌអភិបាលកិច្ច និង ប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ រួមទាំងការបន្តពង្រឹងយន្តការ **«ច្រកចេញ- ចូលតែមួយ»** នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

ទី៥- ការបន្តកែលម្អកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការកែសម្រួលទម្រង់បែបបទ, នីតិវិធីរដ្ឋបាល និង យន្តការនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែន, ការកាត់បន្ថយចំណាយធុរកិច្ច ព្រមទាំងការពង្រឹងកិច្ចសម្របសម្រួលអន្តរស្ថាប័ន ។

ទី៦- ការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងកែលម្អសេវា និង មធ្យោបាយ សម្រាប់សម្រួល និង គាំទ្រដល់កិច្ចដំណើរការធុរកិច្ច រួមទាំងការបន្តពង្រឹង និង អភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ។

ទី៧- ការបន្តពង្រឹងអភិបាលកិច្ចសាជីវកម្ម សម្រាប់ភាពរឹងមាំ និង ភាពធំធាត់របស់វិស័យឯកជន និង សម្រាប់លើកកម្ពស់វប្បធម៌គណនេយ្យភាពចំពោះសង្គម ។

ទី៨- ការបន្តពង្រឹងប្រសិទ្ធភាពនៃយន្តការ **«វេទិការាជរដ្ឋាភិបាល- ផ្នែកឯកជន»** ក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដែលវិស័យឯកជនជួបប្រទះ ហើយបន្ថែមលើនេះ លើកកម្ពស់ឱ្យទៅជាយន្តការសម្រាប់ការពិភាក្សាផ្តល់ជម្រើស និង អនុសាសន៍គោលនយោបាយនានា ដើម្បីបង្កើនតួនាទីរបស់វិស័យឯកជនជាតួអង្គក្នុងកិច្ចការអភិវឌ្ឍន៍ ។

ទី៩- ការពង្រឹងសេវាថែទាំការវិនិយោគ ដើម្បីដោះស្រាយបញ្ហារបស់វិនិយោគិនឱ្យទាន់ពេលវេលា ។

ទី១០- ការពង្រឹងយន្តការតាមដានត្រួតពិនិត្យការអនុវត្តគម្រោងវិនិយោគ ដើម្បីធានាការអនុវត្តត្រឹមត្រូវតាមគោលការណ៍ និង លក្ខខណ្ឌកំណត់ ។

## មុំទី ២. ការអភិវឌ្ឍឧស្សាហកម្ម និង សហគ្រាសធុនតូច និង មធ្យម

**99.** គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ គឺការលើកស្ទួយសហគ្រាសធុនតូច និង មធ្យម ពិសេស ការពង្រឹងបរិស្ថានធុរកិច្ច តាមរយៈការកែលម្អក្របខណ្ឌគតិយុត្ត, ការលើកស្ទួយនវានុវត្តន៍ និង បច្ចេកវិទ្យា, ការលើកកម្ពស់លទ្ធភាពទទួលហិរញ្ញប្បទាន និង ការពង្រឹង និង ពង្រីកសេវាគាំទ្រផ្សេងទៀត ព្រមទាំងការធ្វើសមាហរណកម្មសហគ្រាសធុនតូច និង មធ្យម ទៅក្នុងខ្សែចង្វាក់តម្លៃជាសកល ។

**100.** តាមគោលដៅនេះ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ ពិសេស គឺការជំរុញអនុវត្តឯកសារក្របខណ្ឌអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម តាមរយៈការពង្រឹងអភិបាលកិច្ច សំដៅលើកកម្ពស់បរិយាកាសអាជីវកម្ម, ការរៀបចំស្តង់ដារឧស្សាហកម្ម, ការរៀបចំស្តង់ដារគណនេយ្យ និង របាយការណ៍ហិរញ្ញវត្ថុ សំដៅបង្កើនលទ្ធភាពរបស់សហគ្រាសធុនតូច និង មធ្យមក្នុងការទទួលហិរញ្ញប្បទាន, ការផ្តល់ការលើកទឹកចិត្តផ្នែកពន្ធលើធាតុចូល សម្រាប់ផលិតកម្មមួយចំនួន និង ការកសាងសមត្ថភាពស្ថាប័ន ពិសេស ការបង្កើត **«មជ្ឈមណ្ឌលផលិតភាពជាតិ»** និង **«មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្ម»** ។ ការអនុវត្តវិធានការទាំងនេះ បានរួមចំណែកប្រកបដោយផ្លែផ្កាដល់ការពង្រីកមូលដ្ឋានឧស្សាហកម្ម ក្នុងនោះ មានការកកើតនូវឧស្សាហកម្មថ្មីៗដំឡើង, ឧស្សាហកម្មអេឡិចត្រូនិចឧស្សាហកម្ម ផលិតគ្រឿងបន្លាស់, ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម និង ឧស្សាហកម្មកម្មន្តសាលផ្សេងទៀត ។ ជាតួលេខ ពីឆ្នាំ ២០០៨ ដល់ឆ្នាំ ២០១២ មានរោងចក្រធុនធំថ្មីបានកើតឡើងចំនួន ៥១៨ ដែលបានបង្កើតផលិតផលសរុប គិតជាទឹកប្រាក់ មានចំនួនជិត

៥៥០០ លានដុល្លារ និង បង្កើតការងារបានចំនួន ៥៦០ ពាន់កន្លែង ។ បន្ថែមលើនេះ សហគ្រាសឧស្សាហកម្មធុនតូច និង មធ្យម នៅឆ្នាំ ២០១២ មានចំនួនជាង ៣៨ ពាន់ និង បានបង្កើតការងារសរុបចំនួនជាង ១៨៥ ពាន់កន្លែង ។

**101.** ទោះជាយ៉ាងណាក៏ដោយ កម្ពុជានៅបន្តជួបនឹងបញ្ហាប្រឈមមួយចំនួន ជាពិសេស មូលដ្ឋានឧស្សាហកម្មនៅតូចចង្អៀត, កង្វះខាតឧស្សាហកម្មគាំទ្រ, ភាពមិនទាន់រីកចម្រើននៃទំនាក់ទំនងរវាងសហគ្រាសធុនតូច និង មធ្យម ជាមួយនឹងសហគ្រាសធំ, ផលិតភាពនៅទាប ហើយកត្តាសំខាន់ៗមួយចំនួនដែលកំណត់ភាពប្រកួតប្រជែងរបស់កម្ពុជា នៅមានថ្លៃខ្ពស់, មិនទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់ និង មិនទាន់អាចឆ្លើយតបបានពេញលេញទៅនឹងសេចក្តីត្រូវការទីផ្សារនៅឡើយ បើធៀបនឹងប្រទេសជិតខាង ។ ក្នុងទិដ្ឋភាពដោយឡែកមួយទៀត ការផុសឡើងនៃវិស័យឧស្សាហកម្មនិស្សារណកម្មនៅកម្ពុជា ក៏តម្រូវឱ្យរាជរដ្ឋាភិបាលបង្កើនការយកចិត្តទុកដាក់ជាពិសេសលើកិច្ចការនេះ សំដៅធានាឱ្យបាននូវការគ្រប់គ្រងលើការរុករក និង ការធ្វើអាជីវកម្មធនធានរ៉ែ ប្រកបដោយប្រសិទ្ធភាព, តម្លាភាព និង គណនេយ្យភាព ព្រមទាំងធានាបាននូវចីរភាពបរិស្ថាន ។

**102.** ដូច្នេះ ក្នុងនីតិកាលទី ៥ គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការបន្តធ្វើពិពិធកម្មមូលដ្ឋានឧស្សាហកម្ម តាមរយៈការជំរុញលើកទឹកចិត្តវិនិយោគក្នុងវិស័យឧស្សាហកម្មថ្មីៗ ទំនើប ដែលមានតម្លៃបន្ថែមខ្ពស់, មានភាពច្នៃប្រឌិតរស់រវើក និង មានសមត្ថភាពប្រកួតប្រជែង ពិសេស ឧស្សាហកម្មផ្គុំដំឡើង, ឧស្សាហកម្មអេឡិចត្រូនិច, ឧស្សាហកម្មគ្រឿងបន្លាស់, ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម និង ឧស្សាហកម្មកម្មន្តសាលផ្សេងទៀត, គួបផ្សំនឹងការបន្តជំរុញអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម រួមទាំងសិប្បកម្មផង ព្រមទាំងការរុញការអភិវឌ្ឍឧស្សាហកម្មឱ្យទៅដល់ទីជនបទ សំដៅរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច ក៏ដូចជាបង្កើតការងារ និង បង្កើនចំណូលជូនប្រជាជន ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ផងដែរ ទៅលើការអភិវឌ្ឍ និង ការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវខ្ពស់លើវិស័យឧស្សាហកម្មនិស្សារណកម្ម ដើម្បីប្រែក្លាយសក្តានុពលដែលមាននេះ ឱ្យក្លាយទៅជាប្រភពមួយទៀត នៃកំណើនសេដ្ឋកិច្ចកម្ពុជា ។

**103.** លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការរៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ដែលនឹងផ្តោតលើអភិក្រមគន្លឹះពីរ គឺ (១) • ការពង្រីកមូលដ្ឋានឧស្សាហកម្ម តាមរយៈការបង្កើនភាពទាក់ទាញ និង ការជំរុញលើកទឹកចិត្តការវិនិយោគ ព្រមទាំងការធ្វើទំនើបកម្មសហគ្រាសធុនតូច និង មធ្យម និង (២) • ការតភ្ជាប់ទៅនឹងបណ្តាញផលិតកម្មក្នុងតំបន់ ដើម្បីជ្រៀតចូល និង អភិវឌ្ឍឈានឡើងក្នុងខ្សែចង្វាក់តម្លៃសកល ។

ទី២- ការរៀបចំគោលនយោបាយលើកកម្ពស់វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា សំដៅបង្កើនសមត្ថភាពនៃការស្រាវជ្រាវ និង ការអភិវឌ្ឍរបស់កម្ពុជា ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍប្រទេសក្នុងដំណាក់កាលថ្មី ពិសេស ធានាសង្គតិភាពជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និង គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម នៅក្នុងពេលចំពោះមុខ ។

ទី៣- ការធ្វើបច្ចុប្បន្នកម្ម «**ក្របខណ្ឌនៃការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម**» ក្នុងសង្គតិភាពជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម សំដៅជំរុញលើកកម្ពស់សមត្ថភាពសហគ្រាសធុនតូច និង មធ្យម ឱ្យមាន

លទ្ធភាពតភ្ជាប់ជាមួយសហគ្រាសធំៗ ជាកម្រងឧស្សាហកម្ម, មានសហគ្រិនភាព, ផលិតភាព, សមត្ថភាពច្នៃប្រឌិត, នវានុវត្តន៍ និង មានឯកទេស តាមរយៈការដាក់ចេញ និង អនុវត្តនូវកញ្ចប់វិធានការគាំទ្រគ្រប់ជ្រុងជ្រោយ រួមមានការចងក្រងគ្នាជាប្រព័ន្ធតួអង្គក្នុងខ្សែចង្វាក់ផលិតកម្ម, ការលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យា, ការបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទាន, ការពង្រឹងស្តង់ដារបច្ចេកទេស, ការបង្កើត«**មជ្ឈមណ្ឌលផ្តល់ប្រឹក្សាស្តីពីការអភិវឌ្ឍធុរកិច្ច**», ការបន្តជំរុញ «**ចលនាភូមិមួយ- ផលិតផលមួយ**» និង ការកែលម្អក្របខណ្ឌគតិយុត្ត ព្រមទាំងការពង្រឹងការសម្របសម្រួលស្ថាប័ន ។

ទី៤- ការតម្រង់គោលនយោបាយអភិវឌ្ឍន៍វិស័យឯកជន និង វិនិយោគ ឱ្យឆ្លើយឆ្លងគ្នាជាមួយគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និង សហគ្រាសធុនតូច និង មធ្យម ជាពិសេសការលើកទឹកចិត្តដល់ការវិនិយោគបង្កើតកម្រងឧស្សាហកម្ម និង សួនឧស្សាហកម្មធំៗ តាមរយៈការជំរុញបង្កើតច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស សំដៅអភិវឌ្ឍតំបន់នេះឱ្យឈានឡើងដល់កម្រិតស្តង់ដារអន្តរជាតិ ទាំងក្នុងទិដ្ឋភាពនៃការគ្រប់គ្រង, ហេដ្ឋារចនាសម្ព័ន្ធ និង កិច្ចប្រតិបត្តិការ ។

ទី៥- ការជំរុញការអភិវឌ្ឍរបៀងឧស្សាហកម្ម នៅតាមផ្លូវជាតិសំខាន់ៗ ដែលតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗនៃកម្ពុជា ក៏ដូចជាតភ្ជាប់សេដ្ឋកិច្ចកម្ពុជាជាមួយនឹងប្រទេសជិតខាង ពិសេសក្នុងក្របខណ្ឌនៃការអភិវឌ្ឍរបៀងសេដ្ឋកិច្ចមហាអនុ-តំបន់មេគង្គ និង អាស៊ាន ។

ទី៦- ការបន្តពង្រឹងយន្តការអភិវឌ្ឍន៍វិស័យឧស្សាហកម្មនិស្សារណកម្ម ពិសេស ការគ្រប់គ្រង និង ការត្រួតពិនិត្យទាំងផ្នែកបច្ចេកទេស, ផ្នែកគ្រប់គ្រងហានិភ័យ, ផ្នែកគ្រប់គ្រងផលប៉ះពាល់បរិស្ថាន និង សង្គម តាំងពីដើមទីរហូតដល់ការធ្វើអាជីវកម្ម និង ក្រោយការធ្វើអាជីវកម្ម ព្រមទាំងការគ្រប់គ្រងចំណូលសម្រាប់ថវិកាជាតិ តាមរយៈការរៀបចំគោលនយោបាយ, ការពង្រឹងក្របខណ្ឌគតិយុត្ត, ការលើកកម្ពស់សមត្ថភាព និង ការសម្របសម្រួលស្ថាប័ន រួមទាំងការអភិវឌ្ឍធនធានមនុស្ស ។

ទី៧- ការអភិវឌ្ឍធនធានមនុស្ស ពិសេស ការបណ្តុះបណ្តាលជំនាញ សម្រាប់វិស័យឧស្សាហកម្ម តាមរយៈការ-លើកស្ទួយគុណភាពអប់រំគ្រប់ផ្នែក និង គ្រប់កម្រិត ពិសេស កំណែទម្រង់វិស័យឧត្តមសិក្សា និង ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ដោយផ្តល់អាទិភាពខ្ពស់លើការបណ្តុះបណ្តាលវិស្វករ, អ្នកបច្ចេកទេស និង កម្មករ ដែលមានជំនាញសមស្របតាមសេចក្តីត្រូវការនៃទីផ្សារ ផ្អែកលើអភិក្រមបុរេសកម្ម និង ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ។

### មុំទី ៣. ការអភិវឌ្ឍទីផ្សារការងារ

**104.** គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ គឺការបន្តអនុវត្តគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្មទៅនឹងលក្ខខណ្ឌការងារ, ការបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យសមស្របតាមសេចក្តីត្រូវការទីផ្សារ, ការផ្សព្វផ្សាយព័ត៌មានអំពីសេចក្តីត្រូវការនៃទីផ្សារការងារ, ការកសាងប្រព័ន្ធស្ថិតិការងារ និង ក្របខណ្ឌគុណវុឌ្ឍិជាតិ, ការពង្រឹងយន្តការដោះស្រាយវិវាទការងារ និង ការបន្តការអនុវត្តច្បាប់ស្តីពីការងារ ។

**105.** ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ ក្នុងនោះ នៅឆ្នាំ ២០១១ សហគ្រាសគ្រប់ប្រភេទ, ទាំងធំ ទាំងតូច, ដែលជាអង្គភាពអាជីវកម្ម[6] មានចំនួនសរុបជាង ៥ សែន និង បង្កើតការងារបានជាង ១ លាន ៦ សែន[7] ដែលគ្រាន់តែកម្មករ និយោជិត ផ្នែកវាយនភ័ណ្ឌកាត់ដេរ និង ដេរស្បែកជើងមានចំនួនជាង ៥ សែននាក់ ។ បន្ថែមលើនេះ ពលករដែលត្រូវបានបញ្ជូនជាផ្លូវការឱ្យទៅធ្វើការនៅក្រៅប្រទេសមានចំនួនសរុបជាង ១ សែននាក់ ហើយបាននាំប្រាក់ចំណូលមកក្នុងប្រទេសជាង ២០០ លានដុល្លារ ជាមធ្យមក្នុងមួយឆ្នាំ ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានបង្កើត «**ទីភ្នាក់ងារជាតិមុខរបរ និង ការងារ**» សម្រាប់ផ្តល់សេវារកការងារជូនប្រជាជន ព្រមទាំងបានបង្កើត «**វេទិកាការងារ**» សម្រាប់ផ្លាស់ប្តូរ និង ផ្តល់ព័ត៌មានស្តីពីទីផ្សារការងារ ។ ម្យ៉ាងទៀត រាជរដ្ឋាភិបាលបានជំរុញដំឡើងប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យវាយនភ័ណ្ឌ, កាត់ដេរ និង ផលិតស្បែកជើង ពី ៥០ ទៅដល់ ៨០ ដុល្លារ ព្រមទាំងបានលើកទឹកចិត្តឱ្យនិយោជកផ្តល់ប្រាក់បំណាច់ផ្សេងៗបន្ថែមទៀត ដល់កម្មករ និយោជិត ប្រមាណ ២០ ដុល្លារ ក្នុងមួយខែ ។ ដើម្បីលើកកម្ពស់ការគោរពសិទ្ធិ និង លក្ខខណ្ឌការងារ ក៏ដូចជាភាពសុខដុមរមនា ក្នុងទំនាក់ទំនងវិជ្ជាជីវៈរវាងកម្មករ និយោជិត និង និយោជក រាជរដ្ឋាភិបាលបានបង្កើនការធ្វើអធិការកិច្ចការងារ និង ការផ្សះផ្សាវិវាទការងារនៅនឹងកន្លែង ព្រមទាំងបានផ្តល់ការគាំទ្រដល់កម្មវិធី «**រោងចក្រល្អប្រសើរ**» ។ រាជរដ្ឋាភិបាលក៏បានលើកទឹកចិត្ត ឱ្យមានយន្តការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការផងដែរ គឺយន្តការ «**ក្រុមប្រឹក្សាអាជ្ញាកណ្តាល**» និង «**គណៈកម្មាធិការប្រឹក្សាការងារ**» ។

**106.** ទោះជាយ៉ាងនេះក្តី កម្ពុជានៅបន្តជួបនឹងបញ្ហាប្រឈមមួយចំនួន ពិសេសភាពមិនទាន់ឆ្លើយឆ្លងគ្នារវាងសមាស-ភាគសំខាន់ៗនៃទីផ្សារការងារ មានជាអាទិ៍ សមត្ថភាពជំនាញ និង ផលិតភាពរបស់ពលករ, កង្វះខាតវិស្វករ និង អ្នក-បច្ចេកទេស, ភាពចាំបាច់ក្នុងការធ្វើនិទស្សន៍អំពីសេចក្តីត្រូវការការងារ ទាំងតាមប្រភេទ ទាំងតាមជំនាញ, គុណភាព និង ភាពឆ្លើយតបនៃការបណ្តុះបណ្តាល ទាំងកម្រិតឧត្តមសិក្សា ទាំងកម្រិតបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ, ចល័ត-ភាពនៃកម្លាំងពលកម្ម, ការការពារសិទ្ធិ និង លក្ខខណ្ឌការងាររបស់ពលករ ទាំងក្នុងប្រទេស និង ក្រៅប្រទេស, ទំនាក់-ទំនងវិជ្ជាជីវៈរវាងកម្មករ និយោជិត និង និយោជក, ការកែលម្អយន្តការកំណត់ប្រាក់ឈ្នួលពលកម្ម ក៏ដូចជាសេចក្តីត្រូវការក្នុងការពង្រឹង និង កែលម្អក្របខណ្ឌគោលនយោបាយ និង ក្របខណ្ឌគតិយុត្ត ព្រមទាំងការពង្រឹងសមត្ថភាព និង ការ-សម្របសម្រួលស្ថាប័ន ។

---

[6] *យោងតាមចំណាត់ថ្នាក់ឧស្សាហកម្មស្តង់ដារអន្តរជាតិ(ISIC) ដែលបានប្រើប្រាស់ក្នុង «ជំរឿនសហគ្រាសនៅកម្ពុជាឆ្នាំ ២០១១» សហគ្រាស គឺសំដៅលើអង្គភាពអាជីវកម្មដែលស្ថិតក្រោមកម្មសិទ្ធិ ឬ ការគ្រប់គ្រងរបស់ម្ចាស់តែមួយនិងពាក់ព័ន្ធជាមួយនឹងសកម្មភាពសេដ្ឋកិច្ចអ្វីមួយ ក្នុងទីតាំងរូបវន្តណាមួយជាក់លាក់ ។ ក្នុងនិយមន័យនេះ សហគ្រាសមានបីប្រភេទៈ (១). សហគ្រាសអចល័ត គឺជាសហគ្រាសដែលជានិច្ចកាលដំណើរការអាជីវកម្មក្នុងទីតាំង ឬ អគារជាប់លាប់, (២). សហគ្រាសមានទីតាំងមិនជាប់លាប់ គឺសហគ្រាសដែលតែងតែដំណើរការអាជីវកម្មក្នុងទីតាំងជាប់លាប់ ប៉ុន្តែ អាចផ្លាស់ប្តូរទីតាំងបានយ៉ាងងាយស្រួល និង (៣). សហគ្រាសចល័ត គឺជាសហគ្រាសដែលតែងតែដំណើរការអាជីវកម្មពីទីតាំងមួយទៅទីតាំងមួយនៅតាមដងផ្លូវ ។*

[7] *តួលេខនេះ មិនរាប់បញ្ចូលការងារក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ, ការងារក្នុងរដ្ឋបាលសាធារណៈ សន្តិសុខ និង ការពារជាតិ, សកម្មភាពរកស៊ីចិញ្ចឹមជីវិតជាលក្ខណៈគ្រួសារ និង សកម្មភាពផលិតទំនិញ និង សេវាជាលក្ខណៈគ្រួសារ ដែលបម្រើឱ្យការប្រើប្រាស់ផ្ទាល់ខ្លួន និង ការងារទាំងឡាយ ដែលបម្រើឱ្យសកម្មភាពរបស់អង្គការ ឬ ស្ថាប័នក្រៅប្រទេស ។*

107. ក្នុងន័យនេះ រាជរដ្ឋាភិបាលនីតិកាលទី ៥ នឹងបន្តកែទម្រង់ឱ្យបានស៊ីជម្រៅថែមទៀត ទាំងលើគោលនយោបាយ, ក្របខណ្ឌគតិយុត្ត និង យន្តការស្ថាប័ន ដែលបានអនុវត្តនាពេលកន្លងមក សំដៅធ្វើឱ្យគ្រប់សមាសភាគនៃទីផ្សារការងារ ដំណើរការប្រកបដោយភាពស៊ីសង្វាក់គ្នា និង ជួយគាំទ្រគ្នាទៅវិញទៅមក ដើម្បីរួមចំណែកលើកកម្ពស់កំណើនសេដ្ឋកិច្ច បង្កើតការងារ និង លើកស្ទួយជីវភាពប្រជាជន ។

108. លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការរៀបចំ និង អនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និង ការងារ ដើម្បីអភិវឌ្ឍវិស័យការងារឱ្យស្របតាមការវិវត្តនៃស្ថានភាពសង្គម- សេដ្ឋកិច្ច ដោយយកចិត្តទុកដាក់ជាពិសេសលើការអភិវឌ្ឍការងារសម្រាប់យុវជន, ការ-រៀបចំកម្លាំងពលកម្ម ឱ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ព្រម-ទាំងការត្រៀមលក្ខណៈក្នុងការគ្រប់គ្រង និង ទាញយកផលប្រយោជន៍ឱ្យបានជាអតិបរមាពីការចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ។

ទី២- ការពង្រឹងយន្តការ «**វេទិកាការងារ**» ដែលមានការចូលរួមពីសំណាក់អ្នកផ្តល់ការងារ, អ្នកស្វែងរកការងារ និង អ្នកផ្តល់ការអប់រំ និង បណ្តុះបណ្តាល ក្រោមការសម្របសម្រួលរបស់រាជរដ្ឋាភិបាល សំដៅផ្លាស់ប្តូរព័ត៌មាន, ប្រឹក្សាយោបល់ និង ធ្វើសកម្មភាពរួមគ្នា ដើម្បីឆ្លើយតបទៅនឹងស្ថានភាពទីផ្សារការងារ ។

ទី៣- ការពង្រីកការផ្តល់សេវារកការងារ និង ការផ្សព្វផ្សាយព័ត៌មានអំពីឱកាសការងារក្នុង និង ក្រៅប្រទេស ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ព្រមទាំងការផ្តល់ប្រឹក្សា និង ការគាំទ្រ សម្រាប់ការជ្រើសរើសពលករ តាមរយៈការពង្រីកបន្ថែមនូវមជ្ឈមណ្ឌលការងារនៃទីភ្នាក់ងារជាតិមុខរបរ និង ការងាររបស់គណៈកម្មាធិការជាតិបណ្តុះ-បណ្តាលនៅទូទាំងប្រទេស ។

ទី៤- ការបន្តអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារឱ្យកាន់តែល្អ ជាពិសេស ការពង្រឹងការប្រមូល, ការវិភាគ និង ការផ្សព្វផ្សាយស្ថិតិការងារ, ការផ្សព្វផ្សាយព័ត៌មានស្តីពីការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ, ការផ្តល់ព័ត៌មានអំពីប្រាក់ឈ្នួល រួមទាំងអំពីការផ្គត់ផ្គង់ពលកម្ម និង សេចក្តីត្រូវការជំនាញ ។

ទី៥- ការបន្តអភិវឌ្ឍធនធានមនុស្សលើផ្នែកបច្ចេកទេស ឱ្យឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ពិសេស តាមរយៈការជំរុញការបណ្តុះបណ្តាល និង វិក្រឹតការជំនាញ និង វិជ្ជាជីវៈ ព្រមទាំងការហ្វឹកហ្វឺនកូនជាង ដោយផ្តល់ការលើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជន សំដៅលើកកម្ពស់ផលិតភាពការងារ និង បង្កើនចំណូលជូនពលករ និង និយោជក ។

ទី៦- ការសម្របសម្រួលឱ្យស៊ីសង្វាក់គ្នា រវាងវិស័យអប់រំ និង វិស័យបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ពិសេស ការរៀបចំក្របខណ្ឌ និង ស្តង់ដារនៃការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ដែលអាចទទួលស្គាល់ឆ្លងពីគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ទៅគ្រឹះស្ថានឧត្តមសិក្សា ។

ទី៧- ការបន្តលើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង តាមរយៈ ការពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និង ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ រួមទាំងការបន្តគាំទ្រកម្មវិធី «**រោងចក្រល្អប្រសើរ**» និង ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសទីផ្សារការងារ ។

ទី៨- ការពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ រវាងកម្មករ និយោជិត និង និយោជក តាមរយៈការជំរុញអនុម័តច្បាប់ស្តីពីសហជីព, ការធ្វើបច្ចុប្បន្នកម្មច្បាប់ស្តីពីការងារ, ការពង្រឹងការគោរពវិន័យការងារ និង ក្រមសីលធម៌វិជ្ជាជីវៈ, ការពង្រឹង និង សម្របសម្រួលស្ថាប័នអនុវត្តយន្តការទប់ស្កាត់ និង ដោះស្រាយវិវាទការងារ ក៏ដូចជាយន្តការទប់ស្កាត់ និង ដោះស្រាយបាតុកម្ម ព្រមទាំងការពង្រឹងសមត្ថភាព និង តួនាទីរបស់អធិការកិច្ចការងារ ក្នុងការផ្សះផ្សាដោះស្រាយវិវាទ និង ការបង្កើតតុលាការការងារ ។

ទី៩- ការបង្កើតយន្តការសម្រាប់ធ្វើការសិក្សាជាទៀងទាត់ និង ជាយថាហេតុលើកអនុសាសន៍ សម្រាប់ការពិនិត្យកំណត់ប្រាក់ឈ្នួលអប្បបរមា ស្របតាមស្ថានភាពសេដ្ឋកិច្ចជាតិ តាមវិស័យ និង តាមតំបន់ ព្រមទាំងការបង្កើតយន្តការធានារ៉ាប់រងផលប្រយោជន៍របស់កម្មករ និយោជិត នៅពេលរោងចក្រក្ស័យធន ។

ទី១០- ការបន្តពង្រឹងគ្រប់គ្រងការជ្រើសរើស និង ការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ព្រមទាំងការលើកកម្ពស់យន្តការការពារសិទ្ធិ, សុខភាព និង សុវត្ថិភាពការងាររបស់ពលករកម្ពុជានៅក្រៅប្រទេស ។

## មុំទី ៤. ការអភិវឌ្ឍវិស័យធនាគារ និង ហិរញ្ញវត្ថុ

**109.** គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ គឺការអភិវឌ្ឍវិស័យធនាគារ និង ហិរញ្ញវត្ថុឱ្យមានភាពរឹងមាំ និង ផ្អែកលើគោលការណ៍ទីផ្សារ សំដៅពង្រឹងតួនាទីជាកម្លាំងចលករនៃវិស័យហិរញ្ញវត្ថុក្នុងការអភិវឌ្ឍ និងពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ពិសេសតាមរយៈការគៀរគរធនធានហិរញ្ញវត្ថុ បម្រើសេចក្តីត្រូវការហិរញ្ញប្បទានដែលកើនឡើងជាប្រចាំ ។

**110.** ជាមួយគោលដៅជាយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ មានជាអាទិ៍ (១). ការអភិវឌ្ឍគោលនយោបាយ និង ក្របខណ្ឌគតិយុត្ត ព្រមទាំងការពង្រឹងការគ្រប់គ្រងលើវិស័យធនាគារ និង ហិរញ្ញវត្ថុ, (២). ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ទ្រទ្រង់ប្រព័ន្ធហិរញ្ញវត្ថុឱ្យរឹងមាំ និង ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព រួមមាន ការបង្កើតប្រព័ន្ធទូទាត់ជាតិ និង ការិយាល័យព័ត៌មានឥណទាន, ការពង្រឹងសេវាហិរញ្ញវត្ថុជនបទ, ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ប្រតិបត្តិការធនាគារកណ្តាល និង (៣). ការកសាងសមត្ថភាពធនធានមនុស្ស និងឯកទេសកម្ម និង ការចូលរួមចំណែកកសាងយន្តការ និង បណ្តាញស្ថិរភាពហិរញ្ញវត្ថុក្នុងតំបន់ ។

លទ្ធផលដែលទទួលបានពីការអនុវត្តវិធានការខាងលើ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈភាពកាន់តែរឹងមាំឡើងនៃប្រព័ន្ធធនាគារ និង ហិរញ្ញវត្ថុ ដែលមិនត្រឹមតែរក្សាបាននូវស្ថិរភាពជារួម ក្នុងខណៈដែលសកលលោកត្រូវជួបប្រឈមនឹងវិបត្តិកលិយុគហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបង្កើនបាននូវជវភាព និង ភាពរស់រវើក តាមរយៈការគៀរគរប្រាក់សន្សំ, ទាំងក្នុង និង ក្រៅប្រទេស, ហើយប្រែក្លាយទៅជាប្រភពហិរញ្ញប្បទានដ៏សំខាន់ សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងបង្កើតការងារ ។ លើសពីនេះ វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក៏ត្រូវបានអភិវឌ្ឍថែមទៀត តាមរយៈការបន្តពង្រឹង និងពង្រីកវិសាលភាពនៃវិស័យធានារ៉ាប់រង រួមទាំងការធានារ៉ាប់រងអាយុជីវិត និង ការធានារ៉ាប់រងខ្នាតតូច, ការដាក់ឱ្យដំណើរការទីផ្សារមូលបត្រ, ការបង្កើតឡើងនូវប្រព័ន្ធសុវត្ថិភាពសង្គម រួមមានបេឡាសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល, បេឡាជាតិអតីតយុទ្ធជន, បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់កម្មករ និយោជិត, មូលនិធិជនពិការ និង

សោធនស្ម័គ្រចិត្តពីវិស័យឯកជន ។

ជាតួលេខ គិតពីឆ្នាំ ២០០៨ ដល់ ឆ្នាំ ២០១២ ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារពាណិជ្ជមានការកើនឡើងចំនួន ៣ ដង ពោលគឺមានទឹកប្រាក់ចំនួនជិត ១១ ពាន់លានដុល្លារ, ទំហំឥណទានសរុបកើនឡើងជិត ៤ ដង គឺពីជាង ១ ៥០០ លានដុល្លារ ឬ ត្រូវជាជាង ២៣% នៃ ផសស ដល់ចំនួនជាង ៥ ៨០០ លានដុល្លារ ឬ ត្រូវជាជាង ៤១% នៃ ផសស ហើយប្រាក់បញ្ញើអតិថិជនបានកើនឡើងជិត ៣ ដង គឺពីជាង ២ ៤០០ លានដុល្លារ ឬ ត្រូវជាជាង ២៤% នៃ ផសស ដល់ជាង ៦ ៧០០ លានដុល្លារ ឬ ត្រូវជាជាង ៤៧% នៃ ផសស ។ រីឯទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនឡើងចំនួន ៦ ដង ពីជាង ១៨០ លានដុល្លារ ដល់ជាង ១ ០០០ លានដុល្លារ, ទន្ទឹមនឹងទំហំឥណទានសរុបបានកើនឡើងពីជាង ១៥០ លានដុល្លារ ដល់ជាង ៨៨០ លានដុល្លារ ដែលបម្រើឱ្យអតិថិជនចំនួនជាងមួយលានបីសែន ។ ចំពោះវិស័យធានារ៉ាប់រងវិញ បុព្វលាភរ៉ាប់រងមានការកើនឡើងជិត ២ ដង ពីប្រមាណ ២០ លានដុល្លារ ដល់ជាង ៣៦ លានដុល្លារ ទន្ទឹមនឹងទ្រព្យសកម្មសរុបបានកើនឡើងជិត ២ ដង ផងដែរ ពីប្រមាណ ៦០ លានដុល្លារ ដល់ប្រមាណ ១០៥ លានដុល្លារ ។ តួលេខទាំងនេះ ឆ្លុះបញ្ចាំងអំពីភាពកាន់តែស៊ីជម្រៅ និង វិសាលភាពកាន់តែទូលាយនៃអន្តរការិយកម្មហិរញ្ញវត្ថុ ព្រមទាំងការឈានឡើងទៅដំណាក់កាលឯកទេសកម្មនៃប្រព័ន្ធហិរញ្ញវត្ថុ និង កំណើននៃជំនឿទុកចិត្តរបស់សាធារណជន ។

**111.** ទន្ទឹមនឹងសមិទ្ធផលដែលទទួលបានខាងលើ កម្ពុជានៅបន្តជួបបញ្ហាប្រឈមមួយចំនួន ជាពិសេស ភាពចំបាច់ក្នុងការបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ទន្ទឹមនឹងការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងឡើង លើការធានាស្ថិរភាព និង ភាពធន់របស់ប្រព័ន្ធហិរញ្ញវត្ថុ រួមមាន ការសម្របសម្រួលគោលនយោបាយ ក៏ដូចជាការបំពេញបន្ថែម និង ការធ្វើសុខដុមនីយកម្មក្របខណ្ឌគតិយុត្ត ព្រមទាំងការពង្រឹងសមត្ថភាពស្ថាប័ន និង ការអភិវឌ្ឍធនធានមនុស្ស ។

**112.** លើមូលដ្ឋាននេះ គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ គឺការបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុមួយដែលមានវិសាលភាពកាន់តែទូលាយ, កាន់តែមានពិពិធភាព, កាន់តែស៊ីជម្រៅ ហើយរឹងមាំ និង មានប្រសិទ្ធភាព ដោយផ្អែកលើគោលការណ៍ទីផ្សារ ដើម្បីទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និង ចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

**113.** ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញអនុវត្តឱ្យមានប្រសិទ្ធភាព និង ប្រកបដោយផ្លែផ្កា នូវ «**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០**» ពិសេសដោយផ្តោតអាទិភាពលើ ÷

ទី១- ការបន្តអភិវឌ្ឍ និង សម្របសម្រួលក្របខណ្ឌគោលនយោបាយ និង ក្របខណ្ឌគតិយុត្ត ពិសេស ការពង្រឹងយន្តការគ្រប់គ្រង និង ត្រួតពិនិត្យ, ការពង្រឹងសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស ឱ្យស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា ព្រមទាំងឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការធ្វើសមាហរណកម្មប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាទៅក្នុងតំបន់ និង អន្តរជាតិ ។

ទី២- ការបន្តអភិវឌ្ឍយន្តការបង្ការ និង ដោះស្រាយវិបត្តិ រួមទាំងយន្តការផ្តល់សញ្ញាជាមុន តាមរយៈការបង្កើនការសម្របសម្រួលស្ថាប័ន ពិសេស ការពិនិត្យអំពីភាពចាំបាច់ក្នុងការបង្កើតគណៈកម្មការជាតិស្ថិរភាពហិរញ្ញវត្ថុ ។

ទី៣- ការបន្តពង្រឹង និង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព រួមមាន ប្រព័ន្ធទូទាត់សងប្រាក់, ការដាក់ឱ្យដំណើរការទីផ្សាររូបិយវត្ថុ/ទីផ្សារអន្តរធនាគារ, ការបន្តជំរុញប្រើប្រាស់នូវឧត្តមានុវត្តន៍អន្តរជាតិ ក្នុង

ប្រព័ន្ធគណនេយ្យ និង អភិបាលកិច្ចសាជីវកម្ម ។

ទី៤- ការបន្តគាំទ្រ និង ជំរុញកំណើនក្នុងវិស័យធនាគារ និង មីក្រូហិរញ្ញវត្ថុ សំដៅលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ដោយផ្តោតលើការកែលម្អថែមទៀត នូវយន្តការផ្តល់អាជ្ញាបណ្ណ និង ការចុះបញ្ជី ព្រមទាំងយន្តការត្រួតពិនិត្យ និង តាមដាន ឱ្យមានភាពសាមញ្ញ, មានតម្លាភាព, មានគណនេយ្យភាព និង មានប្រសិទ្ធភាព ពិសេស សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទន្ទឹមនឹងការបន្តធ្វើពិពិធកម្មឧបករណ៍ និង ផលិតផលហិរញ្ញវត្ថុ ដូចជា ការជំរុញអនុវត្តកិច្ចប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ និង ប្រព័ន្ធចែករំលែកហានិភ័យ ។

ទី៥- ការបន្តខិតខំពង្រីកសេវាមីក្រូហិរញ្ញវត្ថុ តាមថ្លៃ និង លក្ខខណ្ឌកាន់តែមានលក្ខណៈអនុគ្រោះ ពិសេសសម្រាប់ប្រជាជនក្រីក្រ ក៏ដូចជាសហគមន៍កសិកម្ម សំដៅលើកស្ទួយសេដ្ឋកិច្ចជនបទ ទន្ទឹមនឹងការបន្តពង្រីកការផ្តល់ឥណទានដល់សហគ្រាសធុនតូច និង មធ្យម ។

ទី៦- ការបន្តពង្រឹង និង ពង្រីកការអនុវត្តកាតព្វកិច្ចធានារ៉ាប់រង និង ការបង្កើតផលិតផលថ្មីៗ ជាពិសេសការពង្រីកការផ្តល់សេវាធានារ៉ាប់រងអាយុជីវិត និង ធានារ៉ាប់រងខ្នាតតូច ដោយរៀបចំ និង កែសម្រួលក្របខណ្ឌគតិយុត្ត ឱ្យកាន់តែប្រសើរ ជាមួយនឹងការពង្រឹងសមត្ថភាពបញ្ញត្តិករធានារ៉ាប់រង ។

ទី៧- ការបន្តអភិវឌ្ឍទីផ្សារមូលបត្រ តាមរយៈការជំរុញ និង លើកទឹកចិត្តដល់សហគ្រាស និង ក្រុមហ៊ុនឱ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ និង ការលើកកម្ពស់យន្តការជួញដូរ និង ការពិនិត្យអំពីសេចក្តីត្រូវការក្នុងការបោះផ្សាយលក់មូលបត្ររដ្ឋ ។

ទី៨- ការបន្តអភិវឌ្ឍ និង ពង្រឹងប្រព័ន្ធសុវត្ថិភាពសង្គម ឱ្យមានលក្ខណៈប្រមូលផ្តុំ, សង្គតិភាព និង ប្រសិទ្ធភាព ។

ទី៩- ការបន្តអភិវឌ្ឍ និង ពង្រឹងអនុវិស័យហិរញ្ញវត្ថុមិនមែនធនាគារផ្សេងទៀត រួមមាន បរធនបាលកិច្ច, ទីផ្សារអចលនវត្ថុ ព្រមទាំងអាជីវកម្មទទួលទិញ- លក់ទ្រព្យបញ្ចាំ និង អាជីវកម្មប្រាតិភោគដោយអនុប្បទាន ។

ទី១០- ការបន្តពិនិត្យលទ្ធភាពបង្កើតមជ្ឈមណ្ឌលនៃការអភិវឌ្ឍហិរញ្ញវត្ថុ ។

### ចតុកោណទី ៤. ការកសាងសមត្ថភាព និង ការអភិវឌ្ឍធនធានមនុស្ស

**114.** ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព, សមត្ថភាព និង គុណធម៌ គឺជាកត្តាគន្លឹះ សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និង ភាពប្រកួតប្រជែងរបស់ប្រទេស ទាំងក្នុងពេលចំពោះមុខ ទាំងសម្រាប់អនាគត ពិសេសក្នុងពេលដែលកម្ពុជាឈានចូលទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងពេលដ៏ខ្លីខាងមុខ ហើយបន្តឡើងទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និង ជាប្រទេសអភិវឌ្ឍនៅឆ្នាំ ២០៥០ តាមចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ។ ក្នុងន័យនេះ ការអភិវឌ្ឍធនធានមនុស្ស ជាពិសេសយុវជន គឺសំដៅទៅលើការកសាងសមត្ថភាពខាងចំណេះដឹង ចំណេះធ្វើ, សហគ្រិនភាព, ជំនាញ, ការច្នៃប្រឌិត និង នវានុវត្តន៍ គ្រប់ផ្នែក គ្រប់វិស័យ ពិសេស ផ្នែកវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា, ព្រមទាំងសមត្ថភាពក្នុងការស្រាវជ្រាវ និង ការអភិវឌ្ឍ ទន្ទឹមនឹងការលើកស្ទួយគុណភាពខាងសុខភាព, កាយសម្បទា, សីលធម៌, ស្មារតីទទួលខុសត្រូវ និង មនសិការស្នេហាជាតិ និងវិជ្ជាជីវៈ ដោយគ្មានការរើសអើងខាងយេនឌ័រ រួមជាមួយនឹងប្រព័ន្ធសុវត្ថិភាពសង្គមគត់មត់ ។

## មុំទី ១. ការពង្រឹង និង ការលើកកម្ពស់វិស័យអប់រំ, វិទ្យាសាស្ត្រ, បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស

115. គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ គឺបន្តអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយផ្តោតលើការផ្តល់ឱកាសស្មើៗគ្នាដល់កុមារ និង យុវជនកម្ពុជាទាំងអស់ ក្នុងការទទួលការអប់រំមូលដ្ឋាន, ទាំងក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ, ព្រមទាំងបន្តយកចិត្តទុកដាក់លើការកែលម្អគុណភាពអប់រំ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការ-អភិវឌ្ឍប្រទេស ។

116. ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលធំៗគួរឱ្យកត់សម្គាល់ ពិសេសការលើកកម្ពស់គុណភាព និង ប្រសិទ្ធភាពនៃការបណ្តុះបណ្តាលធនធានមនុស្ស តាមរយៈការអនុវត្ត «**ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣**» ជាអាទិ៍ ការកែលម្អគោលនយោបាយ និង ក្របខណ្ឌគតិយុត្ត ព្រមទាំងការបង្កើនធនធាន និង ការវិនិយោគលើវិស័យនេះ, ទាំងពីប្រភពថវិការដ្ឋ ទាំងពីប្រភពដៃគូអភិវឌ្ឍន៍, រាប់ទាំងការចូលរួមរបស់វិស័យឯកជនផង ។ ជាលទ្ធផលសូចនាករសំខាន់ៗក្នុងវិស័យអប់រំ ត្រូវបានកែលម្អ រួមមាន : (១). សាលាបឋមសិក្សារដ្ឋមានចំនួនសរុប ៦ ៩១០ នៅឆ្នាំ ២០១២ គឺមានការកើនឡើងចំនួន ៣៨៥ ក្នុងនីតិកាលទី ៤ ទន្ទឹមនឹងអត្រាពិតនៃការសិក្សា[8] នៅបឋមសិក្សាសម្រេចបាន ៩៧% នៅឆ្នាំសិក្សា ២០១២- ២០១៣ ជាមួយនឹងអត្រាបញ្ចប់ការសិក្សា[9] ជាង ៨៧%, (២). អនុវិទ្យាល័យរដ្ឋ មានចំនួន ១ ២៧៤ នៅឆ្នាំ ២០១២ គឺមានការកើនឡើងចំនួន ៩២ ក្នុងនីតិកាលទី ៤ ហើយអត្រារួមនៃការសិក្សា[10] នៅមធ្យមសិក្សាបឋមភូមិ សម្រេចបានជាង ៥៣% នៅឆ្នាំសិក្សា ២០១២- ២០១៣ ជាមួយនឹងអត្រាបញ្ចប់ការសិក្សាជាង ៤០%, (៣). វិទ្យាល័យរដ្ឋ នៅឆ្នាំ ២០១២ មានចំនួន ៤៣៣ គឺមានការកើនឡើងចំនួន ៨៤ ក្នុងនីតិកាលទី ៤ ហើយអត្រារួមនៃការ-សិក្សាមធ្យមសិក្សាទុតិយភូមិ សម្រេចបានជាង ២៧%ជាមួយនឹងអត្រាបញ្ចប់ការសិក្សាប្រមាណ ២៧%, (៤). នៅឆ្នាំ ២០១២ គ្រឹះស្ថានឧត្តមសិក្សារដ្ឋមានចំនួន ៣៩ និង គ្រឹះស្ថានឧត្តមសិក្សាឯកជនមានចំនួន ៦២ ដែលក្នុងនេះ ចំនួននិស្សិត

[8] ***អត្រាពិតនៃការសិក្សា*** *គឺសមាមាត្ររវាងសិស្សគ្រប់អាយុ ដែលបានចូលសិក្សាក្នុងភូមិសិក្សានីមួយៗ ធៀបនឹងចំនួនប្រជាជនគ្រប់អាយុសិក្សា សម្រាប់ភូមិសិក្សានោះ ។ ឧទាហរណ៍ អត្រាពិតនៃការសិក្សាបឋមសិក្សា គឺសមាមាត្រសិស្សអាយុ ៦ ឆ្នាំ ដល់ ១១ ឆ្នាំ រៀននៅបឋមសិក្សាធៀបនឹងចំនួនប្រជាជនអាយុ ៦ ឆ្នាំ ដល់ ១១ ឆ្នាំ ។ អត្រានេះ មានគោលដៅវាស់វែងការទទួលបាននូវសេវាអប់រំប្រែកបដោយសមធម៌ ។*

[9] ***អត្រាបញ្ចប់ការសិក្សា*** *គឺសមាមាត្ររវាងចំនួនសិស្សថ្មី ដែលបានបញ្ចប់ការសិក្សានៅភូមិសិក្សានីមួយៗ ធៀបនឹងចំនួនប្រជាជនគ្រប់អាយុត្រូវបញ្ចប់ការសិក្សានៅភូមិសិក្សានោះ ។ ឧទាហរណ៍ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា គឺសមាមាត្ររវាងចំនួនសិស្សថ្មីរៀននៅថ្នាក់ទី ៦ ធៀបនឹងចំនួនប្រជាជនអាយុ ១១ ឆ្នាំ ។*

[10] ***អត្រារួមនៃការសិក្សា*** *គឺសមាមាត្ររវាងចំនួនសិស្សទាំងអស់នៅភូមិសិក្សានីមួយៗ ធៀបនឹងចំនួនប្រជាជនគ្រប់អាយុសិក្សាសម្រាប់ភូមិសិក្សានោះ ។ ឧទាហរណ៍ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ គឺសមាសមាមាត្រនៃចំនួនសិស្សរៀននៅមធ្យមសិក្សាបឋមភូមិទាំងអស់ ធៀបនឹងចំនួនប្រជាជនអាយុពី ១២ឆ្នាំ ដល់ ១៤ ឆ្នាំ ។ អត្រានេះ បង្ហាញពីចំនួនសិស្សទាំងអស់ ដែលរៀននៅតាមកម្រិតសិក្សា ហើយអាចលើស ១០០% ដោយសារមានសិស្សរៀនត្រួតថ្នាក់ និង លើសអាយុ ប៉ុន្តែ រៀននៅមធ្យមសិក្សាបឋមភូមិដែរ ។*

សិក្សានៅគ្រឹះស្ថានឧត្តមសិក្សា នៅឆ្នាំសិក្សា ២០១២-២០១៣ មានចំនួនជាង ២៥ ម៉ឺននាក់ និង (៥)• គ្រឹះស្ថានបណ្តុះ-បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សរុបទាំងអស់មានចំនួន ៣៣១ គិតត្រឹមឆ្នាំ២០១២ ពោលគឺរបស់រដ្ឋចំនួន ៥៥, របស់ឯកជនចំនួន ២២៧ និង របស់អង្គការមិនមែនរដ្ឋាភិបាលចំនួន ៤៩ ។ បន្ថែមលើនេះ កិច្ចការយុវជន និង កីឡា ក៏ត្រូវបានលើកកម្ពស់ តាមរយៈការអនុវត្តចលនាបីល្អ«**កូនល្អ, សិស្សល្អ, មិត្តល្អ**» និង កិច្ចសហការជំរុញចលនាយុវជនក្នុងសង្គម ដូចជា ចលនាយុវជនក្នុងបុព្វហេតុមាតុភូមិ, ចលនាយុវជនកាកបាទក្រហម, ចលនាកាយរិទ្ធ ក្នុងការងារសង្គមនានា ព្រមទាំងការរៀបចំសកម្មភាព«**កីឡាដើម្បីទាំងអស់គ្នា**» និង ការប្រកួតកីឡាមហាជនជ្រើសរើសជើងឯកថ្នាក់ជាតិ និង ថ្នាក់ភូមិភាគ ។

117. ទន្ទឹមនឹងនេះ កម្ពុជានៅបន្តជួបបញ្ហាប្រឈមមួយចំនួន ជាអាទិ៍ ភាពចាំបាច់ក្នុងការបន្តពង្រឹងគុណភាពអប់រំ នៅគ្រប់កម្រិតសិក្សា, អត្រាបោះបង់ការសិក្សារបស់សិស្សានុសិស្សនៅមានកម្រិតខ្ពស់នៅឡើយ ពិសេសនៅកម្រិតមធ្យមសិក្សា, ភាពចាំបាច់ក្នុងការពង្រឹងការអភិវឌ្ឍជំនាញបច្ចេកទេសសម្រាប់យុវជន, ចំនួននិស្សិតសិក្សាផ្នែកវិស្វកម្ម វិទ្យា-សាស្ត្រ និង បច្ចេកវិទ្យា នៅមានចំនួនមិនទាន់គ្រប់គ្រាន់សម្រាប់ឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃទីផ្សារ និង ការអភិវឌ្ឍប្រទេសនៅឡើយ និង ភាពចាំបាច់ក្នុងការបន្តលើកទឹកចិត្ត និង បន្តពង្រឹងសមត្ថភាពគ្រូបង្រៀន ក៏ដូចជាពង្រឹងសមត្ថភាពនៃគ្រឹះស្ថានសិក្សាតាមរយៈការបំពាក់ហេដ្ឋារចនាសម្ព័ន្ធ និង សម្ភារៈឧបទ្ទេសសិក្សាចាំបាច់ ។

118. លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនីតិកាលទី ៥ នឹងបន្តជំរុញអនុវត្តគោលការណ៍«**ការអប់រំសម្រាប់ទាំងអស់គ្នា**» សំដៅធានាសមធម៌ក្នុងការទទួលបានសេវាអប់រំ, បន្តលើកកម្ពស់គុណភាព និង ប្រសិទ្ធភាពសេវានៃអប់រំគ្រប់កម្រិត ព្រមទាំងបន្តអភិវឌ្ឍស្ថាប័ន និង សមត្ថភាពមន្ត្រីអប់រំ ។

119. ក្នុងទិសដៅនេះ រាជរដ្ឋាភិបាលនីតិកាលទី ៥ នឹងផ្តោតអាទិភាពលើ ÷

ទី១- ការបន្តរៀបចំ និង កែលម្អគោលនយោបាយ និង យុទ្ធសាស្ត្រវិស័យអប់រំ ពិសេសការធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រវិស័យអប់រំ, ផែនការមេបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ក្នុងវិស័យអប់រំ និង គោលនយោបាយស្តីពីការ-អភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ ដើម្បីកសាង និង អភិវឌ្ឍធនធានមនុស្ស ប្រកបដោយគុណភាព, សមត្ថភាព និង គុណធម៌ក្នុងគ្រប់វិស័យ សំដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច និង ពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងក្របខណ្ឌតំបន់ និង អន្តរជាតិ ដោយផ្អែកលើអភិក្រមបុរេសកម្ម ។

ទី២- ការលើកកម្ពស់ការយល់ដឹង និង សមត្ថភាពធនធានមនុស្ស ក្នុងផ្នែកវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា ពិសេសតាមវិស័យអាទិភាពនានា ដូចជា វិស័យកសិកម្ម រួមមាន ដំណាំកសិកម្ម, ការចិញ្ចឹមសត្វ និង វារីវប្បកម្ម, វិស័យឧស្សា-ហកម្ម ថាមពល សំណង់ និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, វិស័យបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍, វិស័យសុខាភិបាល និងវិស័យបរិស្ថាន ជាដើម តាមរយៈវិធានការគន្លឹះមួយចំនួន ជាអាទិ៍ (១)• ការបញ្ជ្រាបការយល់ដឹងអំពីវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា និង ផលប្រយោជន៍នៃការប្រើប្រាស់វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា ទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត ពិសេសកម្រិត មធ្យមសិក្សាទុតិយភូមិ, កម្រិតបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និង នៅកម្រិតឧត្តមសិក្សា និង (២)• ការជំរុញការស្រាវជ្រាវ និង ការអភិវឌ្ឍ រួមទាំងការបង្កើតបណ្តាញស្រាវជ្រាវគំរូរវាង **សកលវិទ្យាល័យ- ស្ថាប័នរដ្ឋ- ឧស្សាហកម្ម** ។

ទី៣- ការបង្កើនលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ តាមរយៈការបន្តជំរុញការកសាងសាលាបឋមសិក្សាឱ្យដល់ភូមិ, ការកសាងអនុវិទ្យាល័យឱ្យបានមួយយ៉ាងតិចក្នុងឃុំនីមួយៗ ស្របតាមស្ថានភាពភូមិសាស្ត្រ, ការជំរុញឱ្យមានសកលវិទ្យាល័យ ឬ សាខាសកលវិទ្យាល័យ នៅតាមខេត្តនីមួយៗស្របតាមលទ្ធភាព និង ស្ថានភាពជាក់ស្តែង, ការពង្រាយគ្រូបង្រៀនឱ្យដល់គ្រប់ទីកន្លែង ក្នុងនេះ រួមមានការផ្តល់អាទិភាពឱ្យគ្រូបង្រៀនអាចធ្វើការនៅតាមមូលដ្ឋានភូមិ- ឃុំរបស់ខ្លួន, ការបង្កើនចំនួនអន្តេវាសិកដ្ឋាន, ការកាត់បន្ថយចំណាយរបស់មាតាបិតាសិស្ស, ការបង្កើនចំណាយសម្រាប់គ្រឹះស្ថានសិក្សា ព្រមទាំងការពង្រីកការចូលរួមពីវិស័យឯកជន និង ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធផ្សេងទៀត ។

ទី៤- ការបន្តអភិវឌ្ឍស្ថាប័ន និង សមត្ថភាពរបស់មន្ត្រីអប់រំ តាមរយៈការអភិវឌ្ឍក្របខណ្ឌគតិយុត្ត និង ការពង្រឹងការអនុវត្តច្បាប់ និង លិខិតបទដ្ឋានពាក់ព័ន្ធ, ការពង្រឹងរចនាសម្ព័ន្ធការងារ និង ការបណ្តុះបណ្តាលជំនាញដល់មន្ត្រី ។

ទី៥- ការបង្កើនគុណភាព និង ប្រសិទ្ធភាពនៃសេវាអប់រំនៅគ្រប់កម្រិតសិក្សា និង ក្នុងការបណ្តុះបណ្តាលបច្ចេកទេស និង មុខជំនាញ ទាំងក្នុងគ្រឹះស្ថានរដ្ឋ និង គ្រឹះស្ថានឯកជន ឱ្យស្របទៅតាមកម្រិតស្តង់ដារអន្តរជាតិ និង តម្រូវការអភិវឌ្ឍរបស់ប្រទេស តាមរយៈការពង្រឹងការបណ្តុះបណ្តាល និង វិក្រឹតការគ្រូបង្រៀន, ការកែលម្អកម្មវិធីសិក្សា, ការធ្វើអធិការកិច្ច និង ការពង្រឹងសមត្ថភាពគ្រប់គ្រង, ការលើកទឹកចិត្តគ្រូបង្រៀនក្នុងការបង្កើនសមត្ថភាពបង្រៀន, ការពង្រឹងគុណភាពក្នុងការប្រឡងបញ្ចប់កម្រិតសិក្សានីមួយៗ, ការលើកកម្ពស់ការសិក្សាភាសាបរទេសដែលចាំបាច់, ការកែលម្អលក្ខខណ្ឌនៃការសិក្សា, ការបង្កើតបណ្ណាល័យ, មន្ទីរពិសោធន៍ និង ការបង្កើនការផ្គត់ផ្គង់សម្ភារៈសិក្សា ព្រមទាំងការចូលរួមរបស់មាតា- បិតា, អាណាព្យាបាល និង សហគមន៍។

ទី៦- ការបន្តជំរុញលើកកម្ពស់តួនាទីសាសនា, ពិសេសគឺព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ, ក្នុងការចូលរួមផ្តល់ការអប់រំផ្នែកគុណធម៌ សីលធម៌ និងចរិយាធម៌ ព្រមទាំងក្នុងការធានាភាពសុខដុមរមនានៅក្នុងសង្គមកម្ពុជា ។

ទី៧- ការជំរុញរៀបចំ និង អនុវត្តគោលនយោបាយជាតិស្តីពីការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ សំដៅលើកកម្ពស់ផលិតភាពការងាររបស់ពលករ, ដោះស្រាយ និង កាត់បន្ថយភាពគ្មានការងារធ្វើរបស់យុវជន ព្រមទាំងបង្កើនចំណូលរបស់ប្រជាជន និង ធានាសមធម៌ ។

ទី៨- ការបន្តពង្រឹងគុណភាពនៃការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ និង ការអភិវឌ្ឍសម្រាប់យុវជននូវជំនាញបច្ចេកទស និង ជំនាញទន់ ពិសេសការធ្វើការងារជាក្រុម, ការគោរពវិន័យ និង ក្រមសីលធម៌វិជ្ជាជីវៈក្នុងកន្លែងការងារ តាមរយៈការកែលម្អកម្មវិធីបណ្តុះបណ្តាល, ការពង្រឹងក្របខណ្ឌគុណវុឌ្ឍិជាតិ, ការបង្កើតស្តង់ដារជាតិសមត្ថភាព, ការត្រួតពិនិត្យ និង ធ្វើតេស្តសមត្ថភាព, ការទទួលស្គាល់មុខជំនាញ, ការអភិវឌ្ឍមុខជំនាញ និង ការប្រកួតប្រជែងជំនាញ សំដៅឆ្លើយតបបានទៅនឹងសេចក្តីត្រូវការទីផ្សារពលកម្ម, បង្កើនឱកាសទទួលបានការងារ និង ប្រើប្រាស់ឱ្យអស់សក្តានុពលនូវផលលាភប្រជាសាស្ត្ររបស់កម្ពុជា ក៏ដូចជា ដើម្បីបង្កើតលក្ខខណ្ឌសមស្រប សម្រាប់ពលករកម្ពុជាអាចឈានឡើងទៅកាន់តួនាទីគ្រប់គ្រង និង ដឹកនាំ ។

ទី៩- ការបន្តជំរុញអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា និង គោលនយោបាយជាតិស្តីពីការអប់រំកាយ និង កីឡា តាមរយៈការបំផុសយុវជនឱ្យចូលរួមក្នុងចលនាការងារសង្គម និង សកម្មភាពកីឡា សំដៅប្រែក្លាយ

យុវជនឱ្យទៅជាធនធានមនុស្ស ប្រកបដោយគុណភាព, សមត្ថភាព និង គុណធម៌ សម្រាប់ការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច និង ការបន្តវេន ។

ទី១០- ការបន្តអភិវឌ្ឍពហុកីឡាដ្ឋានជាតិ និង ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ ព្រមទាំងការរៀបចំបណ្តុះបណ្តាលកីឡាករ- កីឡាការិនី តាមវិស័យដែលកម្ពុជាមានសក្តានុពល ដើម្បីត្រៀមក្នុងការទទួលធ្វើជាម្ចាស់ផ្ទះនៃការប្រកួតកីឡាស៊ីហ្គេម នៅឆ្នាំ ២០២៣ ។

## មុំទី ២. ការលើកកម្ពស់សុខភាព និង អាហារូបត្ថម្ភ

**120.** គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ គឺការបន្តអនុវត្ត «**ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល**» សំដៅលើកកម្ពស់សុខុមាលភាព និង អាហារូបត្ថម្ភរបស់ប្រជាជនទូទៅ, កាត់បន្ថយអត្រាស្លាប់របស់មាតា ទារក និង កុមារ តាមរយៈការពង្រឹង និង ពង្រីកសេវាសុខាភិបាលប្រកបដោយគុណភាព, ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ ។ ជាលទ្ធផល រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ជាច្រើន មានជាអាទិ៍ ការធ្វើឱ្យកាន់តែប្រសើរឡើងនូវស្ថានភាពសុខភាពរបស់ប្រជាជន ជាពិសេស ស្ត្រី ទារក កុមារ និង ប្រជាជនក្រីក្រ ដែលស្តែងឡើង តាមរយៈការកែលម្អសូចនាករសុខាភិបាលសំខាន់ៗមួយចំនួន គឺ : (១). អត្រាមរណភាពមាតាបានធ្លាក់ចុះយ៉ាងលឿនពី ៤៧២ នាក់ ក្នុង ១ សែន កំណើតរស់ នៅឆ្នាំ ២០០៥ មកត្រឹម ២០៦ នាក់ ក្នុង ១ សែន កំណើតរស់ នៅឆ្នាំ ២០១០, (២). អត្រាមរណភាពទារកបានថយពី ៦៦ នាក់ ក្នុង ១ ០០០ កំណើតរស់ នៅឆ្នាំ ២០០៥ មក ត្រឹម ៤៥ នាក់ ក្នុង ១ ០០០ កំណើតរស់ នៅឆ្នាំ ២០១០, (៣). អត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ បានធ្លាក់ពី ៨៣ នាក់ ក្នុង ១ ០០០ កំណើតរស់ នៅឆ្នាំ ២០០៥ មកត្រឹម ៥៤ នាក់ ក្នុង ១ ០០០ កំណើតរស់ នៅឆ្នាំ ២០១០, (៤). អត្រាស្លាប់ដោយជំងឺរបេងបានធ្លាក់ពី ១៩៥ ករណី លើប្រជាជន ១ សែននាក់ នៅឆ្នាំ ១៩៩០ មកនៅត្រឹម ៦៣ ករណី នៅឆ្នាំ ២០១១, (៥). អត្រាប្រេវ៉ាឡង់នៃជំងឺរបេងបានធ្លាក់ពី ១ ៦៧០ ករណី លើប្រជាជន ១ សែន នាក់ នៅឆ្នាំ ១៩៩០ មក ៨១៧ ករណី នៅឆ្នាំ ២០១១, (៦). អត្រាស្លាប់ដោយជំងឺគ្រុនចាញ់បានធ្លាក់ពី ២,០៨ លើប្រជាជន ១ សែននាក់ នៅឆ្នាំ ២០០៧ មក ០,៣២ នៅឆ្នាំ ២០១២, និង (៧). អត្រាប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍បានធ្លាក់ពី ០,៩% នៅឆ្នាំ ២០០៦ មក ០,៧% នៅឆ្នាំ ២០១២ ។ បន្ថែមលើនេះ ការយល់ដឹងអំពីសុខភាព និង អនាម័យ ក្នុងចំណោមប្រជាជនមានភាពកាន់តែប្រសើរឡើង ហើយលទ្ធភាពរបស់ប្រជាជនក្នុងការទទួលបាន និង ការប្រើប្រាស់សេវាសុខាភិបាលប្រកបដោយសមធម៌ ក៏ត្រូវបានលើកកម្ពស់ តាមរយៈការអនុវត្តយន្តការមួយចំនួន រួមមាន ការបង់ថ្លៃជួសសម្រាប់ប្រជាជនក្រីក្រ, មូលនិធិសមធម៌ និង ប័ណ្ណសុខភាពបន្តពូជ ក្នុងនេះ ប្រជាជនក្រីក្រដែលបានទទួលការគាំពារពីមូលនិធិសមធម៌ បានកើនពី ៥៧% នៅឆ្នាំ ២០០៨ ដល់ ៧៨% នៅឆ្នាំ ២០១២ ។

**121.** ទោះបីជាសម្រេចបានសមិទ្ធផលធំៗដូចខាងលើក៏ដោយ ក៏កម្ពុជានៅបន្តជួបបញ្ហាប្រឈមមួយចំនួន ជាអាទិ៍ អត្រាមរណភាពមាតា និង ទារក ក៏ដូចជាកង្វះអាហារូបត្ថម្ភ ពិសេសសម្រាប់កុមារ នៅមានកម្រិតខ្ពស់នៅឡើយ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសក្នុងតំបន់, វិសាលភាព និង គុណភាពនៃសេវាសុខាភិបាល នៅមិនទាន់ឆ្លើយតបបានទាំងស្រុងនៅឡើយ ទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន ។

**122.** ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលនីតិកាលទី ៥ នឹងបន្តជំរុញអនុវត្ត និង ធ្វើបច្ចុប្បន្នកម្ម «**ផែនការយុទ្ធសាស្ត្រ**

**វិស័យសុខាភិបាល ២០០៨-២០១៥**» ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពនៃវិស័យសុខាភិបាល សំដៅលើក ស្ទួយអនាម័យ, សុខភាព, សុខុមាលភាព និង អាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជា ឱ្យកាន់តែល្អប្រសើរឡើង ពិសេស សម្រាប់ប្រជាជនក្រីក្រ, ជនងាយរងគ្រោះ, ស្ត្រី និង កុមារ ។

123. លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ÷

ទី១- ការរៀបចំ និង កែលម្អគោលនយោបាយ និង យុទ្ធសាស្ត្រវិស័យសុខាភិបាល, ការពង្រឹង និង កែលម្អ ក្របខណ្ឌគតិយុត្ត ពិសេស សម្រាប់ការគ្រប់គ្រងសេវាសុខាភិបាលឯកជន, ការលើកកម្ពស់អភិបាលកិច្ចល្អ និង ការពង្រឹង សមត្ថភាពស្ថាប័នសុខាភិបាលគ្រប់លំដាប់ថ្នាក់, ការលើកកម្ពស់ការយល់ដឹងរបស់គ្រូពេទ្យ មន្ត្រី បុគ្គលិក សុខាភិបាល និង អ្នកប្រើប្រាស់សេវា អំពីសិទ្ធិរបស់អតិថិជន, ការលើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជន ក្នុងការផ្តល់សេវាសុខភាព ព្រមទាំងការលើកទឹកចិត្តដល់ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍវិស័យសុខាភិបាល ។

ទី២- ការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រក្នុងការគ្រប់គ្រងវិស័យសុខាភិបាល តាមរយៈការអភិវឌ្ឍ និង ការ-ពង្រីកការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន សំដៅពង្រឹងប្រព័ន្ធទិន្នន័យព័ត៌មានសុខាភិបាល ។

ទី៣- ការបន្តបង្កើនលទ្ធភាពទទួលបានសេវាសុខាភិបាលជូនដល់ប្រជាជន តាមរយៈ ការពង្រីកវិសាលភាពនៃ សេវាសុខភាពសាធារណៈ ឱ្យកាន់តែខិតជិតប្រជាជន ដោយបន្តពង្រីកហេដ្ឋារចនាសម្ព័ន្ធលើវិស័យនេះ ដូចជាការសាង សង់ឱ្យមានមន្ទីរពេទ្យបង្អែក, មណ្ឌលសុខភាព, ប៉ុស្តិ៍សុខភាព ស្របតាមស្ថានភាពភូមិសាស្ត្រ និង ប្រជាសាស្ត្រ រួមជាមួយ នឹងការបំពាក់ឧបករណ៍, សម្ភារៈ, បរិក្ខារពេទ្យ និង ឱសថ ព្រមទាំងបុគ្គលិកសុខាភិបាល ដែលមានជំនាញសមស្រប ។

ទី៤- ការបន្តលើកកម្ពស់សមធម៌ក្នុងការទទួលបាននូវសេវាសុខភាព តាមរយៈ ការពង្រីកកម្មវិធីមូលនិធិសមធម៌ និង ការបង់ថ្លៃជួសសម្រាប់ប្រជាជនក្រីក្រ និង ការអភិវឌ្ឍប្រព័ន្ធធានារ៉ាប់រងសុខភាព តាមបរិការណ៍សង្គម- សេដ្ឋកិច្ច កម្ពុជា ដើម្បីលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន ក៏ដូចជាការពារប្រជាជនក្រីក្រពីហានិភ័យនៃចំណាយធំហួស សមត្ថភាពលើការថែទាំសុខភាព ។

ទី៥- ការបន្តលើកកម្ពស់គុណភាពសេវាសុខាភិបាល តាមរយៈការពង្រឹងសមត្ថភាពបច្ចេកទេសគ្លីនិក និងសមត្ថភាព គ្រប់គ្រងរបស់គ្រូពេទ្យ បុគ្គលិកពេទ្យ និង មន្ត្រីសុខាភិបាល ដោយផ្តោតលើ : (១)• ការបង្កើនគុណភាពនៃការបណ្តុះ-បណ្តាលមូលដ្ឋាន និង ការបណ្តុះបណ្តាលបន្ត, (២)• ការពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ និង (៣)• ការបង្កើន បរិមាណ, ការពង្រាយ និង ការបែងចែកវេជ្ជបណ្ឌិត, ឱសថការី, ទន្តបណ្ឌិត, ឆ្មប, គិលានុបដ្ឋាក និង បុគ្គលិកអមវេជ្ជ-សាស្ត្រ ទៅគ្រប់មូលដ្ឋានសុខាភិបាលសាធារណៈ ពិសេសក្នុងតំបន់ជនបទ ដោយផ្តល់អាទិភាពដល់សិស្ស- និស្សិត មកពី ជនបទ ក្នុងការប្រឡងចូលសិក្សានៅតាមគ្រឹះស្ថានសិក្សាផ្នែកសុខាភិបាលនៅថ្នាក់ជាតិ និង ថ្នាក់ភូមិភាគ ព្រមទាំងផ្តល់ ការលើកទឹកចិត្តសមស្រប រួមទាំងការផ្តល់កន្លែងស្នាក់នៅសមរម្យ នៅទីជនបទ ។

ទី៦- ការបន្តលើកកម្ពស់ការយល់ដឹងអំពីអនាម័យ និង ការលើកស្ទួយស្ថានភាពអនាម័យ ក្នុងចំណោមប្រជាជន សំដៅថែទាំសុខភាព និង កាត់បន្ថយអត្រាឈឺ និង អត្រាឆ្លងជំងឺនានា ។

ទី៧- ការកែលម្អឱ្យកាន់តែប្រសើរឡើងនូវសុខភាពបន្តពូជ និង សុខភាពមាតា ទារក និង កុមារ ព្រមទាំងស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រី និង កុមារ តាមរយៈការពង្រីកសេវាសុខភាពបន្តពូជ និង សេវាសុខភាពមាតា ទារក និង កុមារ ប្រកបដោយគុណភាព និង ប្រសិទ្ធភាព ដោយផ្តោតលើការពង្រីកវិសាលភាពគ្របដណ្តប់នៃការសម្រាលកូនដោយឆ្មប និង គ្រូពេទ្យជំនាញ, ការពង្រីកសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និង សេវាថែទាំទារក, ការពង្រីកសេវាផ្តល់មធ្យោបាយពន្យារកំណើត, ការបង្កើនអត្រាគ្របដណ្តប់នៃការផ្តល់វ៉ាក់សាំងបង្ការជំងឺដល់កុមារ ពិសេសវ៉ាក់សាំងជំងឺកញ្ច្រឹល និង ជំងឺតេតាណូស, ការផ្តល់មីក្រូសារជាតិ និង ជីវជាតិដល់ទារកអាយុ ១ ០០០ ថ្ងៃដំបូង និង សេវាថែទាំព្យាបាលជំងឺកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ ព្រមទាំងការផ្តល់សេវាអប់រំ និង សេវាសុខភាពបន្តពូជដល់យុវវ័យ ។

ទី៨- ការបន្តកាត់បន្ថយអត្រាឈឺ និង អត្រាស្លាប់បណ្តាលមកពីជំងឺឆ្លងចម្បងៗ ដូចជា ហ៊ីវ/អេដស៍, របេង, គ្រុនចាញ់, គ្រុនឈាម, ជំងឺត្រូពិកដែលមិនចាប់អារម្មណ៍ ព្រមទាំងជំងឺឆ្លងលេចឡើងថ្មីៗ និង ជំងឺឆ្លងដែលកើតឡើងសាជាថ្មីម្តងទៀត ពិសេសគឺការខិតខំលុបបំបាត់ជំងឺគ្រុនចាញ់ ឱ្យបានទាំងស្រុងនៅឆ្នាំ ២០២៥ ។

ទី៩- ការកាត់បន្ថយអត្រាឈឺ និង អត្រាស្លាប់ ដែលបណ្តាលមកពីជំងឺមិនឆ្លង-រ៉ាំរ៉ៃ និង បញ្ហាសុខភាពសាធារណៈដែលពាក់ព័ន្ធនឹងសុវត្ថិភាពចំណីអាហារ, ការប្រើប្រាស់គ្រឿងញៀន, គ្រឿងស្រវឹង, ថ្នាំជក់, គ្រោះថ្នាក់ចរាចរណ៍, គ្រោះមហន្តរាយ, បរិស្ថាន និង ការប្រែប្រួលអាកាសធាតុ ។

ទី១០- ការពង្រឹងថែមទៀតនូវកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និង ដៃគូពាក់ព័ន្ធផ្សេងទៀត សំដៅលើកកម្ពស់សេវាសុខភាពសាធារណៈ ពិសេសសម្រាប់កម្មវិធីសំខាន់ៗមួយចំនួន ដូចជា កម្មវិធីសុខភាពបន្តពូជ និង កម្មវិធីអាហារូបត្ថម្ភ សម្រាប់ស្ត្រី និង កុមារ ជាដើម ។

### មុំទី ៣. ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម

**124.** គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ គឺពង្រឹងប្រព័ន្ធគាំពារសង្គម និង បង្កើតឱ្យមានប្រព័ន្ធគាំពារសង្គមផ្លូវការមួយ សំដៅគាំពារជនក្រីក្រ និង ជនងាយរងគ្រោះ ដែលមិនអាចជួយខ្លួនឯងបាន ដើម្បីទប់ទល់នឹងបញ្ហាសុខភាព, អប់រំ, អសន្តិសុខស្បៀង និង ផលប៉ះពាល់នៃវិបត្តិនានា ។ ស្របតាមគោលដៅជាយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវ **«យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និង ជនងាយរងគ្រោះ ២០១១- ២០១៥»** សំដៅប្រមូលផ្តុំបណ្តាកម្មវិធី និង ប្រភេទសេវានានា ដែលបណ្តាស្ថាប័នផ្សេងៗកំពុងអនុវត្តឱ្យស្ថិតនៅក្នុងក្របខណ្ឌគាំពារសង្គមតែមួយ ដើម្បីងាយស្រួលដល់ការវិភាគ កែទម្រង់ និង រៀបរចនាធាន សម្រាប់ការគាំពារសង្គមទាំងមូល ។

**125.** សមិទ្ធផលសំខាន់ៗដែលរាជរដ្ឋាភិបាលសម្រេចបាន រួមមាន (១). កម្មវិធីចែកស្បៀងដល់ជនក្រីក្រ, កម្មវិធីស្បៀងពលកម្ម, កម្មវិធីគាំពារកុមារក្រីក្រឱ្យបានចូលរៀន និង ការជួយឧបត្ថម្ភគាំទ្រជនក្រីក្រ និង ជនងាយរងគ្រោះ ពិសេសកសិករ ក្នុង និង ក្រោយពេលមានគ្រោះមហន្តរាយនានា, (២). ការជួយគាំពារដល់កម្មករ និយោជិត ក្នុងពេលមានវិបត្តិកលយុគហិរញ្ញវត្ថុសកល តាមរយៈការផ្តល់មូលនិធិពិសេសសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ, ការផ្តល់ឥណទានសម្រាប់បង្កើតមុខរបរ ជូនដល់កម្មករ និយោជិត ដែលបានបាត់បង់ការងារ, ការបង់ជំនួសនិយោជកនូវវិភាគទាន

ហានិភ័យការងារចំនួន ០,៣% នៃប្រាក់ឈ្នួលគោលរបស់កម្មករ និយោជិតដល់បេឡាជាតិរបបសន្តិសុខសង្គម និង ការជួយរក្សាការងារជូនដល់កម្មករ និយោជិត តាមរយៈការផ្តល់ការអនុគ្រោះខាងផ្នែកសារពើពន្ធបន្ថែមមួយចំនួន ដល់រោងចក្រវិស័យវាយនភ័ណ្ឌ កាត់ដេរ និង ផលិតស្បែកជើង, (៣)• ការអនុវត្តមូលនិធិសមធមិ, ការបង់ថ្លៃជួសសម្រាប់ជនក្រីក្រ, ប័ណ្ណសុខភាពបន្តពូជ និង យន្តការធានារ៉ាប់រងសុខភាពនៅសហគមន៍ ដោយមានការចូលរួមរបស់ដៃគូដែលមានការពាក់ព័ន្ធ, (៤)• ការកែលម្អប្រព័ន្ធសុវត្ថិភាពសង្គម តាមរយៈការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម, បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល, បេឡាជាតិអតីតយុទ្ធជន និង មូលនិធិជនពិការ ដោយក្នុងនោះ បេឡាជាតិរបបសន្តិសុខសង្គម កំពុងអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារសម្រាប់កម្មករ និយោជិត ចំនួនជិត ៨ សែននាក់ ហើយសេវាផ្តល់ប្រាក់សោធននិវត្តន៍សម្រាប់មន្ត្រីរាជការស៊ីវិល, កងកម្លាំងប្រដាប់អាវុធ, ក្រុមគ្រួសារយុទ្ធជនពលី- ពិការ ត្រូវបានពង្រីកដល់គ្រប់រាជធានី ខេត្ត និង កំពុងប្រើប្រាស់ប្រព័ន្ធធនាគារ ដើម្បីជំរុញការបើកផ្តល់ផ្ទាល់ជូនដល់សាមីជន, (៥)• ការផ្តល់សម្បទានដីសង្គមកិច្ច និង ការធ្វើប្រទានកម្មដីជូនដល់ជនក្រីក្រ ដែលគ្មាន ឬ ខ្វះដីពិតប្រាកដ, យោធិនពិការ, គ្រួសារយោធាពលី និង មរណៈ និង អតីតកងកម្លាំងប្រដាប់អាវុធ និង (៦)• ការពង្រីកវិសាលភាពនៃការផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលកាន់តែមានលក្ខណៈអនុគ្រោះ ជូនដល់ប្រជាជន ។

126. បើទោះបីជាសម្រេចបាននូវសមិទ្ធផល និង ការវិវត្តជាវិជ្ជមានធំៗដូចខាងលើក៏ដោយ ក៏កម្ពុជានៅបន្តជួបបញ្ហាប្រឈមមួយចំនួនទៀត ជាពិសេស ភាពនៅដាច់ដោយដុំៗ មិនទាន់គ្រប់ជ្រុងជ្រោយ និង មិនទាន់បំពេញឱ្យគ្នាទៅវិញទៅមកគ្រប់គ្រាន់នៃប្រព័ន្ធគាំពារសង្គម ។

127. ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលនីតិកាលទី ៥ នឹងបន្តពង្រឹងប្រព័ន្ធគាំពារសង្គមឱ្យកាន់តែមានភាពប្រទាក់ក្រឡាជាប្រព័ន្ធប្រមូលផ្តុំ, មានសង្គតិភាព និង ប្រសិទ្ធភាព គ្របដណ្តប់ទាំងវិស័យសាធារណៈ ទាំងវិស័យឯកជន ដែលមានការបែងចែកតួនាទីច្បាស់លាស់រវាង និង ក្នុងកម្រិតនីមួយៗ ពោលគឺកម្រិតគោលនយោបាយ, កម្រិតបញ្ញត្តិករ និង កម្រិតប្រតិបត្តិករ ។

128. លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការកែលម្អក្របខណ្ឌគោលនយោបាយ និង យុទ្ធសាស្ត្រវិស័យគាំពារសង្គម ក្នុងនេះរួមមាន ការរៀបចំធ្វើបច្ចុប្បន្នកម្ម «**យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និង ជនងាយរងគ្រោះ ២០១១-២០១៥**» និង ឯកសារពាក់ព័ន្ធផ្សេងទៀត ជាអាទិ៍ «**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០១១-២០២០**» ឱ្យមានសង្គតិភាពជាមួយគ្នា និង ឆ្លើយតបទៅនឹងគោលដៅខាងលើ ។

ទី២- ការបន្តជំរុញអនុវត្ត និង រៀបចំយន្តការសម្របសម្រួលស្ថាប័ន ក៏ដូចជាការធ្វើសុខដុមនីយកម្មលើអន្តរាគមន៍ដែលមានស្រាប់ និង ការរៀបចំសិក្សា និង វិភាគអំពីមុខសញ្ញាត្រូវគាំពារ, ឧបករណ៍សម្រាប់គាំពារ និង យន្តការសម្រាប់អនុវត្ត សំដៅបង្កើនប្រសិទ្ធភាព និង បំពេញចន្លោះប្រហោងនៃកិច្ចគាំពារសង្គមសម្រាប់ជនក្រីក្រ និង ជនងាយរងគ្រោះ ហើយឈានទៅរៀបចំបង្កើតប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយមួយ តាមរយៈការជំរុញអនុម័ត **ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ប្រជាជនកម្ពុជា** ។

ទី៣- ការបន្តពង្រឹងការអនុវត្តគោលនយោបាយជាតិចំពោះអតីតយុទ្ធជន និង គោលនយោបាយជាតិចំពោះអតីតមន្ត្រីរាជការស៊ីវិលឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការបន្តពង្រឹងសេវាបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និង បេឡាជាតិសម្រាប់អតីតយុទ្ធជន ។

ទី៤- ការបន្តអនុវត្តគោលនយោបាយជាតិចំពោះជនពិការ តាមរយៈ **ក្រុមប្រឹក្សាសកម្មភាពជនពិការ,** ការពង្រឹងការអនុវត្ត **ច្បាប់ស្តីពីកិច្ចការពារ និង លើកកម្ពស់សិទ្ធិជនពិការ,** ការជំរុញកិច្ចការពារលើកកម្ពស់សិទ្ធិ និង សុខមាលភាពជនពិការ ស្របតាម **អនុសញ្ញានៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ** ព្រមទាំងការពង្រឹងគុណភាព និង ប្រសិទ្ធភាពនៃសេវារបស់មូលនិធិជនពិការ ។

ទី៥- ការបន្តជំរុញអនុវត្ត **គោលនយោបាយជាតិសម្រាប់មនុស្សចាស់** តាមរយៈគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់, ការបន្តពង្រឹងសមាគមមនុស្សចាស់, ការជំរុញកម្មវិធីអភិវឌ្ឍន៍មនុស្សចាស់តាមសហគមន៍ និង កម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារ ឱ្យបានកាន់តែប្រសើរ ជាពិសេស ការជំរុញរៀបចំ និង ដំណើរការសេវាជនចាស់ជរាដើម្បីបណ្តុះបណ្តាលភ្នាក់ងារផ្តល់សេវាថែទាំជនចាស់ជរា ។

ទី៦- ការបន្តពង្រឹងយន្តការឆ្លើយតបនឹងគ្រោះមហន្តរាយ ដោយផ្តោតលើការជួយគាំពារដល់ប្រជាជនរងគ្រោះទាំងក្នុង និង ក្រោយ ពេលមានគ្រោះមហន្តរាយ តាមរយៈការពង្រឹងស្ថាប័ន និង យន្តការពាក់ព័ន្ធ ពិសេសគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដោយបង្កើនថែមទៀតនូវកិច្ចសហការ, កិច្ចសហប្រតិបត្តិការ និង ការសម្របសម្រួលជាមួយគ្រប់តួអង្គពាក់ព័ន្ធ ជាអាទិ៍ កាកបាទក្រហមកម្ពុជា, អង្គការមនុស្សធម៌អន្តរជាតិនានា, វិស័យឯកជន, សប្បុរសជន និង ដៃគូផ្សេងទៀត ។

ទី៧- ការបន្តពង្រឹងយន្តការធានាសន្តិសុខស្បៀង ពិសេសយន្តការ «**គណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា**» ។

ទី៨- ការបន្តអន្តរាគមន៍ក្នុងផ្នែកសុខាភិបាល សំដៅលើកស្ទួយស្ថានភាពអនាម័យ, លើកកម្ពស់ការបង្ការជំងឺឆ្លង និង ហានិភ័យផ្នែកសុខភាពផ្សេងទៀត, លើកស្ទួយសុខុមាលភាពមាតា ទារក និង កុមារ ដោយផ្តោតការយកចិត្តទុកដាក់ពិសេសលើអាហារូបត្ថម្ភ ព្រមទាំងពង្រីកវិសាលភាពនៃមូលនិធិសមធម៌ ក៏ដូចជា ការធានារ៉ាប់រងសុខភាពសហគមន៍មូលដ្ឋាន និង ការធានារ៉ាប់រងសុខភាពដោយស្ម័គ្រចិត្តសម្រាប់មុខសញ្ញាសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។

ទី៩- ការបន្តអន្តរាគមន៍លើការបង្កើតឱកាសការងារ តាមរយៈការបន្តផ្តល់ការឧបត្ថម្ភឱ្យជនក្រីក្របានទទួល ទាំងការបណ្តុះបណ្តាល និង ការបណ្តុះបណ្តាលឡើងវិញ នូវជំនាញបច្ចេកទេស, វិជ្ជាជីវៈ និង សហគ្រិនភាព ដែលម៉្យាង អាចផ្តល់លទ្ធភាពឱ្យពលករដែលមានការពាក់ព័ន្ធ បង្កើតមុខរបរខ្លួនឯង និងម៉្យាងទៀត អាចងាយរកការងារធ្វើនៅក្នុងទីផ្សារពលកម្ម ។

ទី១០- ការបន្តចាត់វិធានការជាកញ្ចប់ ប្រកបដោយភាពទន់ភ្លន់ ស្របតាមសភាពការណ៍ជាក់ស្តែង ដើម្បីផ្តល់ការគាំពារដល់ក្រុមជនងាយរងគ្រោះ ក្នុងពេលដែលប្រទេសជាតិត្រូវជួបប្រឈមនឹងសភាពការណ៍នៃវិបត្តិសេដ្ឋកិច្ចជាយថាហេតុណាមួយ ។

ទី១១- ការបន្តអនុវត្តវិធានការបែងចែកដីធ្លី តាមរយៈការបន្តផ្តល់សម្បទានដីសង្គមកិច្ច និង ការធ្វើប្រទានកម្មដី

ជូនដល់ជនក្រីក្រ, យោធិនពិការ, គ្រួសារយោធាពលី និង មរណៈ និង អតីតកងកម្លាំងប្រដាប់អាវុធ ដែលគ្មាន ឬ ខ្វះដីពិតប្រាកដ ស្របតាមគោលនយោបាយកំណែទម្រង់ដីធ្លីរបស់រាជរដ្ឋាភិបាល ។

ទី១២- ការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ តាមរយៈការពង្រីកវិសាលភាព និង អន្តរការីកម្មនៃសេវាមីក្រូហិរញ្ញវត្ថុ និង មីក្រូធានារ៉ាប់រង ដែលមានថ្លៃ និង លក្ខខណ្ឌកាន់តែអនុគ្រោះ រួមទាំងការបន្តអន្តរាគមន៍របស់រដ្ឋក្នុងការផ្តល់ហិរញ្ញប្បទានសម្រាប់ការបង្កើតមុខរបរ តាមយន្តការ «**មូលនិធិជាតិបណ្តុះបណ្តាលដើម្បីកាត់បន្ថយភាពក្រីក្រ**» ។

ទី១៣- ការបន្តពង្រីកសេវាធានារ៉ាប់រងហានិភ័យការងារ និង ការរៀបចំអនុវត្តយន្តការធានារ៉ាប់រងសុខភាពសម្រាប់កម្មករ និយោជិត និង គ្រួសារក្នុងបន្ទុក ព្រមទាំងរបបធានារ៉ាប់រងផ្នែកសោធន សម្រាប់កម្មករ និយោជិត ។

### មុំទី ៤. ការជំរុញអនុវត្តគោលនយោបាយជាតិប្រជាជន និង សមភាពយេនឌ័រ

129. គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ គឺការពង្រឹងគុណភាពប្រជាជន, លើកស្ទួយស្ថានភាពស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និង សង្គមជាតិ និង ប្រែក្លាយយុវជន ឱ្យទៅជាកម្លាំងចលករដ៏មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ ។

130. ឆ្លើយតបនឹងគោលដៅនេះ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ជាច្រើន ក្នុងការលើកកម្ពស់គុណភាព និង ជីវភាពរបស់ប្រជាជន ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈការកែលម្អសូចនាករសង្គម- សេដ្ឋកិច្ចសំខាន់ៗ ក្នុងវិស័យអប់រំ, បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ, សុខាភិបាល និង ការងារ ជាដើម ។

ជាក់ស្តែង ក្នុងការលើកស្ទួយស្ថានភាពស្ត្រី រាជរដ្ឋាភិបាលបានអនុវត្ត «**ផែនការយុទ្ធសាស្ត្រនារីរតនៈទី ៣**» ដោយផ្តោតទៅលើការពង្រីកកាលានុវត្តភាពសេដ្ឋកិច្ចដល់ស្ត្រី តាមរយៈការអភិវឌ្ឍសមត្ថភាពលើផ្នែកចំណេះដឹង, ជំនាញវិជ្ជាជីវៈ និង ការបង្កើនលទ្ធភាពដល់ស្ត្រីជាសហគ្រិន ក្នុងការទទួលបានសេវាឥណទានខ្នាតតូច និង មធ្យម ។ ក្នុងវិស័យអប់រំ រាជរដ្ឋាភិបាលបានកាត់បន្ថយគម្លាតយេនឌ័រនៅគ្រប់កម្រិត ដោយបានបង្កើនចំនួនអាហារូបករណ៍ដល់សិស្ស និស្សិតក្រីក្រ ពិសេសនារី, បង្កើនចំនួនគ្រឹះស្ថានអប់រំទៅដល់មូលដ្ឋាន, បង្កើនអន្តេវាសិកដ្ឋានសម្រាប់សិស្សស្រី ជាដើម ។ ក្នុងវិស័យសុខាភិបាល រាជរដ្ឋាភិបាលបានបង្កើនសេវាសុខភាព និង អាហារូបត្ថម្ភដល់ស្ត្រី និង កុមារ ដែលបានកាត់បន្ថយគួរឱ្យកត់សម្គាល់ នូវអត្រាមរណភាពមាតា និង ទារក ។ ក្នុងវិស័យសាធារណៈ មន្ត្រីរាជការជាស្ត្រីបានកើនដល់ ៣៥% នៅឆ្នាំ ២០១២, ស្ត្រីចំនួន ២១៨ រូប បានបំពេញតួនាទីជាអភិបាលរងនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ បន្ថែមលើនេះ នៅក្នុងរាជរដ្ឋាភិបាលមានស្ត្រី ១ រូប ជាឧបនាយករដ្ឋមន្ត្រី, ២ រូប ជារដ្ឋមន្ត្រី, ៥៤ រូប ជារដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការ ។ ស្ត្រីជាសមាជិករដ្ឋសភាមានអត្រា ២២% ក្នុងនេះ មានស្ត្រីមួយរូបជាអនុប្រធាននៃរដ្ឋសភា ។ សមាមាត្រស្ត្រីដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ- សង្កាត់ បានកើនឡើងទ្វេដងពី ៨% នៅឆ្នាំ ២០០២ ដល់ ១៨% នៅឆ្នាំ ២០១២ ។ ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី និង លើកកម្ពស់សីលធមិសង្គម តម្លៃស្ត្រី និង គ្រួសារខ្មែរ រាជរដ្ឋាភិបាលបានជំរុញអនុវត្ត «**ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ**», «**ច្បាប់ស្តីពីការ បង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ**» ព្រមទាំង «**ផែនការសកម្មភាពជាតិលើកទី ១ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី**» ។

ចំពោះយុវជន រាជរដ្ឋាភិបាលបានដាក់ចេញ «**គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា**» សំដៅ

អភិវឌ្ឍយុវជន ទាំងខាងចំណេះដឹង ចំណេះធ្វើ, សុខភាព, កាយសម្បទា និង សីលធម៌ ឱ្យក្លាយទៅជា «**មូលធនមនុស្ស**» ប្រកបដោយសក្ដានុពល និង ផ្ដល់ឱកាសឱ្យពួកគេចូលរួម ក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ក៏ដូចជា ក្នុងការអភិវឌ្ឍគ្រួសារ, សហគមន៍ និង ប្រទេសជាតិ ។ ជាក់ស្ដែង យុវជនបានបំពេញតួនាទីយ៉ាងសំខាន់នៅក្នុងកិច្ចការសង្គមផ្សេងៗ តាមរយៈចលនាកាយរិទ្ធិ, យុវជនកាកបាទក្រហម, យុវជនស្ម័គ្រចិត្តក្នុងការអនុវត្ត «**គោលនយោបាយចាស់- សកម្មភាពថ្មីលើវិស័យដីធ្លី**» ព្រមទាំងចលនាយុវជន ក្នុងការលើកតម្កើងវប្បធម៌, ប្រពៃណីជាតិ និង ក្នុងកិច្ចការពារបរិស្ថាន ។

131. ទោះជាយ៉ាងណាក៏ដោយ កម្ពុជានៅបន្តជួបបញ្ហាប្រឈមមួយចំនួនទៀត ជាអាទិ៍ : (១). ភាពចាំបាច់ក្នុងការ-គ្រប់គ្រងបន្លាស់ទីរបស់ប្រជាជន និង នគរូបនីយកម្ម, (២). ការក្ដាប់ឱ្យជាប់នូវកាលានុវត្តភាព ដែលកើតចេញមកពីផលលាភប្រជាសាស្ត្រ ដោយសារបច្ចុប្បន្ន សមាមាត្រនៃប្រជាជនវ័យក្មេង (ក្រុមអាយុតិចជាង ២៥ ឆ្នាំ) មានប្រមាណ ៥០% ធៀបនឹងប្រជាជនសរុប និង (៣). ភាពចាំបាច់ក្នុងការបន្តកែលម្អ និង លើកស្ទួយស្ថានភាពស្ត្រី ដែលជាឆ្អឹងខ្នងនៃសង្គម និង សេដ្ឋកិច្ចកម្ពុជា ។

132. ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលនីតិកាលទី ៥ នឹងផ្ដោតការយកចិត្តទុកដាក់ទៅលើការបន្តពង្រឹងការគ្រប់គ្រងជីវភាពប្រជាសាស្ត្រ សំដៅធានាបង្កើនគុណភាព «**មូលធនមនុស្ស**» ដែលជាគន្លឹះកំណត់ភាពប្រកួតប្រជែងរយៈពេលវែងរបស់ប្រទេស ដើម្បីទាញយកផលប្រយោជន៍ និង ប្រើប្រាស់ឱ្យអស់លទ្ធភាព នូវសក្ដានុពលប្រជាសាស្ត្ររបស់កម្ពុជា សម្រាប់ធានាចីរភាពនៃកំណើនសេដ្ឋកិច្ច ព្រមទាំងវឌ្ឍនភាព និង វិបុលភាពរបស់ប្រជាជន ។

133. លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនឹងផ្ដោតអាទិភាពលើ ÷

ទី១- ការរៀបចំគោលនយោបាយគ្រប់គ្រងចលនាបន្លាស់ទីរបស់ប្រជាជន គួបផ្សំនឹងការពង្រឹងការងាររៀបចំដែនដី និង នគរូបនីយកម្ម ដោយផ្ដោតលើ : (១). ការអភិវឌ្ឍរាជធានីភ្នំពេញ, ប៉ូលសេដ្ឋកិច្ចសំខាន់ៗនៅក្នុងប្រទេស, ក្រុងរណប និង តំបន់ទីប្រជុំជន ទន្ទឹមនឹងការបង្កើតការងារនៅតាមមូលដ្ឋាន និង (២). ការតភ្ជាប់ក្រុងរណប និង តំបន់ទីប្រជុំជនទៅនឹងប៉ូលសេដ្ឋកិច្ចសំខាន់ៗ ឱ្យក្លាយជារបៀងសេដ្ឋកិច្ច ។

ទី២- ការបន្តអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និង គុណធម៌ តាមរយៈការអនុវត្តវិធានការចម្រុះ ប្រទាក់ក្រឡា ក្នុងវិស័យពាក់ព័ន្ធ ជាអាទិ៍ អប់រំ, ស្រាវជ្រាវ, វិទ្យាសាស្ត្រ, បច្ចេកវិទ្យា, បណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវៈ និង សុខាភិបាល ។

ទី៣- ការបន្តលើកកម្ពស់តួនាទីរបស់ស្ត្រី និង យុវជន ក្នុងវិស័យសេដ្ឋកិច្ច តាមរយៈការពង្រីកកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈ, ការបំពាក់បំប៉នជំនាញបច្ចេកទេស និង សហគ្រិនភាព ព្រមទាំងការពង្រឹងភាពអង់អាចរបស់ស្ត្រី និង យុវជន ។

ទី៤- ការបន្តលើកកម្ពស់តួនាទីរបស់ស្ត្រី ក្នុងវិស័យសាធារណៈ តាមរយៈការបង្កើនសមាមាត្រ និង ការពង្រឹងសមត្ថភាពស្ត្រី នៅក្នុងជួរថ្នាក់ដឹកនាំក្រសួង- ស្ថាប័ន ទាំងកម្រិតនយោបាយ ទាំងកម្រិតជំនាញ ។

ទី៥- ការបន្តជំរុញអនុវត្ត «**ផែនការសកម្មភាពជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី** » សំដៅលុបបំបាត់ឥរិយាបថប្រើអំពើហិង្សាលើស្ត្រី និង ពង្រីកវប្បធម៌អហិង្សា ដើម្បីរួមចំណែកលើកកម្ពស់សីលធម៌សង្គម, តម្លៃស្ត្រី និង គ្រួសារខ្មែរ ក៏ដូចជា កសាងគ្រួសារមានសុភមង្គល, សហគមន៍ និង សង្គមជាតិសុខដុមរមនា ។

ទី៦- ការបន្តពង្រឹងការអនុវត្តច្បាប់ ឱ្យមានប្រសិទ្ធភាព ដើម្បីបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ទៅលើស្ត្រី និង កុមារ ។

ទី៧- ការបន្តលើកកម្ពស់សុខុមាលភាព និង សិទ្ធិរបស់កុមារ ដែលមានកំណត់ក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ រួមមាន សិទ្ធិរស់រានមានជីវិត, សិទ្ធិទទួលបានការអភិវឌ្ឍ, សិទ្ធិទទួលបានការការពារ និង សិទ្ធិចូលរួមរបស់កុមារ ។

ទី៨- ការបន្តយកចិត្តទុកដាក់បង្កើតលក្ខខណ្ឌឱ្យយុវជន ដែលជាកម្លាំងបន្តវេន អាចចូលរួមក្នុងការដឹកនាំ និង ការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច និង ការការពាររាល់សមិទ្ធផលសង្គម តាមរយៈការជំរុញការអនុវត្តជាជំហានៗ នូវទិសដៅយុវភាវូបនីយកម្ម ក្នុងការផ្តល់ការទទួលខុសត្រូវនៅគ្រប់លំដាប់ថ្នាក់ ។

ទី៩- ការបន្តជំរុញការបញ្ជ្រាបយេនឌ័រ និង សេចក្តីត្រូវការរបស់យុវជន ទៅក្នុងគោលនយោបាយ និង ផែនការអភិវឌ្ឍគ្រប់វិស័យ និង គ្រប់កម្រិត ។

## សេចក្តីសន្និដ្ឋាន

**134.** ការអនុវត្តប្រកបដោយជោគជ័យនូវ **យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ១ និង ទី ២** នៅក្នុងរយៈពេលមួយទសវត្សកន្លងទៅនេះ បាននាំកម្ពុជាឱ្យឈានឡើងទៅកាន់ដំណាក់កាលថ្មីមួយទៀត នៅលើវិថីនៃការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ។ សមិទ្ធផលសំខាន់ៗដែលមានអត្ថន័យជាប្រវត្តិសាស្ត្រដ៏គួរឱ្យកត់សម្គាល់ទាំងនេះ រួមមាន ÷

**ទី១**- ការធានាចីរភាពនៃសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម ក៏ដូចជាការលើកស្ទួយនីតិរដ្ឋ, ការលើកកម្ពស់សិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស, ការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស, ការលើកស្ទួយកិត្យានុភាពកម្ពុជាឱ្យខ្ពស់ត្រដែតនៅលើឆាកតំបន់ និង អន្តរជាតិ ព្រមទាំងការការពារបានដោយឥតរវាត នូវអធិបតេយ្យភាពជាតិ និង បូរណភាពទឹកដី ។

**ទី២**- ការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ក្នុងអត្រាប្រមាណ ៨% ជាមធ្យម ក្នុងមួយឆ្នាំ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយ នៅលើមូលដ្ឋានទូលាយជាងមុន និង មានសមត្ថភាពប្រកួតប្រជែងជាងមុន នៅក្នុងបរិការណ៍អត្រាអតិផរណាទាប ក្នុងរង្វង់ ៥% ជាមធ្យមក្នុងមួយឆ្នាំ ។

**ទី៣**- ការកាត់បន្ថយអត្រានៃភាពក្រីក្រ បានលើស ១% ក្នុងមួយឆ្នាំ និង ការធានាកែលម្អសូចនាករសំខាន់ៗ ក្នុងវិស័យសង្គមកិច្ច ពិសេស ក្នុងវិស័យអប់រំ, សុខាភិបាល និង សមភាពយេនឌ័រ ។

**ទី៤**- ការបង្កើននិវិសាលភាព, ប្រសិទ្ធភាព និង គុណភាពនៃសេវាសាធារណៈ ឱ្យកាន់តែប្រសើរឡើង ហើយទទួលបាននូវការជឿទុកចិត្តកាន់តែខ្លាំងឡើង ពីសំណាក់ប្រជាជន ។

**135.** លើមូលដ្ឋាននេះ **យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៣** របស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នេះ ត្រូវបានរចនាដាក់ចេញមក ដើម្បីឆ្លើយតបទៅនឹងបេសកម្មជាប្រវត្តិសាស្ត្រដ៏ចម្បងពីរយ៉ាងរបស់ជាតិ គឺ : ទីមួយ- ការបន្តដំណើរទៅមុខ, ក្នុងជំនឿដ៏មុតមាំ, សំដៅសម្រេចឱ្យបានពេញលេញនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា នៅឆ្នាំ ២០១៥ ព្រមទាំងសម្រេចឱ្យបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប, និង ទីពីរ- ការបង្កើតឡើងនូវបុរេលក្ខខណ្ឌចាំបាច់ និង បរិស្ថានអនុគ្រោះ សម្រាប់ដំណើរការផ្លាស់ប្តូរស៊ីជម្រៅរបស់កម្ពុជា ឆ្ពោះទៅរកដំណាក់កាលអភិវឌ្ឍន៍ថ្មីកាន់

តែខ្ពស់ថែមទៀត នៅក្នុងរយៈពេលវែងខាងមុខ ពោលគឺមហិច្ឆតានៃការប្រែក្លាយខ្លួន ឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ ហើយឈានឡើងទៅជាប្រទេសមានចំណូលខ្ពស់ ក្នុងឆ្នាំ ២០៥០ ។

136. ក្នុងគោលដៅនេះ **យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៣** បានឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់នូវរបៀប-វារៈគោលនយោបាយសង្គម- សេដ្ឋកិច្ចរបស់កម្ពុជា សម្រាប់រយៈពេល ៥ ឆ្នាំ ខាងមុខ ដែលផ្តោតទៅលើ **«គោលដៅជាយុទ្ធសាស្ត្រ ៤»** និង **«អាទិភាព ៤»** ដូចបានគូសបញ្ជាក់ពីខាងដើម ។ ដូច្នេះ ក្នុងរយៈពេល ៥ ឆ្នាំខាងមុខ **យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៣** នឹងនាំកម្ពុជាឱ្យបន្តដំណើរឈានឡើងរបស់ខ្លួនយ៉ាងស្វាហាប់តទៅទៀត ដោយឆ្លងកាត់នូវដំណើរផ្លាស់ប្តូរជាប្រវត្តិសាស្ត្រ នៅក្នុងទិដ្ឋភាពប្រទាក់ក្រឡាគ្នាចំនួនបួនសំខាន់ៗ គឺ ÷

ទី១- ដំណើរការនៃការផ្លាស់ប្តូរពីបរិមាណទៅគុណភាពនៅក្នុងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច តាមរយៈកំណែទម្រង់រចនាសម្ព័ន្ធ, ការបង្កើនផលិតភាព និង ការធ្វើពិពិធភាវូបនីយកម្មសេដ្ឋកិច្ច សំដៅលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា, បង្កើនបរិយាប័ន្ន ឬ ការចូលរួមរបស់ប្រជាជន ព្រមទាំងលើកស្ទួយសមធម៌សង្គម ។ ដំណើរការផ្លាស់ប្តូរនេះ នឹងត្រូវបានឆ្លុះបញ្ចាំង តាមរយៈ (១). ការបន្តជំរុញអនុវត្តកំណែទម្រង់ដ៏ស៊ីជម្រៅទាំងឡាយ ពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ, កំណែទម្រង់រដ្ឋបាលសាធារណៈ និង កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌, និង (២). ការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម និង បរិស្ថានវិនិយោគ ។

ទី២- ដំណើរការនៃការអភិវឌ្ឍឧស្សាហកម្ម តាមរយៈការដាក់ចេញ និង ជំរុញអនុវត្ត **«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម»** និង ការធ្វើពាណិជ្ជូបនីយកម្មវិស័យកសិកម្ម ដើម្បីបង្កើនតម្លៃបន្ថែម ពោលគឺការអភិវឌ្ឍវិស័យកសិកម្មកម្ពុជា ពីកសិកម្មបែបវិបុលកម្ម, មានផលិតភាពទាប និង ផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯង ទៅជាកសិកម្មបែបប្រពលកម្ម, មានផលិតភាពខ្ពស់ និង ផលិតសម្រាប់ធ្វើពាណិជ្ជកម្ម ។

ទី៣- ដំណើរការនៃការផ្លាស់ប្តូរពីការសង្កត់ធ្ងន់លើការវិនិយោគលើ **«មូលធនរូបវន្ត»** (Physical Capital) ទៅរកការផ្តល់សារសំខាន់កាន់តែខ្លាំងឡើងលើការវិនិយោគលើ **«មូលធនពុទ្ធិ»** (Knowledge Capital) ពោលគឺការអភិវឌ្ឍ **«មូលធនមនុស្ស»** ពិសេសតាមរយៈការបង្កើនការវិនិយោគលើយុវជន និង ការលើកកម្ពស់តួនាទីរបស់យុវជននៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ព្រមទាំងការលើកស្ទួយសុខមាលភាពរបស់ប្រជាជន ដោយផ្តោតជាសំខាន់លើស្ត្រី, ទារក និង កុមារ ។

ទី៤- ដំណើរការនៃការធ្វើសមាហរណកម្មកាន់តែស៊ីជម្រៅទៅក្នុងសហគមន៍តំបន់ និង ពិភពលោក ពិសេសការ-ចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន នៅឆ្នាំ ២០១៥ ខាងមុខ ដោយខិតខំប្រើប្រាស់ឱ្យបានប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត នូវបណ្តាកាលានុវត្តភាព និង លក្ខខណ្ឌអំណោយផលទាំងឡាយ ដែលកើតចេញមកពីកិច្ចដំណើរការសមាហរណ-កម្មក្នុងតំបន់នេះ សំដៅទាក់ទាញប្រយោជន៍ជាអតិបរមាសម្រាប់កម្ពុជា ពិសេសតាមរយៈការតភ្ជាប់សេដ្ឋកិច្ចកម្ពុជាទៅនឹងបណ្តាញផលិតកម្មតំបន់ និង ខ្សែសង្វាក់តម្លៃសកល ។

137. ដូចនីតិកាលមុនដែរ **«កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា»** និង **«យុទ្ធ-សាស្ត្រចតុកោណ- ដំណាក់កាលទី ៣»** នឹងត្រូវបានអនុវត្តតាមរយៈ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ឆ្នាំ

២០១៣-២០១៨ ដែលនឹងត្រូវបានដាក់ចេញក្នុងពេលដ៏ឆាប់ខាងមុខ ។ យ៉ាងណាមិញ នៅក្នុងការអនុវត្តជាក់ស្តែង រាជរដ្ឋាភិបាលនឹងបន្តខិតខំធានាឱ្យបានល្អប្រសើរនូវសង្គតិភាព និង លំដាប់លំដោយនៃការអនុវត្តរវាង «**កម្មវិធីនយោបាយ**» និង «**យុទ្ធសាស្ត្រចតុកោណ**» ជាមួយនឹង «**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**» ក៏ដូចជាជាមួយយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ព្រមទាំងឯកសារដែលមានចរិតលក្ខណៈជាគោលនយោបាយ, យុទ្ធសាស្ត្រ, កម្មវិធី និង ផែនការសកម្មភាពទាំងឡាយផ្សេងទៀត ទាំងឯកសារដែលត្រូវបានដាក់ចេញមករួចហើយ, ទាំងឯកសារដែលនឹងត្រូវបានដាក់ចេញមកបន្ថែមទៀត និង ទាំងឯកសារដែលនឹងត្រូវបានធ្វើបច្ចុប្បន្នកម្មឡើងវិញក្នុងពេលខាងមុខ ពិសេសគឺកម្មវិធីវិនិយោគរំកិលបីឆ្នាំ និង ថវិកាជាតិប្រចាំឆ្នាំ ។

**138.** ក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះ ក្រោយពីមានការបង្រួបបង្រួមជាតិ និង សុខសន្តិភាពពេញលេញនៅក្នុងផ្ទៃប្រទេស, កម្ពុជាសម្រេចបាននូវសមិទ្ធផលដ៏ច្រើនគួរជាទីមោទនៈ បើប្រៀបធៀបនឹងប្រទេសដទៃទៀតដែលត្រូវចំណាយពេលវេលាអស់រាប់ទសវត្សរ៍ ។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលទទួលស្គាល់ថា ក្នុងការឈានទៅសម្រេចឱ្យបានតាមចក្ខុវិស័យដែលមានចែងនៅក្នុង **យុទ្ធសាស្ត្រចតុកោណ**, កម្ពុជានៅត្រូវបន្តជួបនឹងបញ្ហាប្រឈម ព្រមទាំងឧបសគ្គជាច្រើនទៀតដែលតម្រូវឱ្យជាតិកម្ពុជាទាំងមូល ខិតខំបង្កើនជវភាព និង សមត្ថភាពប្រកួតប្រជែងរបស់ខ្លួន ដើម្បីបន្តបោះជំហានទៅមុខ ក្នុងល្បឿនកាន់តែលឿនជាងមុន និង មានប្រសិទ្ធភាពជាងមុន ។ ក៏ប៉ុន្តែ កម្ពុជាពិតជាមានមូលដ្ឋានដ៏រឹងមាំ សម្រាប់គាំទ្រទស្សនៈអនាគតប្រកបដោយសុទិដ្ឋិនិយមរបស់ខ្លួន ។

**139.** ផ្អែកលើសមិទ្ធផលសម្រេចបានកន្លងមក, ផ្អែកលើសក្តានុពលដ៏ធំធេងរបស់កម្ពុជា, ផ្អែកលើឆន្ទៈដ៏មោះមុត និង ទេពកោសល្យរបស់ប្រជាជនកម្ពុជា ព្រមទាំងផ្អែកលើសមត្ថភាពក្នុងការរៀនសូត្រ, ការដកស្រង់នូវបទពិសោធន៍, ការតម្រឹម, ការបន្សាំ និង ការចេះជ្រើសយកវិធានការចាំបាច់របស់រាជរដ្ឋាភិបាល និង របស់ប្រជាជនកម្ពុជាទាំងមូល រួមជាមួយនឹងយុទ្ធសាស្ត្រដ៏ត្រឹមត្រូវដែលបានដាក់ចេញមកនេះ រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា កម្ពុជានឹងជំនះបាននូវរាល់បញ្ហាប្រឈម និង ឧបសគ្គទាំងឡាយនេះ នៅលើមាគ៌ាឆ្ពោះទៅកាន់វឌ្ឍនភាព, វិបុលភាព និង ភាពថ្កុំថ្កើងរុងរឿង ។

# សុន្ទរកថា

## ឯកឧត្តម គួច ជឿន អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីអភិវឌ្ឍយុវជន និងជាអគ្គនាយកយុវជន ក្រសួងអប់រំ យុវជន និងកីឡា ក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការអនុវត្ត និងការចូលរួមរបស់យុវជនក្នុងផែនការសកម្មភាពជាតិស្តី ពីការអភិវឌ្ឍយុវជនកម្ពុជា ២០១៦-២០១៨

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦

សូមគោរព៖

- ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធនានា
- ឯកឧត្តមអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- តំណាងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- តំណាងដៃគូអភិវឌ្ឍ (UNFPA) អង្គការសង្គមស៊ីវិល
- អង្គសិក្ខាសាលាទាំងមូល ជាទីមេត្រី

ថ្ងៃនេះ ខ្ញុំពិតជាមានកិត្តិយស និងសេចក្តីសោមនស្សក្រៃលែង ដែលបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកពាក់ព័ន្ធទាំងអស់ នៅក្នុង "សិក្ខាសាលាពិគ្រោះយោបល់ស្តីពីការអនុវត្ត និងការចូលរួមរបស់យុវជន ក្នុងផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ២០១៦-២០១៨" ដ៏មានសារៈសំខាន់នេះ។

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា បានទទួលការឯកភាពជាផ្លូវការពីទីស្តីការគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១។ គោលនយោបាយនេះ ត្រូវបានរៀបចំឡើងក្រោមការដឹកនាំ និងសម្របសម្រួលដោយក្រសួងអប់រំ យុវជន និងកីឡា និងមានកិច្ចសហការពេញលេញពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិលនានា ដែលកំពុងបំពេញការងារពាក់ព័ន្ធនឹងយុវជន ដោយបានកំណត់នូវយុទ្ធសាស្ត្រមួយចំនួនដើម្បីបំពេញការងារឱ្យស្របតាមវិស័យរបស់ខ្លួន។ ការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា អាចសម្រេចទៅបានប្រកបដោយប្រសិទ្ធភាព លុះត្រាតែគ្រប់វិស័យនៃសង្គមទទួលស្គាល់ពីសារៈសំខាន់នៃការអភិវឌ្ឍយុវជន និងតួនាទីរបស់យុវជននៅក្នុងសង្គម។

ដើម្បីអនុវត្តគោលនយោបាយជាតិនេះ យន្តការមួយត្រូវបានបង្កើតឡើង "*ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន* " ហៅកាត់ថា" **ក.ជ.យ.** " ដែលមានតួនាទីជាអ្នកសម្របសម្រួលតាមដាន វាយតម្លៃ និងជួយរាជរដ្ឋាភិបាលអំពីដំណើរការអភិវឌ្ឍយុវជនឱ្យមានប្រសិទ្ធភាព។ ការអនុវត្តការងាររបស់ **ក.ជ.យ.** នឹងស្ថិតក្រោមក្របខណ្ឌរបស់ ***ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ២០១៦-២០១៨*** ដែលជាមគ្គុទ្ទេសក៍សម្រាប់បង្ហាញផ្លូវដល់ប្រតិបត្តិការរបស់ខ្លួន ដោយក្នុងនោះយុទ្ធសាស្ត្រចំនួន៦ត្រូវបានលើកឡើងមានដូចជា៖

យុទ្ធសាស្ត្រទី១៖ អភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងយន្តការ

យុទ្ធសាស្ត្រទី២៖ លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព

យុទ្ធសាស្ត្រទី៣៖ បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព

យុទ្ធសាស្ត្រទី៤៖ បណ្តុះស្មារតីសហគ្រិនភាព និងទីផ្សារការងារ

យុទ្ធសាស្ត្រទ៥៖ បង្កើនការចូលរួមរបស់យុវជន

យុទ្ធសាស្ត្រទី៦៖ បង្កើនការងារស្ម័គ្រចិត្ត

ផែនការសកម្មភាពជាតិនេះ មានគោលបំណងធានាឱ្យយុវជនមានអាយុចន្លោះពី ១៥ឆ្នាំ ដល់ ៣០ឆ្នាំ មានការអភិវឌ្ឍកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ ចេះរួមរស់ជាមួយគ្នាដោយសន្តិភាពនិងសុខដុម ព្រមទាំងមានស្មារតីស្នេហាជាតិ ស្នេហាប្រជាជន ប្រកបដោយជំនឿជាក់លើខ្លួនឯង សេចក្តីថ្លៃថ្នូរ ភាពជាអ្នកដឹកនាំ និងលើកកម្ពស់ការយល់ដឹងទូលំទូលាយអំពីសង្គម។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!

សិក្ខាសាលាពិគ្រោះយោបល់នៅថ្ងៃនេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីរួមចំណែកអោយយន្តការសម្រាប់ការអនុវត្ត *ផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ២០១៦-២០១៨* អាចដំណើរការបាន។ សិក្ខាសាលានេះ មានគោលបំណងសំខាន់ៗចំនួន ៣ រួមមាន៖

- ពិគ្រោះយោបល់ជាមួយដៃគូសំខាន់ៗ ដើម្បីទទួលបានមតិត្រឡប់ និងអនុសាសន៍នានាសំដៅបញ្ជ្រៀប និងឆ្លុះបញ្ចាំងពីបញ្ហាយុវជន និងការចូលរួមរបស់ពួកគេទៅក្នុងកិច្ចដំណើរការរៀបចំផែនការ
- តស៊ូមតិ ដើម្បីបង្កើនការវិនិយោគទៅលើយុវជន នៅក្នុងគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍ដោយធ្វើការជំរុញការចូលរួមពេញលេញមួយរបស់យុវជន
- ផ្សព្វផ្សាយអំពីវឌ្ឍនភាពរបស់ ផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន។

ជាទីបញ្ចប់ តាងនាមថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ក្រសួងអប់រំ យុវជន និងកីឡា និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានដ៏ថ្លៃថ្លារបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជានិច្ចកាលតែងយកចិត្តទុកដាក់ខ្ពស់ចំពោះវិស័យយុវជន និងសូមប្រសិទ្ធពរជ័យជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ជួបពុទ្ធពរទាំង ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំសូមបើកសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការអនុវត្ត និងការចូលរួមរបស់យុវជន ក្នុងផែនការសកម្មភាពជាតិស្តីពី ការអភិវឌ្ឍយុវជនកម្ពុជា ២០១៦-២០១៨ ចាប់ពីពេលនេះតទៅ។

សូមអរគុណ!

YCUD

OXFAM

# កិច្ចសន្ទនាយុវជនស្តីពី "បញ្ហាអាទិភាពរបស់យុវជន"

## ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧ នៅក្រុមប្រឹក្សា




ថ្ងៃសរសេរបាយការណ៍៖ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧


សរសេរដោយ៖ លោក ហុង រដ្ឋា មន្ត្រីតស៊ូមតិ

សម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍
Youth Coalition for Unity and Development
Address: #18AB, St 160, Sangkat Touk Laark 2, Khan Toul Kok , Phnom Penh
FB page: Youth Coalition for Unity and Development -YCUD
E-mail:ycudoffice@yahoo.com
Hand phone: 012/81 324 691

# របាយការណ៍លទ្ធផល
# ស្តីពី
# កិច្ចសន្ទនាយុវជន "បញ្ហាអាទិភាពរបស់យុវជន"

## ១. ព័ត៌មានទូទៅ

| | |
|---|---|
| កាលបរិច្ឆេទ | ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧ |
| ពេលវេលា | ចាប់ពីម៉ោង ៨:០០ ដល់ ១១:៣០ ព្រឹក |
| ទីកន្លែង | ក្រុមប្រឹក្សាយុវជនកម្ពុជា YCC |
| រៀបចំដោយ | សម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ |
| ឧបត្ថមដោយ | Oxfam |

## ២. សេចក្តីផ្តើម

យោងតាមលទ្ធផលនៃការស្រាវជ្រាវថ្នាក់ជាតិពីតម្រូវការរបស់យុវជននៅឆ្នាំ២០១៥កន្លងមកនេះបានបង្ហាញថា ជាទូទៅយុវជនមានការយល់ដឹងខ្ពស់អំពីស្ថានភាពសេដ្ឋកិច្ចសង្គម និងនយោបាយនាពេលបច្ចុប្បន្ន ទោះបីជាសមត្ថភាពនៃការវិភាគបញ្ហាក្នុងចំណោមយុវជននៅតំបន់ជនបទ មានកម្រិតទាបជាងយុវជននៅទីប្រជុំជនក៏ដោយ។ កង្វះការផ្សាភ្ជាប់ទំនាក់ទំនងជាមួយបណ្តាញសង្គមធំៗ ការមិនទទួលបានព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយនានា និងគុណភាពនៃការអប់រំមានកម្រិតផងនោះ ជាហេតុធ្វើឱ្យយុវជននៅតំបន់ជនបទខ្វះព័ត៌មាន ដើម្បីជំរុញឱ្យពួកគេចូលរួមនៅក្នុងសកម្មភាពសង្គម។ កង្វះការងារធ្វើ ប្រាក់ខែតិច កង្វះសុវត្ថិភាពក្នុងសង្គម គុណភាពអប់រំមានកម្រិត គឺជាបញ្ហាគន្លឹះដែលយុវជននៅទីប្រជុំជនបានលើកឡើង។ គួរកត់សម្គាល់ថា បញ្ហាសុវត្ថិភាពសង្គម ត្រូវបានលើកឡើងដោយយុវជនជាច្រើននៅទីប្រជុំជន ប៉ុន្តែយុវជននៅតំបន់ជនបទវិញ ស្ទើរតែមិនបានលើកឡើងសោះឡើយ។

ការលើកឡើងរបស់យុវជននៅទីប្រជុំជន ក៏ខុសគ្នាពីយុវជននៅតំបន់ជនបទទៅលើបញ្ហាមួយចំនួនទៀត។ ឧទាហរណ៍ យុវជននៅទីប្រជុំជនបានចាត់ទុកថា បញ្ហាគ្មានការងារធ្វើ ប្រាក់ខែទាប ខ្វះជំនាញដែលស្របតាមតម្រូវការទីផ្សារ គឺជាបញ្ហាសំខាន់ រីឯយុវជននៅតំបន់ជនបទវិញ បង្ហាញនូវបញ្ហាប្លែកគ្នាបន្តិច ដោយគេបានលើកឡើងអំពីគុណភាពនៃការអប់រំមានកម្រិតទាប ការប្រើប្រាស់គ្រឿងញៀន និងចំណាកស្រុក គឺជាបញ្ហាគន្លឹះ ដែលជះឥទ្ធិពលដល់ជីវិតយុវជននៅតំបន់ជនបទ។

បញ្ហាសំខាន់មួយទៀតដែលយុវជនបានលើកឡើងគឺការខ្វះឱកាសការងារសមស្របបន្ទាប់ពីពួកគេបានបញ្ចប់ការសិក្សាពីមធ្យមសិក្សា ឬមហាវិទ្យាល័យ ដែលបញ្ហានេះត្រូវបានលើកឡើងដោយយុវជនស្ទើរតែទាំងអស់ ដែលបានចូលរួមក្នុងការសម្ភាសន៍ជាក្រុម។ ពួកគេបានរៀបរាប់បន្ថែមថា ដោយសារកង្វះខាត

ការងារ និងខ្វះជំនាញ យុវជនជាច្រើនបានសម្រេចចិត្តចេញទៅប្រកបការងារនៅទីប្រជុំជន ឬក៏ទៅក្រៅប្រទេស។

ដូចនេះបញ្ហាអាទិភាពដែលយុវជនកំពុងជួបប្រទះ គឺ យុវជននិងការងារ យុវជននិង សន្តិសុខសង្គម និងយុវជននិងការអប់រំ ។

ដើម្បីចូលរួមដោះស្រាយទៅនឹងបញ្ហាអាទិភាពទាំងបីខាងលើ សម្ព័ន្ធយុវជនដើម្បីឯកភាព និង អភិវឌ្ឍន៍កំពុងសហការគ្នាជាមួយអង្គការ-សមាគមសមាជិកធ្វើការរួមគ្នាក្នុងការតស៊ូមតិថ្នាក់ជាតិពី តម្រូវការរបស់យុវជន ។ ការតស៊ូមតិនេះមានសកម្មភាពជាច្រើន ហើយនៅពេលនេះក្រុមការងារនឹងរៀបចំជាកិច្ចសន្ទនាយុវជនស្តីអំពី " បញ្ហាអាទិភាពរបស់យុវជន" ។

## ៣. គោលបំណង

### ៣.១ គោលបំណងទូទៅ (□□□□□□□□ □□□□□□□□ □□□□□□□□□□□)

ដើម្បីឲ្យ ក្រុមយុវជន (អង្គការយុវជន ឬបណ្តាញយុវជន) អាចរៀបចំសកម្មភាពផ្សេងៗដើម្បីបញ្ចុះបញ្ចូលអ្នកធ្វើសេចក្តីសម្រេចចិត្តឲ្យដោះស្រាយបញ្ហារបស់ពួកគេ។

### ៣.២ គោលបំណងជាក់លាក់ (□□□□□□□□□ □□□□□□□□□□□)

- ដើម្បីឲ្យក្រុមយុវជនបានដឹងពីបញ្ហាអាទិភាពរបស់ពួកគេតាមរយៈលទ្ធផលស្រាវជ្រាវរបស់សម្ព័ន្ធយុវជន ដើម្បីឯកភាព និងអភិវឌ្ឍន៍ (YCUD) កាលពីឆ្នាំ២០១៥។
- ដើម្បីឲ្យក្រុមយុវជនបានចូលរួមបញ្ចេញនូវមតិយោបល់ និងអនុសាសន៍ចំពោះភាគីពាក់ព័ន្ធ ទាក់ទិននឹង "បញ្ហាអាទិភាពរបស់យុវជន" ក្នុងប្រទេសកម្ពុជាដែលបានរកឃើញដោយ YCUD ព្រមទាំងរៀបចំផែនការសកម្មភាពតាមលទ្ធភាពរបស់ខ្លួនដើម្បីដោះស្រាយបញ្ហានេះ។

## ៤. លទ្ធផលរំពឹងទុក

### ៤.១ ចំពោះអ្នកចូលរួម

ក្រោយបញ្ចប់កម្មវិធី អ្នកចូលរួមនឹងទទួលបាននូវៈ

- ការយល់ដឹងពីបញ្ហាអាទិភាពរបស់យុវជនថ្នាក់ជាតិ
- ការចូលរួម ផ្តល់យោបល់ និងអនុសាសន៍ទាក់ទិននឹងបញ្ហាយុវជន និងការងារ ជូនចំពោះអ្នកពាក់ព័ន្ធ(ស្ថាប័នរដ្ឋ អង្គការក្រៅរដ្ឋាភិបាល ក្រុមយុវជនខ្លួនឯង ។ល។) ក្នុងការដោះស្រាយ ពីតម្រូវការពិត
- ការផ្តាច់ថ្នាចិត្តក្នុងការចូលរួមតាមលទ្ធភាពរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាទាំងនោះ

### ៤.២ ចំពោះបញ្ហា

- បញ្ហាយុវជន និងការងារ របស់យុវជននឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈតាមរយៈប្រព័ន្ធ Social Media
- ស្ថាប័នរដ្ឋដែលពាក់ព័ន្ធនឹងបានលឺ ព្រមទាំងចូលរួមដោះស្រាយ

## ៥. អ្នកចូលរួម

ជាបណ្តាយុវជនមកពីគ្រប់មជ្ឈដ្ឋាននានាក្នុងរាជធានីភ្នំពេញ ចំនួន ១៧ នាក់ (ស្ត្រី ៨ នាក់)

## ៦. របៀបវារៈសំខាន់ៗ

- បទបង្ហាញពីលទ្ធផលស្រាវជ្រាវស្តីពី "បញ្ហាអាទិភាពយុវជន"

- ពិភាក្សាក្រុមលើបញ្ហាអាទិភាពរបស់យុវជន

## ៧. សកម្មភាព

កម្មវិធីនេះសម្របសម្រួលដោយលោក ហុង រដ្ឋា មន្ត្រីតស៊ូមតិ នៃសម្ព័ន្ធយុវជន ដើម្បីឯកភាព និងអភិវឌ្ឍន៍ ហើយ ប្រព្រឹត្តិទៅតាមលំដាប់លំដោយដូចខាងក្រោម៖

### កិច្ចស្វាគមន៍ និងប្រកាសពីគោលបំណង

ជាកិច្ចចាប់ផ្ដើមការបង្ហាញពីកិច្ចស្វាគមន៍ និងប្រកាសពីគោលបំណងដោយលោក ហុង រដ្ឋា មន្ត្រីតស៊ូមតិនៃសម្ព័ន្ធយុវជន ដើម្បីឯកភាព និងអភិវឌ្ឍន៍ ដោយគោលនៃកម្មវិធីមាន៖

- ដើម្បីឲ្យក្រុមយុវជនបានដឹងពីបញ្ហាអាទិភាពរបស់ពួកគេតាមរយៈលទ្ធផលស្រាវជ្រាវរបស់សម្ព័ន្ធយុវជន ដើម្បីឯកភាព និងអភិវឌ្ឍន៍ (YCUD) កាលពីឆ្នាំ២០១៥។
- ដើម្បីឲ្យក្រុមយុវជនបានចូលរួមបញ្ចេញនូវមតិយោបល់ និងអនុសាសន៍ចំពោះភាគីពាក់ព័ន្ធ ទាក់ទិននឹង "បញ្ហាអាទិភាពយុវជន" ក្នុងប្រទេសកម្ពុជាដែលបានរកឃើញដោយ YCUD ព្រមទាំងរៀបចំផែនការសកម្មភាពតាមលទ្ធភាពរបស់ខ្លួនដើម្បីដោះស្រាយបញ្ហានេះ។

### ការណែនាំខ្លួនពីសំណាក់អ្នកចូលរួម

អ្នកចូលរួមគឺជាយុវជនដែលមកពីសាកលវិទ្យាល័យផ្សេងៗគ្នា ព្រមទាំងក្រុមហ៊ុនឯកជន និងអង្គការក្រៅរដ្ឋាភិបាល នានាក្នុងរាជធានីភ្នំពេញ។ ហើយជារួមអ្នកចូលរួមមានការរំពឹងទុកថា ចង់ដឹងពីបញ្ហាយុវជន និងការងារដែល YCUD បានរកឃើញ ចងបណ្ដាញជាមួយយុវជនថ្មីៗ ចូលរួមការងារសង្គម ផ្ដល់យោបល់ អនុសាសន៍ជូនភាគីពាក់ព័ន្ធ និងចូលរួមចំណែកធ្វើសកម្មភាពតាមលទ្ធភាពដែលខ្លួនអាចធ្វើបានដើម្បីរួមចំណែកដោះស្រាយបញ្ហាយុវជន និងការងារនេះ។

### ការលេងល្បែងសាមគ្គី

ក្រោយពីណែនាំខ្លួន លោក ហុង រដ្ឋា អ្នករៀបចំកម្មវិធីបានអោយអ្នកចូលរួមទាំងអស់ ឈរជារង្វង់ ហើយ អោយទាញស្មាតហ្វូនរៀងៗខ្លួនមកដើម្បី Add Friend នៃហ្វេសប៊ុក គ្នាទៅវិញទៅមក ហើយអ្នកដែលអត់មានស្មាតហ្វូន ត្រូវរកសៀវភៅកត់ត្រាដើម្បី កត់ និងចំណាំមុខមិត្តភក្ដិដែលពួកគេបានសួរនោះ។ ការធ្វើបែបនេះដើម្បីអោយយុវជន ចេះចងបណ្ដាញគ្នា ដោយអាចតាមដានស្ថានភាពគ្នា និងស្វែងយល់ ព្រមទាំងរៀនសូត្រពីគ្នាទៅវិញទៅមក។

### បទបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវ

បទបង្ហាញនេះធ្វើឡើងដោយលោក ហុង រដ្ឋា មន្ត្រីតស៊ូមតិនៃសម្ព័ន្ធយុវជន ដើម្បីឯកភាព និងអភិវឌ្ឍន៍ (YCUD)។

មាតិកានៃបទបង្ហាញមាន ១. អំពីសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ ២. អំពីសមាជិកក្រុមប្រឹក្សាភិបាល ៣. ទីកន្លែង និងចំនួនសំណាក់ដែលបានសម្ភាសន៍ ៤. ចំណុចអាទិភាពដែលសម្ព័ន្ធបានសិក្សារឃើញ ៥. អនុសាសន៍ពីអ្នកដែលបានសម្ភាសន៍ ៦. សកម្មភាពដែលសម្ព័ន្ធកំពុងអនុវត្ត។

**១. អំពីសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍**

សម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ ជាសម្ព័ន្ធអង្គការយុវជននៅក្នុងប្រទេសកម្ពុជា ដែលបង្កើតឡើងដើម្បីធ្វើ ការរួមគ្នា និងចូលរួមចំណែកដោះស្រាយបញ្ហានានារបស់យុវជនជាអាទិ៍មានការតស៊ូមតិឲ្យមាន គោលនយោបាយយុវជនជាតិលើកកម្ពស់ការគោរពសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទំនួលខុសត្រូវសង្គមក៏ដូចជាបញ្ហាសុខភាព បរិស្ថាន និងការងារធ្វើជាដើម ។ល។ ហើយសម្ព័ន្ធមានសមាជិកចំនួន ៧ អង្គការយុវជនដែលមានដូចជា វិទ្យាស្ថាន សម្រាប់អភិវឌ្ឍន៍ជាតិ សមាគមយុវជនខ្មែរ កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន អង្គការយុវជនខ្មែរ និងការអភិវឌ្ឍសង្គម មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព អង្គការយុវសន្តិភាព ក្រុមប្រឹក្សាយុវជនកម្ពុជា។

**២. អំពីសមាជិកក្រុមប្រឹក្សាភិបាល**

បច្ចុប្បន្នសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ មានសមាជិកក្រុមប្រឹក្សាភិបាលចំនួន៥រូប ដែលមាន លោក យង់ គឹមអេង ប្រធានមជ្ឈមណ្ឌល PDP លោក ជាង សុខា នាយកប្រតិបត្តិអង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន លោក ឡុង ខែត នាយកប្រតិបត្តិ នៃអង្គការ យុវសន្តិភាព លោក អ៊ឹម សុធី នាយកប្រតិបត្តិអង្គការក្រុមប្រឹក្សាយុវជនកម្ពុជា និងលោកស្រី សិទ្ធិ ហុងអៀង ប្រធានសមាគមយុវជនខ្មែរ។

**៣. ទីកន្លែង និងចំនួនសំណាក់ដែលបានសម្ភាសន៍**

ទំហំសំណាកបែងចែកតាមខេត្ត ក្នុងតំបន់ជនបទ និងទីក្រុង

| ខេត្ត | ទីក្រុង | ជនបទ | សរុប |
|---|---|---|---|
| បន្ទាយមានជ័យ | ៦០ | ៥០ | ១១០ |
| កំពង់ធំ | ៨១ | ៥០ | ១៣១ |
| ភ្នំពេញ | ១០៩ | ០ | ១០៩ |
| ព្រះសីហានុ | ៥០ | ៥០ | ១០០ |
| រតនគីរី | ០ | ៦០ | ៦០ |
| សរុប | ៣០០ | ២១០ | ៥១០ |

អ្នកផ្តល់ចម្លើយចំនួន៥១០នាក់ ដែលមាន៤៩% ជាបុរស និង ៥១% ជាស្រ្តី ហើយ៥៩% មកពីតំបន់ទីក្រុង និង៤១% មកពីជនបទ។ មានចំនួន ៤២% នៃសំណាកស្ថិតក្នុងអាយុចន្លោះពី១៥-១៧ឆ្នាំ និងមាន៤៣% មានអាយុចាប់ពី១៨-២៤ឆ្នាំ និងមានតែ១៥% មានអាយុពី២៥-៣០ឆ្នាំ។ មានចំនួន ៥៧% នៃយុវជន បានចូលរួមក្នុងការសិក្សានេះ មានការគាំទ្រយ៉ាងពេញទំហឹងពីក្រុមគ្រួសារ។ ហើយមាន ៥៦% មានការអប់រំកម្រិតបឋមសិក្សា និង ៦៤% កំពុងនៅរៀន។

**៤. ចំណុចអាទិភាពដែលសម្ព័ន្ធបានសិក្សារឃើញ**

***យុវជននិងការងារ*** គឺជាបញ្ហាអាទិភាពទី១ ដែលយុវជនកំពុងប្រឈមខ្លាំងជាងគេ។មូលហេតុដែលធ្វើឲ្យយុវជនគ្មានការងារធ្វើគឺបណ្តាលមកពីៈ

- ❖ គុណភាពនៃការអប់រំនៅមានកម្រិត
- ❖ ប្រាក់ខែទាប
- ❖ ខ្វះជំនាញដែលស្របតាមតម្រូវការទីផ្សារ
- ❖ ខ្វះឱកាសការងារសមស្រប
- ❖ បញ្ហាបក្សពួកនិយម ។

***យុវជន និងសន្តិសុខ*** គឺជាបញ្ហាអាទិភាពទី២ ដែលជាកង្វល់ដ៏សំខាន់មួយក្នុងចំណោមឪពុកម្តាយ ក៏ដូចជាក្នុងចំណោមយុវជនផងដែរ។ ដោយសារយុវជនជាច្រើនកំពុងតែជួបប្រទះបញ្ហាទាំងអស់នេះ (ទាំងយុវជននៅទីប្រជុំជន និងយុវជននៅតាមជនបទ) ។ បញ្ហាទាំងអស់នេះត្រូវបានលើកឡើងដោយក្រុមយុវជនដែលបានចូលរួមសម្ភាសន៍ជាក្រុមផ្សេងៗពីគ្នាទាំងនៅក្នុងខេត្តចំនួន៥ និងរាជធានីភ្នំពេញរួមមាន ៖

- ❖ ការប្រើប្រាស់គ្រឿងញៀន/គ្រឿងស្រវឹង
- ❖ សកម្មភាពក្មេងទំនើង
- ❖ គ្រោះថ្នាក់ចរាចរណ៍
- ❖ ការរំលោភសិទ្ធិមនុស្ស។

***ការអប់រំ គឺជាបញ្ហាដែលជាអាទិភាពទី៣*** ដែលយុវជនទាំងនៅទីប្រជុំជន និងតំបន់ជនបទបានលើកឡើង។ ក្រុមយុវជនបានលើកឡើងថា សាសារៀនពិតជាត្រូវការជាចាំបាច់នូវគ្រូល្អៗ និងឲ្យមានការបង្រៀនទៀងទាត់ពេលវេលា។ បញ្ហា នេះក៏ត្រូវបានលើកឡើងស្របគ្នាជាមួយយុវជន ៣៨% ដែលត្រូវបានអង្កេតដែលបានលើកឡើងអំពីកង្វល់ទៅលើ៖

- ❖ គុណភាពនៃការអប់រំនៅមានកម្រិត
- ❖ ឱកាសសម្រាប់ឲ្យយុវជនទទួលបាននូវការ អប់រំមិនទាន់មានភាពល្អប្រសើរ។

### ៥. អនុសាសន៍ពីអ្នកដែលបានសម្ភាសន៍

១. ផ្តល់ឱកាសដល់យុវជនសម្រាប់ផ្សាភ្ជាប់ជាមួយបណ្តាញ ផ្សេងៗ និងចងក្រងក្រុមយុវជនតាមសហគមន៍របស់ពួកគេ និងភ្ជាប់ជាមួយបណ្តាញឲ្យបានទូលំទូលាយចាប់ពីមូលដ្ឋានជនបទរហូតដល់ថ្នាក់ជាតិ ហើយបើអាចធ្វើបានគឺផ្សាភ្ជាប់ជាមួយបណ្តាញយុវជនមកពីគណបក្សនយោបាយនានា។

២. ពង្រឹងបណ្តាញសង្គម និងជំរុញឱ្យមានការជជែកជាមួយគ្នានៅក្នុងសិក្ខាសាលា ឬ វេទិកាយុវជន។

៣. អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារជាមួយយុវជន គួរខិតខំតស៊ូមតិជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីលើកកម្ពស់ជំនាញវិជ្ជាជីវៈសំដៅជួយដល់យុវជន ដែលមានតម្រូវការចាំបាច់។

៤. រៀបចំយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈ និងកសាងសម្លេងរួមរបស់យុវជនក្នុងការទាមទារសិទ្ធិពីរដ្ឋាភិបាល ជាពិសេសក្រសួងអប់រំយុវជន និងកីឡា ដើម្បីដាក់បញ្ចូលមុខវិជ្ជាសិក្សាអំពីអាស៊ាន ទៅក្នុងកម្មវិធីសិក្សានៃមធ្យមសិក្សានិងរៀបចំវេទិកាយុវជនដើម្បីឱ្យមានការគិតគូរអំពីបញ្ហា និងគោលនយោបាយទាក់ទងនឹងការអប់រំ។ យុវជន ក៏អាចទទួលបានផលប្រយោជន៍ផងដែរ ពីការចូលរួមជជែកគ្នានៅក្នុងសិក្ខាសាលា ឬ វេទិកាយុវជនទាំងក្នុងនិងក្រៅប្រទេស។

### ៦. សកម្មភាពដែលសម្ព័ន្ធកំពុងអនុវត្ត

- ❖ សភាយុវជនត្រាប់
- ❖ ការចងក្រងបណ្តាញយុវជន
- ❖ បណ្តុះបណ្តាលពីការតស៊ូមតិដល់បណ្តាញ
- ❖ ការតស៊ូមតិតាមរយៈជួបប្រជុំដោយផ្ទាល់និង តាមរយៈប្រព័ន្ធផ្សាយសង្គម(វេទិកាសម្ព័ន្ធយុវជន)
- ❖ ការបោះពុម្ពផ្សាយនៅសម្ភារៈនានាពីបញ្ហាយុវជន

ដើម្បីធ្វើការតស៊ូមតិ

## ការបែងចែកក្រុមពិភាក្សាលើប្រធានបទ "បញ្ហាអាទិភាពរបស់យុវជន"

អ្នកចូលរួមទាំងអស់ត្រូវ បែងចែកជាបីក្រុមដើម្បីពិភាក្សាលើប្រធានបទបីផ្សេងគ្នា ពាក់ព័ន្ធនឹងបញ្ហាអាទិភាពរបស់យុវជន ហើយដែលប្រធានបទទាំងនោះមាន៖

ក្រុមទី១ បញ្ហាយុវជន និងការងារ

ក្រុមទី២ បញ្ហាយុវជន និងសន្តិសុខ

ក្រុមទី៣ បញ្ហាយុវជន និងការអប់រំ

ក្រុមនីមួយៗត្រូវពិភាក្សាដោយឆ្លើយនូវសំនួរដូចខាងក្រោម៖

- តើក្រុមរបស់អ្នកអាចធ្វើអ្វីបានខ្លះ ក្នុងការដោះស្រាយបញ្ហាទាំងនេះ?
- តើអ្នកមានអនុសាសន៍អ្វីខ្លះចំពោះភាគីពាក់ព័ន្ធ (យុវជន រដ្ឋាភិបាល សង្គមស៊ីវិល)

**ក្រុមទី១ កាបញ្ហាយុវជន និងការងារ**

- ការចូលរួមរបស់ក្រុមយុវជនក្នុងការដោះស្រាយ
  - បង្កើតក្លឹបសិក្សា៖ ដើម្បីបង្កើនសមត្ថភាព សិស្ស និស្សិត
  - តស៊ូមតិ៖ ការតស៊ូមតិមានច្រើនសណ្ឋាន ទន់ ( ការស្នើរសុំ និង ដាក់ញ្ញាត្តិ), រឹង (តាមរយៈបាតុកម្ម កូដកម្ម)
  - ចូលរួមចែករំលែកព័ត៌មាន៖ លើឱកាសការងារ និង ព័ត៌មានផ្សេងដែលផ្តល់ប្រយោជន៍ដល់យុវជន
  - ច្បាប់ធំជាងញ្ញាត្តិ៖

- អនុសាសន៍ចំពោះភាគីពាក់ព័ន្ធ
  - ផ្សព្វផ្សាយព័ត៌មានតាមវិទ្យាល័យ៖ សុំឲ្យរាជរដ្ឋាភិបាលកែប្រែ និង យកចិត្តទុកដាក់ទៅលើវិស័យអប់រំ
  - បង្កើនសមត្ថភាពគ្រូបង្រៀន៖ បង្កើនសមត្ថភាពក្នុងការបង្រៀន ត្រូវមានវិជ្ជាជីវៈជាក់លាក់ក្នុងការបង្រៀន
  - រៀបចំគោលនយោបាយអប់រំ៖ គោលនយោបាយឲ្យច្បាស់លើការសិក្សាក្នុងវិស័យរដ្ឋ ពិសេសលើគុណភាព និង ថវិកា

**ក្រុមទី២ បញ្ហាយុវជន និងសន្តិសុខ**

**✦ គ្រឿងញៀន និង គ្រឿងស្រវឹង**

- ការចូលរួមរបស់ក្រុមយុវជនក្នុងការដោះស្រាយ
  - ផ្សព្វផ្សាយពីគុណវិបត្តនៃការប្រើប្រាស់វា៖ បន្ទាប់ពីការប្រើប្រាស់តើផ្តល់ផលប៉ះពាល់យ៉ាងណាខ្លះ
  - ជំរុញទឹកចិត្តយុវជនឲ្យចូលរួមសកម្មភាពសង្គម៖ ចូលរួមសិក្ខាសាលា និង វេទិកាផ្សេងៗ

– ចូលរួមសហការជាមួយអាជ្ញាធរមានសម្ថកិច្ចៈ ផ្តល់ព័ត៌មានទៅអាជ្ញាធរនូវអ្វីដែលយើងបានដឹងពីយុវជនណាដែលប្រើប្រាស់គ្រឿងស្រវឹង

✦ **សកម្មភាពក្មេងទំនើង**

- ការចូលរួមរបស់ក្រុមយុវជនក្នុងការដោះស្រាយ
  – ចូលរួមពង្រឹងសកម្មភាពអប់រំក្នុងសង្គមគ្រួសារនិងសង្គមជាតិៈ ជជែកជាមួយមាតាបិតាឲ្យគាត់ចូលរួមណែនាំកូនចៅរបស់គាត់ និង ស្ថាប័នរួមទាំងសិក្ខាសាលាផ្សេងៗ
  – ចូលរួមអនុវត្តន៍គោលនយោបាយភូមិឃុំមានសុវត្ថិភាពៈ គ្មានគ្រោះថ្នាក់ចរាចរណ៍ គ្មានគ្រឿងញៀន គ្មានអំពើហិង្សា គ្មានការជួញដូរមនុស្ស គ្មានល្បែងស៊ីសង នៅក្នុងភូមិឃុំ

✦ **គ្រោះថ្នាក់ចរាចរណ៍**

– ផ្សព្វផ្សាយពីច្បាប់ចរាចរណ៍ឲ្យបានទូលំទូលាយៈ ផ្សព្វផ្សាយតាមស្ថាប័នអប់រំ
– ចូលរួមអនុវត្តច្បាប់នេះទាំងអស់គ្នាៈ ដឹងហើយចូលរួមផ្សព្វផ្សាយទៅអ្នកដទៃ

✦ **ការរំលោភសិទ្ធិមនុស្ស**

– រាយការណ៍ដល់អាជ្ញាធរមានសមត្ថកិច្ចនិងស្ថាប័នដែលពាក់ព័ន្ធៈ យើងអាចផ្តល់ព័ត៌មានឲ្យគាត់ឲ្យបានទាន់ពេលវេលា
– បញ្ជ្រាបការយល់ដឹងពីសិទ្ធិមនុស្សៈ ផ្សព្វផ្សាយតាមបណ្តាញសង្គម បង្កើតជាស្គតខ្លីៗ អប់រំតាមស្ថាប័នអប់រំ

- អនុសាសន៍ចំពោះភាគីពាក់ព័ន្ធ
  – អនុវត្តច្បាប់ឲ្យមានប្រសិទ្ធិភាពៈ អនុវត្តច្បាប់ឲ្យបានតឹងរឹងទាំងអស់គ្នា

**ក្រុមទី៣ បញ្ហាយុវជន និងការអប់រំ**

✦ **ឱកាសសម្រាប់យុវជនទទួលបានការអប់រំមិនទាន់ល្អ និង គុណភាពនៃការអប់រំ**

- ការចូលរួមរបស់ក្រុមយុវជនក្នុងការដោះស្រាយ
  – ការផ្សព្វផ្សាយៈ ទៅដល់សាលា(ចែករំលែកតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និង ចែកខិតប័ណ្ណ)
  – ការចែករំលែកចំនេះដឹងៈ ទៅកាន់អ្នកដែលយើងអាចចែករំលែកបាន
  – ការសង្កេត និង តាមដានៈ ទៅតាមដានសកម្មភាពរបស់ពួកគាត់មុន និង ក្រោយការចែករំលែក
  – ចុះជជែកពិភាក្សាជាមួយយុវជន និង គ្រួសារៈ ជជែកពីសារៈប្រយោជន៍នៃការសិក្សាទៅកាន់មាតាបិតា និង យុវជន

- អនុសាសន៍ចំពោះភាគីពាក់ព័ន្ធ
  – យុវជនៈ ស្គាល់ខ្លួនឯង(គាត់ជានរណា គាត់ចង់បានអី គាត់មានគោលបំណងអី , ចូលរួមសង្គមឲ្យបានច្រើន គាត់នឹងស្វែងយល់បានកាន់តែច្រើន)

– រដ្ឋាភិបាលៈ យកចិត្តទុកដាក់ឲ្យខ្លាំងលើវិស័យអប់រំៈ ជាផ្នែកមួយដល់សំខាន់លើវិស័យអប់រំចាប់ផ្តើមតាំងពីថ្នាក់បឋមទៅ

– សង្គមស៊ីវិលៈ បង្កើនសកម្មភាពរបស់ខ្លួនលើវិស័យអប់រំ តែមិនតែលើយុវជនដែលរៀនបានខ្ពស់នោះទេ ជាពិសេសយុវជនដែលជាកម្មកររោងចក្រ ឬ កម្មករ លើការងារផ្សេងៗឲ្យគាត់មានឱកាសបានចូលរួម។

## ៨. លទ្ធផល

យុវជនដែលបានចូលរួមទាំងអស់បានដឹងពីបញ្ហាអាទិភាពរបស់យុវជនទាំងបី ដែលមាន យុវជន និងការងារ យុវជន និងសន្តិសុខ និងចុងក្រោយយុវជន និងការអប់រំ ដោយអ្នកចូលរួមទាំងអស់ស្តាប់យ៉ាងយកចិត្តទុកដាក់អំឡុងពេលធ្វើបទបង្ហាញ។ ហើយជាពិសេសបញ្ហាអាទិភាពរបស់យុវជន ដែលជាប្រធានបទពិភាក្សា ដោយពួកគេបានចូលរួមយ៉ាងជជែកយ៉ាងសស្រាកសស្រាំ។

យុវជនបានពិភាក្សាយ៉ាងផុសផុលលើប្រធានបទទាំង ៣ ដែលជាមូលហេតុដែលនាំឲ្យមានយុវជនបារម្ភ ហើយដែល YCUD បានរកឃើញកាលពីឆ្នាំ២០១៥។ ជាលទ្ធផល ក្រុមយុវជនទាំងបីក្រុមបានរកឃើញនូវដើមចមនៃបញ្ហា អនុសាសន៍សម្រាប់យុវជន និងភាគីពាក់ព័ន្ធ ព្រមទាំងកំណត់ផែនការពីសកម្មភាពរបស់ខ្លួនក្នុងការចូលរួមចំណែកដោះស្រាយបញ្ហាទាំងនោះ ដូចក្នុងលទ្ធផលបែងចែកក្រុមពិភាក្សាខាងលើ។

## ៩. កម្រងរូបថត










***<u>រូបថតសកម្មភាពនៃកិច្ចសន្ទនាយុវជនស្តីពីបញ្ហាអាទិភាពរបស់យុវជន</u>***

**អ្នកសរសេររបាយការណ៍** **អ្នកត្រួតពិនិត្យ**

លោក ហុង រដ្ឋា
មន្ត្រីតស៊ូមតិ
កាលបរិច្ឆេទ៖ ថ្ងៃទី....ខែ........ឆ្នាំ២០១៧

លោកស្រី មុី សម្ផស្ស
អគ្គលេខាធិការ
កាលបរិច្ឆេទ៖ ថ្ងៃទី....ខែ........ឆ្នាំ២០១៧

# កិច្ចសន្ទនាយុវជនស្តីពី "យុវជន និងការអប់រំ"

## ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ នៅសមាគម



ថ្ងៃសរសេរបាយការណ៍៖ ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧

សរសេរដោយ៖ លោក ហុង រដ្ឋា មន្រ្តីតស៊ូមតិ

សម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍
Youth Coalition for Unity and Development
Address: #18AB, St 160, Sangkat Touk Laark 2, Khan Toul Kok , Phnom Penh
FB page: Youth Coalition for Unity and Development -YCUD
E-mail:ycudoffice@yahoo.com
Hand phone: 012/81 324 691

# របាយការណ៍លទ្ធផល
# ស្តីពី
# កិច្ចសន្ទនាយុវជន "យុវជន និងការអប់រំ"

## ១. ព័ត៌មានទូទៅ

| | |
|---|---|
| កាលបរិច្ឆេទ | ថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៧ |
| ពេលវេលា | ចាប់ពីម៉ោង ៨:០០ ដល់ ១១:៣០ ព្រឹក |
| ទីកន្លែង | សមាគមយុវជនខ្មែរ |
| រៀបចំដោយ | សម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ |
| ឧបត្ថមដោយ | Oxfam |

## ២. សេចក្តីផ្តើម

យោងតាមលទ្ធផលនៃការស្រាវជ្រាវថ្នាក់ជាតិពីតម្រូវការរបស់យុវជននៅឆ្នាំ២០១៥កន្លងមកនេះបាន បង្ហាញថា ជាទូទៅយុវជនមានការយល់ដឹងខ្ពស់អំពីស្ថានភាពសេដ្ឋកិច្ចសង្គម និងនយោបាយនាពេល បច្ចុប្បន្ន ទោះបីជាសមត្ថភាពនៃការវិភាគបញ្ហាក្នុងចំណោមយុវជននៅតំបន់ជនបទ មានកម្រិតទាបជាងយុវ ជននៅទីប្រជុំជនក៏ដោយ។ កង្វះការផ្សាភ្ជាប់ទំនាក់ទំនងជាមួយបណ្តាញសង្គមធំៗ ការមិនទទួលបាន ព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយនានា និងគុណភាពនៃការអប់រំមានកម្រិតផងនោះ ជាហេតុធ្វើឱ្យយុវជននៅតំបន់ ជនបទខ្វះព័ត៌មាន ដើម្បីជំរុញឱ្យពួកគេចូលរួមនៅក្នុងសកម្មភាពសង្គម។ កង្វះការងារធ្វើ ប្រាក់ខែតិច កង្វះ សុវត្ថិភាពក្នុងសង្គម គុណភាពអប់រំមានកម្រិត គឺជាបញ្ហាគន្លឹះដែលយុវជននៅទីប្រជុំជនបានលើកឡើង។ គួរ កត់សម្គាល់ថា បញ្ហាសុវត្ថិភាពសង្គម ត្រូវបានលើកឡើងដោយយុវជនជាច្រើននៅទីប្រជុំជន ប៉ុន្តែយុវជននៅ តំបន់ជនបទវិញ ស្ទើរតែមិនបានលើកឡើងសោះឡើយ។

ការលើកឡើងរបស់យុវជននៅទីប្រជុំជន ក៏ខុសគ្នាពីយុវជននៅតំបន់ជនបទទៅលើបញ្ហាមួយចំនួន ទៀត។ ឧទាហរណ៍ យុវជននៅទីប្រជុំជនបានចាត់ទុកថា បញ្ហាគ្មានការងារធ្វើ ប្រាក់ខែទាប ខ្វះជំនាញដែល ស្របតាមតម្រូវការទីផ្សារ គឺជាបញ្ហាសំខាន់ រីឯយុវជននៅតំបន់ជនបទវិញ បង្ហាញនូវបញ្ហាប្លែកគ្នាបន្តិច ដោយគេបានលើកឡើងអំពីគុណភាពនៃការអប់រំមានកម្រិតទាប ការប្រើប្រាស់គ្រឿងញៀន និងចំណា កស្រុក គឺជាបញ្ហាគន្លឹះ ដែលជះឥទ្ធិពលដល់ជីវិតយុវជននៅតំបន់ជនបទ។

បញ្ហាសំខាន់មួយទៀតដែលយុវជនបានលើកឡើងគឺការខ្វះឱកាសការងារសមស្របបន្ទាប់ពីពួកគេ បានបញ្ចប់ការសិក្សាពីមធ្យមសិក្សា ឬមហាវិទ្យាល័យ ដែលបញ្ហានេះត្រូវបានលើកឡើងដោយយុវជនស្ទើរតែ ទាំងអស់ ដែលបានចូលរួមក្នុងការសម្ភាសន៍ជាក្រុម។ ពួកគេបានរៀបរាប់បន្ថែមថា ដោយសារកង្វះខាត

ការងារ និងខ្វះជំនាញ យុវជនជាច្រើនបានសម្រេចចិត្តចេញទៅប្រកបការងារនៅទីប្រជុំជន ឬក៏ទៅក្រៅប្រទេស។

ដូចនេះបញ្ហាអាទិភាពដែលយុវជនកំពុងជួបប្រទះ គឺ យុវជននិងការងារ យុវជននិង សន្តិសុខសង្គម និងយុវជននិងការអប់រំ ។

ដើម្បីចូលរួមដោះស្រាយទៅនឹងបញ្ហាអាទិភាពទាំងបីខាងលើ សម្ព័ន្ធយុវជនដើម្បីឯកភាព និង អភិវឌ្ឍន៍កំពុងសហការគ្នាជាមួយអង្គការ-សមាគមសមាជិកធ្វើការរួមគ្នាក្នុងការតស៊ូមតិថ្នាក់ជាតិពី តម្រូវការរបស់យុវជន ។ ការតស៊ូមតិនេះមានសកម្មភាពជាច្រើន ហើយនៅពេលនេះក្រុមការងារនឹងរៀបចំជាកិច្ចសន្ទនាយុវជនស្តីអំពី " យុវជន និងការអប់រំ" ។

## ៣. គោលបំណង

### ៣.១ គោលបំណងទូទៅ (□□□□□□□□ □□□□□□□□ □□□□□□□□□□□)

ដើម្បីឲ្យ ក្រុមយុវជន (អង្គការយុវជន ឬបណ្តាញយុវជន) អាចរៀបចំសកម្មភាពផ្សេងៗដើម្បីបញ្ចុះបញ្ចូលអ្នកធ្វើសេចក្តីសម្រេចចិត្តឲ្យដោះស្រាយបញ្ហារបស់ពួកគេ។

### ៣.២ គោលបំណងជាក់លាក់ (□□□□□□□□□ □□□□□□□□□□□)

- ដើម្បីឲ្យក្រុមយុវជនបានដឹងពីបញ្ហាអាទិភាពរបស់ពួកគេតាមរយៈលទ្ធផលស្រាវជ្រាវរបស់សម្ព័ន្ធយុវជន ដើម្បីឯកភាព និងអភិវឌ្ឍន៍ (YCUD) កាលពីឆ្នាំ២០១៥។
- ដើម្បីឲ្យក្រុមយុវជនបានចូលរួមបញ្ចេញនូវមតិយោបល់ និងអនុសាសន៍ចំពោះភាគីពាក់ព័ន្ធ ទាក់ទិននឹង "បញ្ហាយុវជន និងការអប់រំ" ក្នុងប្រទេសកម្ពុជាដែលបានរកឃើញដោយ YCUD ព្រមទាំងរៀបចំផែនការសកម្មភាពតាមលទ្ធភាពរបស់ខ្លួនដើម្បីដោះស្រាយបញ្ហានេះ។

## ៤. លទ្ធផលរំពឹងទុក

### ៤.១ ចំពោះអ្នកចូលរួម

ក្រោយបញ្ចប់កម្មវិធី អ្នកចូលរួមនឹងទទួលបាននូវះ

- ការយល់ដឹងពីបញ្ហាអាទិភាពរបស់យុវជនថ្នាក់ជាតិ
- ការចូលរួម ផ្តល់យោបល់ និងអនុសាសន៍ទាក់ទិននឹងបញ្ហាយុវជន និងការងារ ជូនចំពោះអ្នកពាក់ព័ន្ធ(ស្ថាប័នរដ្ឋ អង្គការក្រៅរដ្ឋាភិបាល ក្រុមយុវជនខ្លួនឯង ។ល។) ក្នុងការដោះស្រាយ ពីតម្រូវការពិត
- ការផ្តាច់ជ្ជាចិត្តក្នុងការចូលរួមតាមលទ្ធភាពរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាទាំងនោះ

### ៤.២ ចំពោះបញ្ហា

- បញ្ហាយុវជន និងការងារ របស់យុវជននឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈតាមរយៈប្រព័ន្ធ Social Media
- ស្ថាប័នរដ្ឋដែលពាក់ព័ន្ធនឹងបានលឺ ព្រមទាំងចូលរួមដោះស្រាយ

## ៥. អ្នកចូលរួម

ជាបណ្តាយុវជនមកពីគ្រប់មជ្ឈដ្ឋាននានាក្នុងរាជធានីភ្នំពេញ ចំនួន ២៨ នាក់ (ស្ត្រី ១៦ នាក់)

## ៦. របៀបវារៈសំខាន់ៗ

- បទបង្ហាញពីលទ្ធផលស្រាវជ្រាវស្តីពី "បញ្ហាអាទិភាពយុវជន"

- ពិភាក្សាក្រុមលើបញ្ហាយុវជននិងការអប់រំ

## ៧. សកម្មភាព

កម្មវិធីនេះសម្រប់សម្រួលដោយលោក ហុង រដ្ឋា មន្ត្រីតស៊ូមតិ នៃសម្ព័ន្ធយុវជន ដើម្បីឯកភាព និងអភិវឌ្ឍន៍ ហើយ ប្រព្រឹត្តិទៅតាមលំដាប់លំដោយដូចខាងក្រោម៖

### កិច្ចស្វាគមន៍ និងប្រកាសពីគោលបំណង

ជាកិច្ចចាប់ផ្តើមការបង្ហាញពីកិច្ចស្វាគមន៍ និងប្រកាសពីគោលបំណងដោយលោក ហុង រដ្ឋា មន្ត្រីតស៊ូមតិនៃសម្ព័ន្ធយុវជន ដើម្បីឯកភាព និងអភិវឌ្ឍន៍ ដោយគោលនៃកម្មវិធីមាន៖

- ដើម្បីឲ្យក្រុមយុវជនបានដឹងពីបញ្ហាអាទិភាពរបស់ពួកគេតាមរយៈលទ្ធផលស្រាវជ្រាវរបស់សម្ព័ន្ធយុវជន ដើម្បីឯកភាព និងអភិវឌ្ឍន៍ (YCUD) កាលពីឆ្នាំ២០១៥។
- ដើម្បីឲ្យក្រុមយុវជនបានចូលរួមបញ្ចេញនូវមតិយោបល់ និងអនុសាសន៍ចំពោះភាគីពាក់ព័ន្ធ ទាក់ទិននឹង "បញ្ហាយុវជន និងការងារ" ក្នុងប្រទេសកម្ពុជាដែលបានរកឃើញដោយ YCUD ព្រមទាំងរៀបចំផែនការសកម្មភាពតាមលទ្ធភាពរបស់ខ្លួនដើម្បីដោះស្រាយបញ្ហានេះ។

### ការណែនាំខ្លួនពីសំណាក់អ្នកចូលរួម

អ្នកចូលរួមគឺជាយុវជនដែលមកពីសាកលវិទ្យាល័យផ្សេងៗគ្នា ព្រមទាំងក្រុមហ៊ុនឯកជន និងអង្គការក្រៅរដ្ឋាភិបាល នានាក្នុងរាជធានីភ្នំពេញ។ ហើយជារួមអ្នកចូលរួមមានការរំពឹងទុកថា ចង់ដឹងពីបញ្ហាយុវជននិងការងារដែល YCUD បានរកឃើញ ចងបណ្តាញជាមួយយុវជនថ្មីៗ ចូលរួមការងារសង្គម ផ្តល់យោបល់អនុសាសន៍ជូនភាគីពាក់ព័ន្ធ និងចូលរួមចំណែកធ្វើសកម្មភាពតាមលទ្ធភាពដែលខ្លួនអាចធ្វើបានដើម្បីរួមចំណែកដោះស្រាយបញ្ហាយុវជន និងការងារនេះ។

### ការលេងល្បែងសាមគ្គី

ក្រោយពីណែនាំខ្លួន លោក ហុង រដ្ឋា អ្នករៀបចំកម្មវិធីបានអោយអ្នកចូលរួមទាំងអស់ ឈរជារង្វង់ ហើយ អោយទាញស្នាតហ្វូនរៀងៗខ្លួនមកដើម្បី Add Friend នៃហ្វេសប៊ុក គ្នាទៅវិញទៅមក ហើយអ្នកដែលអត់មានស្មាតហ្វូន ត្រូវរកសៀវភៅកត់ត្រាដើម្បី កត់ និងចំណាំមុខមិត្តភក្តិដែលពួកគេបានសួរនោះ។ ការធ្វើបែបនេះដើម្បីអោយយុវជន ចេះចងបណ្តាញគ្នា ដោយអាចតាមដានស្ថានភាពគ្នា និងស្វែងយល់ ព្រមទាំងរៀនសូត្រពីគ្នាទៅវិញទៅមក។

### បទបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវ

បទបង្ហាញនេះធ្វើឡើងដោយលោក ហុង រដ្ឋា មន្ត្រីតស៊ូមតិនៃសម្ព័ន្ធយុវជន ដើម្បីឯកភាព និងអភិវឌ្ឍន៍ (YCUD)។

មាតិកានៃបទបង្ហាញមាន ១. អំពីសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ ២. អំពីសមាជិកក្រុមប្រឹក្សាភិបាល ៣. ទីកន្លែង និងចំនួនសំណាក់ដែលបានសម្ភាសន៍ ៤. ចំណុចអាទិភាពដែលសម្ព័ន្ធបានសិក្សារឃើញ ៥. អនុសាសន៍ពីអ្នកដែលបានសម្ភាសន៍ ៦. សកម្មភាពដែលសម្ព័ន្ធកំពុងអនុវត្ត។

**១. អំពីសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍**

សម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ ជាសម្ព័ន្ធអង្គការយុវជននៅក្នុងប្រទេសកម្ពុជា ដែលបង្កើតឡើងដើម្បីធ្វើ ការរួមគ្នា និងចូលរួមចំណែកដោះស្រាយបញ្ហានានារបស់យុវជនជាអាទិ៍មានការតស៊ូមតិឲ្យមាន គោលនយោបាយយុវជនជាតិលើកកម្ពស់ការគោរពសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទំនួលខុសត្រូវសង្គមក៏ដូចជាបញ្ហាសុខភាព បរិស្ថាន និងការងារធ្វើជាដើម ។ល។ ហើយសម្ព័ន្ធមានសមាជិកចំនួន ៧ អង្គការយុវជនដែលមានដូចជា វិទ្យាស្ថាន សម្រាប់អភិវឌ្ឍន៍ជាតិ សមាគមយុវជនខ្មែរ កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន អង្គការយុវជនខ្មែរ និងការអភិវឌ្ឍសង្គម មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព អង្គការយុវសន្តិភាព ក្រុមប្រឹក្សាយុវជនកម្ពុជា។

**២. អំពីសមាជិកក្រុមប្រឹក្សាភិបាល**

បច្ចុប្បន្នសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ មានសមាជិកក្រុមប្រឹក្សាភិបាលចំនួន៥រូប ដែលមាន លោក យង់ គឹមអេង ប្រធានមជ្ឈមណ្ឌល PDP លោក ជាង សុខា នាយកប្រតិបត្តិអង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន លោក ឡុង ខែត នាយកប្រតិបត្តិ នៃអង្គការ យុវសន្តិភាព លោក អ៊ឹម សុធី នាយកប្រតិបត្តិអង្គការក្រុមប្រឹក្សាយុវជនកម្ពុជា និងលោកស្រី សិទ្ធិ ហុងអៀង ប្រធានសមាគមយុវជនខ្មែរ។

**៣. ទីកន្លែង និងចំនួនសំណាក់ដែលបានសម្ភាសន៍**

ទំហំសំណាកបែងចែកតាមខេត្ត ក្នុងតំបន់ជនបទ និងទីក្រុង

| ខេត្ត | ទីក្រុង | ជនបទ | សរុប |
|---|---|---|---|
| បន្ទាយមានជ័យ | ៦០ | ៥០ | ១១០ |
| កំពង់ធំ | ៨១ | ៥០ | ១៣១ |
| ភ្នំពេញ | ១០៩ | 0 | ១០៩ |
| ព្រះសីហានុ | ៥0 | ៥0 | ១00 |
| រតនគីរី | 0 | ៦0 | ៦0 |
| សរុប | ៣00 | ២១0 | ៥១0 |

អ្នកផ្តល់ចម្លើយចំនួន៥១០នាក់ ដែលមាន៤៩% ជាបុរស និង ៥១% ជាស្ត្រី ហើយ៥៩% មកពីតំបន់ទីក្រុង និង៤១% មកពីជនបទ។ មានចំនួន ៤២% នៃសំណាកស្ថិតក្នុងអាយុចន្លោះពី១៥-១៧ឆ្នាំ និងមាន៤៣% មានអាយុចាប់ពី១៨-២៤ឆ្នាំ និងមានតែ១៥% មានអាយុពី២៥-៣០ឆ្នាំ។ មានចំនួន ៥៧% នៃយុវជន បានចូលរួមក្នុងការសិក្សានេះ មានការគាំទ្រយ៉ាងពេញទំហឹងពីក្រុមគ្រួសារ។ ហើយមាន ៥៦% មានការអប់រំកម្រិតបឋមសិក្សា និង ៦៤% កំពុងនៅរៀន។

**៤. ចំណុចអាទិភាពដែលសម្ព័ន្ធបានសិក្សារឃើញ**

***យុវជននិងការងារ*** គឺជាបញ្ហាអាទិភាពទី១ ដែលយុវជនកំពុងប្រឈមខ្លាំងជាងគេ។មូលហេតុដែលធ្វើឲ្យយុវជនគ្មានការងារធ្វើគឺបណ្តាលមកពី:

- គុណភាពនៃការអប់រំនៅមានកម្រិត
- ប្រាក់ខែទាប
- ខ្វះជំនាញដែលស្របតាមតម្រូវការទីផ្សារ
- ខ្វះឱកាសការងារសមស្រប
- បញ្ហាបក្សពួកនិយម ។

***យុវជន និងសន្តិសុខ*** គឺជាបញ្ហាអាទិភាពទី២ ដែលជាកង្វល់ដ៏សំខាន់មួយក្នុងចំណោមឪពុកម្តាយ ក៏ដូចជាក្នុងចំណោមយុវជនផងដែរ។ ដោយសារយុវជនជាច្រើនកំពុងតែជួបប្រទះបញ្ហាទាំងអស់នេះ (ទាំងយុវជននៅទីប្រជុំជន និងយុវជននៅតាមជនបទ) ។ បញ្ហាទាំងអស់នេះត្រូវបានលើកឡើងដោយក្រុមយុវជនដែលបានចូលរួមសម្ភាសន៍ជាក្រុមផ្សេងៗពីគ្នាទាំងនៅក្នុងខេត្តចំនួន៥ និងរាជធានីភ្នំពេញរួមមាន ៖

- ❖ ការប្រើប្រាស់គ្រឿងញៀន/គ្រឿងស្រវឹង
- ❖ សកម្មភាពក្មេងទំនើង
- ❖ គ្រោះថ្នាក់ចរាចរណ៍
- ❖ ការរំលោភសិទ្ធិមនុស្ស។

***ការអប់រំ គឺជាបញ្ហាដែលជាអាទិភាពទី៣*** ដែលយុវជនទាំងនៅទីប្រជុំជន និងតំបន់ជនបទបានលើកឡើង។ ក្រុមយុវជនបានលើកឡើងថា សាសារៀនពិតជាត្រូវការជាចាំបាច់នូវគ្រូល្អៗ និងឲ្យមានការបង្រៀនទៀងទាត់ពេលវេលា។ បញ្ហា នេះក៏ត្រូវបានលើកឡើងស្របគ្នាជាមួយយុវជន ៣៨% ដែលត្រូវបានអង្កេតដែលបានលើកឡើងអំពីកង្វល់ទៅលើះ

- ❖ គុណភាពនៃការអប់រំនៅមានកម្រិត
- ❖ ឱកាសសម្រាប់ឲ្យយុវជនទទួលបាននូវការ
  អប់រំមិនទាន់មានភាពល្អប្រសើរ។

### ៥. អនុសាសន៍ពីអ្នកដែលបានសម្ភាសន៍

១. ផ្តល់ឱកាសដល់យុវជនសម្រាប់ផ្សាភ្ជាប់ជាមួយបណ្តាញ ផ្សេងៗ និងចងក្រងក្រុមយុវជនតាមសហគមន៍របស់ពួកគេ និងភ្ជាប់ជាមួយបណ្តាញឲ្យបានទូលំទូលាយចាប់ពីមូលដ្ឋានជនបទរហូតដល់ថ្នាក់ជាតិ ហើយបើអាចធ្វើបានគឺផ្សាភ្ជាប់ជាមួយបណ្តាញយុវជនមកពីគណបក្សនយោបាយនានា។
២. ពង្រឹងបណ្តាញសង្គម និងជំរុញឱ្យមានការជជែកជាមួយគ្នានៅក្នុងសិក្ខាសាលា ឬ វេទិកាយុវជន។
៣. អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារជាមួយយុវជន គួរខិតខំតស៊ូមតិជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីលើកកម្ពស់ជំនាញវិជ្ជាជីវៈសំដៅជួយដល់យុវជន ដែលមានតម្រូវការចាំបាច់។
៤. រៀបចំយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈ និងកសាងសម្លេងរួមរបស់យុវជនក្នុងការទាមទារសិទ្ធិពីរដ្ឋាភិបាល ជាពិសេសក្រសួងអប់រំយុវជន និងកីឡា ដើម្បីដាក់បញ្ចូលមុខវិជ្ជាសិក្សាអំពីអាស៊ាន ទៅក្នុងកម្មវិធីសិក្សានៃមធ្យមសិក្សានិងរៀបចំវេទិកាយុវជនដើម្បីឱ្យមានការគិតគូរអំពីបញ្ហា និងគោលនយោបាយទាក់ទងនឹងការអប់រំ។ យុវជន ក៏អាចទទួលបានផលប្រយោជន៍ផងដែរ ពីការចូលរួមជជែកគ្នានៅក្នុងសិក្ខាសាលា ឬ វេទិកាយុវជនទាំងក្នុងនិងក្រៅប្រទេស។

### ៦. សកម្មភាពដែលសម្ព័ន្ធកំពុងអនុវត្ត

- ❖ សភាយុវជនគ្រាប់
- ❖ ការចងក្រងបណ្តាញយុវជន
- ❖ បណ្តុះបណ្តាលពីការតស៊ូមតិដល់បណ្តាញ
- ❖ ការតស៊ូមតិតាមរយៈជួបប្រជុំដោយផ្ទាល់និង
  តាមរយៈប្រព័ន្ធផ្សាយសង្គម(វេទិកាសម្ព័ន្ធយុវជន)
- ❖ ការបោះពុម្ពផ្សាយនៅសម្ភារៈនានាពីបញ្ហាយុវជន

ដើម្បីធ្វើការតស៊ូមតិ

## ការបែងចែកក្រុមពិភាក្សាលើប្រធានបទ "យុវជន និងការអប់រំ"

ក្រុមត្រូវបែងចែកជាពីរ ដើម្បីពិភាក្សាលើប្រធានបទពីរផ្សេងគ្នា ពាក់ព័ន្ធនឹងបញ្ហាយុវជននិងការអប់រំ ហើយដែលប្រធានបទទាំងពីរនោះមាន៖

ក្រុមទី១ គុណភាពអប់រំនៅមានកំរិត

ក្រុមទី២ ឱកាសសម្រាប់ឲ្យយុវជនទទួលបាននូវការ អប់រំមិនទាន់មានភាពល្អប្រសើរ។

ក្រុមនីមួយៗត្រូវពិភាក្សាដោយឆ្លើយនូវសំនួរដូចខាងក្រោម៖

- តើដើមចមនៃបញ្ហានេះអ្វី?
- បើតាមយោបល់អ្នក តើយុវជនអាចធ្វើអីខ្លះដើម្បីចូលរួមដោះស្រាយវា?(តាមលទ្ធភាពរបស់ពួកគេ)
- តើក្រុមអ្នកនឹងគ្រោងធ្វើអ្វីដើម្បីចូលរួមដោះស្រាយវា? ធ្វើនៅពេលណា?
- តើអ្នកមានអនុសាសន៍អ្វីដល់អ្នកពាក់ព័ន្ធ?

**ក្រុមទី១ គុណភាពអប់រំនៅមានកំរិត**

- ដើមចមនៃបញ្ហានេះរួមមាន៖
  - កត្តាធនធានមនុស្ស
    - កម្រិតនៃការយល់ដឹងរបស់គ្រូបង្រៀននៅមានកម្រិត
    - កម្រិតនៃការអប់រំរបស់ឪពុកម្តាយ
    - កម្រិតនៃការយល់ដឹងរបស់ខ្លួនឯង
  - កត្តាសេដ្ឋកិច្ច និងនយោបាយ
    - សង្គ្រាមរាំរ៉ៃអស់ជាច្រើនទសវត្ស
    - កម្រិត GDP នៅមានកម្រិតទាប
    - បក្សពួកនិយម
  - កត្តាប្រពៃណីប្រកាន់នូវប្រពៃណី (ការផ្តល់ឱកាសរវាងកូនប្រុស និងកូនស្រីមិនស្មើរគ្នា។
- យោបល់ចំពោះយុវជនក្នុងការចូលរួមដោះស្រាយវាៈ
  - ពង្រឹងសមត្ថភាពខ្លួនឯង
  - បង្កើត ឬចូលជាសមាជិកក្រុមយុវជននានា ដើម្បីធ្វើការងារស្ម័គ្រចិត្ត។
  - ធ្វើខ្លួនជាគម្រូសម្រាប់អ្នកដទៃ។
- គម្រោងរបស់យុវជនក្នុងការដោះស្រាយបញ្ហាៈ
  - គម្រោងបង្កើតការអានដល់កុមារ (នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៧)
- អនុសាសន៍របស់យុវជនលើអ្នកដែលពាក់ព័ន្ធៈ
  - មាតាបិតាគួរតែយកចិត្តទុកដាក់តាមដានលើការសិក្សាកូន និងអប់រំកូន

- សូមឲ្យក្រសួងអប់រំយុវជន និងកីឡាបង្កើតគោលនយោបាយបន្ថែមទៀតដើម្បីឲ្យគុណភាពអប់រំអាចប្រកួតប្រជែងជាមួយប្រទេសជិតខាងបាន។

**ក្រុមទី២ ឱកាសសម្រាប់ឲ្យយុវជនទទួលបាននូវការ អប់រំមិនទាន់មានភាពល្អប្រសើរ**

- បញ្ហា
  - ជីវភាពរបស់គ្រូ និងសិស្សខ្សត់ខ្សោយ
  - ខ្វះខាតពត៌មានទូលំទូលាយពីការសិក្សា
  - ខ្វះការជម្រុញលើកទឹកចិត្តពីអាណាព្យាបាល
  - ហេដ្ឋារចនាសម្ព័ន្ធក្នុងសាលារៀនមិនគ្រប់គ្រាន់
- យោបល់ចំពោះយុវជនក្នុងការចូលរួមដោះស្រាយវា:
  - ចែករំលែកបទពិសោធន៍ ចំណេះដឹង ពត៌មានជុំវិញការសិក្សារៀនសូត្រ
  - ចូលរួមការងារស្ម័គ្រចិត្តក្នុងសង្គម
  - ជម្រុញ និងលើកទឹកចិត្ត (អាណាព្យាបាល និងអ្នកពាក់ព័ន្ធ)
  - ធ្វើជាគម្រូដល់អ្នកដទៃ ដោយខិតខំរៀនសូត្រ ប្រព្រឹត្តិល្អ
- ផែនការដែលគ្រោងធ្វើ
  - ចូលរួមផ្សព្វផ្សាយពីឱកាសការសិក្សារៀនសូត្រតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងដោយផ្ទាល់។
- អនុសាសន៍របស់យុវជនលើអ្នកដែលពាក់ព័ន្ធ:
  - ផ្សព្វផ្សាយពត៌មានពាក់ព័ន្ធនឹងការសិក្សាឲ្យបានទូលំទូលាយ
  - ពង្រឹងគរុកោសល្យគ្រូ

## ៨. លទ្ធផល

យុវជនដែលបានចូលរួមទាំងអស់បានដឹងពីបញ្ហាអាទិភាពរបស់យុវជនទាំងបី ដែលមាន យុវជន និងការងារ យុវជន និងសន្តិសុខ និងចុងក្រោយយុវជន និងការអប់រំ ដោយអ្នកចូលរួមទាំងអស់ស្តាប់យ៉ាងយកចិត្តទុកដាក់អំឡុងពេលធ្វើបទបង្ហាញ។ ហើយជាពិសេសបញ្ហាយុវជន និងការអប់រំ ដែលជាប្រធានបទពិភាក្សា ដោយពួកគេបានចូលរួមយ៉ាងជជែកយ៉ាងសស្រាកសស្រាំ។

យុវជនបានពិភាក្សាយ៉ាងផុសផុលលើប្រធានបទទាំង ពីរ ដែលជាមូលហេតុដែលនាំឲ្យមានបញ្ហាយុវជន និងការអប់រំ ហើយដែល YCUD បានរកឃើញកាលពីឆ្នាំ២០១៥។ ជាលទ្ធផល ក្រុមយុវជនពីរក្រុមបានរកឃើញនូវដើមចមនៃបញ្ហា អនុសាសន៍សម្រាប់យុវជន និងភាគីពាក់ព័ន្ធ ព្រមទាំងកំណត់ផែនការពីសកម្មភាពរបស់ខ្លួនក្នុងការចូលរួមចំណែកដោះស្រាយបញ្ហាទាំងនោះ ដូចក្នុងលទ្ធផលបែងចែកក្រុមពិភាក្សាខាងលើ។

## ៩. កម្រងរូបថត




រូបថតសកម្មភាពពិភាក្សាលើប្រធានបទ យុវជន និងការអប់រំ

**អ្នកសរសេររបាយការណ៍** **អ្នកត្រួតពិនិត្យ**

លោក ហុង រដ្ឋា
មន្ត្រីតស៊ូមតិ
កាលបរិច្ឆេទ៖ ថ្ងៃទី....ខែ........ឆ្នាំ២០១៦

លោកស្រី ម៉ី សម្ផស្ស
អគ្គលេខាធិការ
កាលបរិច្ឆេទ៖ ថ្ងៃទី....ខែ........ឆ្នាំ២០១៦